ក្រសួងយុត្តិធម៌

# ព្រឹត្តិបត្រ ច្បាប់ និងយុត្តិធម៌

## លេខ ២



ខែមីនា
ឆ្នាំ២០២៥

ព្រឹត្តិបត្រច្បាប់ និងយុត្តិធម៌លេខ២ នេះ ត្រូវបានរៀបចំឡើងដើម្បីចងក្រងទុកនូវព្រឹត្តិការណ៍ “មហាសន្និបាតលើកទី១ នៃវិស័យយុត្តិធម៌” ដែលជាមហាព្រឹត្តការណ៍ដ៏ធំមិនធ្លាប់មានក្នុងប្រវត្តិនៃវិស័យយុត្តិធម៌នៅកម្ពុជា។ មហាសន្និបាតវិស័យយុត្តិធម៌នេះ ត្រូវបានរៀបចំឡើងពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តម **ជីវ កេង** ប្រធានតុលាការកំពូល និង លោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល និងមានការចូលរួមពីសមាជិក សមាជិកានៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ថ្នាក់ដឹកនាំនៃក្រសួងយុត្តិធម៌ ថ្នាក់ដឹកនាំនៃសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ព្រមទាំងចៅក្រម និងព្រះរាជអាជ្ញានៅទូទាំងប្រទេស។ ព្រឹត្តិបត្រនេះបានចងក្រងទុកនូវកិច្ចដំណើរការ និងខ្លឹមសារនៃមហាសន្និបាតលើកទី១ នៃវិស័យយុត្តិធម៌ ដោយរួមទាំងសន្ទរកថាគន្លឹះដែលបានបង្ហាញពីគោលការណ៍ដឹកនាំ និងការប្តេជ្ញាចិត្តរួមគ្នាជានយោបាយសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាពនៃកែទម្រង់វិស័យយុត្តិធម៌ ព្រមទាំងសេចក្តីសម្រេច ចិត្តរួមរបស់មហាសន្និបាត។ បន្ថែមពីនេះ ព្រឹត្តិបត្រនេះក៏មានចងក្រងនូវអត្ថបទស្រាវជ្រាវ និងវិភាគពាក់ព័ន្ធនឹងប្រធានបទ ពិភាក្សាសំខាន់ៗមួយនៅក្នុងមហាសន្និបាត ដើម្បីជាទុកជាចំណេះដឹងសម្រាប់មន្ត្រីក្នុងវិស័យយុត្តិធម៌ និងអ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ និងយុត្តិធម៌គ្រប់ជំនាន់អាចស្វែងយល់ និងអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

9 789924 998709
លេខ ISBN: 978-9924-9987-0-9

ព្រឹត្តិបត្រ

# ច្បាប់ និងយុត្តិធម៌

## លេខ ២

**សេចក្ដីបញ្ជាក់**

«រាល់ទស្សនៈ និងការវិភាគនៅក្នុងព្រឹត្តិបត្រនេះ គឺជាគំនិត និងការយល់ឃើញផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈ ឬគោលជំហររបស់ក្រសួងយុត្តិធម៌នោះទេ។»

**ក្រសួងយុត្តិធម៌**

© រក្សាសិទ្ធិគ្រប់បែបយ៉ាង ខែមីនា ឆ្នាំ២០២៥

ដោយអនុលោមតាមច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨

ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០០៣

# មាតិកា

**និមិត្តរូបរូបនៃការកាត់ក្ដីនៅកម្ពុជា** ១

**ផ្នែកទី១-មហាសន្និបាតលើកទី១ នៃវិស័យយុត្តិធម៌** ២

១- អំពីកិច្ចដំណើរការនៃមហាសន្និបាតលើកទី១ នៃវិស័យយុត្តិធម៌ ៣

២-អំពីសមិទ្ធផលនៃវិស័យយុត្តិធម៌ ១៦

៣-អំពីខ្លឹមសារនៃសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាត ៣១

៤-សុន្ទរកថារបស់ថ្នាក់ដឹកនាំ ៣៩

**ផ្នែកទី២-អត្ថបទស្រាវជ្រាវនិងវិភាគផ្នែកច្បាប់** ៥៩

១- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៦០

ដោយឯកឧត្តម **សេង ប៊ុនឃាង** និងឯកឧត្តម **ញាន វណ្ណៈ**

២- បណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿងព្រហ្មទណ្ឌ ៧៧

ដោយឯកឧត្តម **ម៉ុង មុនីចរិយា** និង លោក **ឆុន ករណា**

៣- ការឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ ៩១

ដោយឯកឧត្តម **គង់ តារាឆាត** និងឯកឧត្តម **ហេង សុខណា**

៤- សារការីនៅក្នុងនីតិកម្ពុជា

ដោយលោកស្រី **នៅ សុជាតា** ១០៣

៥- ការបកស្រាយច្បាប់

ដោយឯកឧត្តម **ញាន វណ្ណៈ** និង **ឯកឧត្តម សេង នាង** ១២៧

៦- ការចេញដីកាសម្រេចរក្សាការពារ

ដោយលោក **ឈឿន គុយអេង** និងកញ្ញា **គន្ធា ស្រីសុជាតា** ១៤៧

កុំលុះដោយ
ឆន្ទាគតិ
ទោសាគតិ
ភយាគតិ
មោហាគតិ



ទិរិយសម្បយុត្ត
សុចរិតយុត្តិធម៌
បញ្ញត្តិការទោ
សមិចណ្ណោ
បញ្ញាទុជទិនិច្ច័យ

# និមិត្តរូបនៃការកាត់ក្តីនៅកម្ពុជា

រូប “**ទេវកាត់ក្តី**” ជារូបនៅចំកណ្តាលដែលគង់នៅលើព្រះបល័ង្កដោយព្រះហស្តខាងស្តាំមានកាន់ព្រះខ័នហើយព្រះហស្តខាងឆ្វេងមានកាន់ជញ្ជីងជានិមិត្តរូបនៃការកាត់ក្តីក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

រូបទេវនៅផ្នែកខាងស្តាំនៃរូបទេវកាត់ក្តីមានកាន់សាស្ត្រាដែលមានចារិកអក្សរថា

*“នាកដែរលុះដោយអាគតិ ៤ បទ*
*គឺដូចកញ្ជាំងនៅត្រនិចត្រាជូវឱ្យឡៀង*
*ចុះ នាកនោះនិងត្រូវទោស្រទ័ណ្ឌាកម្ម*
*ក្នុងឥធលោក និងបរលោក”*

រូបទេវនៅផ្នែកខាងឆ្វេងនៃរូបទេវកាត់ក្តីមានកាន់សាស្ត្រាដែលមានចារិកអក្សរថា

*“នាកដែរពុំលុះដោយអាគតិ ៤ បទ*
*គឺដូចកញ្ជាំងនៅត្រនិចត្រាជូវ*
*ឱ្យទៀងត្រង នាកនោះនិងទទូល*
*នៅសេចក្តីសុខក្នុង ឥធលោក*
*និងបរលោក ”*

*(រូបគំនូរនៅក្នុងសាលសវនាការនៃអតីតសាលាវិនិច្ឆ័យ តុលាការកំពូល តាំងពីថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩២៥ ហើយបច្ចុប្បន្ន ជាទីស្តីការក្រសួងយុត្តិធម៌)*

# ផ្នែកទី
# ១

# មហាសន្និបាតលើកទី១
# នៃវិស័យយុត្តិធម៌





# ១.កិច្ចដំណើរការរបស់មហាសន្និបាត



មហាសន្និបាតវិស័យយុត្តិធម៌លើកទី១ ត្រូវបានរៀបចំឡើងរយៈពេលចំនួន៣ថ្ងៃពេញ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ឯកឧត្តមបណ្ឌិត **ឌិត មុន្ទី** ប្រធានតុលាការកំពូល និងលោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល។ មហាសន្និបាតវិស័យយុត្តិធម៌នេះ គឺជាការជួបជុំដ៏ធំ និងដ៏មានសារៈសំខាន់ ដែលពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រនៃវិស័យយុត្តិធម៌នាពេលកន្លងមក។ ការជួបជុំដ៏កម្រនេះបានបង្កើតជា“ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀតសម្រាប់វិស័យយុត្តិធម៌”។

មហាសន្និបាតវិស័យយុត្តិធម៌លើកទី១នេះត្រូវបានរៀបចំឡើងក្នុងបរិការណ៍នៃការចាប់ផ្ដើមចេញដំណើររបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានកំណត់យក “ការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌”

ជាមុំមួយក្នុងចំណោមមុំទាំង ៥ ដែលបង្កើតបានជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល និងជាវិធានការគន្លឹះមួយក្នុងចំណោមវិធានការគន្លឹះទាំង៥ របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**។ ជាមួយគ្នានេះ, មហាសន្និបាតនេះ ក៏ត្រូវបានរៀបចំឡើងស្របពេលដែលវិស័យយុត្តិធម៌ទាំងមូល បាននិងកំពុងខិតខំប្រឹងប្រែងរួមគ្នាក្នុងការអនុវត្តយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការផងដែរ។ មហាសន្និបាតនេះ ក៏មានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងជាថ្នាក់ដឹកនាំនៃក្រសួងយុត្តិធម៌ ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ, ជាចៅក្រម និងជាព្រះរាជអាជ្ញានៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស និងថ្នាក់ដឹកនាំនៃអង្គភាពរដ្ឋបាលតុលាការនៅទូទាំងប្រទេស សរុបចំនួនប្រមាណជាង ៧៥០ នាក់។

ថ្លែងក្នុងពិធីបើកមហាសន្និបាតនេះលោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល បានក្រើនរំលឹកផងដែរថាក្នុងនាមជាអគ្គព្រះរាជអាជ្ញា និងជាប្រធានក្រុមប្រឹក្សាវិន័យក្នុងមុខការដាក់វិន័យចំពោះព្រះរាជអាជ្ញា លោកជំទាវនឹងយកទំនួលខុសត្រូវនិងភាពជាម្ចាស់ការលើការងារ ត្រួតពិនិត្យ វាយតម្លៃ និងដាក់វិន័យតាមរយៈបណ្តឹងលើព្រះរាជអាជ្ញាដែលអនុវត្តមុខងាររបស់ខ្លួនមានកំហុសវិជ្ជាជីវៈ និង/ឬបំពានយ៉ាងធ្ងន់ធ្ងរលើក្រមសីលធម៌វិជ្ជាជីវៈចៅក្រម-ព្រះរាជអាជ្ញា ដែលបានបង្កនូវអយុត្តិធម៌សង្គម និងការឈឺចាប់ធំធេងដល់អ្នកពាក់ព័ន្ធក្នុងសំណុំរឿងក្តី។ លោកជំទាវអគ្គព្រះរាជអាជ្ញាបានចាត់ទុកថា ការអនុវត្តមុខការនេះគឺមិនមែនគោលដៅនៃការដាក់វិន័យនោះទេ ប៉ុន្តែជាយន្តការត្រួតពិនិត្យតាមនីតិវិធីច្បាប់មួយដែលធានាថាអង្គចៅក្រម ប្តេជ្ញាចិត្តរួមគ្នាលើនាវាតែមួយ ពង្រឹងនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។ លោកជំទាវបានសង្កត់ធ្ងន់ថា *"បើនិយាយចំពោះយើងម្នាក់ៗ គឺរួមគ្នាស្តារមុខមាត់ និងកេរ្តិ៍ឈ្មោះរបស់វិស័យយុត្តិធម៌យើង។ ដូច្នេះយើងត្រូវនាំគ្នារួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ"*។

លោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញា បានបន្ថែមទៀតថា ភារកិច្ចចម្បងរបស់យើងគ្រប់គ្នាដែលស្គាល់ជាប់ស្មា ហើយជាអម្រែកនោះ គឺការផ្តល់យុត្តិធម៌ ហើយ "យុត្តិធម៌" នេះ គឺ



*លោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញា*
*នៃមហាអយ្យការអមតុលាការកំពូល*
*ថ្លែងចំណាប់អារម្មណ៍ក្នុងពិធីបើកមហាសន្និបាតវិស័យយុត្តិធម៌*




សំដៅតែទៅលើយុត្តិធម៌តាមផ្លូវច្បាប់ប៉ុណ្ណោះ។ចៅក្រមគឺផ្តល់យុត្តិធម៌ជូនដល់ភាគីដែលមានវិវាទចូលមកតុលាការ។ដោយសារពាក្យយុត្តិធម៌នេះហើយដែលចៅក្រមទាំងអស់ត្រូវរងព្យុះភ្លៀងមកពីគ្រប់ទិសទីនូវពាក្យប្រមាថពាក្យទិទៀនសព្វបែបយ៉ាងដូចជាតុលាការមិនយុត្តិធម៌ ពុករលួយ បក្ខពួកនិយម តុលាការរបស់ពួកអ្នកមានលុយ ។ល។

លោកជំទាវ **ជា លាង** ថា អង្គចៅក្រមរងនូវពាក្យប្រមាថទិទៀនទាំងនេះរាប់សិបឆ្នាំមកជាពិសេសក្នុងសម័យឌីជីថលដ៏ទំនើបនេះ។ តើចៅក្រមពិតជាអយុត្តិធម៌ដូច្នេះមែនឬទេ? បើពិនិត្យដោយឈលើការពិតការសម្រេចសេចក្តីរបស់ចៅក្រមនៅមានបញ្ហាអសកម្មខ្លះដែលយើងត្រូវហ៊ានទទួលយកការពិត តែទន្ទឹមហ្នឹងនេះ ក៏ចៅក្រមបានសម្រេចសេចក្តីដោយយុត្តិធម៌ជូនដល់ភាគីយ៉ាងច្រើនលើសលប់ធ្វើឱ្យសង្គមមានស្ថិរភាពការពារបាននូវរបៀបរៀបរយសារធារណៈនិងទ្រព្យសម្បត្តិស្របច្បាប់របស់ប្រជាពលរដ្ឋនេះមិនមែនជាការរួមចំណែករបស់ចៅក្រមទេឬ?។ ការរៀបចំមហាសន្និបាតនាពេលនេះគឺជាឆន្ទៈដ៏មោះមុតរបស់ ឯកឧត្តមឧបនាយក រដ្ឋមន្ត្រី និងការប្តេជ្ញាចិត្តរបស់ចៅក្រម ព្រះរាជអាជ្ញាទាំងអស់គ្នាក្នុងការចូលរួមអនុវត្តដើម្បីឆ្ពោះទៅកាន់ការកែទម្រង់ប្រកបដោយបានជោគជ័យ។




*ឯកឧត្តមបណ្ឌិត **ជីវ កេង** ប្រធានតុលាការកំពូល ថ្លែងចំណាប់អារម្មណ៍ក្នុងពិធីបើក មហាសន្និបាតវិស័យយុត្តិធម៌*

ឯកឧត្តមបណ្ឌិត **ជីវ កេង** ប្រធានតុលាការកំពូល បានមានប្រសាសន៍ថា “*ការលើកកម្ពស់ និងការពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌*” ត្រូវបានកំណត់យកជាវិធានការគន្លឹះដែលមានគោលដៅយុទ្ធសាស្ត្រផ្ដោតលើការពង្រឹងគោលការណ៍នីតិរដ្ឋ, ការពង្រឹងការប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធម៌ក្នុងសង្គម, ការពង្រឹងជំនឿទុកចិត្តពីសាធារណជនមកលើវិស័យយុត្តិធម៌។ ឯកឧត្តមប្រធានតុលាការកំពូលបន្ថែមថា ទោះជាបានទទួលនូវសមិទ្ធផលល្អប្រសើរជាច្រើនយ៉ាងណាក៏ដោយ ក៏ជាក់ស្ដែងមិនទាន់ឆ្លើយតបតាមបំណងប្រាថ្នារបស់យើងទាំងអស់គ្នា ក្នុងការបម្រើ និងការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅឡើយ។ ការណ៍នេះ បណ្ដាលមកពីមានបញ្ហាប្រឈម ជាអាទិ៍ **កត្តាបញ្ញត្តិច្បាប់** (ខ្វះចន្លោះ, មិនមានភាពច្បាស់លាស់ជាដើម), **កត្តាអត្តនោម័ត** (ការមិនគោរពក្រមសីលធម៌វិជ្ជាជីវៈ ដូចជាការមិនប្រឹងប្រែងពង្រឹងសមត្ថភាព, ការមិនយកចិត្តទុកដាក់ផ្ដល់សេវាយុត្តិធម៌ឱ្យបានឆាប់រហ័ស) និង **កត្តាសត្យានុម័ត** (ខ្វះការសហការពីតួអង្គពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌, មានអន្តរាគមន៍ដោយមិនត្រឹមត្រូវលើកិច្ចការតុលាការ)។ល។ ហេតុដូច្នេះហើយ ទើបអង្គមហាសន្និបាតបានកំណត់យកនូវប្រធានបទជាអាទិភាពចំនួន៨ ទាំងក្នុងវិស័យរដ្ឋប្បវេណី ទាំងក្នុងវិស័យព្រហ្មទណ្ឌមកធ្វើការពិភាក្សា ហើយក៏មានបទបង្ហាញស្ដីពីប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលតុលាការនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់វិស័យយុត្តិធម៌ដែរ។ ឯកឧត្តមបណ្ឌិត **ជីវ កេង** បានធ្វើការសង្កត់ធ្ងន់ថា យន្តការនៃការលើកទឹកចិត្តត្រូវធ្វើឡើងដោយម៉ត់ចត់, យុត្តិធម៌, តម្លាភាព និងសុក្រឹតភាព តាមរយៈការវាយតម្លៃឡើងថ្នាក់ និងឋានន្តរសក្តិ, រីឯអ្នកប្រព្រឹត្តខុសត្រូវតែកសាងជាសំណុំរឿងវិន័យ ដោយមានយន្តការនៃការស៊ើបអង្កេតឱ្យបានច្បាស់លាស់ស្របតាមច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ហើយខ្ញុំស្នើសុំឱ្យសមាជិក សមាជិកាក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចូលរួមសម្រេចដាក់វិន័យចំពោះអ្នកមានកំហុសវិជ្ជាជីវៈឱ្យសមស្របតាមកំហុសមិនត្រូវយោគយល់ឡើយ ដើម្បីជៀសវាងការជះឥទ្ធិពលដល់អង្គចៅក្រមទាំងមូលកុំឱ្យដូចពាក្យបុរាណដែលពោលថា “***ត្រីមួយកន្ត្រក ស្អុយមួយ គឺស្អុយទាំងអស់***” ។ដូច្នេះមានភាពចាំបាច់ណាស់ត្រូវតែដកយកត្រីមួយនេះចេញកុំឱ្យស្អុយដល់ត្រីផ្សេងទៀត។

ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានចាត់ទុកថា ការរៀបចំមហាសន្និបាតនេះនឹងត្រូវចារឹកទុកជា “***ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀតសម្រាប់វិស័យយុត្តិធម៌***” ដោយហេតុថានេះ គឺជាការរៀបចំមហាសន្និបាតលើកទី១ ក្នុងវិស័យយុត្តិធម៌ ដែលមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំសំខាន់ៗក្នុងវិស័យយុត្តិធម៌ ព្រមទាំងចៅក្រម ព្រះរាជអាជ្ញានៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស (លើកលែងតែអ្នកត្រូវនៅប្រចាំការ) ក្នុងឯកសណ្ឋានអាវផាយដ៏ស្រស់ស្អាតប្រកបដោយមោទនភាពដែលយើងពុំធ្លាប់ដែលបានរៀបចំឡើយពីមុនមក គិតចាប់តាំងពីព្រះរាជាណាចក្រកម្ពុជាទី២ ត្រូវបានបង្កើតឡើង។

មហាសន្និបាតនេះ ត្រូវបានរៀបចំឡើងក្នុងបរិការណ៍នៃការចាប់ផ្ដើមចេញដំណើររបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ប្រមុខរាជរដ្ឋាភិបាលថ្មី ដែល **សម្តេច** បានប្រកាសកំណត់យក “**ការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌**” ជាការងារអាទិភាពក្នុងវិធានការគន្លឹះទាំង ៥ របស់ **សម្តេច** និងជាការដ្ឋានកែទម្រង់ដ៏សំខាន់របស់រាជរដ្ឋាភិបាល។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានបន្ថែមថា មហាសន្និបាតនេះ ត្រូវបានរៀបចំឡើងបន្ទាប់ពីយន្តការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានកែសម្រួលរៀបចំឡើងវិញ ដោយមានឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល ជាសហប្រធាន។

មហាសន្និបាតវិស័យយុត្តិធម៌នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីអនុញ្ញាតឱ្យចៅក្រម ព្រះរាជអាជ្ញា និងតួអង្គដែលមានការពាក់ព័ន្ធទាំងអស់ ពិនិត្យ និងពិភាក្សាលើបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃ

ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ព្រមទាំងដើម្បីសម្រេចដាក់ចេញនូវដំណោះស្រាយរួមចំពោះបញ្ហាប្រឈមទាំងនោះ ដែលអាចធានាបាននូវការឯកភាពទាំងគោលជំហរ ទាំងទស្សនៈ ក្នុងការអនុវត្តនៅតាមសាលាជម្រះក្តី និង អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ សំដៅ «**រួមគិត រួមធ្វើ រួមទទួលខុសត្រូវ**» ក្នុងចក្ខុវិស័យ រួមតែមួយក្នុងជំហានកាន់តែបុរេសកម្ម កាន់តែសកម្ម កាន់តែស្វាហាប់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីនាំមកនូវការប្រែប្រួលជាវិជ្ជមានបន្ថែមទៀតសម្រាប់វិស័យយុត្តិធម៌។



ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានគូសបញ្ជាក់ថា ក្នុងការអនុវត្តអភិក្រមនៃការពង្រឹងអភិបាលកិច្ចល្អ និងអភិក្រមនៃការងារកែទម្រង់ បើ «**ត្រីមួយកន្ត្រក បើមានត្រីមួយស្អុយ ត្រូវដកត្រីនោះចេញ**»។ ប៉ុន្តែ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បញ្ជាក់ថា «ខ្ញុំមិនចង់ឃើញអ្នកណាម្នាក់ក្លាយជាកម្មវត្ថុនៃការវះកាត់នោះទេ ប៉ុន្តែ ខ្ញុំចង់ឃើញអ្នកទាំងអស់គ្នា រួមគ្នាធ្វើឲ្យមានការប្រែប្រួលជាវិជ្ជមាននូវមុខមាត់វិស័យយុត្តិធម៌របស់យើង ដើម្បីជាប្រយោជន៍នៃអង្គរបស់យើង និងដើម្បីជាប្រយោជន៍ដល់សង្គមជាតិ និងប្រជាជន»។

មហាសន្និបាតបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានាក្នុងវិស័យយុត្តិធម៌ដែលសម្រេចបាននាពេលកន្លងមក ហើយបានឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការបំពេញតួនាទី និងភារកិច្ចអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញា និងស្មារតីប្រកបដោយភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងយុត្តិធម៌ សាលាជម្រះក្តី និងអង្គការ




*ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ថ្លែងសុន្ទរកថាបើកមហាសន្និបាតវិស័យយុត្តិធម៌*

អយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌ឈានឆ្ពោះទៅធ្វើឱ្យមានការ **“ផ្លាស់ប្តូរជាវិជ្ជមានជាបន្តបន្ទាប់នូវទស្សនៈ និងការយល់ឃើញរបស់ប្រជាពលរដ្ឋចំពោះវិស័យយុត្តិធម៌។”**

មហាសន្និបាតនេះ បានចាប់ផ្តើមដំណើរការជាមួយនឹងការរាយការណ៍អំពីសមិទ្ធផលនានាដែលវិស័យយុត្តិធម៌សម្រេចបាននៅក្នុងឆ្នាំ២០២៣ កន្លងទៅ។ សមិទ្ធផលសំខាន់ៗដែលវិស័យយុត្តិធម៌សម្រេចបាន រួមមាន៖ (១)-ការបង្កើតឱ្យមានអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, (២)-ការដាក់ចេញនូវយុទ្ធនាការ ចំនួន ២ គឺ យុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ, (៣)-ការលើកកម្ពស់យន្តការផ្តល់សេវាមេធាវីដល់ជនក្រីក្រ, (៤)-ការបន្តកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដែលបម្រើឱ្យសេចក្តីចាំបាច់នានារបស់សង្គម និង (៥)-ការពង្រឹងប្រសិទ្ធភាពនៃយន្តការអធិការកិច្ច។

បន្ទាប់ពីបានពិនិត្យលើរបាយការណ៍សមិទ្ធផលការងារនេះ និងដើម្បីដោះស្រាយបញ្ហាចំពោះមុខជាក់ស្តែងដែលកើតមានឡើងក្នុងការអនុវត្តការងាររបស់ចៅក្រម និងព្រះរាជអាជ្ញានាពេលកន្លងមក អង្គមហាសន្និបាតបានពិនិត្យ និងពិភាក្សាលើប្រធានបទចំនួន ៨ ដែលក្នុងនោះមានប្រធានបទពាក់ព័ន្ធនឹងវិស័យរដ្ឋប្បវេណី ចំនួន ៤ និងប្រធានបទពាក់ព័ន្ធនឹងវិស័យព្រហ្មទណ្ឌ ចំនួន ៤ ដូចខាងក្រោម៖




*ឯកឧត្តម* ***កេង សុម៉ារិទ្ធ*** *រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ធ្វើបទបង្ហាញក្នុងមហាសន្និបាតវិស័យយុត្តិធម៌*

១-ប្រសិទ្ធភាព និងបញ្ហាប្រឈមនៃការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី

២-ការចេញដីកាសម្រេចរក្សាការពារ

៣-ការលើកកម្ពស់ប្រសិទ្ធភាព និងជំនឿទុកចិត្តលើការលក់ដោយបង្ខំនូវអចលនវត្ថុ

៤- ការជូនដំណឹង និងការបញ្ជូនសេចក្ដីសម្រេចរបស់តុលាការ

៥-ប្រសិទ្ធភាព និងបញ្ហាប្រឈមនៃការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ

៦-ការជូនដំណឹងអំពីសាលក្រមកំបាំងមុខ (ការជូនដំណឹងអំពីសេចក្ដីសម្រេចតុលាការ)

៧-បទល្មើសប្រព្រឹត្តដោយអនីតិជន

៨- បណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសេចក្ដីសម្រេចព្រហ្មទណ្ឌ។

នៅក្នុងកិច្ចដំណើរការនៃការពិភាក្សាលើប្រធានបទទាំងអស់ខាងលើនេះ ក្រុមការងារបច្ចេកទេសត្រូវបានរៀបចំឡើង ដើម្បីកំណត់បញ្ហាប្រឈម ព្រមទាំងស្វែងរកដំណោះស្រាយចំពោះមុខ និងដំណោះស្រាយរយៈពេលវែងលើបញ្ហាប្រឈមទាំងនោះ។




## រូបភាពសកម្មភាពបែកក្រុមពិភាក្សាក្នុងមហាសន្និបាត

## កិច្ចពិភាក្សាតាមក្រុមប្រធានបទនីមួយៗ





## ប្រធានបទពាក់ព័ន្ធកិច្ចការព្រហ្មទណ្ឌ

## ប្រធានបទពាក់ព័ន្ធកិច្ចការរដ្ឋប្បវេណី



# រូបភាពសកម្មភាពចែកក្រុមពិភាក្សាក្នុងមហាសន្និបាត











## កិច្ចពិភាក្សាតាមក្រុម ប្រធានបទពាក់ព័ន្ធ កិច្ចការរដ្ឋប្បវេណី និង ព្រហ្មទណ្ឌ

កិច្ចពិភាក្សារួមក្រុមនេះត្រូវបានរៀបចំឡើង ក្រោមការដឹកនាំដោយផ្ទាល់របស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងឯកឧត្តមបណ្ឌិតប្រធានតុលាការកំពូលនិងមានការចូលរួមជាយោបល់យ៉ាងផុសផុលពីអង្គមហាសន្និបាត។







## អង្គមហាសន្និបាត បានឯកភាពគ្នាលើ ដំណោះស្រាយរួម

អង្គមហាសន្និបាត បានឯកភាពគ្នាលើដំណោះស្រាយរួមចំពោះបញ្ហាប្រឈមទាំងនេះ និងបានចេញសេចក្តីសម្រេចចិត្តរួម ដែលបានចុះហត្ថលេខាដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌,ឯកឧត្តមប្រធានតុលាការកំពូល និងលោកជំទាវអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ សេចក្តីសម្រេចចិត្តនេះ បានក្លាយជាគោលការណ៍រួម និង ស្មារតីរួម ដែលអាចធានាបានទាំងប្រសិទ្ធភាព ទាំងសង្គតិភាពសម្រាប់ការអនុវត្តបន្តដោយសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស។





# ២-អំពីសមិទ្ធផលនៃវិស័យយុត្តិធម៌

ផ្អែកតាមរបាយការណ៍ស្តីពីលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣, ក្រៅពីការងារពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពការងារផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈ សមិទ្ធផលសំខាន់ៗដែលក្រសួងយុត្តិធម៌ និងសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទូទាំងប្រទេសសម្រេចបាន ក្នុងឆ្នាំ២០២៣ រួមមាន ៖

## ទី១-ការងាររៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ក្នុងឆ្នាំ២០២៣, ការងាររៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងការពិនិត្យ និងផ្តល់យោបល់លើផ្នែកទោសប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលក្រសួងយុត្តិធម៌សម្រេចបានមានដូចខាងក្រោម៖

**(១)-លិខិតបទដ្ឋានគតិយុត្តដែលបានរៀបចំរួចដោយក្រសួងយុត្តិធម៌** រួមមានព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣, ព្រះរាជក្រឹត្យស្តីពីការបង្កើតការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣, ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣, អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃរចនាសម្ព័ន្ធចំណុះបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣, អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ និង អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ និងសេចក្តីព្រាងច្បាប់ស្តីពីការចាត់ចែងបណ្តោះអាសន្ននូវវត្ថុចាប់យក និងសេចក្តីព្រាងច្បាប់ស្តីពីក្រឡាបញ្ជី ដែលកំពុងរៀបចំចាត់ចែងបន្តតាមនីតិវិធី។

**(២)-សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលរៀបចំឡើងដោយក្រសួងស្ថាប័ននានា ហើយដែលក្រសួងយុត្តិធម៌បានពិនិត្យ និងផ្តល់យោបល់លើផ្នែកទោសប្បញ្ញត្តិរួចរាល់** រួមមាន៖ សេចក្តីព្រាងច្បាប់ស្តីពីវិធានដើមកំណើតទំនិញ (ក្រសួងពាណិជ្ជកម្ម), សេចក្តីព្រាងច្បាប់ស្តីពីអគ្គិភ័យ... 

(ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ), សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ (**គ.ជ.អ.ប.**, ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ), សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត (ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍), អនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច, អនុក្រឹត្យស្តីពីការស្រាវជ្រាវ និងអភិវឌ្ឍន៍, អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម, អនុក្រឹត្យស្តីពីការគ្រប់គ្រងការសាងសង់ និងការប្រើប្រាស់រួមនៃហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍, អនុក្រឹត្យស្តីពីការរៀបចំការគ្រប់គ្រង និងការបែងចែកវិសាលគមន៍ហ្វ្រេកង់, សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តមួយចំនួនផ្សេងទៀត។

(៣)-**សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលក្រសួងយុត្តិធម៌ បានរៀបចំជិតរួចរាល់រួមមាន៖**, សេចក្តីព្រាងច្បាប់ស្តីពីសារការី, សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា, សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការពាណិជ្ជកម្ម និងបទប្បញ្ញត្តិនីតិវិធីពាណិជ្ជកម្ម, សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការការងារ និងបទប្បញ្ញត្តិនីតិវិធីការងារ។ តាមផែនការ, សេចក្តីព្រាងច្បាប់ទាំងនេះនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០២៤។

## ទី២-ការដោះស្រាយសំណុំរឿង

ក្នុងឆ្នាំ២០២៣, សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទូទាំងប្រទេស បានទទួលចាត់ការលើសំណុំរឿងសរុប **១៤៨ ៨៦៩ ករណី** ក្នុងនោះ **សំណុំរឿងព្រហ្មទណ្ឌ** មានចំនួនសរុប **៨២ ៥៤៦ ករណី** និង **សំណុំរឿងរដ្ឋប្បវេណី** មានចំនួនសរុប **៦៦ ៣២៣ ករណី**។






**សំណុំរឿងសរុបដែលសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទូទាំងប្រទេសបានទទួលចាត់ការក្នុងឆ្នាំ២០២៣**

**សំណុំរឿងដែលសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទូទាំងប្រទេសបានចាត់ការរួច និងនៅសល់កំពុងចាត់ការ ក្នុងឆ្នាំ២០២៣**




**ក-សំណុំរឿងព្រហ្មទណ្ឌ** មានចំនួនសរុប **៨២ ៥៤៦ ករណី** ក្នុងនោះ សំណុំរឿងនៅសាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មានចំនួន **៧៧ ២៧៦ ករណី**, សំណុំរឿង នៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ទាំង ៤ មានចំនួន **៤ ០៨៧ ករណី** និងសំណុំនៅតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលមានចំនួន **១ ១៨៣ ករណី**។

សំណុំរឿងព្រហ្មទណ្ឌសរុបក្នុងឆ្នាំ២០២៣



-សំណុំរឿងព្រហ្មទណ្ឌនៅសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មានចំនួន **៧៧ ២៧៦ ករណី** ក្នុងនោះ បទឧក្រិដ្ឋ មានចំនួន **១២ ២៩១ ករណី**, បទមជ្ឈិមមានចំនួន **៦៣ ៤៦៧ ករណី** និង បទលហុ មានចំនួន **១ ៥១៨ ករណី** (ចំនួនបទលហុនេះមិនរាប់បញ្ចូលករណីដែលមិនបានបញ្ជូនមកតុលាការនោះទេ)។ ក្នុងចំណោមសំណុំរឿងសរុបនេះ, សំណុំរឿងដែលបានចាត់ការរួចមានចំនួន **៥៦ ០១៣ ករណី** និងសំណុំរឿងនៅសល់កំពុងចាត់ការមានចំនួន **២១ ២៦៣ ករណី**។

សំណុំរឿងព្រហ្មទណ្ឌនៅសាលាដំបូង និងអយ្យការអមសាលាដំបូង
រាជធានី-ខេត្តទូទាំងប្រទេសក្នុងឆ្នាំ២០២៣




សំណុំរឿងព្រហ្មទណ្ឌតាមចំណាត់ថ្នាក់បទល្មើសជា បទឧក្រិដ្ឋ បទមជ្ឈិម
និងបទលហុ ក្នុងឆ្នាំ២០២៣




សំណុំរឿងព្រហ្មទណ្ឌដែលបានចាត់ការរួច និងសំណុំរឿងសល់កំពុងចាត់ការ ក្នុងឆ្នាំ២០២៣




-សំណុំរឿងព្រហ្មទណ្ឌនៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ទាំង ៤ មានចំនួន **៤ ០៨៧ ករណី** ក្នុងនោះ សំណុំរឿងដែលបានចាត់ការរួចមានចំនួន **២ ៧៦៥ ករណី** និងសំណុំរឿងនៅសល់កំពុងចាត់ការមានចំនួន **១ ៣២២ ករណី**។

សំណុំរឿងព្រហ្មទណ្ឌនៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ទាំង ៤ ក្នុងឆ្នាំ២០២៣



-សំណុំរឿងព្រហ្មទណ្ឌនៅតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានចំនួន **១ ១៨៣ ករណី** ក្នុងនោះ សំណុំរឿងដែលបានចាត់ការរួចមានចំនួន **៧៤១ ករណី** និងសំណុំរឿងនៅសល់កំពុងចាត់ការមានចំនួន **៤៤២ ករណី**។

សំណុំរឿងព្រហ្មទណ្ឌនៅតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល ក្នុងឆ្នាំ២០២៣




**ខ-សំណុំរឿងរដ្ឋប្បវេណី** មានចំនួនសរុប **៦៦ ៣២៣ ករណី** ក្នុងនោះសំណុំរឿងរដ្ឋប្បវេណីនៅសាលាដំបូងរាជធានី-ខេត្ត មានចំនួន **៦១ ៨៥៩ ករណី**, សំណុំរឿងរដ្ឋប្បវេណីនៅសាលាឧទ្ធរណ៍ទាំង ៤ មានចំនួន **៣ ៣៩៨ ករណី**, សំណុំរឿងរដ្ឋប្បវេណីនៅតុលាការកំពូលមានចំនួន ១ ០៦៦ ករណី។

សំណុំរឿងរដ្ឋប្បវេណីនៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទូទាំងប្រទេស ក្នុងឆ្នាំ២០២៣






-សំណុំរឿងរដ្ឋប្បវេណីនៅសាលាដំបូងរាជធានី-ខេត្ត មានចំនួន **៦១ ៨៥៩ ករណី** ក្នុងនោះ សំណុំរឿងដែលបានចាត់ការរួចមានចំនួន **៤២ ៤៣៤ ករណី** និងសំណុំរឿងនៅសល់កំពុងចាត់ការមានចំនួន **១៩ ៤២៥ ករណី**។

សំណុំរឿងរដ្ឋប្បវេណីនៅសាលាដំបូងរាជធានី-ខេត្តទូទាំងប្រទេ ក្នុងឆ្នាំ២០២៣




សំណុំរឿងរដ្ឋប្បវេណីនៅសាលាដំបូងរាជធនី-ខេត្តនីមួយៗ ក្នុងឆ្នាំ២០២៣



-សំណុំរឿងរដ្ឋប្បវេណីនៅសាលាឧទ្ធរណ៍ទាំង ៤ មានចំនួន **៣ ៣៩៨ ករណី** ក្នុងនោះ សំណុំរឿងដែលបានចាត់ការរួចមានចំនួន **១ ៧៩៤ ករណី** និងសំណុំរឿងនៅសល់កំពុងចាត់ការ មានចំនួន **១ ៦០៤ ករណី**។




-សំណុំរឿងរដ្ឋប្បវេណីនៅតុលាការកំពូល មានចំនួន **១ ០៦៦ ករណី** ក្នុងនោះ សំណុំរឿងដែលបានចាត់ការរួចមានចំនួន **៦៦៧ ករណី** និងសំណុំរឿងកំពុងចាត់ការមានចំនួន ៣៩៩ ករណី។






## ទី៣-ការខារធនធានមនុស្សក្នុងវិស័យយុត្តិធម៌

**១-ចំនួនចៅក្រម និងព្រះរាជអាជ្ញា៖** នៅក្នុងដំណាក់កាលដំបូងនៃការបង្កើតឡើងវិញនូវសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីរបស់កម្ពុជា, ចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានជ្រើសចេញពីក្នុងចំណោមបុគ្គលដែលមានចំណេះដឹង និងបទពិសោធន៍ខ្លះៗ ដែលមានចំនួនប្រមាណ **១៩៥ រូប** ដើម្បីទទួលបានការបណ្តុះបណ្តាលសុក្រឹត្យមុននឹងបំពេញមុខងាររបស់ខ្លួន។ ក្រោយមក, បន្ទាប់ពីការបង្កើត “**សាលាភូមិន្ទចៅក្រម**” នៅឆ្នាំ២០០២ ដែលត្រូវបានកែសម្រួលទៅជា “**រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ**” នៅឆ្នាំ២០០៥ និងត្រូវបានកែសម្រួលទៅជា “**បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា**” នៅឆ្នាំ២០១៣, ការជ្រើសរើសចៅក្រម និងព្រះរាជអាជ្ញាត្រូវបានធ្វើតាមការប្រឡងប្រជែង។ គិតចាប់ពីឆ្នាំ២០០២ រហូតដល់ឆ្នាំ២០១៣, **បណ្ឌិត្យសភា ភូមិន្ទយុត្តិធម៌កម្ពុជា** បានបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញា បានចំនួន ១០ ជំនាន់ មានចំនួនសរុប **៥៦០រូប** ក្នុងនោះ ចៅក្រមចំនួន **៣៦៣រូប** និងព្រះរាជអាជ្ញា **១៩៧រូប**។ ដោយចៅក្រម និងព្រះរាជអាជ្ញាមួយចំនួនបានចូលនិវត្តន៍ ឬបានទទួលមរណភាព ឬបានស្នើសុំព្យួរការងារជាដើម, ដូចនេះ ចៅក្រម និងព្រះរាជអាជ្ញា ដែលកំពុងបំពេញការងារនៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទូទាំងព្រះរាជាណាចក្រកម្ពុជា នាពេលបច្ចុប្បន្ននេះមានចំនួនសរុប ៦៥៦រូប ក្នុងនោះ ចៅក្រមមានចំនួន **៣៨៦រូប** និងព្រះរាជអាជ្ញាមានចំនួន **២៧០រូប**។

ចំនួនចៅក្រម និងព្រះរាជអាជ្ញាសរុប គិតត្រឹមឆ្នាំ២០២៣



ចំនួនចៅក្រម និងព្រះរាជអាជ្ញា គិតត្រឹមឆ្នាំ២០២៣




**ខ-ក្រឡាបញ្ជី៖** គិតត្រឹមឆ្នាំ២០១៣, ក្រឡាបញ្ជី ដែលកំពុងបំពេញការងារនៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ មានចំនួនសរុប **១៥០២ រូប**។




**គ-អាជ្ញាសាលា៖** គិតត្រឹមឆ្នាំ២០១៣, អាជ្ញាសាលា មានចំនួនសរុប **២៨រូប**។




**ឃ-សារការី៖** គិតត្រឹមឆ្នាំ២០១៣, សារការី មានចំនួនសរុប **៦៨រូប** ដែលកំពុង



## ទី៣-ការងាររដ្ឋបាលតុលាការ

ក្នុងឆ្នាំ២០២៣, ក្រសួងយុត្តិធម៌បានបន្តយកចិត្តទុកដាក់ខ្ពស់លើការងារសម្របសម្រួល គ្រប់គ្រង និងត្រួតពិនិត្យអង្គភាពរដ្ឋបាលរបស់អង្គការតុលាការ និងអង្គការអយ្យការ រួមមាន កិច្ចការសាធារណៈ រដ្ឋបាលនីតិវិធី កិច្ចការហិរញ្ញវត្ថុ កិច្ចការគ្រប់គ្រងធនធានមនុស្ស កិច្ចការអាជ្ញាសាលា កិច្ចការក្រឡាបញ្ជី និងកិច្ចការតម្កល់ និងផ្ញើ ជាពិសេសការជំរុញនូវការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ជាមធ្យោបាយជំនួយលើការងាររដ្ឋបាល ការចុះបញ្ជី និងការគ្រប់គ្រងសំណុំរឿង ក្នុងគោលបំណងលើកកម្ពស់ និងធានានូវដំណើរការល្អនៃយុត្តិធម៌។ ក្រុមការងាររបស់ក្រសួងយុត្តិធម៌បានសហការជាមួយអង្គភាពដែលមានការពាក់ព័ន្ធ និងក្រុមហ៊ុនឯកជន ដើម្បីរៀបចំ និងបំពាក់ឧបករណ៍ធ្វើទំនើបកម្មសេវូបករណ៍ ដោយធ្វើការបន្ថែមនូវឧបករណ៍សម្រាប់រក្សាទុកទិន្នន័យ ការដាក់ឱ្យដំណើរការប្រព័ន្ធភ្លើង អគ្គិសនីបំរុង និងប្រព័ន្ធការពារសុវត្ថិភាពទិន្នន័យពីការវាយប្រហារតាមអនឡាញ សំដៅពង្រីកទំហំផ្ទុក និងពង្រឹងប្រព័ន្ធសុវត្ថិភាពឱ្យកាន់តែប្រសើរ។ ឧបករណ៍នេះ កំពុងត្រូវបានប្រើប្រាស់ដោយភ្ជាប់ជាមួយសាលាដំបូងរាជធានី ខេត្ត ទូទាំងប្រទេស តាមប្រព័ន្ធបញ្ជូនទិន្នន័យអនឡាញ។

## ទី៤-ការងារពង្រឹងវិន័យ និងក្រមសីលធម៌

ក្នុងឆ្នាំ២០២៣, ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានយកចិត្តទុកដាក់ខ្ពស់លើការងារពង្រឹងវិន័យរបស់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ព្រមទាំងបុគ្គលិកទាំងអស់ ដែលបម្រើការងារនៅក្រសួងយុត្តិធម៌ និងនៅតាមសាលាជម្រះក្តីនានា សំដៅពង្រឹងប្រសិទ្ធភាពការងារ និងលើកកម្ពស់ការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ។ សម្រាប់ឆ្នាំ២០២៣, អគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានទទួលពាក្យបណ្តឹងចំនួន **៥៧ ករណី** ក្នុងនោះ ពាក្យបណ្តឹងពាក់ព័ន្ធនឹងចំណាត់ការរបស់ចៅក្រមមានចំនួន **៤០ ករណី** និងពាក្យបណ្តឹងពាក់ព័ន្ធនឹងចំណាត់ការរបស់ព្រះរាជអាជ្ញាមានចំនួន **១៧ ករណី**។ ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានប្រជុំចំនួន **១៥ លើក** ដើម្បីពិនិត្យ និងសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធនឹងចំណាត់ការការងាររបស់ចៅក្រម និងព្រះរាជអាជ្ញាចំនួន **១៧រូប**។ ក្រុមប្រឹក្សាវិន័យបានសម្រេចអំពីវិន័យការងាររួមមាន (១)-ឱ្យរួចផុតពីវិន័យចំនួន **៨រូប**, (២)-ការស្តីបន្ទោសដោយផ្ទាល់មាត់ចំនួន **១រូប**, (៣)-ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួនចំនួន **៦រូប** និង(៤)-ការផ្អាកមិនឱ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឱ្យលើសពី ២ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញ ក្នុងករណីដែលមានចុះឈ្មោះរួចហើយចំនួន **២រូប**។

## ទី៥-ការងារសហប្រតិបត្តិការអន្តរជាតិផ្នែកច្បាប់ក្នុងវិស័យយុត្តិធម៌

ក្រសួងយុត្តិធម៌ ជាអាជ្ញាធរកណ្តាលសម្រាប់កិច្ចសហប្រតិបត្តិការផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី បត្យាប័ន និងការផ្ទេរទណ្ឌិត។ ក្នុងឆ្នាំ២០២៣, ក្រសួងយុត្តិធម៌បានទទួលសំណើចូល និងរៀបចំសំណើចេញ លើការងារជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី, កិច្ចការបត្យាប័ន និងកិច្ចការផ្ទេរទណ្ឌិត សរុបចំនួន **១២៤ ករណី** ក្នុងនោះ សំណើចូលមានចំនួន **១១០ករណី** និងសំណើចេញចំនួន **១៤ករណី** ដែលរួមមាន៖

**-ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ (MLA ព្រហ្មទណ្ឌ) ៖** ក្រសួងយុត្តិធម៌បានទទួលនូវការស្នើសុំការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌចំនួន **៧៣ ករណី** ពីបណ្តាប្រទេសចំនួន ១៥។ សំណើដែលបានចាត់ការរួចរាល់មានចំនួន **១៩ ករណី**, សំណើកំពុងរង់ចាំការឆ្លើយតបពីស្ថាប័នមានសមត្ថកិច្ចមានចំនួន **៣២ ករណី** និងសំណើកំពុងពិនិត្យ និយ័តភាពមានចំនួន **២២ ករណី**។ ទន្ទឹមនេះ, ក្រសួងយុត្តិធម៌បានផ្ញើសំណើចេញ **១២ ករណី** ទៅប្រទេសចំនួន ៤។

**-ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យរដ្ឋប្បវេណី (MLA រដ្ឋប្បវេណី) ៖** ក្រសួងយុត្តិធម៌បានទទួលសំណើសុំការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យរដ្ឋប្បវេណី ចំនួន **២២ករណី** ពីប្រទេសចំនួន ៧។ សំណើដែលបានចាត់ការរួច មានចំនួន **៥ ករណី**, សំណើកំពុងរង់ចាំការឆ្លើយតបពីស្ថាប័នមានសមត្ថកិច្ចមានចំនួន **២ករណី** និងសំណើដែលកំពុងពិនិត្យនិយ័តភាពមានចំនួន **១៤ ករណី**។ ទន្ទឹមនេះ, ក្រសួងយុត្តិធម៌បានផ្ញើសំណើចេញ **១ ករណី** ទៅប្រទេសម៉ាឡេស៊ី។

**-កិច្ចការផ្ទេរទណ្ឌិត ៖** ក្រសួងយុត្តិធម៌បានទទួលសំណើសុំការផ្ទេរទណ្ឌិតចំនួន **៩ ករណី** ពីប្រទេសចំនួន ៧ ដែលទណ្ឌិតសរុបចំនួន **៧១ រូប**។ ក្រសួងយុត្តិធម៌បានផ្ទេរទណ្ឌិតចំនួន **៦៨ រូប** ក្នុងនោះមានទណ្ឌិតឡាវចំនួន **៣៤ រូប**, ទណ្ឌិតថៃចំនួន **៣២ រូប**, ទណ្ឌិតឥណ្ឌាចំនួន **១ រូប** និងទណ្ឌិតស៊ុយអែតចំនួន **១ រូប**។

**-កិច្ចការបត្យាប័ន ៖** ក្រសួងយុត្តិធម៌បានទទួលការស្នើសុំធ្វើបត្យាប័នចំនួន **៦ ករណី** ពីប្រទេសចំនួន ៤ ដែលសំណើចំនួន **១ ករណី** បានធ្វើបត្យាប័នរួចរាល់ និងសំណើដែលកំពុងសិក្សា ពិនិត្យនិយ័តភាពមានចំនួន **៥ ករណី**។ ជាមួយគ្នានេះ, ក្រសួងយុត្តិធម៌បានស្នើសុំធ្វើបត្យាប័នចំនួន **១ ករណី** ទៅប្រទេសថៃ។

# ៣-ខ្លឹមសារនៃសេចក្តីសម្រេចចិត្ត របស់មហាសន្និបាត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីសម្រេចចិត្ត
## មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត

មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត បានប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃពេញ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ឯកឧត្តមបណ្ឌិត ជីវ កេង** ប្រធានតុលាការកំពូល និង **លោកជំទាវ ជា លាង អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល**។ មហាសន្និបាតនេះ មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំនៃក្រសួងយុត្តិធម៌ ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ ជាចៅក្រម និងព្រះរាជអាជ្ញា នៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស និង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនៃអង្គភាពរដ្ឋបាលតុលាការនៅទូទាំងប្រទេស សរុបចំនួនប្រមាណជាង **៧៥០ រូប**។

មហាសន្និបាតវិស័យយុត្តិធម៌នេះ មិនត្រឹមតែជាការជួបជុំដ៏ធំលើកទី១ ពុំធ្លាប់មានក្នុងវិស័យយុត្តិធម៌ និងត្រូវបានចាត់ទុកថាជា **"ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀតសម្រាប់វិស័យយុត្តិធម៌"** ប៉ុណ្ណោះទេ ប៉ុន្តែព្រឹត្តិការណ៍នេះត្រូវបានរៀបចំឡើងក្នុងបរិការណ៍នៃការចាប់ផ្តើមចេញដំណើររបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានកំណត់យក **"ការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌"** ជាមុំមួយក្នុងចំណោមមុំទាំង ៥ ដែលបង្កើតបានជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល និងជាវិធានការគន្លឹះមួយក្នុងចំណោមវិធានការគន្លឹះទាំង៥ របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**។ មហាសន្និបាតនេះ ក៏ត្រូវបានរៀបចំឡើងស្របពេលដែលវិស័យយុត្តិធម៌ទាំងមូល បាននិងកំពុងខិតខំប្រឹងប្រែងរួមគ្នាក្នុងការអនុវត្ត **"យុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ"** និង **"យុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ"** ផងដែរ។ មហាសន្និបាតវិស័យយុត្តិធម៌លើកទី១ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីអនុញ្ញាតឱ្យចៅក្រម ព្រះរាជអាជ្ញា និងតួអង្គដែលមានការពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ទាំងអស់ ពិនិត្យ និងពិភាក្សាលើបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ព្រមទាំងសម្រេចដាក់ចេញនូវដំណោះស្រាយរួមចំពោះបញ្ហាប្រឈមទាំងនោះ ដែលអាចធានាបាននូវការឯកភាពទាំងលើគោលជំហរ ទាំងលើទស្សនៈ ដើម្បីធានាប្រសិទ្ធភាព និងសង្គតិភាព សម្រាប់ការអនុវត្តនៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ សំដៅ **"រួមគិត រួមធ្វើ រួមទទួលខុសត្រូវ"** ក្នុងចក្ខុវិស័យរួមតែមួយក្នុងជំហានកាន់តែបុរេសកម្ម កាន់តែសកម្ម កាន់តែស្វាហាប់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីនាំមកនូវការប្រែប្រួលជាវិជ្ជមាននូវមុខមាត់នៃវិស័យយុត្តិធម៌នៅក្នុងសង្គមជាតិ។

KR



អង្គមហាសន្និបាតបានពិនិត្យ និងពិភាក្សាលើប្រធានបទសរុបចំនួន ៨ ពាក់ព័ន្ធនឹងបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌នាពេលកន្លងមក ដែលក្នុងនោះ**ប្រធានបទចំនួន ៤ ពាក់ព័ន្ធនឹងវិស័យរដ្ឋប្បវេណី** ដែលរួមមាន៖ (**ទី១**)-ការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី៖ ប្រសិទ្ធភាព និងបញ្ហាប្រឈម, (**ទី២**)-ការចេញដីកាសម្រេចរក្សាការពារ, (**ទី៣**)-ការលើកកម្ពស់ប្រសិទ្ធភាព និងជំនឿទុកចិត្តលើការលក់ដោយបង្ខំនូវអចលនវត្ថុ និង (**ទី៤**)-ការជូនដំណឹង និងការបញ្ជូនសេចក្តីសម្រេចរបស់តុលាការ និង**ប្រធានបទចំនួន ៤ ទៀតពាក់ព័ន្ធនឹងវិស័យព្រហ្មទណ្ឌ** ដែលរួមមាន៖ (**ទី១**)-ការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ៖ ប្រសិទ្ធភាព និងបញ្ហាប្រឈម, (**ទី២**)-ការជូនដំណឹងអំពីសាលក្រមកំបាំងមុខ (ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ), (**ទី៣**)-បទល្មើសប្រព្រឹត្តដោយអនីតិជន និង (**ទី៤**)-បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសាលក្រម ឬសាលដីកាក្នុងរឿងព្រហ្មទណ្ឌ។

ឆ្លងតាមការពិភាក្សា និងផ្លាស់ប្តូរយោបល់យ៉ាងផុលផុសលើប្រធានបទនីមួយៗរួចមក, អង្គមហាសន្និបាត បានឯកភាពលើខ្លឹមសារនៃសេចក្តីសម្រេចចិត្តរួម ដូចខាងក្រោម៖

### ប្រធានបទទី១-ការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី៖ ប្រសិទ្ធភាព និងបញ្ហាប្រឈម

អង្គមហាសន្និបាតវិស័យយុត្តិធម៌ សម្តែងនូវអំណរគុណ និងការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះរាជរដ្ឋាភិបាល និងប្រជាជនជប៉ុន, ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), សាស្ត្រាចារ្យ និងអ្នកជំនាញការជប៉ុនទាំងអស់ ដែលបានផ្តល់ការគាំទ្រ និងជំនួយនានា ប្រកបដោយការទទួលខុសត្រូវដល់វិស័យយុត្តិធម៌របស់ព្រះរាជាណាចក្រកម្ពុជា តាមរយៈ **"គម្រោងអភិវឌ្ឍន៍វិស័យច្បាប់និងយុត្តិធម៌"** រយៈពេលជាង ២០ឆ្នាំ កន្លងមកនេះ ដោយបានកសាងនូវប្រព័ន្ធច្បាប់រដ្ឋប្បវេណីមួយយ៉ាងពេញលេញសម្រាប់ព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបានបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់កម្ពុជា ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យរដ្ឋប្បវេណីនេះ។

ឆ្លងកាត់ការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីអស់រយៈពេលជិត ២០ឆ្នាំ កន្លងទៅនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៤ រួមមាន៖ (១)-ការប្រើពាក្យពេចន៍ និងឃ្លាឃ្លោងដែលពិបាកយល់, (២)-សង្គតិភាពរវាងបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីជាមួយច្បាប់ផ្សេងទៀត, (៣)-កង្វះនូវបទប្បញ្ញត្តិមួយចំនួន និង (៤)-ការមិនអាចអនុវត្តបាននូវបទប្បញ្ញត្តិមួយចំនួនក្នុងការជាក់ស្តែង។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាត បានសម្រេចឯកភាពគ្នាលើភាពចាំបាច់ក្នុងការពិនិត្យ និងសិក្សាដើម្បីធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងច្បាប់ពាក់ព័ន្ធក្នុងវិស័យរដ្ឋប្បវេណី សំដៅធ្វើឱ្យប្រសើរឡើងនូវបទប្បញ្ញត្តិដែលមានចែងនៅក្នុងក្រមទាំងពីរនេះ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមនានាក្នុងការអនុវត្តដែលមាននាពេលកន្លងមក និងអាចឆ្លើយតបទៅនឹងតថភាពជាក់ស្តែងនៃសង្គមកម្ពុជា ជាពិសេស ក្នុងបរិការណ៍នៃឌីជីថលូបនីយកម្ម។ ទន្ទឹមនេះ, អង្គមហាសន្និបាត បានសម្រេចប្រគល់ភារកិច្ចជូនក្រុមការងារបច្ចេកទេសរៀបចំការធ្វើវិសោធនកម្មច្បាប់ក្នុងវិស័យរដ្ឋប្បវេណី ដែលបង្កើតឡើងដោយក្រសួងយុត្តិធម៌ ដើម្បីយកចំណុចសំខាន់ៗដែលបានពិភាក្សាក្នុងមហាសន្និបាតនេះ ជាធាតុចូលសម្រាប់ការរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ក្នុងវិស័យនេះ ដោយមិនត្រូវធ្វើឱ្យប៉ះពាល់នូវគោលការណ៍គ្រឹះសំខាន់ៗ និងរចនាសម្ព័ន្ធនៃក្រមទាំងពីរនេះ ព្រមទាំងធ្វើការពិគ្រោះយោបល់ជាមួយអ្នកជំនាញការជប៉ុនក្នុងក្របខ័ណ្ឌនៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌។

KR

## ប្រធានបទទី២-ការចេញដីកាសម្រេចរក្សាការពារ

ពាក់ព័ន្ធនឹងប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៣ រួមមាន៖ (១)-ការចេញដីកាសម្រេចរក្សាការពារមិនត្រឹមត្រូវតាមប្រភេទនៃការចាត់ចែងរក្សាការពារ និងមិនទាន់មានសង្គតិភាពលើទម្រង់នៃដីកាសម្រេចរក្សាការពារ ព្រមទាំងពុំមានលក្ខខណ្ឌតាមច្បាប់គ្រប់គ្រាន់ក្នុងការចេញដីកាសម្រេចរក្សាការពារ, (២)-ការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុដែលមិនបានចុះបញ្ជីសុរិយោដីនៅមិនទាន់អាចធ្វើបាន និង (៣)-ការមិនអាចអនុវត្តបាននូវដីកាសម្រេចរក្សាការពារមួយចំនួន។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាតវិស័យយុត្តិធម៌ បានឯកភាពគ្នាសម្រេច ដូចខាងក្រោម៖

១-រៀបចំ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវទម្រង់រួមនៃដីកាសម្រេចរក្សាការពារ នៅតាមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ ដើម្បីធានាសង្គតិភាព ទាំងលើទម្រង់នៃដីកា ទាំងលើខ្លឹមសារនៃសេចក្ដីសម្រេចបញ្ជប់តាមប្រភេទនៃការចាត់ចែងរក្សាការពារ និងអាចយកទៅអនុវត្តបានប្រកបដោយប្រសិទ្ធភាព។ ក្នុងការអនុវត្តការងារនេះ, អង្គមហាសន្និបាត បានសម្រេចប្រគល់ភារកិច្ចជូន ក្រសួងយុត្តិធម៌ ដើម្បីរៀបចំឱ្យមានទម្រង់រួមនៃដីកាសម្រេចរក្សាការពារ ដោយមានការពិគ្រោះយោបល់ជាមួយសាលាជម្រះក្ដីទាំងអស់មុននឹងដាក់ឱ្យអនុវត្តនៅទូទាំងប្រទេស។

២-យន្តការវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវពង្រឹងការត្រួតពិនិត្យខាងវិន័យ ក្នុងករណីចៅក្រមប្រើធន្ទានុសិទ្ធិដោយរំលោភបំពានក្នុងការចេញដីកាសម្រេចរក្សាការពារ សំដៅធានាការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ និងលើកកម្ពស់ជំនឿទុកចិត្តរបស់សាធារណជនលើវិស័យយុត្តិធម៌។

## ប្រធានបទទី៣-ការលើកកម្ពស់ប្រសិទ្ធភាព និងជំនឿទុកចិត្តលើការលក់ដោយបង្ខំនូវអចលនវត្ថុ

ពាក់ព័ន្ធនឹងប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៣ រួមមាន៖ (១)-ការកំណត់តម្លៃលក់អប្បបរមានៃអចលនវត្ថុមិនមានភាពច្បាស់លាស់ ដោយមិនទាន់បានកំណត់ច្បាស់លាស់នូវស្ថាប័ន ឬយន្តការធ្វើការវាយតម្លៃអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ដោយបង្ខំ, (២)-ការផ្សព្វផ្សាយជាសាធារណៈអំពីការលក់ឡាយឡុង មិនបានទូលំទូលាយ និង (៣)-ការអូសបន្លាយពេលវេលានៃការអនុវត្តការលក់ដោយបង្ខំដោយតុលាការ ដោយសារភាពស្មុគស្មាញនៃនីតិវិធីជាធរមាន។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាតវិស័យយុត្តិធម៌ បានឯកភាពគ្នាសម្រេច ដូចខាងក្រោម៖

១-ការផ្សព្វផ្សាយជាសាធារណៈអំពីការលក់ដោយបង្ខំតាមផ្លូវតុលាការ ត្រូវធ្វើឡើងឱ្យបានទូលំទូលាយ។ ក្នុងការអនុវត្តការងារនេះ, ក្រសួងយុត្តិធម៌ នឹងបង្កើតឱ្យមានបណ្ដាញទំនាក់ទំនងសង្គមផ្លូវការ ជាអាទិ៍ Facebook ឬ Telegram ដើម្បីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការលក់ដោយបង្ខំតាមផ្លូវតុលាការ។ ទន្ទឹមនេះ, សាលាជម្រះក្ដីនីមួយៗអាចបង្កើតព្រឹត្តិបត្រព័ត៌មាន ដើម្បីផ្សព្វផ្សាយនៅតាមបណ្ដាញសង្គមផ្លូវការរបស់ខ្លួនផងដែរ។

២-ដើម្បីធានាតម្លាភាព និងជំនឿទុកចិត្តក្នុងការកំណត់តម្លៃនៃអចលនវត្ថុដែលត្រូវលក់ដោយបង្ខំតាមផ្លូវតុលាការ, ការវាយតម្លៃអចលនវត្ថុដែលត្រូវលក់ដោយបង្ខំ ត្រូវធ្វើឡើងដោយក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ ដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌។ ក្នុងការអនុវត្តការងារនេះ, ក្រសួងយុត្តិធម៌ នឹងពិចារណាចុះកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ។ ដើម្បីធានាប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្ត, ក្រសួងយុត្តិធម៌ និងតុលាការកំពូល នឹងដាក់ចេញនូវសេចក្ដីណែនាំរួម ពាក់ព័ន្ធនឹងការងារនេះ។

KR



៣-នីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុ នឹងត្រូវបានពិនិត្យកែសម្រួលឡើងវិញឱ្យមានលក្ខណៈសាមញ្ញ និងងាយស្រួលក្នុងការអនុវត្ត នៅក្នុងក្របខ័ណ្ឌនៃការធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីធានាភាពឆាប់រហ័ស និងប្រសិទ្ធភាពនៃការអនុវត្តការលក់ដោយបង្ខំនេះ។

## ប្រធានបទទី៤-ការជូនដំណឹង និងការបញ្ជូនសេចក្ដីសម្រេចរបស់តុលាការ

ចំពោះប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៤ រួមមាន៖ (១)-បញ្ហាកង្វះមន្ត្រីប្រតិបត្តិកិច្ចការបញ្ជូន, (២)-ការអនុវត្តមិនបានត្រឹមត្រូវរបស់មន្ត្រីប្រតិបត្តិកិច្ចការបញ្ជូន, (៣)-វិធីបញ្ជូនដែលបានកំណត់ក្នុងច្បាប់លែងឆ្លើយតបនឹងស្ថានភាពវិវត្តរបស់សង្គម និងបច្ចេកវិទ្យាឌីជីថល និង (៤)-ការអនុវត្តមិនត្រឹមត្រូវនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាតវិស័យយុត្តិធម៌ បានឯកភាពគ្នាសម្រេច ដូចខាងក្រោម៖

១-ក្នុងអំឡុងពេលរង់ចាំច្បាប់ស្ដីពីអាជ្ញាសាលាត្រូវបានរៀបចំនិងអនុម័តឱ្យប្រើ, ក្រសួងយុត្តិធម៌ ត្រូវរៀបចំឱ្យមានមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូន ដែលនឹងទទួលបានប្រតិភូកម្មអំណាចពីអាជ្ញាសាលា ឬក្រឡាបញ្ជី ហើយដែលស្ថិតក្រោមការទទួលខុសត្រូវរួមរបស់ប្រធានសាលាជម្រះក្ដី ដើម្បីអនុវត្តកិច្ចការបញ្ជូន។

២-ក្រសួងយុត្តិធម៌ នឹងសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីរៀបចំឱ្យមានយន្តការរួមមួយ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃក្នុងការអនុវត្តកិច្ចការបញ្ជូនឱ្យបានឆាប់រហ័ស និងឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ជាធរមាន។

៣-ក្នុងការធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី នឹងត្រូវបញ្ចូលបន្ថែមនូវរបៀបនៃការបញ្ជូន ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធទំនាក់ទំនងសង្គម ដែលអាចធានាបាននូវប្រសិទ្ធភាព, ភាពឆាប់រហ័ស និងកាត់បន្ថយការចំណាយថវិកាលើកិច្ចការបញ្ជូននេះ។

## ប្រធានបទទី៥-ការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ៖ ប្រសិទ្ធភាព និងបញ្ហាប្រឈម

អង្គមហាសន្និបាតវិស័យយុត្តិធម៌ សម្ដែងនូវអំណរគុណដល់ជំនួយនៃសហប្រតិបត្តិការរបស់សាធារណរដ្ឋបារាំង និងប្រជាជនបារាំង ដែលបានផ្ដល់នូវកិច្ចសហប្រតិបត្តិការក្នុងការកសាងក្របខ័ណ្ឌច្បាប់ព្រហ្មទណ្ឌសម្រាប់ព្រះរាជាណាចក្រកម្ពុជា ដែលជាមូលដ្ឋានគតិយុត្ត និងគ្រឹះនៃច្បាប់ដ៏សំខាន់ សម្រាប់អ្នកអនុវត្តច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដើម្បីបង្ការ បង្ក្រាប និងទប់ស្កាត់បទល្មើសប្រកបដោយប្រសិទ្ធភាព តម្លាភាព និងធានាបាននូវការការពារសិទ្ធិ សេរីភាព និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ព្រមទាំងចូលរួមចំណែកក្នុងការពង្រឹងសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម។

ឆ្លងកាត់ការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ អស់រយៈពេលជាង ១៥ ឆ្នាំកន្លងទៅនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញនូវកញ្ចប់បញ្ហាចំនួន ៤ រួមមាន៖ (**ទី១**)-បទប្បញ្ញត្តិមួយចំនួននៅមានភាពមិនទាន់ច្បាស់លាស់ ឬមិនទាន់រលូន ដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៅក្នុងការអនុវត្ត, (**ទី២**)-បទប្បញ្ញត្តិមួយចំនួននៅមិនទាន់អាចឆ្លើយតបទៅនឹងស្ថានភាពនៃសង្គមជាក់ស្ដែង, (**ទី៣**)-ភាពចាំបាច់ក្នុងការរៀបចំបទប្បញ្ញត្តិថ្មីៗបន្ថែម ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល និង (**ទី៤**)-ក្នុងករណីចាំបាច់ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនឹងអាចត្រូវពិនិត្យមើលឡើងវិញ ដើម្បីធានាប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា។

KR

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាត បានសម្រេចឯកភាពគ្នា លើភាពចាំបាច់ក្នុងការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ, ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធក្នុងវិស័យព្រហ្មទណ្ឌ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវការលំបាកនៅក្នុងការអនុវត្ត, បំពេញបន្ថែមនូវចំណុចខ្វះខាត ដោយផ្អែកតាមការវិវត្តនៃស្ថានភាពសង្គម និងបច្ចេកវិទ្យា ព្រមទាំងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៅកម្ពុជា។

**<u>ប្រធានបទទី៦-ការជូនដំណឹងអំពីសាលក្រមកំបាំងមុខ (ការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ)</u>**

ចំពោះប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ២ រួមមាន៖ (**ទី១**)-បទប្បញ្ញត្តិច្បាប់មួយចំនួនមានភាពមិនច្បាស់លាស់ដែលនាំឱ្យមានការបកស្រាយផ្សេងគ្នា និងការអនុវត្តមិនមានសង្គតិភាព និង (**ទី២**)-បញ្ហាប្រឈមក្នុងការជូនដំណឹងដែលធ្វើឱ្យសេចក្ដីសម្រេចមួយចំនួនរបស់តុលាការមិនអាចចូលជាស្ថាពរបាន។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាត បានសម្រេចឯកភាពគ្នាថា ត្រូវបន្តអនុវត្តស្របតាមមាតិកាទី៤ ចាប់ពីមាត្រា៤៨២ ដល់មាត្រា៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប៉ុន្តែ, ដើម្បីដោះស្រាយបញ្ហាចំពោះមុខ និងក្នុងអំឡុងពេលនៃការរង់ចាំការធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ, អង្គមហាសន្និបាតបានសម្រេចឯកភាពគ្នាលើវិធានការបំពេញបន្ថែម ដូចខាងក្រោម៖

**១**-ការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ អាចធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ស្របតាមស្មារតីនៃមាត្រា៤៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២**-បន្ថែមលើការអនុវត្តនីតិវិធីនៃការជូនដំណឹងដែលបានអនុវត្តនាពេលកន្លងមក ស្របតាមមាត្រា៤៨៨ និងមាត្រា៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ អាចធ្វើឡើងតាមរយៈសារព័ត៌មាន ឬតាមយន្តការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងវិស័យយុត្តិធម៌ ក្នុងករណីដែលភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន ឬពុំមានលំនៅឋានឬទីសំណាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងយុត្តិធម៌ និងតុលាការកំពូលនឹងដាក់ចេញនូវសេចក្ដីណែនាំរួមអំពីការជូនដំណឹងនេះ ដើម្បីធានាបាននូវការឯកភាពក្នុងការអនុវត្ត។

**<u>ប្រធានបទទី៧-បទល្មើសប្រព្រឹត្តដោយអនីតិជន</u>**

ចំពោះប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៤ រួមមាន៖ (**ទី១**)-ការអនុវត្តនីតិវិធី និងវិធានពិសេស ដែលមានចែងនៅក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជននៅមានកម្រិត, (**ទី២**)-កង្វះទីកន្លែងសម្រាប់ទទួលថែរក្សាអនីតិជនទំនាស់នឹងច្បាប់ក្នុងករណីមានការអនុវត្តវិធានការបង្វែរ និង (**ទី៣**)-ការខ្វែងគំនិតគ្នាលើការលើកយកស្ថានសម្រាល ឬស្ថានទម្ងន់ទោសមកអនុវត្ត ជាពិសេស ការថ្លឹងថ្លែងរវាងផលប្រយោជន៍របស់ជនល្មើសជាអនីតិជន, ផលប្រយោជន៍របស់ជនរងគ្រោះ និងផលប្រយោជន៍នៃសន្តិសុខសង្គម និងសណ្ដាប់ធ្នាប់សាធារណៈ។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាត បានសម្រេចឯកភាពគ្នាក្នុងការបន្តពង្រឹងការអនុវត្តបទប្បញ្ញត្តិដែលមានស្រាប់ទាក់ទងនឹងអនីតិជនទំនាស់នឹងច្បាប់ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ, ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។ ទន្ទឹមនេះ, អង្គមហាសន្និបាតគាំទ្រការកំណត់យក

KR



វិធានការបង្វែរជាវិធានការអាទិភាពដែលត្រូវអនុវត្តតាមការកំណត់របស់ច្បាប់នៅក្នុងសំណុំរឿងព្រហ្មទណ្ឌពាក់ព័ន្ធនឹងអនីតិជន ប៉ុន្តែ ត្រូវពិចារណាថ្លឹងថ្លែងឱ្យបានច្បាស់លាស់អំពីផលប្រយោជន៍របស់អនីតិជនទំនាស់នឹងច្បាប់ និងផលប្រយោជន៍នៃសន្តិសុខសង្គម និងសណ្ដាប់ធ្នាប់សាធារណៈ ទៅតាមករណីជាក់ស្ដែងនីមួយៗ។

**<u>ប្រធានបទទី៨-បណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសាលក្រម ឬសាលដីកាក្នុងរឿងព្រហ្មទណ្ឌ</u>**

ពាក់ព័ន្ធនឹងប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៣ រួមមាន៖ (**ទី១**)-បទប្បញ្ញត្តិច្បាប់មួយចំនួនមានភាពមិនច្បាស់លាស់ដែលនាំឱ្យមានការបកស្រាយផ្សេងគ្នា និងការអនុវត្តមិនមានសង្គតិភាព, (**ទី២**)-អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាមិនបានប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខ ឬមិនបានការពារបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខរបស់ខ្លួន និង (**ទី៣**)-ការទទួលយក និងការសម្រេចអំពីបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿងព្រហ្មទណ្ឌ នៅមិនទាន់មានសង្គតិភាពរវាងសាលាជម្រះក្ដីនានា។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាត បានសម្រេចឯកភាពគ្នា ដូចខាងក្រោម៖

**១**-អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាទាំងអស់ ត្រូវពង្រឹងតួនាទី, ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខ និងត្រូវការពារបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខរបស់ខ្លួនក្នុងសំណុំរឿងព្រហ្មទណ្ឌឱ្យបានត្រឹមត្រូវស្របតាមច្បាប់ ដើម្បីធានាការពារសន្តិសុខសង្គម និងផលប្រយោជន៍សាធារណៈ។

**២**-ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ មានសិទ្ធិក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសាទុក្ខ ស្របតាមមាត្រា២, មាត្រា២២, មាត្រា២៣, មាត្រា២៤, មាត្រា៣៧៥, មាត្រា៤០២, មាត្រា៤១៧, មាត្រា៤១៨ និងមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានានូវសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ក្នុងការទាមទារសំណងជំងឺចិត្តចំពោះព្យសនកម្មដែលខ្លួនបានទទួលរង ប៉ុន្តែ បណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខ ដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី មានអានុភាពតែទៅលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីប៉ុណ្ណោះ។ ក្នុងករណីដែលពុំមានបណ្ដឹងឧទ្ធរណ៍របស់អយ្យការអមសាលាដំបូង ឬមហាអយ្យការអមសាលាឧទ្ធរណ៍, តុលាការ ដែលទទួលបណ្ដឹងឧទ្ធរណ៍តែពីដើមបណ្ដឹងរដ្ឋប្បវេណី អាចសម្រេចបានតែអំពីសំណងរដ្ឋប្បវេណីប៉ុណ្ណោះ ក្នុងករណីពិនិត្យឃើញមានកំហុសរបស់ជនជាប់ចោទ ប៉ុន្តែ តុលាការមិនអាចសម្រេចអំពីការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌបានឡើយ។ ករណីនេះ ត្រូវអនុវត្តដូចគ្នាផងដែរចំពោះបណ្ដឹងសាទុក្ខ។

ក្រៅពីប្រធានបទទាំង ៨ ខាងលើ, អង្គមហាសន្និបាត បានពិនិត្យ និងពិភាក្សាលើការងារពាក់ព័ន្ធនឹងការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃរដ្ឋបាលតុលាការ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យយុត្តិធម៌ក្នុងបរិបទគណនេយ្យភាពសមិទ្ធកម្ម។ ចំពោះការងារនេះ, **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** បានធ្វើការណែនាំ ដូចខាងក្រោម៖

**១**-អង្គភាពរដ្ឋបាលតុលាការ ត្រូវពង្រឹងប្រសិទ្ធភាពនៃការអនុវត្តតួនាទីរបស់ខ្លួនក្នុងនាមជាសេនាធិការផ្នែករដ្ឋបាល, ហិរញ្ញវត្ថុ និងបច្ចេកទេស ទាំងសម្រាប់សាលាជម្រះក្ដី ទាំងសម្រាប់អង្គការអយ្យការអមសាលា

KR

ជម្រះក្តីគ្រប់ជាន់ថ្នាក់។ សាលាច្បាប់នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា និងអង្គភាពរដ្ឋបាលតុលាការនៃសាលាជម្រះក្តីនានា ត្រូវសហការគ្នារៀបចំផែនការពង្រឹងសមត្ថភាពមន្ត្រីអង្គភាពរដ្ឋបាលតុលាការ ដោយត្រូវចាប់ផ្តើមបណ្តុះបណ្តាលចាប់ពីឆមាសទី២ ឆ្នាំ២០២៤ តទៅ។

២-ប្រគល់ភារកិច្ចដល់ក្រុមការងារតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមលើការងារថវិកាក្នុងវិស័យយុត្តិធម៌របស់ក្រសួងយុត្តិធម៌ ដើម្បីរៀបចំ និងអនុវត្តឱ្យមានប្រសិទ្ធភាពនូវវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដល់មន្ត្រីរដ្ឋបាលតុលាការ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តថវិកានៅតាមសាលាជម្រះក្តីនីមួយៗ។

បន្ថែមលើសេចក្តីសម្រេចចិត្តរបស់អង្គមហាសន្និបាត, **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈអធិបតី** ក៏បានផ្តល់ការណែនាំបន្ថែមចំពោះមហាសន្និបាត ដែលមានខ្លឹមសារដូចមានភ្ជាប់មកជាមួយ។

អាស្រ័យហេតុនេះ, សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ និងអង្គភាពចំណុះក្រសួងយុត្តិធម៌, ជាចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធទាំងអស់** ចូលរួមអនុវត្តសេចក្តីសម្រេចចិត្តរួមរបស់អង្គមហាសន្និបាតខាងលើឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនសំដៅពង្រឹងប្រសិទ្ធភាពការងារ, ប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ដើម្បីជាឧត្តមប្រយោជន៍នៃវិស័យយុត្តិធម៌ និងឧត្តមប្រយោជន៍របស់ជាតិ និងប្រជាជនកម្ពុជា។ KR

ថ្ងៃព្រហស្បតិ៍ ៩រោច ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**ប្រធានតុលាការកំពូល**

**បណ្ឌិត ជីវ កេង**

**អគ្គព្រះរាជអាជ្ញា**
**នៃមហាអយ្យការអមតុលាការកំពូល**

**ជា លាង**

៧/៧

# ៤-សុន្ទរកថារបស់ថ្នាក់ដឹកនាំ

## សុន្ទរកថា

## ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## ថ្លែងក្នុងពិធីបើកមហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌
## ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារអាទិភាពបន្ត

*នៅសណ្ឋាគារ **ហ្គាឌិនស៊ីធី** (Garden City), ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤*

**សូមគោរពគណៈអធិបតី**

- ឯកឧត្តមបណ្ឌិត **ជីវ កេង** ប្រធានតុលាការកំពូល
- លោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល
- ឯកឧត្តម លោកជំទាវ ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ នៃក្រសួងយុត្តិធម៌
- ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ នៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ឯកឧត្តម **លី ច័ន្ទតុលា** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា នៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- អង្គមហាសន្និបាតទាំងមូល ជាទីមេត្រី!

១-ថ្ងៃនេះ វិស័យយុត្តិធម៌របស់យើងបានមកជួបជុំគ្នា ដើម្បីរៀបចំនូវកិច្ចប្រជុំដ៏ធំមួយ ដែលមិនធ្លាប់មានកន្លងមកក្នុងទម្រង់ជា "មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារអាទិភាពបន្ត"។ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុង "ពិធីបើកព្រឹត្តិការណ៍នៃការជួបជុំដ៏ធំ និងដ៏មានសារសំខាន់" នាឱកាសដ៏វិសេសវិសាលនេះ។

២-**មហាសន្និបាតវិស័យយុត្តិធម៌នេះ** ដែលនឹងប្រព្រឹត្តទៅរយៈពេល ៣ ថ្ងៃពេញ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ នេះ នឹងត្រូវចារឹកទុកជា "ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀតសម្រាប់វិស័យយុត្តិធម៌" ដោយហេតុថា៖ *(ទី១)*-នេះ គឺជាមហាសន្និបាតលើកទី១ ក្នុងវិស័យយុត្តិធម៌ ដែលមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំសំខាន់ៗក្នុងវិស័យយុត្តិធម៌ ព្រមទាំងចៅក្រម ព្រះរាជអាជ្ញា នៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស (លើកលែងតែអ្នកត្រូវនៅប្រចាំការ) ក្នុងឯកសណ្ឋានអាវផាយដ៏ស្រស់ស្អាតប្រកបដោយមោទនភាព ដែលយើងពុំធ្លាប់ដែលបានរៀបចំឡើយពីមុនមក គិតចាប់តាំងពីព្រះរាជាណាចក្រកម្ពុជាទី២ ត្រូវបានបង្កើតឡើង, *(ទី២)*-មហាសន្និបាតនេះ ត្រូវបានរៀបចំឡើងបន្ទាប់ពីយន្តការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានកែសម្រួលរៀបចំឡើងវិញ ដោយមាន **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** និង**ប្រធានតុលាការកំពូល** ជាសហប្រធាន, *(ទី៣)*-មហាសន្និបាតនេះ ត្រូវបានរៀបចំឡើងក្នុងបរិការណ៍នៃការចាប់ផ្តើមចេញដំណើររបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិត របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**



**ប្រមុខរាជរដ្ឋាភិបាលថ្មី** ដែល **សម្តេច** បានប្រកាសកំណត់យក "ការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌" ជាការងារអាទិភាពក្នុងវិធានការគន្លឹះទាំង ៥ របស់ **សម្តេច** និងជាការដ្ឋានកែទម្រង់ដ៏សំខាន់របស់រាជរដ្ឋាភិបាល និង *(ទី៤)*-មហាសន្និបាតនេះ ក៏ត្រូវបានរៀបចំឡើងស្របពេលដែលវិស័យយុត្តិធម៌ទាំងមូល បាននិងកំពុងខិតខំប្រឹងប្រែងរួមគ្នាក្នុងការអនុវត្តយុទ្ធនាការសំខាន់ៗចំនួន ២ ដែល **ឯកឧត្តម លោកជំទាវ** បានជ្រាបស្រាប់ គឺ យុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ដែលជាការចាប់ផ្តើមអនុវត្តការដ្ឋានកែទម្រង់ដ៏សំខាន់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌ សំដៅរួមគ្នាសម្រេចឱ្យបាននូវការពង្រឹង និងការលើកកម្ពស់ជំនឿទុកចិត្តលើស្ថាប័នអនុវត្តច្បាប់ ពិសេស អំណាចតុលាការ ពីសំណាក់ប្រជាពលរដ្ឋ និងធុរជន។ តាមការគ្រោងទុក, មហាសន្និបាតវិស័យយុត្តិធម៌ដ៏ធំបែបនេះ នឹងត្រូវរៀបចំឡើងរៀងរាល់ ៥ ឆ្នាំម្តង ដើម្បីជាការបូកសរុបលទ្ធផលការងារដែលវិស័យយុត្តិធម៌សម្រេចបាន និងដាក់ចេញនូវទិសដៅបន្ត សំដៅធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌កម្ពុជា ក៏ដូចជា ការលើកកម្ពស់ និងពង្រឹងនីតិរដ្ឋ ដែលជាគ្រឹះសម្រាប់ភាពសុខសាន្តរបស់ប្រជាជន និងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

៣-មហាសន្និបាតវិស័យយុត្តិធម៌រយៈពេល ៣ ថ្ងៃនេះ គឺធ្វើឡើងមិនត្រឹមតែដើម្បីបូកសរុបលទ្ធផលការងារដែលវិស័យយុត្តិធម៌សម្រេចបានក្នុងឆ្នាំ២០២៣ កន្លងទៅ និងពិនិត្យវាយតម្លៃបញ្ហាប្រឈម និងដាក់ចេញនូវទិសដៅការងារអាទិភាពដែលត្រូវអនុវត្តបន្តប៉ុណ្ណោះទេ ប៉ុន្តែ មហាសន្និបាតនាពេលនេះ គឺជាវេទិកានៃការជួបជុំដ៏ធំសម្រាប់មន្ត្រីអនុវត្តច្បាប់ក្នុងវិស័យយុត្តិធម៌ រួមគ្នាពិនិត្យ និងពិភាក្សាលើបញ្ហាប្រឈមធំៗមួយចំនួនក្នុងការអនុវត្ត សំដៅដាក់ចេញនូវដំណោះស្រាយរួមគ្នា ដែលអាចធានាបានទាំងសង្គតិភាព ទាំងប្រសិទ្ធភាពក្នុងការអនុវត្តនៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីនានានៅទូទាំងប្រទេស។ ទន្ទឹមនេះ, មហាសន្និបាតនេះ ក៏នឹងអនុញ្ញាតឱ្យចៅក្រម ព្រះរាជអាជ្ញា និងតួអង្គដែលមានការពាក់ព័ន្ធទាំងអស់ក្នុងវិស័យយុត្តិធម៌ ក្តាប់ឱ្យជាប់នូវអ្វីដែលជាចក្ខុវិស័យ, គោលនយោបាយ និងទិសដៅយុទ្ធសាស្ត្រនៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលយើងត្រូវរួមគ្នាចូលរួមអនុវត្ត សំដៅលើកកម្ពស់មុខមាត់នៃវិស័យយុត្តិធម៌ និងពង្រឹងជំនឿទុកចិត្តរបស់ប្រជាជន និងអ្នកវិនិយោគ មកប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

**ឯកឧត្តម លោកជំទាវ និង អង្គមហាសន្និបាតទាំងមូល ជាទីមេត្រី !**

៤-ដូចដែលខ្ញុំតែងបានលើកឡើងនាពេលកន្លងមកជាមួយថ្នាក់ដឹកនាំ និងសហការីមួយចំនួនដែលមានវត្តមាននៅទីនេះថា ការសម្រេចយកការកែទម្រង់វិស័យយុត្តិធម៌ ជាវិធានការគន្លឹះមួយក្នុងចំណោមវិធានការគន្លឹះទាំង ៥ របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** **គឺមិនមែនជារឿងចៃដន្យនោះទេ ហើយក៏មិនមែនជារឿងដែលយើងត្រូវសំឡឹងក្នុងជ្រុងនៃការអបអរសាទរនោះទេ** ប៉ុន្តែ យើងត្រូវយល់ថា គឺដោយសារតែវិស័យនេះកំពុងតែជួបបញ្ហាប្រឈម និងជាការដ្ឋានកែទម្រង់ដ៏សំខាន់របស់ប្រទេសជាតិ។ និយាយបែបនេះ មិនមែនមានន័យថា វិស័យយុត្តិធម៌មានតែបញ្ហានោះទេ។ ជាក់ស្តែង, កន្លងមក វិស័យយុត្តិធម៌ក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ព្រមទាំងការធានាថែរក្សាសន្តិសុខ, សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គមក្រោមម្លប់នៃសុខសន្តិភាពនៅព្រះរាជាណាចក្រកម្ពុជា។ ឆ្លៀតឱកាសនៃការជួបជុំដ៏ថ្លៃថ្លានេះ, ក្នុងនាមរាជរដ្ឋាភិបាល, ក្នុងនាម**ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**, ក្នុងនាម**ឯកឧត្តមប្រធានតុលាការកំពូល**, ក្នុងនាម**លោកជំទាវអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងការវាយតម្លៃខ្ពស់ចំពោះ **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៅតាមសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ក្នុងការអនុវត្តការងារយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់ នាពេលកន្លងមក ក្នុងការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។

ប៉ុន្តែ, ទន្ទឹមនេះ យើងក៏ត្រូវទទួលស្គាល់ផងដែរថា វិស័យយុត្តិធម៌នៅមានបញ្ហាប្រឈមជាច្រើនដែលយើងត្រូវរួមគ្នាដោះស្រាយ និងធ្វើឱ្យវិស័យនេះបានកាន់តែល្អប្រសើរឡើងថែមទៀត។ ហេតុដូចនេះ, មហាសន្និបាតវិស័យយុត្តិធម៌ដ៏ធំរបស់យើងនាពេលនេះ គឺជាឱកាសសម្រាប់យើងនិយាយគ្នាត្រង់ទៅត្រង់មក, ក្ដាប់ឱ្យជាប់នូវគោលនយោបាយ និងទិសដៅការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌, ក្ដាប់ឱ្យជាប់នូវរាល់បញ្ហាប្រឈមសំខាន់ៗក្នុងវិស័យយុត្តិធម៌ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីយើង **"រួមគិត រួមធ្វើ រួមទទួលខុសត្រូវ"** ក្នុងគោលជំហរ, ទិសដៅ និងចក្ខុវិស័យរួមតែមួយ ក្នុងជំហានកាន់តែបុរេសកម្ម, កាន់តែសកម្ម, កាន់តែស្វាហាប់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីនាំមកនូវការប្រែប្រួលជាវិជ្ជមាន និងល្អប្រសើរឡើងបន្ថែមទៀតនូវមុខមាត់នៃវិស័យយុត្តិធម៌នៅក្នុងសង្គមជាតិ ហើយទទួលបាននូវជំនឿទុកចិត្តខ្ពស់ពីសំណាក់ប្រជាពលរដ្ឋ និងអ្នកវិនិយោគ។

ក្នុងន័យនេះ, ខ្ញុំសូមឆ្លៀតយកឱកាសនៃការជួបជុំដ៏ធំនេះ ដើម្បីគូសរំលេចសាជាថ្មីម្ដងទៀតជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គមហាសន្និបាតទាំងមូល** អំពីក្របខ័ណ្ឌគោលនយោបាយ និងទិសដៅជាយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក៏ដូចជា អាទិភាពការងារសំខាន់ៗក្នុងវិស័យនេះ ដែលខ្ញុំធ្លាប់បានលើកឡើងជាច្រើនលើកច្រើនសាររួចមកហើយក្នុងកម្មវិធីនានានាពេលកន្លងមក ដើម្បីឱ្យអង្គមហាសន្និបាតរបស់យើងក្ដាប់បានទាំងអស់គ្នា និងធានាបាននូវឯកភាពគ្នាទាំងលើគោលជំហរ ទាំងលើទស្សនៈ ទាំងលើទិសដៅសំខាន់ៗជាអាទិភាព។

**ឯកឧត្តម លោកជំទាវ និងអង្គមហាសន្និបាតទាំងមូល ជាទីមេត្រី!**

៥-រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ត្រូវបានបង្កើតឡើងជាផ្លូវការ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ហើយពីរថ្ងៃក្រោយមក គឺនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត ប្រមុខរាជរដ្ឋាភិបាលថ្មី នៃព្រះរាជាណាចក្រកម្ពុជា** ក៏បានដឹកនាំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ របស់ខ្លួន ដែលនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីជាប្រវត្តិសាស្ត្រនេះ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** ក៏ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"** ដែលជារបៀបវារៈគោលនយោបាយដ៏សំខាន់របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា។

៦-ផ្អែកតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល, រាជរដ្ឋាភិបាល នៅតែបន្តចាត់ទុក **"ការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌"** គឺជាអាទិភាពមួយដ៏សំខាន់របស់ខ្លួនសំដៅពង្រឹង និងលើកកម្ពស់ **"នីតិរដ្ឋ"** នៅកម្ពុជា ដែលជាមូលដ្ឋានដ៏សំខាន់ ក្នុងការធានាថែរក្សាស្ថិរភាពសង្គម សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ, ការលើកកម្ពស់ការគោរពសិទ្ធិមនុស្ស និងការពង្រឹង **"យុត្តិធម៌នៅក្នុងសង្គមជាតិ"** ដែលជាគ្រឹះសម្រាប់ភាពសុខសាន្តរបស់ប្រជាជន និងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។ **"ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌"** ត្រូវបានរៀបចំបញ្ចូលជាមុំមួយដ៏សំខាន់ក្នុងចំណោមមុំទាំង ៥ ដែលបង្កើតបានជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល សំដៅ **"ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌"** នៅកម្ពុជា ហើយដើម្បីសម្រេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រនៃមុំទី៤ នេះ, រាជរដ្ឋាភិបាល បានដាក់ចេញនូវអាទិភាពលើកិច្ចការចំនួន ៦ រួមមាន៖

**ទី១**-ការលើកកម្ពស់សមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យយុត្តិធម៌ ព្រមទាំង ប្រសិទ្ធភាព និងភាពរហ័សនៃការដោះស្រាយវិវាទ ទាំងក្នុងប្រព័ន្ធតុលាការ ទាំងក្រៅប្រព័ន្ធតុលាការ។

**ទី២**-ការលើកកម្ពស់ប្រសិទ្ធភាព, សង្គតិភាព និងអនុលោមភាពគតិយុត្តនៃការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សំដៅធានាឆ្លើយតបបានទៅនឹងចក្ខុវិស័យ និងសេចក្ដីត្រូវការរបស់សង្គមជាតិ។

**ទី៣**-ការលើកកម្ពស់ការគោរពច្បាប់ និងការផ្ដល់សេវាជំនួយផ្នែកច្បាប់ តាមរយៈការបន្តជំរុញការអប់រំ និងផ្សព្វផ្សាយច្បាប់, ការផ្ដល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការផ្ដល់ការការពារក្ដីនៅចំពោះមុខតុលាការ សំដៅធានាសិទ្ធិទទួលបានយុត្តិធម៌ ជាពិសេស សម្រាប់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះ។



**ទី៤**-ការលើកកម្ពស់ភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពីសំណាក់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ ជាពិសេស ការពង្រឹងប្រសិទ្ធភាពនៃចំណាត់ការលើសំណុំរឿង, ការពង្រឹងភាពសុចរិត ភាពស្អាតស្អំ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់និងមន្ត្រីតុលាការ ព្រមទាំងការពង្រឹងយន្តការអធិការកិច្ច និងការដាក់វិន័យ សំដៅពង្រឹងជំនឿទុកចិត្តលើការអនុវត្តច្បាប់។

**ទី៥**-ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធតុលាការ តាមរយៈការបន្តធ្វើទំនើបកម្មរដ្ឋបាលតុលាការ ដើម្បីលើកកម្ពស់គុណភាពនៃការផ្ដល់សេវាយុត្តិធម៌ឱ្យកាន់តែប្រសើរ និងការពង្រឹងគុណភាពនៃយុត្តិធម៌។

**ទី៦**-ការជំរុញរៀបចំក្របខ័ណ្ឌគតិយុត្ត និងយន្តការសម្រុះសម្រួលនិងផ្សះផ្សាវិវាទ ទាំងក្នុងប្រព័ន្ធតុលាការ ទាំងក្រៅប្រព័ន្ធតុលាការ សំដៅលើកកម្ពស់ប្រសិទ្ធភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទ និងបង្ខិតសេវានៃការដោះស្រាយវិវាទឱ្យកៀកនឹងប្រជាពលរដ្ឋ។

៧-ទន្ទឹមនឹងការប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ ដូចបានរៀបរាប់ជូនខាងលើ, **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានប្រកាសដាក់ចេញនូវវិធានការគន្លឹះបន្ថែមចំនួន ៥ ដែលជាកិច្ចការអាទិភាពដ៏សំខាន់របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខដែលត្រូវសម្រេចឱ្យចេញជាលទ្ធផលជាក់ស្ដែងនៅក្នុងនីតិកាលទី៧ នេះ រួមមាន៖

(១)- ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ ដោយផ្ដោតសំខាន់លើការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន,

(២)- ការលើកកម្ពស់គុណភាពអប់រំ ដោយផ្ដោតសំខាន់លើការពង្រឹងគុណភាពសាលារដ្ឋចាប់ពីថ្នាក់មត្តេយ្យដល់មធ្យមសិក្សា,

(៣)- ការលើកកម្ពស់គុណភាពសេវាសុខាភិបាល ដោយផ្ដោតសំខាន់លើការពង្រឹងសមត្ថភាពផ្ដល់សេវាសុខភាពបឋមនៅមូលដ្ឋាន,

(៤)- ការពង្រឹងការអនុវត្តគោលនយោបាយ **"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"** ដោយផ្ដោតការយកចិត្តទុកដាក់ ជាពិសេស លើការកាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀននៅក្នុងសហគមន៍ និង

(៥)- ការពង្រឹង និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។

៨-ក្នុងចំណោមវិធានការគន្លឹះទាំង ៥ នេះ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** បានប្រកាសយក **"ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌"** ជាវិធានការគន្លឹះទី៥ ហើយ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** បានប្រគល់ភារកិច្ចឱ្យក្រសួងយុត្តិធម៌ ដើម្បីរៀបចំផែនការសកម្មភាពជាក់ស្ដែង សំដៅធ្វើយ៉ាងណាសម្រេចឱ្យបាននូវកិច្ចការអាទិភាពសំខាន់ចំនួន ៣ នៃវិធានការគន្លឹះទី៥ នេះ ដែលកិច្ចការអាទិភាពទាំង ៣ នេះ រួមមាន៖

(ទី១)- ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បន្ថែមលើយន្តការដែលមានស្រាប់ ដើម្បីជួយសម្រុះសម្រួលដោះស្រាយវិវាទឱ្យបានឆាប់រហ័ស ជាពិសេស វិវាទរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

(ទី២)- ការជំរុញ និងពន្លឿនការដោះស្រាយរឿងក្ដីនៅតាមតុលាការឱ្យបានឆាប់រហ័ស សំដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាយុត្តិធម៌ជូនប្រជាជន និង

(ទី៣)- ការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ សំដៅជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ក៏ដូចជា លើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្ដីដោយតុលាការ។

៩-ផ្អែកតាម **"យុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី១"** និង **"វិធានការគន្លឹះទី៥"** នេះ, ជាទិសដៅការងារទៅមុខ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជានេះ នឹងត្រូវប្រមូលផ្ដុំការយកចិត្តទុកដាក់ទៅលើ **"សសរស្ដម្ភ"** សំខាន់ចំនួន ២ គឺ៖

(**សសរស្ដម្ភទី១**)-**គឺការកែទម្រង់ប្រព័ន្ធតុលាការ៖** បេសកកម្មជាអាទិភាពនៃការកែទម្រង់ប្រព័ន្ធតុលាការ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល គឺ ការធានា និងការសម្រេចឱ្យបាននូវគោលដៅចម្បងយ៉ាងតិចចំនួន ២ គឺ៖ (ទី១)-គុណភាពនៃយុត្តិធម៌កាន់តែសុក្រឹត្យ និង (ទី២)-ការផ្ដល់សេវាយុត្តិធម៌កាន់តែរហ័ស និងកាន់តែល្អប្រសើរ ដែលគោលដៅចម្បងទាំងពីរនេះ គឺជាមូលដ្ឋាននៃការពង្រឹងជំនឿទុកចិត្តលើអំណាចតុលាការពីសំណាក់ប្រជាពលរដ្ឋ និង អ្នកវិនិយោគ ។

(**សសរស្ដម្ភទី២**)-**គឺការកែទម្រង់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា៖** តាមរយៈការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សំដៅបង្ហិតសេវានៃការដោះស្រាយវិវាទដែលមានលក្ខណៈងាយស្រួល និងសម្បូរបែបឱ្យទៅជិតប្រជាពលរដ្ឋនៅមូលដ្ឋាន, ជួយសម្រុះសម្រួលផ្សះផ្សាដោះស្រាយបញ្ចប់វិវាទឱ្យបានឆាប់រហ័សជូនប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកលើកកម្ពស់វប្បធម៌សន្តិភាពនិយមក្នុងសង្គមកម្ពុជា។ ចំពោះសសរស្ដម្ភទី២ នេះ, បច្ចុប្បន្ន **អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ត្រូវបានបង្កើតឡើងរួចហើយ ដើម្បីជាយន្តការបន្ថែមលើយន្តការដែលមានស្រាប់ ហើយនឹងមិនជំនួសយន្តការដែលមានស្រាប់នោះទេ។

១០-ការបង្កើតបាននូវ**អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**នេះ គឺជា **"ការបោះជំហានថ្មីមួយដ៏សំខាន់"** នៅក្នុងកិច្ចការកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ហើយរាជរដ្ឋាភិបាលបានផ្ដល់អាទិភាពខ្ពស់លើកិច្ចការងារនេះ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ មានលក្ខណៈស្របទៅនឹងប្រពៃណីនៃការដោះស្រាយវិវាទនៅក្នុងសង្គមកម្ពុជា ហើយផ្ដល់អត្ថប្រយោជន៍ដល់សង្គមជាតិ និងវិស័យយុត្តិធម៌ គឺ៖ (១)-ការកាត់បន្ថយចំនួនសំណុំរឿងនៅតាមតុលាការ, (២)-ការបង្ហិតសេវាដោះស្រាយវិវាទឱ្យទៅកៀកនឹងប្រជាពលរដ្ឋ ពិសេស សេវាដោះស្រាយវិវាទឆាប់រហ័ស និងងាយស្រួលប្រើប្រាស់, (៣)-ធានាបាននូវភាពសុខដុមរមនារបស់ប្រជាជន ដែលជាកោសិការបស់សង្គម និងធានាបាននូវស្ថិរភាពតាមរយៈការលើកកម្ពស់វប្បធម៌សន្តិភាពនិយម និងការពន្លត់បាននូវភ្លើងវិវាទនៅក្នុងសង្គមជាតិរបស់យើងបានឆាប់រហ័ស និង (៤)-ធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តដំណោះស្រាយដែលបានស្រុះស្រួលគ្នា។

១១-ទោះបី **អ.ជ.ក.** ត្រូវបានបង្កើតឡើងក្ដី ប៉ុន្តែ អ្វីដែលសំខាន់ គឺការលើកកម្ពស់ការសម្រុះសម្រួលដោះស្រាយវិវាទរវាងគូភាគី ទាំងនៅក្នុងប្រព័ន្ធតុលាការ ទាំងនៅក្រៅប្រព័ន្ធតុលាការ។ **ហេតុដូច្នេះ, ចៅក្រមទាំងអស់គប្បីព្យាយាមធ្វើការសម្រុះសម្រួល និងផ្សះផ្សា ដើម្បីអាចបញ្ចប់វិវាទនៅក្នុងសំណុំរឿងរដ្ឋប្បវេណីនានា មុននឹងឈានទៅសម្រេចសេចក្ដីតាមរយៈការចេញសាលក្រម ឬសាលដីកា ដើម្បី *ម្យ៉ាង* អាចបញ្ចប់វិវាទនោះឱ្យបានឆាប់រហ័សផង និង *ម្យ៉ាងទៀត* ធ្វើឱ្យគូភាគីទទួលបាននូវលទ្ធផលឈ្នះ-ឈ្នះទាំងអស់គ្នា ហើយដែលនេះក៏ជាយុត្តិធម៌មួយសម្រាប់គូភាគីផងដែរ។** ខ្ញុំសូមគូសបញ្ជាក់ថា ផ្អែកតាមច្បាប់ ការផ្សះផ្សាដែលធ្វើឡើងដោយតុលាការ អាចធ្វើឡើងបាននៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ ហើយមានតម្លៃគតិយុត្តរឹងមាំ ដោយហេតុថា កំណត់ហេតុស្ដីពីការសះជា ដែលជាលទ្ធផលនៃការផ្សះផ្សាបញ្ចប់វិវាទនៅក្នុងប្រព័ន្ធតុលាការ គឺមានអានុភាពអនុវត្តដូចសាលក្រមស្ថាពរផងដែរ។ ឆ្លៀតឱកាសនេះ, ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះចៅក្រមនៃសាលាដម្រះក្ដីមួយចំនួនដែលកន្លងមកបានខិតខំសម្រុះសម្រួលផ្សះផ្សាវិវាទមួយចំនួនរបស់ប្រជាពលរដ្ឋបានដោយជោគជ័យ នាពេលកន្លងមក។



**អបអរមហាសន្និបាតទាំងមូល ជាទីមេត្រី!**

១២-ដើម្បីអនុវត្តកិច្ចការអាទិភាពទី២ និងទី៣ នៃវិធានការគន្លឹះទី៥ របស់ **សម្ដេចធិបតីប្រមុខរាជរដ្ឋាភិបាល** ក្នុងការសម្រេចឱ្យបាននូវបេសកកម្មជាអាទិភាព និងគោលដៅនៃការកែទម្រង់ប្រព័ន្ធតុលាការដូចបានគូសបញ្ជាក់ជូនអង្គពិធីមុននេះ, ក្រសួងយុត្តិធម៌ បានសម្រេចដាក់ចេញជាយុទ្ធនាការចំនួន ២ ព្រមពេលជាមួយគ្នា ដើម្បីអនុវត្តកិច្ចការអាទិភាពទី២ និងទី៣ ក្នុងនោះ **យុទ្ធនាការទី១ គឺ ជាយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្ដីនៅតាមតុលាការ** និង**យុទ្ធនាការទី២ គឺ យុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ**។

១៣-យុទ្ធនាការទាំង ២ នេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌ ដែលជាបំណងប្រាថ្នារបស់ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងការលើកកម្ពស់ **"គោលការណ៍នីតិរដ្ឋ"** និង **"យុត្តិធម៌នៅក្នុងសង្គមជាតិ"** ដែលកិច្ចការនេះត្រូវបានចាត់ទុកជាអាទិភាពនយោបាយដ៏សំខាន់មួយដែលត្រូវអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្ដែង ក្នុងនោះ ***យុទ្ធនាការទី១*** នឹងជួយលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាយុត្តិធម៌ជូនប្រជាជន ប្រកបដោយភាពឆាប់រហ័ស ហើយ ***យុទ្ធនាការទី២*** នឹងជួយដោះស្រាយរកយុត្តិធម៌ឱ្យបានត្រឹមត្រូវជូនប្រជាពលរដ្ឋ ក៏ដូចជា លើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្ដីដោយតុលាការ។

១៤-ការសម្រេចចិត្តអនុវត្តកិច្ចការអាទិភាពទាំង ២ នេះ ក្នុងទម្រង់ជាយុទ្ធនាការទាំង ២ ខាងលើនេះ គឺ មានគោលបំណងសំខាន់ ២ គឺ៖ *(ម្យ៉ាង)*-ដើម្បីធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្ត និងសម្រេចឱ្យបាននូវលទ្ធផលជាក់ស្ដែងតាមអាទិភាពនយោបាយរបស់ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** និង *(ម្យ៉ាងទៀត)*-ដើម្បីជាការក្រើនរំលឹកដល់សាលាដម្រះក្ដី និងអង្គការអយ្យការអមសាលាដម្រះក្ដីគ្រប់ជាន់ថ្នាក់, ដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជីអាជ្ញាសាលា និង មន្ត្រីតុលាការទាំងអស់ ត្រូវចងចាំក្នុងចិត្តថា ការជំរុញ និង ពន្លឿនការដោះស្រាយសំណុំរឿងឱ្យបាន (ទី១)-លឿនឆាប់រហ័ស និង (ទី២)-ត្រឹមត្រូវ និង យុត្តិធម៌ ស្របតាមច្បាប់ គឺជាកិច្ចការចាំបាច់ដែលត្រូវបន្តអនុវត្តជាប់ជាប្រចាំ ទាំងក្នុងក្របខ័ណ្ឌនៃការអនុវត្តការងាររបស់ខ្លួនក្នុងការបម្រើសេវាយុត្តិធម៌ជូនប្រជាជន ទាំងក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធតុលាការនៅកម្ពុជា។

១៥-ជារួម, ការដាក់ចេញនូវយុទ្ធនាការទាំង ២ ខាងលើនេះ នឹងជំរុញឱ្យសាលាដម្រះក្ដី និងអង្គការអយ្យការអមសាលាដម្រះក្ដីគ្រប់ជាន់ថ្នាក់ យកចិត្តទុកដាក់ដោះស្រាយវិវាទនានាឱ្យបានលឿន និងឱ្យបានត្រឹមត្រូវ ដោយធានាបាន ទាំងគុណភាពនៃការផ្ដល់សេវា ទាំងគុណភាពនៃការសម្រេចសេចក្ដីរបស់តុលាការ។

១៦-ការដោះស្រាយវិវាទប្រកបដោយភាពឆាប់រហ័ស ត្រឹមត្រូវ និងយុត្តិធម៌ នឹងពង្រឹងបាននូវជំនឿទុកចិត្តលើការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ច និងប្រព័ន្ធតុលាការនៅកម្ពុជា ដែលនឹងរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់ **"គោលការណ៍នីតិរដ្ឋ"** និង **"យុត្តិធម៌នៅក្នុងសង្គមជាតិ"** ស្របតាមទិសដៅកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាល ជាពិសេស បំណងប្រាថ្នារបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ក្នុងការយកចិត្តទុកដាក់ដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋដែលរងគ្រោះដោយអយុត្តិធម៌ ឬដោយការរំលោភបំពានដោយខុសច្បាប់នៅក្នុងសង្គមជាតិ ។

**អបអរមហាសន្និបាតទាំងមូល ជាទីមេត្រី!**

១៧-ចំពោះយន្តការដឹកនាំការងារទម្រង់វិស័យយុត្តិធម៌, សម្រាប់រាជរដ្ឋាភិបាល នីតិកាលទី៧ នេះ, ការដ្ឋានកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវបានបំបែកជា ២ ៖ (ទី១)-ការងារកែទម្រង់ច្បាប់ ត្រូវប្រគល់ជូនទីស្ដីការគណៈរដ្ឋមន្ត្រី ហើយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់មួយ ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ

២០២៤ ដែលដឹកនាំដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និង (ទី២)-ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលដឹកនាំដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលមានរូបខ្ញុំ និង **ឯកឧត្តមប្រធានតុលាការកំពូល** ជាសហប្រធាន ដែលគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ថ្មីនេះ នឹងផ្តោតលើបេសកកម្មសំខាន់ ២ គឺ៖ (ទី១)-ការកែទម្រង់ច្បាប់ក្នុងវិស័យយុត្តិធម៌ និង (ទី២)-ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក៏ដូចជាយន្តការដោះស្រាយវិវាទនៅកម្ពុជា។

១៨-ផ្អែកតាមស្មារតីនៃកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៤ កន្លងទៅ, **"ផែនការយុទ្ធសាស្ត្រសម្រាប់ការកែទម្រង់ប្រព័ន្ធយុត្តិធម៌"** និង **"ផែនការសកម្មភាពជាក់ស្តែងសម្រាប់រយៈពេល ១០ឆ្នាំ"** នឹងត្រូវបង្កើតឡើង ដើម្បីជាត្រីវិស័យ ឬផែនទីបង្ហាញផ្លូវមួយសម្រាប់ការអនុវត្តការកែទម្រង់របស់យើង សំដៅ *(ម្យ៉ាង)* សម្រេចឱ្យបាននូវចក្ខុវិស័យក្នុងការពង្រឹង និងលើកកម្ពស់ **"សង្គមនីតិរដ្ឋ"** និង **"យុត្តិធម៌នៅក្នុងសង្គមជាតិ"** នៅកម្ពុជា ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការធានាថែរក្សាស្ថិរភាពសង្គម សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការលើកកម្ពស់ និងការគោរពសិទ្ធិមនុស្ស ភាពសុខសាន្តរបស់ប្រជាជន និងការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព និង *(ម្យ៉ាងទៀត)* ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការសម្រេចឱ្យបាននូវ **"ចក្ខុវិស័យកម្ពុជា ២០៥០"** ក្នុងការកសាងជាតិមួយឱ្យរឹងមាំ រស់រវើក រុងរឿង និងមានវិបុលភាព ក្លាយជាប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ ២០៥០។

**ឯកឧត្តម លោកជំទាវ និងអង្គមហាសន្និបាតទាំងមូល ជាទីមេត្រី !**

១៩-ផ្អែកតាមរបៀបវារៈដែលបានគ្រោងទុក, ក្រៅពីការពិនិត្យ វាយតម្លៃ និងបូកសរុបលទ្ធផលការងារដែលវិស័យយុត្តិធម៌របស់យើងសម្រេចបានក្នុងឆ្នាំ២០២៣ កន្លងទៅ, មហាសន្និបាតដ៏ធំនេះ នឹងយកបញ្ហាប្រឈមសំខាន់ៗ ចំនួន ៨ ដែលសុទ្ធសឹងជាបញ្ហាប្រឈមក្នុងការអនុវត្តនាពេលកន្លងមក ដើម្បីអង្គមហាសន្និបាតពិនិត្យ ពិភាក្សា និងសម្រេចដាក់ចេញនូវដំណោះស្រាយរួមចំពោះបញ្ហាប្រឈមគន្លឹះទាំងនេះ ដែលអាចធានាបាននូវការឯកភាពទាំងជំហរ ទាំងទស្សនៈ ក្នុងការអនុវត្តនៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ សំដៅពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌នៅកម្ពុជា។ ប្រធានបទទាំង ៨ រួមមាន៖

**ប្រធានបទទី១-** ការអនុវត្តក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ៖ ប្រសិទ្ធភាព និង បញ្ហាប្រឈម

**ប្រធានបទទី២-** ការចេញដីកាសម្រេចរក្សាការពារ

**ប្រធានបទទី៣-** ការលើកកម្ពស់ប្រសិទ្ធភាព និងជំនឿទុកចិត្តលើការលក់ដោយបង្ខំនូវអចលនវត្ថុ

**ប្រធានបទទី៤-** ការជូនដំណឹង និងការបញ្ជូនសេចក្តីសម្រេចរបស់តុលាការ

**ប្រធានបទទី៥-** ការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ៖ ប្រសិទ្ធភាព និងបញ្ហាប្រឈម

**ប្រធានបទទី៦-** ការជូនដំណឹងអំពីសាលក្រមកំបាំងមុខ (ការជូនដំណឹងសេចក្តីសម្រេចរបស់តុលាការ)

**ប្រធានបទទី៧-** បទល្មើសប្រព្រឹត្តដោយអនីតិជន និង

**ប្រធានបទទី៨-** បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសេចក្តីសម្រេចព្រហ្មទណ្ឌ។

២០-ក្នុងន័យនេះ, ខ្ញុំសូមស្នើឱ្យ **អង្គមហាសន្និបាតទាំងមូល** មេត្តាយកចិត្តទុកដាក់ប្រើប្រាស់សមត្ថភាព ចំណេះដឹង ទាំងខាងទ្រឹស្តី ទាំងខាងបទពិសោធន៍អនុវត្ត ដើម្បីចូលរួមពិភាក្សា ផ្លាស់ប្តូរទស្សនៈ លើកជាមតិយោបល់ និង



ធាតុចូលល្អៗបន្ថែមទៀត ឱ្យបានផុសផុលលើប្រធានបទពិភាក្សាតាមក្រុមនីមួយៗ សំដៅរកឱ្យបាននូវការឯកភាពគ្នាមួយខាងគោលជំហរ និងទស្សនៈ ដើម្បីដោះស្រាយចំពោះបញ្ហាប្រឈម ទាក់ទងនឹងការអនុវត្តដោយសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ តាមកម្មវិធីដែលបានគ្រោងទុក, យើងនឹងរៀបចំឱ្យមានក្រុមពិភាក្សាចំនួន ៤ ដែលអាចបំបែកជាក្រុមពិភាក្សាតូចៗបន្តទៀត ដើម្បីធានាប្រមូលធាតុចូលល្អៗសម្រាប់ពិនិត្យ ពិភាក្សា និងរកដំណោះស្រាយ សម្រាប់ប្រធានបទនីមួយៗ ហើយបន្ទាប់មក យើងនឹងប្រើពេលវេលារួមគ្នា ២ ពេលទៀត ដើម្បីធ្វើការពិភាក្សារួមក្នុងមហាសន្និបាត។ ការពិភាក្សាប្រធានបទទាំង ៨ នេះ គឺមានសារៈសំខាន់ណាស់ព្រោះដើម្បីធានាគោលជំហរ និងទស្សនៈឯកភាពគ្នាក្នុងការបកស្រាយច្បាប់ ក៏ដូចជា ដាក់ចេញនូវដំណោះស្រាយ សំដៅធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងពង្រឹងជំនឿទុកចិត្តនៃស្ថាប័នអនុវត្តច្បាប់ ពិសេស អំណាចតុលាការ។ នៅចុងក្រោយ, យើងនឹងត្រូវសម្រេចរួមគ្នា ដើម្បីដោះស្រាយបញ្ហាក្នុងប្រធានបទទាំង ៨ ហើយដាក់ចេញជាសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត ដើម្បីជាមូលដ្ឋានសម្រាប់ការអនុវត្តបន្តប្រកបដោយស្មារតីទទួលខុសត្រូវ។ ខ្ញុំសូមជូនពរឱ្យកិច្ចពិភាក្សារបស់យើងប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលជាផ្លែផ្កាដ៏ត្រចេះត្រចង់ តាមការរំពឹងទុករបស់អង្គមហាសន្និបាត។

២១-ជាទីបញ្ចប់ ខ្ញុំសូមជូនពរ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទាំងអស់ សូមសមប្រកបនឹងពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើក **"មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារអាទិភាពបន្ត"** ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***

## <u>ចំណាប់អារម្មណ៍</u>

## របស់ ឯកឧត្តមបណ្ឌិត ជីវ កេង ប្រធានតុលាការកំពូល
## នៅក្នុង "មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេស ឆ្នាំ២០២៣ និងកំណត់ទិសដៅការងារអាទិភាពឆ្នាំ ២០២៤"

*ថ្ងៃទី២៧-២៨-២៩ ខែមីនា ឆ្នាំ២០២៤ នៅសណ្ឋាគារ ហ្គាឌិន ស៊ីធី*

- ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- លោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញាមហាអយ្យការអមតុលាការកំពូល
- ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកានៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយសទាំងអស់
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក សមាជិកា នៃអង្គមហាសន្និបាត ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ចូលរួមជាមួយ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទាំងអស់ ក្នុង "**ពិធីមហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារអាទិភាពឆ្នាំ២០២៤**" ផ្តួចផ្តើមរៀបចំដោយ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** ដែលនាំឱ្យមានឱកាសជួបជុំដ៏ឱឡារិកជាប្រវត្តិសាស្ត្រសម្រាប់វិស័យយុត្តិធម៌ នៅព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងវេលានេះ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដល់ថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ដែលបានដឹកនាំរៀបចំមហាសន្និបាតនេះឡើង និងថ្នាក់ដឹកនាំចៅក្រមនៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ជាតួអង្គយ៉ាងសំខាន់ក្នុងវិស័យយុត្តិធម៌ដែលបានបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ ដោះស្រាយរឿងក្តី រកយុត្តិធម៌ជូនភាគី និងចូលរួមយ៉ាងមោះមុតក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់, លើកស្ទួយនីតិរដ្ឋ និងធានាការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលគ្រប់អាណត្តិកន្លងមក ក៏ដូចជាក្នុងនីតិកាលទី៧ នេះ ក្រោមការដឹកនាំប្រកបដោយថាមពល ម៉ឺងម៉ាត់ និងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានកំណត់នូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ មានស្នូលនៃយុទ្ធសាស្ត្រផ្តោតលើ "**ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច**" ដើម្បីធ្វើជាមូលដ្ឋានគ្រឹះនៃការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ប្រសិទ្ធភាពខ្លាំង វៃឆ្លាត និងស្អាតស្អំ។ ក្នុងន័យនេះ "**ការលើកកម្ពស់ និងការពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌**" ត្រូវបានកំណត់យកជាវិធានការគន្លឹះដែលមានគោលដៅយុទ្ធសាស្ត្រផ្តោតលើការពង្រឹងគោលការណ៍នីតិរដ្ឋ, ការពង្រឹងការប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធម៌ក្នុងសង្គម, ការពង្រឹងជំនឿទុកចិត្តពីសាធារណជនមកលើវិស័យយុត្តិធម៌។

ទោះជាបានទទួលនូវសមិទ្ធផលល្អប្រសើរជាច្រើនយ៉ាងណាក៏ដោយ ក៏ជាក់ស្តែងមិនទាន់ឆ្លើយតបតាមបំណងប្រាថ្នារបស់យើងទាំងអស់គ្នា ក្នុងការបម្រើនិងការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅឡើយ។ ការណ៍នេះបណ្តាលមកពីមានបញ្ហាប្រឈម ជាអាទិ៍ **កត្តាបញ្ញត្តិច្បាប់** (ខ្វះចន្លោះ, មិនមានភាពច្បាស់លាស់ជាដើម), **កត្តាអត្តនោម័ត** (ការមិនគោរពក្រមសីលធម៌វិជ្ជាជីវៈ ដូចជា ការមិនប្រឹងប្រែងពង្រឹងសមត្ថភាព, ការមិនយកចិត្តទុកដាក់ផ្តល់សេវាយុត្តិធម៌ឱ្យបានឆាប់រហ័ស) និង**កត្តាសត្យានុម័ត** (ខ្វះការសហការពីតួអង្គពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌, មានអន្តរាគមន៍ដោយមិនត្រឹមត្រូវលើកិច្ចការតុលាការ) ។ល។ ហេតុដូច្នេះហើយ ទើបអង្គមហាសន្និបាតបានកំណត់យកនូវប្រធានបទជា



អាទិភាពចំនួន ៨ ទាំងក្នុងវិស័យរដ្ឋប្បវេណី ទាំងក្នុងវិស័យព្រហ្មទណ្ឌមកធ្វើការពិភាក្សា ហើយក៏មានបទបង្ហាញស្តីពីប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលតុលាការនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់វិស័យយុត្តិធម៌ដែរ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ផ្អែកលើរបៀបវារៈ និងបទពិសោធន៍របស់ខ្ញុំផ្ទាល់ ខ្ញុំសូមធ្វើការកត់សម្គាល់ជូនអង្គមហាសន្និបាត ដូចខាងក្រោម៖

**១**-ឈរលើមូលដ្ឋាននៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់អំពីសិទ្ធិអំណាច និងតួនាទីរបស់ប្រធានសាលាជម្រះក្តីមានអំណាចលើវិធានការគ្រប់គ្រងជាចាំបាច់ក្នុងដំណើរការរដ្ឋបាលទូទៅផង, រដ្ឋបាលសំណុំរឿងក្តីផង ព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ស្ថាប័នសាមី។ ក្នុងន័យនេះ, ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវតែយកចិត្តទុកដាក់បន្តលើការពង្រឹងប្រសិទ្ធភាពការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ ដូចជា៖

ក-រៀបចំ តាមដាន ត្រួតពិនិត្យផែនការការងារ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធធនធាន (មនុស្ស, ហិរញ្ញវត្ថុ, មធ្យោបាយ និងបច្ចេកវិទ្យាឌីជីថល) សម្រាប់បម្រើសេចក្តីត្រូវការរបស់ស្ថាប័ន ទាំងរដ្ឋបាលទូទៅ និងរដ្ឋបាលសំណុំរឿងក្តី ស្របតាមការវិវត្តន៍របស់សង្គមជាតិ។

ខ-ជំរុញប្រសិទ្ធភាពក្នុងការផ្តល់សេវា ដោះស្រាយរឿងក្តីចាប់ពីនីតិវិធីដំបូង រហូតដល់ការចេញសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេច ប្រកបដោយភាពឆាប់រហ័ស ងាយស្រួល និងមានគុណភាព។

គ-បន្តលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធលើកទឹកចិត្តដល់តួអង្គពាក់ព័ន្ធក្នុងស្ថាប័ន។

ឃ-ត្រូវមាន **នវានុវត្តន៍** និងម្ចាស់ការលើការងារដឹកនាំស្ថាប័ន ដោយមិនបាច់រង់ចាំការចង្អុលបង្ហាញ ឬការរំលឹកដាស់តឿនពីថ្នាក់លើ។

ង-ណែនាំ និងកែលម្អការងារចំពោះមន្ត្រីតុលាការនៅក្រោមឱវាទឱ្យខិតខំបំពេញការងារ និងអនុវត្តក្រមសីលធម៌វិជ្ជាជីវៈឱ្យបានល្អ។ មិនត្រូវបណ្តែតបណ្តោយឱ្យមន្ត្រីក្រោមឱវាទប្រព្រឹត្តមិនត្រឹមត្រូវក្នុងវិជ្ជាជីវៈ។

**២**-ឧបករណ៍គតិយុត្តចម្បង ជាពិសេស ក្រមទាំងបួនត្រូវបានដាក់ឱ្យប្រើប្រាស់មានរយៈពេលជិត ២ទសវត្សរ៍មកហើយ ប៉ុន្តែ យើងទាំងអស់គ្នាដែលជាអ្នកអនុវត្តផ្ទាល់ សុទ្ធតែទទួលស្គាល់ថា បញ្ញត្តិច្បាប់មួយចំនួននៅតែមានការពិបាកយល់ ហើយខ្លឹមសារខ្លះទៀត មិនច្បាស់លាស់ ដែលទាំងនេះអាចបង្កជាឧបសគ្គមួយផ្នែកដល់ការអនុវត្តមិនស្របតាមបរិបទនិងការវិវត្តន៍នៃសង្គមកម្ពុជា។ ការណ៍នេះ ប្រសិនបើចាំបាច់ អង្គមហាសន្និបាតមិនត្រូវស្ទាក់ស្ទើរឡើយក្នុងការសម្រេចចិត្តស្នើសុំធ្វើវិសោធនកម្ម, ទំនើបកម្មច្បាប់ ឬចេញសេចក្តីណែនាំដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះឱ្យមានលក្ខណៈសង្គតិភាព ត្រឹមត្រូវតាមច្បាប់ដែលអាចយកទៅអនុវត្តបាន។

**៣**-ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងវិស័យយុត្តិធម៌ ត្រូវបន្តពង្រឹងយន្តការនៃការលើកទឹកចិត្តចំពោះមន្ត្រីល្អៗ និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការវិន័យចំពោះមន្ត្រីប្រព្រឹត្តខុស ដោយចេតនាលើក្រមសីលធម៌វិជ្ជាជីវៈ។

ក្នុងន័យនេះ យន្តការនៃការលើកទឹកចិត្តត្រូវធ្វើឡើងដោយម៉ត់ចត់, យុត្តិធម៌, តម្លាភាព និងសុក្រឹតភាពតាមរយៈការវាយតម្លៃឡើងថ្នាក់ និងឋានន្តរសក្តិ, រីឯអ្នកប្រព្រឹត្តខុសត្រូវតែកសាងជាសំណុំរឿងវិន័យ ដោយមានយន្តការនៃការស៊ើបអង្កេតឱ្យបានច្បាស់លាស់ ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ហើយខ្ញុំស្នើសុំឱ្យសមាជិកសមាជិកាក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចូលរួមសម្រេចដាក់វិន័យចំពោះអ្នកមានកំហុសវិជ្ជាជីវៈឱ្យសមស្របតាមកំហុស មិនត្រូវយោគយល់ឡើយ ដើម្បីជៀសវាងការជះឥទ្ធិពលដល់អង្គចៅក្រមទាំងមូលកុំឱ្យដូច

ពាក្យបុរាណដែល ពោលថា "**ត្រីមួយកន្ត្រក ស្អុយមួយ គឺស្អុយទាំងអស់**"។ ដូច្នេះមានភាពចាំបាច់ណាស់ត្រូវតែដកយកត្រីមួយនេះចេញ កុំឱ្យស្អុយដល់ត្រីផ្សេងទៀត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ខ្ញុំសូមបញ្ជាក់ជូនផងដែរថា តុលាការកំពូលក៏បានលើកទិសដៅការងារ សម្រាប់ឆ្នាំ២០២៤ ដូចជា៖ (១)-ខិតខំដោះស្រាយបញ្ហាប្រឈមនានា, (២)-ប្រជុំពិភាក្សាដោះស្រាយរាល់បញ្ហាស្មុគស្មាញក្នុងការអនុវត្តក្រម និងចំណុចមិនឯកភាពគ្នា, (៣)-បន្តជំរុញការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណីឱ្យបានយុត្តិធម៌ ឆាប់រហ័ស និងបានច្រើន, (៤)-លើកកម្ពស់សមត្ថភាពធនធានមនុស្សដែលមានស្រាប់ដើម្បីឱ្យទាន់បរិបទសង្គមជាក់ស្តែង តាមរយៈការរៀបចំឱ្យសិក្សាស្រាវជ្រាវបន្ថែម, (៥)-ជំរុញឱ្យបន្តការបោះពុម្ព និងផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការកំពូល, (៦)-បន្តកិច្ចការសហប្រតិបត្តិការអន្តរជាតិជាមួយបណ្តាតុលាការកំពូលនៃប្រទេសអាស៊ាន ក៏ដូចជាប្រទេសផ្សេងៗទៀតនៅក្នុងពិភពលោក និងអង្គការអន្តរជាតិនានា, (៧)-ធ្វើសេចក្តីសន្និដ្ឋាន និងជូនដំណឹងអំពីកាលបរិច្ឆេទជំនុំជម្រះលើសំណុំរឿងដែលតុលាការកំពូលបានបញ្ជូនមកមហាអយ្យការ ឱ្យទាន់ពេលវេលា, (៨)-តុលាការកំពូលចូលរួមគាំទ្រដល់ការប្រព្រឹត្តទៅនៃគណៈកម្មាធិការ ដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងគណៈបញ្ជាការដឹកនាំយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ, និង (៩)-ជំរុញឱ្យមន្ត្រីអគ្គលេខាធិការដ្ឋានខិតខំបំពេញភារកិច្ចឱ្យបានល្អ តាមអនុក្រឹត្យលេខ ២៣អនក្រ.បក ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល និងសេចក្តីសម្រេចលេខ ២២៤/១៦ តកក.សសរ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ របស់ប្រធានតុលាការកំពូលស្តីពីការបែងចែកភារកិច្ច និងការទទួលខុសត្រូវនៅក្នុងអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

មុននឹងបញ្ចប់ ជាការបញ្ជាក់ដោយសុច្ឆន្ទៈជូនអង្គមហាសន្និបាតថា ក្នុងនាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំ និងសូមជូនពរឱ្យមហាសន្និបាតនេះ ប្រព្រឹត្តប្រកដោយជោគជ័យ និងបញ្ចប់ទៅជាមួយនឹងផ្លែផ្កាដ៏ត្រចះត្រចង់ តាមរយៈការពិភាក្សាយ៉ាងផុលផុសជុំវិញប្រធានបទដ៏មានសារៈសំខាន់ ដើម្បីទទួលបាននូវដំណោះស្រាយជាវិជ្ជមានសម្រាប់យកទៅអនុវត្តនិងធ្វើឱ្យមានភាពប្រសើរឡើងមួយកម្រិតទៀតសម្រាប់វិស័យយុត្តិធម៌ ហើយយើងទាំងអស់គ្នាត្រូវតែប្រកាន់ខ្ជាប់នូវអភិក្រមទាំង ៥ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** គឺ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" និងអភិក្រមវិសេសវិសាលរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលថ្លែងថា "**គ្មានការកែទម្រង់ណាមួយដែលងាយស្រួលនោះទេ ការកែទម្រង់ដែលជោគជ័យត្រូវផ្អែកលើកត្តាសំខាន់ៗចំនួន ៤៖ (១)-ត្រូវមានចក្ខុវិស័យច្បាស់លាស់, (២)-ត្រូវមានការប្តេជ្ញាចិត្តខ្ពស់, (៣)-ត្រូវមានការចូលរួមដោយស្មោះត្រង់ និង (៤)-ត្រូវមានការលះបង់**"។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលបានជោគជ័យលើគ្រប់ភារកិច្ច និងបានជួបប្រទះនូវពុទ្ធពរទាំង ៤ ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ។**

៣/៣

## ចំណាប់អារម្មណ៍

## របស់លោកជំទាវ ជា លាង អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល នៅក្នុង "មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារអាទិភាពឆ្នាំ២០២៤"

*ថ្ងៃទី២៧-២៩ ខែមីនា ឆ្នាំ២០២៤ នៅសណ្ឋាគារ ហ្គាឌិន ស៊ីធី*

សូមគោរព៖

- ឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ឯកឧត្តមបណ្ឌិត **ជីវ កេង** ប្រធានតុលាការកំពូល
- ឯកឧត្តម លោកជំទាវ ជាសមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ឯកឧត្តម លោកជំទាវ លោកលោកស្រី ជាសមាជិកសមាជិកានៃអង្គសន្និបាត ជាទីរាប់អាន!

ថ្ងៃនេះអង្គចៅក្រមយើងមានមោទនភាពយ៉ាងជ្រាលជ្រៅក្រៃលែង ដោយបានចូលរួមមហាសន្និបាត បូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ប្រចាំឆ្នាំ២០២៣ និងកំណត់ទិសដៅការងារអាទិភាពឆ្នាំ២០២៤ នាពេលនេះ។ ជំនួបដ៏កម្រក្នុងចំនួនច្រើនថ្ងៃ និងមានគ្រប់សមាសភាពពាក់ព័ន្ធ មកពីគ្រប់ជាន់ថ្នាក់ក្នុងវិស័យយុត្តិធម៌របស់យើងនៅពេលនេះ គឺជាជំនួបដំបូងបំផុត ហើយជាជំនួបជាប្រវត្តិសាស្ត្រក្នុងវិស័យយុត្តិធម៌របស់យើង ដែលយើងមិនធ្លាប់រៀបចំកន្លងមក ហើយយើងហៅថាជាជំនួបនៃ "**មហាសន្និបាតវិស័យយុត្តិធម៌**"។

### ឯកឧត្តមគណៈអធិបតី ជាទីគោរព អង្គមហាសន្និបាតជាទីរាប់អាន !

ការរៀបចំអង្គមហាសន្និបាត ក្នុងការបូកសរុបលទ្ធផលការងារក្នុងវិស័យយុត្តិធម៌ឆ្នាំ២០២៣ និងលើកទិសដៅការងារអាទិភាពសម្រាប់ឆ្នាំ២០២៤ នាពេលនេះ គឺជាការចាប់ផ្ដើមពិនិត្យ និងវាយតម្លៃលើការងារវិស័យយុត្តិធម៌ ឆ្នាំចាស់ឆ្នាំ២០២៣ ហើយតួលេខឆ្នាំ២០២៣ នឹងក្លាយជាសូចនាករណ៍មួយដែលយើងអាចព្យាករណ៍ថាបញ្ហាក្នុងវិស័យយុត្តធម៌របស់យើងណាខ្លះត្រូវកំណត់ជាអាទិភាព និងអ្វីជាដំណោះស្រាយពិតប្រាកដដែលឈានដល់ការដាក់ចេញវិធានការគន្លឹះក្នុងរយៈពេលខ្លី និងរយៈពេលវែង ដើម្បីដោះស្រាយបញ្ហាប្រឈមនោះប្រកបដោយស្មារតីម្ចាស់ការ និងបុរេសកម្ម។

ដំណើរនៃការពិភាក្សាដ៏លម្អិត រវាងអ្នកច្បាប់ ប្រមាណ ៧០០នាក់ ជាមួយនឹងរបៀបវារៈ និងប្រធានបទគន្លឹះសំខាន់ៗដែលយើងបានដាក់ចេញនាថ្ងៃនេះ និងរយៈពេល ២ (ពីរ) ថ្ងៃខាងមុខ គឺនឹងចូលរួមឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយមគ្គុទេសន៍ និងពិសិដ្ឋ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាពិសេស គឺការចូលរួមក្នុងកម្មវិធីគោលនយោបាយសម្រាប់ចាប់ផ្ដើមអនុវត្តភ្លាមនៅឆ្នាំ២០២៣ ដោយដោះស្រាយនូវបញ្ហាប្រឈមអាទិភាពចំនួន ៥ ដែលទាមទារនូវវិធានការគន្លឹះក្នុងការដោះស្រាយ ហើយវិធានការគន្លឹះមួយក្នុងវិស័យយុត្តិធម៌របស់យើង គឺ "**ការពង្រឹង និងការលើក កម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌**"។

ខ្ញុំក៏យកអង្គមហាសន្និបាតនេះដើម្បីគូសបញ្ជាក់ និងក្រើនរំលឹកផងដែរថាក្នុងនាមជា **អគ្គព្រះរាជអាជ្ញា និងជាប្រធានក្រុមប្រឹក្សាវិន័យក្នុងមុខការដាក់វិន័យចំពោះព្រះរាជអាជ្ញា** ខ្ញុំនឹងយកទំនួលខុសត្រូវ និងភាពជាម្ចាស់ការលើការងារ នេះធ្វើការ**ត្រួតពិនិត្យ វាយតម្លៃ និងដាក់វិន័យ**តាមរយៈបណ្ដឹង លើព្រះរាជអាជ្ញា ដែលអនុវត្តមុខងាររបស់ខ្លួនមានកំហុសវិជ្ជាជីវៈ និង/ឬ បំពានយ៉ាងធ្ងន់ធ្ងរលើក្រមសីលធម៌វិជ្ជាជីវៈចៅក្រម-ព្រះរាជអាជ្ញា ហើយបានបង្កនូវអយុត្តិធម៌សង្គម និងការឈឺចាប់ធំធេងដល់អ្នកពាក់ព័ន្ធក្នុងសំណុំរឿងក្ដី។ ការអនុវត្តមុខការនេះ គឺមិនមែនគោលដៅនៃការដាក់វិន័យនោះទេ ប៉ុន្តែ ជាយន្តការត្រួតពិនិត្យតាមនីតិវិធីច្បាប់មួយ ដែលធានាថាអង្គចៅក្រមរបស់យើងប្ដេជ្ញាចិត្តរួមគ្នាលើ



នាវារបស់យើង ពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ ហើយបើនិយាយចំពោះយើងម្នាក់ៗគឺរួមគ្នាស្ដារមុខមាត់ និងកេរ្តិ៍ឈ្មោះរបស់ វិស័យយុត្តិធម៌យើង។ ដូច្នេះយើងត្រូវនាំគ្នារួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ។

- **ឯកឧត្តមគណៈអធិបតី ជាទីគោរព**
- **អង្គមហាសន្និបាតជាទីមេត្រី**

ភារកិច្ចចម្បងរបស់យើងគ្រប់គ្នាដែលស្ពាយដាប់ស្នា ហើយជាអម្រែកនោះ គឺការផ្ដល់យុត្តិធម៌ ហើយ "**យុត្តិធម៌**" នេះ គឺសំដៅតែទៅលើយុត្តិធម៌តាមផ្លូវច្បាប់ប៉ុណ្ណោះ។ ចៅក្រមគឺ ផ្ដល់យុត្តិធម៌ជូនដល់ភាគីដែលមានវិវាទចូលមកតុលាការ។ ដោយសារពាក្យយុត្តិធម៌នេះហើយដែលចៅក្រមទាំងអស់ត្រូវរងព្យុះភ្លៀងមកពីគ្រប់ទិសទីនូវពាក្យប្រមាថពាក្យទិទៀនសព្វបែបយ៉ាងដូចជាតុលាការមិនយុត្តិធម៌ ពុករលួយ បក្ខពួកនិយម តុលាការរបស់ពួកអ្នកមានលុយ ។ល។ អង្គចៅក្រមយើងរងនូវពាក្យប្រមាថទិទៀនទាំងនេះរាប់សិបឆ្នាំមកហើយ ជាពិសេស ក្នុងសម័យឌីជីថលដ៏ទំនើបនេះ។ តើចៅក្រមពិតជាអយុត្តិធម៌ដូច្នេះមែនឬទេ? បើពិនិត្យដោយឈលើការពិតការសម្រេចសេចក្ដីរបស់ចៅក្រមនៅមានបញ្ហាអសកម្មខ្លះដែលយើងត្រូវហ៊ានទទួលយកការពិតតែទន្ទឹមហ្នឹងនេះ ក៏ចៅក្រមយើងបានសម្រេចសេចក្ដីដោយយុត្តិធម៌ជូនដល់ភាគីយ៉ាងច្រើនលើសលប់ធ្វើឱ្យសង្គមមានស្ថិរភាព ការពារបាននូវរបៀបរៀបរយសាធារណៈ និងទ្រព្យសម្បត្តិស្របច្បាប់របស់ប្រជាពលរដ្ឋ នេះមិនមែនជាការ រួមចំណែករបស់ចៅក្រមទេឬ? ការរៀបចំមហាសន្និបាតនាពេលនេះគឺជាឆន្ទៈដ៏មោះមុតរបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងការប្ដេជ្ញាចិត្តរបស់ចៅក្រម ព្រះរាជអាជ្ញា ទាំងអស់គ្នាក្នុងការចូលរួមអនុវត្តដើម្បីឆ្ពោះទៅកាន់ការកែទម្រង់ប្រកបដោយបានជោគជ័យ។

ក្នុងនាមជា **អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល** ក្នុងឱកាសដ៏កម្រមួយនេះ ខ្ញុំក៏កត់សម្គាល់នូវបញ្ហាមួយចំនួនដែល មហាអយ្យការអមតុលាការកំពូល បានពិនិត្យឃើញ ហើយគប្បីលើកក្នុងអង្គមហាសន្និបាតនេះដើម្បីគណៈអធិបតីអង្គមហាសន្និបាតបានទទួលជ្រាប និងជាពិសេសឱ្យចៅក្រម និងព្រះរាជអាជ្ញាយើងបានដឹង និងបន្ថែមការប្រុងប្រយ័ត្នលើការបំពេញមុខងារប្រចាំថ្ងៃរបស់ខ្លួន។ បញ្ហាទាំងនោះរួមមាន៖

១-<u>ការចោទប្រកាន់អង្គហេតុរដ្ឋប្បវេណី៖</u> មកដល់បច្ចុប្បន្ននេះហើយ គឺយើងនៅតែពិនិត្យឃើញថា នៅតែមានការចោទប្រកាន់ និងផ្ដន្ទាទោសលើអង្គហេតុដែលជារឿងរដ្ឋប្បវេណីទៅជារឿងព្រហ្មទណ្ឌ។ ត្រង់ចំណុចនេះ ខ្ញុំសូមបញ្ជាក់ឡើងវិញម្ដងទៀត ទោះបីជាមានការណែនាំច្រើនលើកច្រើនសារមកហើយថា បើអង្គហេតុជាទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី គឺត្រូវឱ្យភាគីដោះស្រាយគ្នាក្នុងនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកវាមកចោទប្រកាន់ក្នុងបទល្មើសព្រហ្មទណ្ឌក្រោមបទចោទ "**រំលោភលើទំនុកចិត្ត ឬ ឆបោក**" ជាដាច់ខាត។ ហើយករណីប្រភេទនេះ បើមានបណ្ដឹងមកក្រុមប្រឹក្សាវិន័យ ខ្ញុំនឹងពិនិត្យឱ្យបានហ្មត់ចត់។

២-<u>ការចោទប្រកាន់ និងការផ្ដន្ទាទោសលើប្រភេទបទល្មើសដែលពាក់ព័ន្ធនឹងកម្មសិទ្ធិជាអាទិ៍</u> (បទល្មើសហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត, បទល្មើសធ្វើឱ្យខូចខាតដោយចេតនា...) ការស៊ើបអង្កេត និងការស៊ើបសួរត្រូវធ្វើឡើងឱ្យបានហ្មត់ចត់ជាទីបំផុត ហើយលើកទឹកចិត្តឱ្យអ្នកទទួលបន្ទុកសំណុំរឿង (ចៅក្រម ព្រះរាជអាជ្ញា) ត្រូវចុះធ្វើការស៊ើបអង្កេត ឬស៊ើបសួរដោយផ្ទាល់នៅកន្លែងកើតហេតុ។ ក្នុងករណីដែលមានភាពមិនច្បាស់លាស់លើកម្មសិទ្ធិ ឬភាគីកំពុងមានវិវាទគ្នាលើកម្មសិទ្ធិ មុននឹងធ្វើការចោទប្រកាន់ សូមធ្វើការត្រួតពិនិត្យឱ្យបានហ្មត់ចត់ជាទីបំផុត និងជាពិសេស ពិនិត្យលើធាតុអត្តនោម័តរបស់ជនដែលប្រព្រឹត្ត។

៣-<u>បញ្ហាសាលក្រម/សាលដីកា៖</u> សាលាជម្រះក្ដីជាន់ទាប រួមទាំងសាលាឧទ្ធរណ៍តំបន់នៅតែប្រឈមនឹងការបញ្ជូនឯកសារសាលក្រមមានការយឺតយ៉ាវ។ ការបញ្ជូនឯកសារសាលក្រម/សាលដីកាយឺតយ៉ាវ មិនត្រឹមតែប៉ះពាល់ដល់សិទ្ធិរបស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូលនោះទេ ប៉ុន្តែ វាក៏ប៉ះពាល់ដល់ភាគីក្នុងរឿងក្ដីផងដែរ ក្នុងករណីដែលមានកំហុសផ្នែកនីតិវិធីធ្ងន់ធ្ងរ ហើយសាលក្រមនោះ

បានចូលជាស្ថាពរ ព្រោះថាមូលហេតុនៃការធ្វើបណ្តឹងសើរើ គឺមានតែមូលហេតុសារជាតុប៉ុណ្ណោះ គ្មានមូលហេតុនីតិវិធីនោះទេ។

**៤-បញ្ហាត្រួតពិនិត្យជនជាប់ឃុំនៅតាមពន្ធនាគារ ឬមណ្ឌលឃុំខ្លួនជាប្រចាំ៖** កន្លងមកអ្នកនាំពាក្យក្រសួងមហាផ្ទៃបានលើកឡើងថា គិតត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ នេះ ជនជាប់ឃុំនៅក្នុងពន្ធនាគារមានចំនួនសរុបប្រមាណ **៤៥ ១១២ នាក់** ក្នុងនោះមានសាលក្រម-សាលដីកាស្ថាពរ **១១ ៩៨២ នាក់** ដូចនេះអ្នកដែលគ្មានសាលក្រម-សាលដីកា **៣៣ ១៣០ នាក់**។ ក្នុងតួរលេខ **៣៣ ១៣០ នាក់** ជនជាប់ឃុំខ្លះអាចស្ថិតនៅក្នុងនីតិវិធីតុលាការ ឯមួយចំនួនទៀតគឺគ្មានសាលក្រម-សាលដីកា នេះគឺជាបញ្ហាដែលពាក់ព័ន្ធដល់ការឃុំខ្លួនខុសច្បាប់ តើឯកឧត្តមព្រះរាជអាជ្ញា លោកជំទាវមានចុះត្រួតពិនិត្យពន្ធនាគារទៀងទាត់ឬទេ? (មា.៥០៥ ក្រមនីតិវិធីព្រហ្មទណ្ឌ)។ ហើយបើជនជាប់ឃុំខ្វះសាលក្រមស្ថាពរ ឬខ្វះសាលដីកាស្ថាពរ ឬគ្មានសាលក្រម/សាលដីកាតែម្តង តើឯកឧត្តមព្រះរាជអាជ្ញាមានទំនួលខុសត្រូវ និងមានបុរេសកម្មក្នុងការដោះស្រាយយ៉ាងដូចម្តេចដែរ ឬត្រូវរង់ចាំទាល់តែខាងពន្ធនាគាធ្វើលិខិតមកទារពីយើង។

**៥-ការបន្ថយទោសការផ្តល់ស្ថានសម្រាលដល់ជនជាប់ចោទនៅក្នុងសំណុំរឿងគ្រឿងញៀន៖** ចំពោះករណីនេះ ជាញឹកញាប់ ខ្ញុំសង្កេតឃើញថាជនជាប់ចោទត្រូវបានសាលាក្តីជាន់ទាបផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ ឬផ្តន្ទាទោសក្នុងបទមជ្ឈឹមក្នុងកម្រិតទោសធ្ងន់ធ្ងរ ហើយក្រោយមកជនជាប់ចោទបានប្តឹងឧទ្ធរណ៍។ ពេលមកដល់សាលាឧទ្ធរណ៍ជនជាប់ចោទត្រូវបានសាលាឧទ្ធរណ៍ផ្តល់ស្ថានសម្រាល (មា.៩៣-៩៤-៩៥ នៃក្រមព្រហ្មទណ្ឌ)។ ការផ្តល់ស្ថានសម្រាលទោសគឺជាឆន្ទានុសិទ្ធិរបស់ចៅក្រម និងក្រុមប្រឹក្សាជំនុំជម្រះ ប៉ុន្តែ ក្នុងបទល្មើសគ្រឿងញៀនគប្បីពិចារណាទៅលើមាត្រា៣៣នៃច្បាប់ពីស្តីការត្រួតពិនិត្យគ្រឿងញៀនអំពីស្ថានសម្រាលទោស។

**៦-បណ្តឹងសាទុក្ខរបស់មហាអយ្យការអមសាលាឧទ្ធរណ៍៖** ករណីនេះក៏មានបញ្ហាដែរពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ជាក់ស្តែងចំពោះការអនុវត្តកន្លងមក តំណាងមហាអយ្យការសម្រេចប្តឹងសាទុក្ខរយៈពេលដែលត្រូវប្តឹងសល់១ថ្ងៃ ឬ ២ថ្ងៃ។ តំណាងមហាអយ្យការបានចុះហត្ថលេខានៅលើសៀវភៅកំណត់ហេតុប្តឹងសាទុក្ខ តែអ្នកកាន់សៀវភៅប្តឹងសាទុក្ខ បានចុះហត្ថលេខានៅលើសៀវភៅប្តឹងសាទុក្ខ ក្រោយមក ៤ ឬ ៥ថ្ងៃ ទើបអ្នកកាន់សៀវភៅប្តឹងសាទុក្ខចុះហត្ថលេខា ជាហេតុនាំឱ្យថ្ងៃប្តឹងសាទុក្ខ និងថ្ងៃចុះបញ្ជីខុសគ្នា សភាព្រហ្មទណ្ឌតុលាការកំពូលមិនទទួលស្គាល់ការប្តឹងសាទុក្ខបែបនេះទេ។

**៧-ការដោះលែងឱ្យនៅក្រៅឃុំ និងការអនុវត្តមាត្រា៤៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** ចំពោះការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ និងការអនុវត្តមាត្រា៤៣៥ មានការភាន់ច្រឡំ។ ជាគោលការណ៍ការសម្រេចឱ្យនៅក្រៅឃុំកាលណាមានបណ្តឹងឧទ្ធរណ៍របស់តំណាងមហាអយ្យការចំពោះជាន់សាលាដំបូង និងបណ្តឹងសាទុក្ខរបស់តំណាងមហាអយ្យការចំពោះរឿងសាលាឧទ្ធរណ៍ ជនត្រូវចោទពុំអាចដោះលែងបានឡើយ។

ចំពោះមាត្រា៤៣៥ ក្នុងករណីសាលាឧទ្ធរណ៍សម្រេចឱ្យរួចខ្លួនត្រូវដោះលែងឱ្យមានសេរីភាព។

**៨-រយៈពេលសរសេរសាលក្រម (មា.៣៥៨ ក្រមនីតិវិធីព្រហ្មទណ្ឌ)៖** ជាទូទៅ សាលក្រមត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជី យ៉ាងយូរបំផុត ៨ថ្ងៃ ក្រោយពីថ្ងៃប្រកាស ប៉ុន្តែ តាមការសង្កេតឃើញ រយៈពេល ៨ថ្ងៃ ពុំអាចចេញសាលក្រមព្រហ្មទណ្ឌឡើយ។ ត្រង់ចំណុចនេះ បើជាបញ្ហាប្រឈមដូចការកត់សម្គាល់ គប្បីមហាសន្និបាត យកមកពិភាក្សា និងពិចារណាកំណត់អំពិថិរវេលាសមរម្យដែលចៅក្រម អាចធ្វើសាលក្រមមួយដែលមានភាពពេញលេញ និងមានគុណភាព។ បើស្ថានភាពតម្រូវក្នុងការធ្វើវិសោធនកម្ម គប្បីអង្គសន្និបាតពិចារណាក្នុងការបំផុសផងដែរ។

**៩-រយៈពេលសម្រាប់សម្រេចសេចក្តី (មា.៤៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ)៖** តាមមាត្រានេះរឿងក្តីព្រហ្មទណ្ឌតុលាការកំពូលត្រូវដោះស្រាយរយៈពេលយ៉ាងយូ ៦ខែ គិតពីពេលទទួលសំណុំរឿង (ក្រៅពីរឿងមុនអង្គសេចក្តី) តែតាម



ការសង្កេត ឃើញថារឿងក្តីមួយចំនួន ពុំបានដោះស្រាយក្នុងរយៈពេល ៦ខែឡើយ។ ត្រង់ចំណុចនេះក៏ជាបញ្ហាប្រឈមរបស់តុលាការជាន់ខ្ពស់ផងដែរ ហើយគប្បីយកមកពិចារណា ដោះស្រាយ។

ដោយពេលវេលាមានកំណត់ខ្ញុំសូមបញ្ចប់ចំណាប់អារម្មណ៍ត្រឹមនេះ សូមគោរពជូនពរ **គណៈអធិបតី ឯកឧត្តម លោកជំទាវជាសមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសមាជិក សមាជិកានៃអង្គមហាសន្និបាត** មានសុខភាពល្អ និងទទួលជោគជ័យគ្រប់ភារកិច្ច។

សូមជូនពរ **អង្គមហាសន្និបាត** ដំណើរការទៅដោយរលូន និងទទួលលទ្ធផលជាវិជ្ជមាន។

***សូមអរគុណ !***

## សុន្ទរកថា

## ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## ថ្លែងក្នុងពិធីបិទមហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ ២០២៣ និងកំណត់ទិសដៅការងារអាទិភាពបន្ត

*ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ២:៣០រសៀល នៅសណ្ឋាគារហ្គោឌិនស៊ីធី*

**សូមគោរពគណៈអធិបតី**

- ឯកឧត្តមបណ្ឌិត **ឌីថ មុនី** ប្រធានតុលាការកំពូល
- លោកជំទាវ **ជា លាង** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល
- ឯកឧត្តម លោកជំទាវ ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ នៃក្រសួងយុត្តិធម៌
- ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ នៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ឯកឧត្តម **លី ច័ន្ទតុលា** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង នៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- អង្គមហាសន្និបាតទាំងមូល ជាទីមេត្រី!

១-"មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត" របស់យើង បានប្រព្រឹត្តទៅដោយរលូនអស់រយៈពេល ៣ ថ្ងៃពេញ និងបានឈានមកដល់ទីបញ្ចប់នាពេលនេះ។

២-ទន្ទឹមនេះ, ខ្ញុំក៏សូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះគណៈកម្មការទទួលបន្ទុករៀបចំមហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារអាទិភាពបន្ត ដែលបានខិតខំប្រឹងប្រែងរៀបចំមហាសន្និបាតវិស័យយុត្តិធម៌នេះឡើងបានយ៉ាងអធិកអធម និងសូមថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលបានចូលរួមពិភាក្សា ផ្លាស់ប្តូរយោបល់យ៉ាងផុលផុសលើបញ្ហាប្រឈមសំខាន់ៗដែលជាប្រធានបទនៃកិច្ចពិភាក្សាក្នុងមហាសន្និបាតរបស់យើង ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល ប្រកបដោយស្មារតីសាមគ្គីភាព និងការទទួលខុសត្រូវខ្ពស់ ហេតុសម្រេចបានជាលទ្ធផលផ្លែផ្កាគួរឱ្យកត់សម្គាល់តាមការរំពឹងទុក។

៣-ផ្អែកតាមរបាយការណ៍បូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ឆ្នាំ២០២៣ ដែលបានរាយការណ៍ដោយ **ឯកឧត្តម កេង សុម៉ារិទ្ធ** នៅពេលបើកមហាសន្និបាត និងឆ្លងកាត់មហាសន្និបាតរយៈពេល ៣ថ្ងៃនេះ, ក្នុងនាម **ឯកឧត្តមប្រធានតុលាការកំពូល** ក្នុងនាម**លោកជំទាវអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមសំដែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានាដែលវិស័យយុត្តិធម៌របស់យើងសម្រេចបាន ដែលនេះបានឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការបំពេញតួនាទី និងភារកិច្ច អស់ពីកម្លាំងកាយចិត្ត



ប្រាជ្ញា និងស្មារតី ប្រកបដោយភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់របស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទាំងអស់ ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងយុត្តិធម៌ សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ នាពេលកន្លងមក ដែលទាំងនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ និងគុណភាពនៃយុត្តិធម៌ ឈានឆ្ពោះទៅធ្វើឱ្យមាន**ការផ្លាស់ប្តូរជាវិជ្ជមានជាបន្តបន្ទាប់នូវទស្សនៈ និងការយល់ឃើញរបស់ប្រជាពលរដ្ឋចំពោះវិស័យយុត្តិធម៌របស់យើង។**

**ឯកឧត្តម លោកជំទាវ អង្គមហាសន្និបាតទាំងមូល ជាទីមេត្រី !**

៤-ឆ្លងកាត់កិច្ចពិភាក្សាយ៉ាងផុលផុសអស់រយៈពេលជិត ៣ ថ្ងៃពេញ លើប្រធានបទសំខាន់ៗមួយចំនួនដែលជាបញ្ហាប្រឈមក្នុងការអនុវត្តនាពេលកន្លងមក អង្គមហាសន្និបាតរបស់យើងបានឯកភាពគ្នាលើដំណោះស្រាយរួមចំពោះបញ្ហាប្រឈមទាំងនេះ ដែលនឹងត្រូវរៀបចំចេញជាសេចក្តីសម្រេចចិត្តរួមរបស់មហាសន្និបាត ដែលនឹងត្រូវចុះហត្ថលេខាដោយរូបខ្ញុំ, **ឯកឧត្តមប្រធានតុលាការកំពូល** និង**លោកជំទាវអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល**។ សេចក្តីសម្រេចចិត្តនេះ នឹងក្លាយជាគោលការណ៍រួម និងស្មារតីរួម ដែលអាចធានាបានទាំងប្រសិទ្ធភាពទាំងសង្គតិភាពសម្រាប់ការអនុវត្តបន្តដោយសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្នុងន័យនេះ, ខ្ញុំសូមស្នើឱ្យក្រុមការងារទទួលបន្ទុករៀបចំសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតនេះ ត្រូវរៀបចំសេចក្តីសម្រេចចិត្តនេះឱ្យបានឆាប់ ហើយធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចចិត្តនេះឱ្យបានទូលំទូលាយដល់គ្រប់តួអង្គដែលមានការពាក់ព័ន្ធទាំងអស់ និងសូមឱ្យសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស ត្រូវអនុវត្តសេចក្តីសម្រេចចិត្តនេះឱ្យបានម៉ឺងម៉ាត់ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលើកកម្ពស់ជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធយុត្តិធម៌។ ក្នុងករណីចាំបាច់, ក្រសួងយុត្តិធម៌ និងតុលាការកំពូល នឹងរៀបចំសេចក្តីណែនាំលម្អិតបន្ថែមទៀតដើម្បីអនុវត្តសេចក្តីសម្រេចចិត្តនេះ។

៥-ទន្ទឹមនេះ, ខ្ញុំក៏សូមណែនាំឱ្យក្រុមការងារបច្ចេកទេសដែលទទួលបន្ទុករៀបចំការធ្វើវិសោធនកម្មក្រមក្នុងវិស័យព្រហ្មទណ្ឌ និង ក្រមក្នុងវិស័យរដ្ឋប្បវេណី យកចំណុចសំខាន់ៗដែលបានពិភាក្សាក្នុងមហាសន្និបាតនេះ ជាធាតុចូលសម្រាប់ការរៀបចំសេចក្តីព្រាងវិសោធនកម្មក្រមទាំងនេះ ។ ប៉ុន្តែ, ទោះបីជាក្រុមការងារបានខិតខំពិភាក្សាគ្នាយ៉ាងផុលផុសប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់យ៉ាងណាក៏ដោយ ដោយសារកត្តាពេលវេលា ខ្ញុំជឿជាក់ថានៅមានបញ្ហាប្រឈមជាច្រើនផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តក្រមទាំង ៤ ដែលអង្គមហាសន្និបាតមិនទាន់មានឱកាសលើកយកមកពិភាក្សាគ្នាឱ្យបានស៊ីជម្រៅ។ ក្នុងន័យនេះ និងផ្អែកលើលទ្ធផលដែលទទួលបានតាមរយៈកិច្ចពិភាក្សារួមគ្នាជាក្រុមក្នុងមហាសន្និបាតរបស់យើងនេះ, ខ្ញុំសូមណែនាំឱ្យក្រុមការងារទទួលបន្ទុករៀបចំការធ្វើវិសោធនកម្មក្រមក្នុងវិស័យព្រហ្មទណ្ឌ និងក្រមក្នុងវិស័យរដ្ឋប្បវេណី ក៏ដូចជា ច្បាប់ដែលមានការពាក់ព័ន្ធ រៀបចំឱ្យមានកិច្ចពិភាក្សាជាបន្តទៀតដើម្បីអាចកំណត់បាននូវបញ្ហាប្រឈមផ្សេងទៀត ក៏ដូចជា ប្រមូលនូវធាតុចូលសម្រាប់ការរៀបចំសេចក្តីព្រាងវិសោធនកម្មក្រមទាំង ៤ ក្នុងវិស័យយុត្តិធម៌របស់យើង ឱ្យបានគ្រប់ជ្រុងជ្រោយ និងឱ្យបានរួចរាល់នៅចុងឆ្នាំ២០២៤ សម្រាប់វិស័យព្រហ្មទណ្ឌ និងនៅឆ្នាំ២០២៥ សម្រាប់វិស័យរដ្ឋប្បវេណី តាមផែនការដែលបានគ្រោងទុក។

**អង្គមហាសន្និបាតទាំងមូល ជាទីមេត្រី !**

៦-ជារួម, ខ្ញុំសូមឯកភាពចំពោះលទ្ធផលរបស់មហាសន្និបាត និងរាយការណ៍ដោយ **ឯកឧត្តម ជិន ម៉ាលីន** នាមុននេះបន្តិច ហើយដែលយើងត្រូវរួមគ្នាជាធ្លុងមួយ បន្តអនុវត្តទៅតាមមុខងារ និងភារកិច្ចរៀងៗខ្លួន សំដៅ *(ម្យ៉ាង)* រួមចំណែកសម្រេចឱ្យបាននូវគោលដៅជាយុទ្ធសាស្ត្រក្នុង "**ការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌**" ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្ត

ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចំពោះមុខប្រជាជាតិ នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ កន្លងទៅ និង *(ម្យ៉ាងទៀត)* រួមគ្នាលើកមុខមាត់ និងកិត្តិយសនៃស្ថាប័នតុលាការ និងអង្គការអយ្យការ ដែលតំណាងឱ្យអំណាចមួយដ៏សំខាន់ក្នុងចំណោមអំណាចទាំងបី ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការដោះស្រាយវិវាទផ្សេងៗរបស់ប្រជាពលរដ្ឋ ប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ នៅក្នុងសង្គមកម្ពុជា សំដៅធានាថែរក្សាសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងស្ថិរភាពសង្គម និងពង្រឹងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋលើវិស័យយុត្តិធម៌របស់យើង។ ក្នុងស្មារតីនេះ, ខ្ញុំសូមឆ្លៀតយកឱកាសនៃការជួបជុំដ៏កម្រនេះ គូសរំលេចបញ្ជាក់ជូន និងផ្តល់ការណែនាំបន្ថែមមួយចំនួន ដូចខាងក្រោម៖

(ទី១)-ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងតួអង្គដែលមានការពាក់ព័ន្ធទាំងអស់ ត្រូវបន្តចូលរួមដោយស្មោះត្រង់ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តទាំង ២ ដែលបានប្រកាសដាក់ចេញ គឺ **យុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ** និង**យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ** ព្រមទាំងវិធានការម៉ឺងម៉ាត់ចំពោះសំណុំរឿងអាទិភាពទាំងបី គឺ **សំណុំរឿងគ្រឿងញៀន**, **សំណុំរឿងគ្រោះថ្នាក់ចរាចរណ៍** និង**សំណុំរឿងអត្រានុកូលដ្ឋាន** ឱ្យទទួលបានលទ្ធផលខ្ពស់។

(ទី២)-សម្រាប់ឆ្នាំ ២០២៤ នេះ, ការងារពង្រឹងវិន័យការងារ និងក្រមសីលធម៌នេះ នៅតែបន្តជាការងារអាទិភាពរបស់ក្រសួងយុត្តិធម៌ និងរបស់សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងធានាបានប្រសិទ្ធភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់យើង។ ហេតុដូចនេះ, ទាំងអង្គភាពជំនាញ ទាំងយន្តការវិន័យរបស់ក្រសួងយុត្តិធម៌ ទាំងយន្តការក្រុមប្រឹក្សាវិន័យរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សូមអនុវត្តវិធានការវិន័យឱ្យបានតឹងរឹង ម៉ឺងម៉ាត់ និងដោយគ្មានការយោគយល់ចំពោះអ្នកល្មើសវិន័យ ជាពិសេស ការជំរុញការអនុវត្តទណ្ឌកម្មវិន័យថ្នាក់ទី២ (**ការផ្លាស់ប្តូរដោយបង្ខំ**, **ការព្យួរពីការងារ**, **ការបន្ថយថ្នាក់ ឬឋានន្តរស័ក្តិ**, **ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ**, **ការបញ្ឈប់ពីមុខងារដោយបង្ខំ** និង**ការបណ្តេញចេញពីក្របខ័ណ្ឌ**) ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ ទន្ទឹមនេះ, ខ្ញុំសូមស្នើឱ្យមានការផ្សព្វផ្សាយជាសាធារណៈឱ្យបានទៀតទាត់អំពីវិធានការវិន័យម៉ឺងម៉ាត់ដែលត្រូវបានសម្រេចដោយក្រុមប្រឹក្សាវិន័យរបស់ឧត្តម-ក្រុមប្រឹក្សានៃអង្គចៅក្រម ដោយគ្រាន់តែមិនបញ្ជាក់ឈ្មោះចៅក្រម ឬព្រះរាជអាជ្ញាដែលរងវិន័យ ប៉ុន្តែ យើងត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីចំនួនសំណុំរឿងវិន័យដែលក្រុមប្រឹក្សាវិន័យបានចាត់ការ, ចំនួនចៅក្រម-ព្រះរាជអាជ្ញាដែលទទួលរងវិន័យ និងប្រភេទទណ្ឌកម្មវិន័យដែលត្រូវបានសម្រេច ដើម្បីពង្រឹង និងលើកកម្ពស់ជំនឿទុកចិត្តរបស់សាធារណជនមកប្រព័ន្ធតុលាការកម្ពុជា។

ទន្ទឹមនឹងការពង្រឹងវិន័យការងារ និងក្រមសីលធម៌ខាងលើនេះ, ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នឹងបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់ការលើកទឹកចិត្តនានាដល់មន្ត្រីរាជការ និងមន្ត្រីតុលាការទាំងអស់ ដែលបានខិតខំប្រឹងប្រែងអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីបុរេសកម្ម, ភាពជាម្ចាស់, ការទទួលខុសត្រូវខ្ពស់, មានសាមគ្គីភាពផ្ទៃក្នុង និងកិច្ចសហប្រតិបត្តិការល្អ តាមរយៈការលើកកម្ពស់ការអនុវត្តនូវគោលការណ៍គុណាធិបតេយ្យ (Meritocracy) ក្នុងការរៀបចំតែងតាំង និងផ្លាស់ប្តូរ មុខតំណែងទទួលខុសត្រូវនានានៅក្នុងវិស័យយុត្តិធម៌។

(ទី៣)-យន្តការទទួលបន្ទុកកិច្ចការព័ត៌មាន និងសាធារណមតិ នៃក្រសួងយុត្តិធម៌ និងសាលាជម្រះក្តីនិងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស ត្រូវយកចិត្តទុកដាក់ខ្ពស់លើកិច្ចការព័ត៌មាន និងសាធារណមតិ ដោយត្រូវផ្លាស់ប្តូរពីការនាំពាក្យដែលមានលក្ខណៈជា**ប្រតិកម្មឆ្លើយតបទៅទាល់តែមានការចោទប្រកាន់ (Reactive)** ទៅជាការនាំពាក្យដែលមានលក្ខណៈ**បុរេសកម្ម (Proactive)** ផង និងលក្ខណៈជា**ប្រតិកម្មឆ្លើយតប (Reactive)** ផង ដោយសារការងារនាំពាក្យ និងសារព័ត៌មាន គឺជាកិច្ចការដ៏មានសារៈសំខាន់ និងចាំបាច់



សាលក្រម ឬសាលដីការបស់ខ្លួនយូរខែយូរឆ្នាំពេក បន្ទាប់ពីការប្រកាសរួច ព្រោះការមិនផ្តល់សាលក្រម ឬសាលដីកាធ្វើឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការប្តឹងឧបាស្រ័យរបស់ភាគី ហើយកាន់តែធ្ងន់ធ្ងរទៀតនោះ ក្នុងសំណុំរឿងព្រហ្មទណ្ឌដែលមានការឃុំខ្លួន។ ការយឺតយ៉ាវក្នុងការចេញសាលក្រម ឬសាលដីកាពាក់ព័ន្ធនឹងសំណុំរឿងដែលមានការឃុំខ្លួនមនុស្សក្នុងពន្ធនាគារ ស្មើនឹងការឃុំខ្លួនមនុស្សដោយខុសច្បាប់។ ហេតុដូចនេះ ប្រធានសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីនានា ត្រូវយកការទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យការអនុវត្តការងារនេះឱ្យមានប្រសិទ្ធភាពខ្ពស់។ ចំពោះចៅក្រម ឬព្រះរាជអាជ្ញាណា ដែលមិនបានអនុវត្តត្រឹមត្រូវ និងម៉ឺងម៉ាត់ចំពោះវិធានការនេះ អាចនឹងក្លាយជាកម្មវត្ថុនៃការកសាងសំណុំរឿងបញ្ជូនទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីចាត់ការឱ្យបានតឹងរឹងតាមច្បាប់ជាធរមាន។

(ទី៧)-ដោយការពង្រឹងសមត្ថភាពមន្ត្រីក្នុងវិស័យយុត្តិធម៌នៅតែជាអាទិភាពការងារដ៏សំខាន់ ដើម្បីគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌, បណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា ជាពិសេស សាលាច្បាប់ និងសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវសហការគ្នា ធ្វើការសិក្សា និងវាយតម្លៃពីតម្រូវការ ដើម្បីដាក់ចេញនូវផែនការអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌ ទាំងសម្រាប់មន្ត្រីបម្រើការនៅក្រសួងយុត្តិធម៌ ទាំងមន្ត្រីរដ្ឋបាលតុលាការ ទាំងចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីតុលាការទាំងអស់ ឱ្យបានឆាប់ និងអាចឆ្លើយតបបានទៅនឹងការវិវត្តយ៉ាងឆាប់រហ័សក្នុងសង្គម ជាពិសេស ការយកចិត្តទុកដាក់ខ្ពស់លើការងារបរិវត្តកម្មឌីជីថល និងបច្ចេកវិទ្យា សំដៅធ្វើយ៉ាងណាទាញយកឱ្យអស់សក្តានុពលពីបច្ចេកវិទ្យាថ្មីនេះ សម្រាប់បម្រើដល់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពការងារក្នុងវិស័យយុត្តិធម៌ ព្រមទាំងអភិវឌ្ឍខ្លួនឱ្យទាន់ដំណើរវិវត្តឈានឡើងជាលំដាប់ដ៏ឆាប់រហ័សនៃវិស័យបច្ចេកវិទ្យាក្នុងសង្គមសម័យទំនើបបច្ចុប្បន្ន។

ទន្ទឹមនេះ, សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ក៏ត្រូវបន្តយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងសមត្ថភាពធនធានមនុស្សរបស់ខ្លួនផងដែរ តាមរយៈការពង្រឹងលើការសិក្សាស្រាវជ្រាវ ការរៀបចំជាសិក្ខាសាលា វគ្គបណ្តុះបណ្តាល ឬកម្មវិធីចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ថ្មីៗ ដល់មន្ត្រីរាជការដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ហើយក្រសួងយុត្តិធម៌អាចផ្តល់ជាការគាំទ្រជាបច្ចេកទេសតាមតម្រូវការចាំបាច់ថែមទៀត។ ម្យ៉ាងទៀត, មន្ត្រីគ្រប់រូបក្នុងវិស័យយុត្តិធម៌ក៏ត្រូវយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួនជាប់ជាប្រចាំផងដែរ ដើម្បីអាចសម្របខ្លួនបានទាន់នឹងការវិវត្តយ៉ាងឆាប់រហ័ស ក្នុងសង្គម និងវិស័យយុត្តិធម៌។

**ឯកឧត្តម លោកជំទាវ និងអង្គមហាសន្និបាតទាំងមូល ជាទីមេត្រី!**

មុននឹងបញ្ចប់ ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមាន និងកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលជាគណៈចាត់តាំងកម្មវិធី, ជាវាគ្មិន និងជាអ្នកចូលរួមទាំងអស់ ដែលបានធ្វើឱ្យមហាសន្និបាតរបស់យើង បានដំណើរការយ៉ាងរលូន អធិកអធម និងទទួលបានលទ្ធផលផ្លែផ្កាតាមការរំពឹងទុក ហើយខ្ញុំក៏សូមលើកទឹកចិត្តថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងវិស័យយុត្តិធម៌ទាំងអស់ឱ្យបន្តខិតខំប្រឹងប្រែងជាបន្តទៀត។

ជាទីបញ្ចប់, ក្នុងនាម**ឯកឧត្តមប្រធានតុលាការកំពូល** ក្នុងនាម**លោកជំទាវអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមជូនពរ **គណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** និងអង្គមហាសន្និបាតទាំងមូល សូមទទួលបានសុខភាពល្អ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចការងារ ជាពិសេស ជោគជ័យក្នុងបេសកកម្ម ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជាជនកម្ពុជា និងបុព្វហេតុនៃវិស័យយុត្តិធម៌របស់យើង។ ***ខ្ញុំសូមប្រកាសបិទមហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត របស់យើងចាប់ពីពេលនេះតទៅ*** ។

***សូមអរគុណ!***

# ផ្នែកទី ២

# អត្ថបទស្រាវជ្រាវនិងវិភាគផ្នែកច្បាប់

# ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ដោយៈ

-ឯកឧត្តម **សេង ប៊ុនឃាង** សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-ឯកឧត្តម **ញ៉ាន វណ្ណៈ** រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យក្រសួងយុត្តិធម៌

ឯករាជ្យភាពនៃអំណាចតុលាការ គឺជាធាតុដ៏សំខាន់មិនអាចខ្វះបាននៅក្នុងសង្គមនីតិរដ្ឋស្របតាមគោលការណ៍នៃការបែងចែកអំណាចរវាងអំណាចទាំង ៣ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ ជាគោលការណ៍ ឯករាជ្យភាពនៃអំណាចតុលាការនេះ ត្រូវបានធានាដោយប្រមុខរដ្ឋ ដែលអាចជាព្រះមហាក្សត្រ ឬប្រធានាធិបតី អាស្រ័យទៅតាមប្រព័ន្ធនៃការដឹកនាំប្រទេសនីមួយៗ។ សម្រាប់កម្ពុជា យន្តការសម្រាប់ធានាឯករាជ្យភាពនៃអំណាចតុលាការ ត្រូវបានបង្កើតឡើងជាលើកដំបូងដោយរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាឆ្នាំ១៩៤៧ និងមានការវិវត្តជាបន្តបន្ទាប់ទៅតាមរបបនៃការដឹកនាំប្រទេស។ នៅឆ្នាំ១៩៤៧ ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ត្រូវបានបង្កើតឡើងដើម្បីធានាឱ្យចៅក្រមទាំងឡាយរក្សាវិន័យ និងធានាឥស្សរភាពនៃចៅក្រម។ ការធានាឯករាជ្យភាពនៃអំណាចតុលាការ មិនត្រូវបានកំណត់ជាក់លាក់ថាជាមុខងាររបស់ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការនោះទេ។ ក្រុមប្រឹក្សានេះត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអធិបតី និងក្រោយមកត្រូវបានកែសម្រួលឱ្យមកស្ថិតនៅក្រោមអធិបតីភាពនៃព្រះមហាក្សត្រវិញ ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្លាយជាអនុប្រធាន រួមនិងសមាជិកចំនួន ៦ រូប ដែលក្នុងនោះ ចាត់តាំងដោយព្រះមហាក្សត្រចំនួន ២ រូប, ជ្រើសតាំងដោយរដ្ឋសភាចំនួន ២ រូប និងជ្រើសតាំងដោយចៅក្រមទូទាំងប្រទេសចំនួន ២ រូប[1]។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងទទួលធ្វើជាអធិបតី ក្នុងករណីព្រះមហាក្សត្រមិនមានព្រះរាជវត្តមាន ឬមិនចាត់តាំងសមាជិកឧត្តមក្រុមប្រឹក្សាអមព្រះអង្គធ្វើជាអធិបតីទេ។ នៅក្នុងរបបសាធារណរដ្ឋខ្មែរ ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការនេះ ត្រូវបានប្តូរទៅជាឧត្តមក្រុមប្រឹក្សាតុលាការ ដោយរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ដែលមានប្រធានាធិបតីនៃសាធារណរដ្ឋជាប្រធាន ហើយក្នុងករណីប្រធានាធិបតីមានធុរៈ ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់អនុប្រធានាធិបតីនៃសាធារណរដ្ឋ[2]។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ឧត្តមក្រុមប្រឹក្សាតុលាការនេះ ត្រូវបានលុបបំបាត់ចោល។ ក្រោយការរំដោះជាតិពីរបបខ្មែរក្រហម, យន្តការនេះមិនទាន់ត្រូវបានបង្កើតឡើងវិញនោះទេ ទាំងនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ទាំងក្នុងរបបរដ្ឋកម្ពុជា ដោយអំណាចទាំងអស់ត្រូវប្រមូលផ្តុំនៅក្រោមក្រុមប្រឹក្សារដ្ឋ។ យន្តការនេះ ទើបត្រូវបានបង្កើតឡើងវិញនៅពេលដែលរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ដោយមានឈ្មោះថ្មីថា **“ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម”**។

ផ្អែកតាមរដ្ឋធម្មនុញ្ញដែលចែងអំពីអំណាចតុលាការ[3] គឺអំណាចតុលាការជាអំណាចឯករាជ្យ។ គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការបានឡើយ។ ព្រះមហាក្សត្រ ដែលជាព្រះប្រមុខរដ្ឋមួយជីវិត គឺទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានបង្កើតឡើងដើម្បីជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នកំពូលមួយរបស់ជាតិ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាអធិបតីភាពនៃព្រះមហាក្សត្រ។ សមាសភាព មុខងារ និងការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវកំណត់ក្នុងច្បាប់រៀបចំអង្គការមួយដោយឡែក គឺច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៩ ន.ស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤។ យោងតាមច្បាប់នេះ សមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺមានព្រះមហាក្សត្រជាព្រះប្រធាន និងមានសមាជិក ៨រូប ដែលរួមមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ប្រធានតុលាការកំពូល, អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល, ប្រធានសាលាឧទ្ធរណ៍, អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងចៅក្រម ៣រូប ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយចៅក្រមទូទាំងប្រទេស។ ក្រោយពីច្បាប់នេះចូលជាធរមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីមានការព្រមព្រៀងពីប្រធានតុលាការកំពូល ត្រូវស្នើសុំទៅព្រះមហាក្សត្រតែងតាំងចៅក្រម ៣រូប ជាសមាជិកបណ្តោះអាសន្នសិន សម្រាប់អំឡុងពេលដែលពុំទាន់អាចរៀបចំការបោះឆ្នោតបាន។ សមាជិកជ្រើសតាំង ៣រូប នេះ មានអាណត្តិ ៥ឆ្នាំ ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយចៅក្រម បន្ទាប់ពីច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមចូលជាធរមាន។ ប៉ុន្តែ ដោយសារមិនទាន់មានច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ទើបការបោះឆ្នោតជ្រើសតាំងត្រូវអូសបន្លាយរហូតដល់មានច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា[4] និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមថ្មី[5] បានប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០១៤។ ផ្អែកតាម

[1] មាត្រា១១៤ (មាត្រា៩៦ចាស់) នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៤៧ ដែលត្រូវបានកែប្រែ និងបន្ថែមតាមច្បាប់ដែលរដ្ឋសភាទី៣ បានអនុម័តជាលើកទី២ កាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៥៥ ហើយដែលមានព្រះរាជក្រមប្រកាសឱ្យប្រើលេខ ៦៥ ន.ស. ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥៦។

[2] មាត្រា៨៩ ដល់មាត្រា៩១ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឆ្នាំ១៩៧២។

[3] អំពី អំណាចតុលាការ (ជំពូកទី១១ថ្មី, មាត្រា១២៨ថ្មី ដល់មាត្រា ១៣៥ថ្មី) នៃរដ្ឋធម្មនុញ្ញ។

[4] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, ព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

[5] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦-០៧-២០១៤

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមថ្មីនេះ តើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសមាសភាពអ្វីខ្លះ? តើសមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានជ្រើសរើសដោយរបៀបណា? តើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានមុខងារ ឬសមត្ថកិច្ចអ្វីខ្លះ? និង តើកិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

### ១- សមាសភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។ បើប្រៀបធៀបច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឆ្នាំ១៩៩៤ និងឆ្នាំ២០១៤, សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានដំឡើងពី ៨រូប[6] ទៅជា ១១រូប ហើយសមាជិកបម្រុងដែលមានកំណត់ក្នុងច្បាប់ឆ្នាំ១៩៩៤ ត្រូវបានលុបចោល។ ចំពោះសមាជិកទាំង ១១រូប ក្នុងច្បាប់ឆ្នាំ២០១៤ ត្រូវបានចែកចេញជា ២ ប្រភេទ គឺសមាជិកស្វ័យប្រវត្តិដោយផ្អែកលើមុខងារ និងសមាជិកជ្រើសតាំង ដែលរួមមានដូចខាងក្រោម៖

ក-សមាជិកភាពស្វ័យប្រវត្តិដោយផ្អែកលើមុខងារ មាន ៣រូប រួមមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។

ខ-សមាជិកជ្រើសតាំងមាន ៨រូប ដូចខាងក្រោម៖

- ៤រូប ជាសមាជិកជ្រើសតាំងដោយព្រឹទ្ធសភា, ជ្រើសតាំងដោយរដ្ឋសភា, ជ្រើសតាំងដោយក្រុមប្រឹក្សាធម្មនុញ្ញ, និងជ្រើសតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ចំពោះសមាជិកជ្រើសតាំងដោយព្រឹទ្ធសភា, ជ្រើសតាំងដោយរដ្ឋសភា និងជ្រើសតាំងដោយក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសក្នុងចំណោមបេក្ខជនជាឥស្សរជនដែលជាអតីតចៅក្រម ឬព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារយ៉ាងតិច ១៥ឆ្នាំ ឡើងទៅក្នុងវិស័យច្បាប់ ឬតុលាការ។ ចំពោះសមាជិកជ្រើសតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវជ្រើសរើសក្នុងចំណោមព្រះរាជអាជ្ញាពេញសិទ្ធិ។

[6]· ផ្អែកតាមមាត្រា២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឆ្នាំ១៩៩៤, សមាសភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រួមមាន ព្រះមហាក្សត្រជាព្រះប្រធាន និងមានសមាជិក ៨រូបទៀត រួមមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ប្រធានតុលាការកំពូល, អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល, ប្រធានសាលាឧទ្ធរណ៍, អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងចៅក្រម ៣ រូប ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រម។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវមានសមាជិកបម្រុង ៣ រូបទៀត ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រមទូទាំងប្រទេស សម្រាប់ជំនួសសមាជិកជាប់ឆ្នោតដែលអវត្តមាន។



- ៤រូប ជាសមាជិកជ្រើសតាំង តាមរយៈការបោះឆ្នោតដោយចៅក្រម និងព្រះរាជអាជ្ញាទូទាំងប្រទេស ដែលក្នុងនោះ ១រូប ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់, ១រូប ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាបម្រើការងារនៅមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ និងនៅក្រសួងយុត្តិធម៌, ១រូប ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមពេញសិទ្ធិនៃសាលាដំបូងទូទាំងប្រទេស និង ១រូប ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាពេញសិទ្ធិនៃអយ្យការអមសាលាដំបូងទូទាំងប្រទេស។ ចំពោះបែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងសមាជិកជ្រើសតាំងដោយចៅក្រម និងព្រះរាជអាជ្ញាទូទាំងប្រទេសនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីទទួលបានការឯកភាពពីសមាជិកភាគច្រើននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ បេក្ខជនដែលមានបំណងឈរឈ្មោះ ត្រូវដាក់ពាក្យសុំឈរឈ្មោះដោយផ្ទាល់នៅអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[7]។ ក្រោយពីការបោះឆ្នោតដោយចៅក្រម និងព្រះរាជអាជ្ញាទូទាំងប្រទេសរួច រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈកម្មការរៀបចំការបោះឆ្នោត ប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅពេលរាប់សន្លឹកឆ្នោតរួច និងចុងក្រោយបន្ទាប់ពីផុតរយៈពេលនៃការប្តឹងតវ៉ាក្នុងរយៈពេល ២៤ ម៉ោង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។ សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអាណត្តិ ៥ឆ្នាំ ហើយអាចឈរឈ្មោះជាថ្មីសម្រាប់អាណត្តិបន្តបន្ទាប់ទៀតបានដោយមិនមានកំណត់ចំនួនអាណត្តិនោះទេ។ សមាជិកជ្រើសតាំងនេះ ត្រូវបញ្ចប់នៅពេលសមាជិកជ្រើសតាំងថ្មីត្រូវបានតែងតាំង។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចសម្រេចដកតំណែងសមាជិកជ្រើសតាំងណាម្នាក់បាន ក្នុងករណីដែលសមាជិកជ្រើសតាំងនោះ បានរំលោភបំពានធ្ងន់ធ្ងរលើបទបញ្ជាផ្ទៃក្នុងរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬការធ្វើសកម្មភាពនានាដែលនាំឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ការដកតំណែងនេះ ត្រូវធ្វើឡើងដោយការបោះឆ្នោតសម្រេច ដែលត្រូវមានសម្លេងយល់ព្រមពីសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមយ៉ាងតិច ៨រូប។ ចំពោះសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ដោយគ្មានការព្យួរទោសពី

[7]· បេក្ខជនដែលអាចដាក់ពាក្យសុំឈរឈ្មោះបានគឺជាចៅក្រម-ព្រះរាជអាជ្ញាពេញសិទ្ធិនៃសាលាដំបូង និងអយ្យការអមសាលាដំបូង, សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍, តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល និងនៅក្រសួងយុត្តិធម៌។

បទឧក្រិដ្ឋ ឬពីបទមជ្ឈិមដែលប្រព្រឹត្តដោយចេតនា ត្រូវដកចេញពីមុខតំណែងដោយស្វ័យប្រវត្តិ។ ចំណែកឯការសម្រេចផ្តន្ទាទោសពីបទមជ្ឈិមដោយអចេតនា មិនមែនជាមូលហេតុនៃការដកចេញពីមុខតំណែងដោយស្វ័យប្រវត្តិនោះទេ។

មុខងារជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាចៅក្រម ឬព្រះរាជអាជ្ញា នៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី លើកលែងតែប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានវិសមិតភាពមុខងារ ត្រូវស្នើសុំផ្អាច់ពីមុខងារជាចៅក្រម ឬព្រះរាជអាជ្ញា នៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី ដោយអនុវត្តស្របតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[8] និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា[9]។

## ២-រចនាសម្ព័ន្ធ និងកិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវដំណើរការប្រជុំក្រោមព្រះរាជាធិបតីភាពរបស់ព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬព្រះរាជតំណាងណាម្នាក់ ដែលទទួលបានការចាត់តាំងដោយព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ព្រះរាជតំណាងដែលទទួលបានការចាត់តាំង ដឹកនាំ និងចាត់ចែងការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរាយការណ៍ឱ្យបានទៀងទាត់អំពីសកម្មភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមថ្វាយព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

កិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវធ្វើឡើងតាមការកោះប្រជុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមព្រះរាជបញ្ជានៃព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ សមាជិក ៤រូបយ៉ាងតិច អាចស្នើឱ្យមានកិច្ចប្រជុំរបស់ឧត្តមប្រឹក្សានៃអង្គចៅក្រមបាន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវរៀបចំទូលថ្វាយព្រះប្រធាន ស្នើសុំព្រះរាជតម្រិះដើម្បីកោះប្រជុំ។ កិច្ចប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចដំណើរការទៅបានលុះត្រាតែមានសមាជិកចូលរួមប្រជុំចំនួន ៦ រូបយ៉ាងតិច ហើយការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលយកជាការបាន ត្រូវមានសំឡេងយ៉ាងតិច ៦សំឡេង តាមការបោះឆ្នោតជាសម្ងាត់។ ព្រះប្រធាន ឬព្រះរាជតំណាង មិនចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ។ ប៉ុន្តែក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬប្រធានតុលាការកំពូល ត្រូវបានចាត់តាំងជាព្រះរាជតំណាងនោះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬប្រធានតុលាការកំពូល មានសិទ្ធិចូលរួមធ្វើសេចក្តីសម្រេចចិត្តដូចសមាជិកដទៃទៀតដែរ។

ជាទូទៅ កិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវធ្វើឡើងរៀងរាល់ ៣ខែម្តងក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ឬព្រះរាជតំណាង។ កិច្ចប្រជុំនេះក៏អាចធ្វើមុនកាលកំណត់បានដែរ តាមរយៈការស្នើសុំរបស់សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៤រូបយ៉ាងតិច[10]។ បន្ទាប់ពីទទួលបានព្រះរាជតម្រិះយល់ព្រមពីព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អគ្គលេខាធិការត្រូវរៀបចំរាល់លិខិតអញ្ជើញគ្រប់សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយភ្ជាប់នូវរបៀបវារៈប្រជុំ[11] របាយការណ៍ និងឯកសារផ្សេងៗសម្រាប់ប្រជុំ ឱ្យបានយ៉ាងតិច ១០ថ្ងៃមុនថ្ងៃប្រជុំ ហើយក្នុងករណីបន្ទាន់ រយៈពេលនេះត្រូវបន្ថយមកក្រោម ៥ថ្ងៃ[12]។ ចំពោះសេចក្តីព្រាងរបៀបវារៈត្រូវដាក់ជូនអង្គប្រជុំដើម្បីសុំការអនុម័តតាមមតិភាគច្រើនដោយលើកដៃ ហើយសមាជិកគ្រប់រូបអាចស្នើបន្ថែម ឬបន្ថយរបៀបវារៈបានដែលត្រូវសម្រេចដោយការបោះឆ្នោតជាសម្ងាត់។

មុននឹងមានកិច្ចប្រជុំនីមួយៗដែលទាក់ទងនឹងការផ្លាស់ប្តូរ ឬផ្ទេរភារកិច្ចចៅក្រម ព្រះរាជអាជ្ញា, អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវធ្វើលិខិតជូនដំណឹងដល់ប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូងនីមួយៗ ដើម្បីជម្រាបជូនបន្តដល់សាមីខ្លួនដែលដល់វេនអតីតភាពចាប់ពីបួនឆ្នាំឡើង ត្រូវដាក់ពាក្យសុំជ្រើសរើសទីកន្លែងដែលសាមីខ្លួនមានបំណងចង់ទៅបំពេញការងារ[13]។ លុះដល់ពេលបញ្ចប់កិច្ចប្រជុំ អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃ

8· មាត្រា ៦ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។
9· មាត្រា ៤៤ និងមាត្រា ៩០ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

10· ប្រការ១ នៃបទបញ្ជាផ្ទៃក្នុង នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥។
11· ជាទូទៅរបៀបវារៈមានដូចជា៖ របាយការណ៍ស្តីពីសកម្មភាពការងារចន្លោះសម័យប្រជុំ, ពិនិត្យសម្រេចលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ, ពិនិត្យសម្រេចអំពីការតែតាំង ផ្លាស់ប្តូរ ចៅក្រម និងពិគ្រោះយោបល់លើសំណើតែងតាំង ផ្លាស់ប្តូរ ព្រះរាជអាជ្ញា ។ល។
12· ប្រការ២ នៃបទបញ្ជាផ្ទៃក្នុង នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥។
13 មានបញ្ជីស្ថិតិចំនួនចៅក្រម ព្រះរាជអាជ្ញា នៅតាមអង្គភាពនីមួយៗ ដែលដល់វេននឹងត្រូវផ្លាស់ប្តូរភ្ជាប់ជាមួយ។

អង្គចៅក្រម ចេញសេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលនៃសម័យប្រជុំ ដើម្បីជម្រាបជូនដល់អង្គចៅក្រម និងសាធារណជនជ្រាប។

ការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវធ្វើឡើងតាមការបោះឆ្នោតជាសម្ងាត់ដោយផ្ទាល់។ ប៉ុន្តែ ក្នុងករណីចាំបាច់បន្ទាន់ និងតាមសំណើរបស់សមាជិកចំនួន ៦ រូប យ៉ាងតិច ការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចធ្វើឡើងតាមការបោះឆ្នោតជាសម្ងាត់ដោយប្រយោលបាន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវរៀបចំកិច្ចការនេះ បន្ទាប់ពីទទួលបានព្រះរាជតម្រិះពីព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ក្នុងក្របខ័ណ្ឌនៃច្បាប់ឆ្នាំ១៩៩៤, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជ្រើសរើសចៅក្រមម្នាក់ និងក្រឡាបញ្ជីម្នាក់ ឱ្យទទួលរ៉ាប់រងមុខងារជាលេខាធិការ ដែលមានភារកិច្ចធ្វើរបាយការណ៍ធ្វើកំណត់ហេតុ រក្សាឯកសារ និងបំពេញកិច្ចការផ្សេងៗទៀត។ ប៉ុន្តែក្នុងក្របខ័ណ្ឌនៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ឆ្នាំ ២០១៤ បានបង្កើតឱ្យមានអគ្គលេខាធិការដ្ឋានមួយ ធ្វើជាសេនាធិការសម្រាប់គាំទ្រដល់កិច្ចដំណើរការការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាពិសេស លើការងាររដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក កិច្ចការព័ត៌មានវិទ្យា ការសម្របសម្រួលកិច្ចការចៅក្រម និងព្រះរាជអាជ្ញា និងការទទួលពាក្យបណ្តឹងទាក់ទងនឹងវិន័យចៅក្រម និងព្រះរាជអាជ្ញា។ អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌[14]។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាតំណាងឱ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅក្នុងទំនាក់ទំនងជាមួយបុគ្គលឯកជន ឬបុគ្គលសាធារណៈនានា និងមានភារកិច្ចចាត់ចែងកិច្ចការរដ្ឋបាលរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានអគ្គលេខាធិការដ្ឋានជាសេនាធិការ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាអាណាប័កទទួលសិទ្ធិដោយពេញច្បាប់ពីព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំពោះការងារថវិការបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ រាល់កិច្ចការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទាក់ទង

14. ផ្អែកតាមមាត្រា ៨ នៃច្បាប់ឆ្នាំ២០១៤, ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវកំណត់ដោយអនុក្រឹត្យ (អនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៤)។



នឹងការលើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវរៀបចំកិច្ចការនេះក្នុងនាមឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## ៣-សមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

មាត្រា១៣៤ថ្មី (មាត្រា១១៥ ចាស់) នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានកំណត់ឱ្យមានច្បាប់រៀបចំអង្គការមួយដែលនឹងកំណត់អំពីមុខងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ មាត្រាដដែលនេះក៏បានកំណត់រួចជាស្រេចនូវមុខងារសំខាន់ៗ ២ ដែលមិនអាចខ្វះបានរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់ធានាឯករាជ្យភាពនៃអំណាចតុលាការ ដែលរួមមាន មុខងារពាក់ព័ន្ធនឹងការតែងតាំងចៅក្រម និងព្រះរាជអាជ្ញា និងមុខងារក្នុងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា។ ផ្អែកតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានមុខងារបន្ថែមសំខាន់ ៣ ទៀត គឺពាក់ព័ន្ធនឹងការផ្តល់មតិពិគ្រោះយោបល់លើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ទាក់ទងដល់ការរៀបចំវិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ[15], ការផ្តល់យោបល់ចំពោះការដំឡើងថ្នាក់ និងការដំឡើងឋានន្តរស័ក្តិឱ្យចៅក្រម និងព្រះរាជអាជ្ញាទាំងអស់[16] និងការពិនិត្យ និងសម្រេចលើក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា[17]។

ផ្អែកតាមច្បាប់, សមត្ថកិច្ចទាំងនេះត្រូវបានកំណត់ជា **សមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម***(៣-១)* និង **សមត្ថកិច្ចក្នុងមុខការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា***(៣-២)*។

### ៣-១. សមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

សមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គ្របដណ្តប់លើមុខងារក្នុងការតែងតាំងចៅក្រម និងព្រះរាជអាជ្ញា, មុខងារក្នុងការពិនិត្យ និងសម្រេចលើក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា, មុខងារផ្តល់យោបល់ចំពោះការដំឡើងថ្នាក់ និងការដំឡើងឋានន្តរស័ក្តិឱ្យចៅក្រម និងព្រះរាជអាជ្ញា, និងមុខងារពិគ្រោះមតិលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ពាក់ព័ន្ធនឹង

15. មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។
16. មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។
17. មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ការរៀបចំវិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ។ យោបល់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នេះ ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នេះពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណីប្រញាប់ រយៈពេលនេះអាចបន្ថយមកត្រឹម ១០ថ្ងៃ។ ចំពោះមុខងារពាក់ព័ន្ធនឹងការតែងតាំងចៅក្រម, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអ្នកសម្រេច និងលើកយោបល់ថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះចៅក្រមទាំងអស់។ ដោយឡែក ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ពីសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចកើតមានឡើងបន្ទាប់ពីមានកិច្ចប្រជុំដោយផ្ទាល់ ឬដោយប្រយោលក្នុងករណីបន្ទាន់ចាំបាច់។

អំឡុងពេលចន្លោះសម័យប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិកមានភារកិច្ចចុះទៅតាមសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី ក្នុងគោលដៅជួយពង្រឹងដល់អង្គចៅក្រមក្នុងការបំពេញការងារ, អនុវត្តច្បាប់ស្តីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងក្រមសីលធម៌ ព្រមទាំងលើកកម្ពស់ដំណើរការល្អនៃរដ្ឋបាល និងគុណភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹងសុវត្ថិភាពសង្គម។

## ៣-២.សមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងមុខការដាក់វិន័យ

មុខការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានកំណត់ជាសមត្ថកិច្ចពិសេសរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ជាគោលការណ៍ច្បាប់ ចៅក្រមមានឯករាជ្យភាពក្នុងការសម្រេចសេចក្តី ប៉ុន្តែការសម្រេចនេះត្រូវឈរលើគោលការណ៍គោរពច្បាប់។ ចៅក្រម និងព្រះរាជអាជ្ញា មិនត្រូវទទួលកំហុសខាងវិន័យចំពោះការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការអនុវត្តច្បាប់នោះទេ លើកលែងតែការសម្រេចសេចក្តីនោះធ្វើឡើងដោយរំលោភបំពានក្នុងចេតនាទុច្ចរិតលើសមត្ថកិច្ច និងមុខងាររបស់ខ្លួន។ ចៅក្រម និងព្រះរាជអាជ្ញា មានកាតព្វកិច្ចត្រូវគោរពតាមច្បាប់ និងនីតិវិធីជាធរមានឱ្យបានត្រឹមត្រូវ។ ទន្ទឹមនេះ ចៅក្រម និងព្រះរាជអាជ្ញា ក៏មានកាតព្វកិច្ចក្នុងការគោរពឱ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌ចៅក្រម[18] ដោយមិនត្រូវប្រព្រឹត្តអំពើណាមួយដែលនាំឱ្យអាប់ឱនដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គចៅក្រមឡើយ។ ក្នុងករណីដែលមានការបំពាន, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសមត្ថកិច្ចក្នុងការពិនិត្យ និងសម្រេចដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញាណាដែលប្រព្រឹត្តកំហុសនេះ។ ការសម្រេចដាក់វិន័យលើចៅក្រម និងព្រះរាជអាជ្ញា ត្រូវធ្វើឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ ដែលស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូលសម្រាប់មុខការដាក់វិន័យចំពោះចៅក្រម និងក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល សម្រាប់មុខការដាក់វិន័យចំពោះព្រះរាជអាជ្ញា។ ព្រះមហាក្សត្រ ឬព្រះរាជតំណាង ធ្វើជាអធិបតីនៃអង្គប្រជុំក្រុមប្រឹក្សាវិន័យ ដោយមានការចូលរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីសំណុំរឿងវិន័យទាក់ទងនឹងប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាក់ទងនឹងការងារវិន័យនេះ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។ តើបណ្តឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញាទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានរបបគតិយុត្តយ៉ាងដូចម្តេច? តើបណ្តឹងនេះនឹងត្រូវចាត់ការរបៀបណាដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម?

### ក- របបគតិយុត្តនៃបណ្តឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា

បណ្តឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ត្រូវដាក់នៅអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬនៅក្រសួងយុត្តិធម៌។ នៅពេលទទួលបានពាក្យបណ្តឹង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់ឱ្យពិនិត្យ និងស្រាវជ្រាវជាបឋមលើពាក្យបណ្តឹងទាំងនេះ ដើម្បីកសាងសំណុំរឿងវិន័យ មុននឹងសម្រេចបញ្ជូនសំណុំរឿងនេះទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីចាត់នីតិវិធីបន្ត។

18. ក្រមសីលធម៌ចៅក្រមដែលត្រូវបានអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧ និងឡាយព្រះហស្តលេខាដាក់ឱ្យប្រើដោយព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧។

ជាគោលការណ៍ បុគ្គលគ្រប់រូបដែលជាភាគីនៃសំណុំរឿងនៅតុលាការ មានសិទ្ធិប្ដឹងទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអំពីភាពមិនប្រក្រតី ឬកំហុសរបស់ចៅក្រម និងព្រះរាជអាជ្ញានៅក្នុងចំណាត់ការសំណុំរឿង។ បណ្ដឹងនេះធ្វើឡើងដើម្បីទាមទារឱ្យមានការដាក់ទណ្ឌកម្មវិន័យចំពោះចៅក្រម ឬព្រះរាជអាជ្ញាដែលបានប្រព្រឹត្តកំហុសក្នុងការអនុវត្តមុខងាររបស់ខ្លួនជាចៅក្រម ឬជាព្រះរាជអាជ្ញា។ បណ្ដឹងនេះត្រូវធ្វើដោយផ្ទាល់ដោយភាគីនៃសំណុំរឿង ឬដោយមេធាវីតំណាងឱ្យម្ចាស់ភាគីបណ្ដឹង។ ផ្អែកតាមគោលការណ៍នៃការធ្វើបណ្ដឹងទៅតុលាការ, បុគ្គលដែលមិនមានផលប្រយោជន៍ក្នុងការធ្វើបណ្ដឹង មិនមានសិទ្ធិក្នុងការដាក់ពាក្យបណ្ដឹងទៅតុលាការមានសមត្ថកិច្ចនោះទេ។ ក្នុងន័យនេះ បុគ្គលផ្សេងក្រៅពីភាគីនៅក្នុងសំណុំរឿងនៅតុលាការ ឬបុគ្គលដែលមិនទទួលបានសិទ្ធិជាតំណាងឱ្យភាគីនៅក្នុងសំណុំរឿងនៅតុលាការ ឬបុគ្គលដែលមិនមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន ក៏មិនគួរមានសិទ្ធិដាក់ពាក្យប្ដឹងទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអំពីកំហុសរបស់ចៅក្រម ឬព្រះរាជអាជ្ញា នៅក្នុងចំណាត់ការសំណុំរឿងជាក់លាក់ណាមួយបាននោះដែរ។ ត្រង់ចំណុចនេះ ច្បាប់មិនបានចែងច្បាស់លាស់នោះទេ។ ប៉ុន្តែ បើពិនិត្យអំពីក្រមសីលធម៌ចៅក្រម ដែលតម្រូវឱ្យចៅក្រម និងព្រះរាជអាជ្ញា ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវភាពមិនលម្អៀងដើម្បីការពារថែរក្សា និងបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ ពីអ្នកមានវិជ្ជាជីវៈច្បាប់ និងពីភាគីវិវាទនោះ គួរតែទទួលយករាល់បណ្ដឹងអំពីចំណាត់ការមិនប្រក្រតីរបស់ចៅក្រម ឬព្រះរាជអាជ្ញា ដែលប្ដឹងដោយភាគីនៃសំណុំរឿង ឬបណ្ដឹងបរិហារទាំងឡាយណាដែលមានភាពសមហេតុផលបញ្ជាក់ថាចៅក្រម ឬព្រះរាជអាជ្ញាណាមួយ បានប្រព្រឹត្តខុសនឹងកាតព្វកិច្ចវិជ្ជាជីវៈ ឬធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ស្អាតស្អំ និងសេចក្ដីថ្លៃថ្នូរ ប្រាសចាកពីក្រមសីលធម៌។ ចំពោះការដាក់ពាក្យប្ដឹងអំពីចំណាត់ការមិនប្រក្រតីលើចៅក្រម ឬព្រះរាជអាជ្ញា ហើយទោះបីជាមានការសម្រុះសម្រួលគ្នារវាងភាគីពាក់ព័ន្ធ ឬការដកពាក្យបណ្ដឹងវិញក៏ដោយ ក៏ពាក្យបណ្ដឹងនេះនៅតែត្រូវបានចាត់ការបន្តដដែល។

តើបណ្ដឹងទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចធ្វើបាននៅពេលណា? ចំពោះចំណុចនេះ ទោះបីជាច្បាប់មិនបានកំណត់ច្បាស់លាស់ក៏ដោយ, ការប្ដឹងទៅក្រុមប្រឹក្សាវិន័យ គឺមានកម្មវត្ថុទាមទារឱ្យមានការដាក់វិន័យចំពោះចៅក្រម ឬព្រះរាជអាជ្ញា ដែលបានប្រព្រឹត្តកំហុសក្នុងចំណាត់ការសំណុំរឿងក្ដី។ ក្នុងន័យនេះ បណ្ដឹងនេះគួរតែអាចទទួលយកបាន លុះត្រាតែចៅក្រម ឬព្រះរាជអាជ្ញា បានចេញនូវសេចក្ដីសម្រេចណាមួយនៅក្នុងសំណុំរឿងជាមុនសិន។ ហេតុដូចនេះ ដើម្បីធានាបាននូវឯករាជ្យភាពនៃការសម្រេចសេចក្ដីរបស់ចៅក្រម ឬព្រះរាជអាជ្ញា, បើសិនភាគីគ្រាន់តែយល់ថាចៅក្រម ឬព្រះរាជអាជ្ញាណាមួយបានប្រព្រឹត្តកំហុសក្នុងការចាត់ការសំណុំរឿងក្នុងពេលដែលចៅក្រម ឬព្រះរាជអាជ្ញានោះ មិនទាន់បានចេញសេចក្ដីសម្រេចណាមួយនៅឡើយនោះ បណ្ដឹងនេះមិនគួរអាចធ្វើទៅបាននោះទេ។ ម្យ៉ាងទៀត បណ្ដឹងអំពីវិន័យទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា ទៅក្រុមប្រឹក្សាវិន័យមិនមានអានុភាពចំពោះចំណាត់ការសំណុំរឿងនោះទេ។ ដូចនេះ ដើម្បីជៀសវាងការដាក់សម្ពាធលើចៅក្រម ឬព្រះរាជអាជ្ញា ដែលទទួលបន្ទុកសំណុំរឿង, បណ្ដឹងនេះមិនគួរត្រូវបានទទួលយកមកពិនិត្យ និងចាត់ការនោះទេ នៅពេលដែលសំណុំរឿងកំពុងស្ថិតក្នុងចំណាត់ការរបស់ចៅក្រម ឬព្រះរាជអាជ្ញា ដោយពុំទាន់មានចេញសេចក្ដីសម្រេចណាមួយនោះ លើកលែងតែបណ្ដឹងនោះ ប្ដឹងអំពីការមិនគោរពក្រមសីលធម៌ ដែលមិនពាក់ព័ន្ធនឹងសេចក្ដីសម្រេចក្នុងចំណាត់ការសំណុំរឿង ដូចជា ចៅក្រម ឬព្រះរាជអាជ្ញា បានបង្ហាញអំពីភាពលម្អៀងក្នុងចំណាត់ការសំណុំរឿង ឬមានអាកប្បកិរិយាមិនសមរម្យជាមួយភាគីនៃសំណុំរឿងជាដើម។

ម្យ៉ាងវិញទៀត តើបទប្បញ្ញត្តិគតិយុត្តជាធរមាន បានកំណត់អំពីអាជ្ញាយុកាលសម្រាប់ការដាក់ពាក្យបណ្ដឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ដែរឬទេ? អាជ្ញាយុកាលនៃបណ្ដឹងទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក៏មិនបានកំណត់ក្នុងច្បាប់ជាធរមាននោះដែរ។ តើគួរមានការកំណត់អំពីអាជ្ញាយុកាលនៃបណ្ដឹងនេះដែរឬទេ ស្របពេលដែលអាជ្ញាយុកាលនៃបណ្ដឹងទៅតុលាការ ត្រូវបានកំណត់ទាំងសំណុំរឿងរដ្ឋប្បវេណី ទាំងសំណុំរឿងព្រហ្មទណ្ឌ? លើសពីនេះ បើពិនិត្យមើលក្នុងសំណុំរឿងរដ្ឋប្បវេណី ជាពិសេសផ្អែកតាមមាត្រា៣១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគីអាចធ្វើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានក្នុងអំឡុងពេល ៥ឆ្នាំ គិតចាប់ពីពេលដែលសេចក្ដីសម្រេចរបស់តុលាការបានចូលជាស្ថាពរ ឬគិតចាប់ពីថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតឡើង ក្នុងករណីដែលមូលហេតុនោះកើតឡើងក្រោយពេលសេចក្ដីសម្រេចរបស់តុលាការបានចូលជាស្ថាពរ។ ហេតុដូចនេះ តើគួរទទួលយកបណ្ដឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា មកពិនិត្យទៀតដែរឬទេ នៅពេលដែលសេចក្ដីសម្រេចរបស់តុលាការ

បានចូលជាស្ថាពរ ហើយភាគីលែងមានសិទ្ធិប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីឡើងវិញហើយ? ឈរលើមូលដ្ឋាននៃអាជ្ញាយុកាលទាំងនៅក្នុងសំណុំរឿងរដ្ឋប្បវេណី និងសំណុំរឿងព្រហ្មទណ្ឌ, បណ្ដឹងទៅក្រុមប្រឹក្សាវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ក៏គួរត្រូវបានគិតគូរពិចារណាផងដែរ។

## ខ- ចំណាត់ការរបស់ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងមុខការដាក់វិន័យ

ដូចបានគូសបញ្ជាក់ពីខាងលើ ការសម្រេចដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ត្រូវធ្វើឡើងដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ។ ក្រុមអធិការកិច្ចនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានបង្កើតឡើងដើម្បីជួយក្រុមប្រឹក្សាវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការស៊ើបអង្កេត និងស្រាវជ្រាវសំណុំរឿងវិន័យ។

រាល់ពាក្យបណ្ដឹងវិន័យទាំងអស់ ដែលពាក់ព័ន្ធនឹងកំហុសក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ ឬប្រាសចាកក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា ត្រូវដាក់នៅអគ្គលេខាធិការដ្ឋាននៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ឬក្រសួងយុត្តិធម៌។ បន្ទាប់ពីទទួលបានសំណុំរឿងវិន័យ ប្រធានក្រុមប្រឹក្សាវិន័យអាចចាត់ឱ្យក្រុមអធិការកិច្ចធ្វើការស៊ើបអង្កេត និងស្រាវជ្រាវ ឬធ្វើការពិនិត្យវាយតម្លៃ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន។ ក្រុមអធិការកិច្ចក្នុងក្របខ័ណ្ឌបំពេញការងាររបស់ខ្លួន ដោយមានការចាត់តាំងពីប្រធានក្រុមប្រឹក្សាវិន័យ អាចស្នើសុំពិនិត្យសំណុំរឿងនានាដែលពាក់ព័ន្ធ ឬមានប្រយោជន៍ដល់សំណុំរឿងវិន័យ ហើយក្នុងករណីចាំបាច់អាចស្នើសុំការបំភ្លឺពីគ្រប់បុគ្គលនានាបាន។ ចៅក្រម ឬព្រះរាជអាជ្ញា ដែលមិនផ្ដល់កិច្ចសហការតាមការស្នើសុំរបស់ក្រុមអធិការកិច្ច ត្រូវចាត់ទុកជាកំហុសវិន័យ[19]។ ចំពោះចៅក្រម ឬព្រះរាជអាជ្ញា ដែលកំពុងជាប់នៅក្នុងនីតិវិធីវិន័យ ប្រធានក្រុមប្រឹក្សាវិន័យ អាចសម្រេចផ្អាកពីមុខងារបណ្ដោះអាសន្នមួយរយៈសិន[20]។

បន្ទាប់ពីស៊ើបអង្កេតចប់ ក្រុមអធិការកិច្ចត្រូវធ្វើរបាយការណ៍ដាក់ជូនប្រធានក្រុមប្រឹក្សាវិន័យដើម្បីចាត់ការបន្ត។ របាយការណ៍របស់ក្រុមអធិការកិច្ច មិនមែនជាចំណងដល់ប្រធាន

19. មាត្រា ២២ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម។

20. មាត្រា ៥៤ នៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។



ក្រុមប្រឹក្សាវិន័យដើម្បីសម្រេចលើសំណុំរឿងវិន័យនោះទេ។ បើយល់ឃើញថាគ្មានកំហុសខាងវិន័យ ប្រធានក្រុមប្រឹក្សាវិន័យអាចសម្រេចតម្កល់សំណុំរឿងទុកឥតចាត់ការបាន។ ប៉ុន្តែ ក្នុងករណីសំណុំរឿងវិន័យត្រូវបានសម្រេចបញ្ជូនទៅក្រុមប្រឹក្សាវិន័យនោះ ប្រធានក្រុមប្រឹក្សាវិន័យ ត្រូវកំណត់ថ្ងៃប្រជុំក្រុមប្រឹក្សាវិន័យ ហើយអគ្គលេខាធិការត្រូវរៀបចំរាល់សំណុំរឿងវិន័យ និងឯកសារពាក់ព័ន្ធដើម្បីផ្ញើជូនគ្រប់សមាជិកទាំងអស់ និងចៅក្រមរបាយការណ៍ ឬព្រះរាជអាជ្ញារបាយការណ៍ និងសាមីខ្លួន យ៉ាងតិច ១០ថ្ងៃ មុនថ្ងៃប្រជុំ។ សាមីខ្លួនជាចៅក្រម ឬព្រះរាជអាជ្ញាដែលជាប់ពាក់ព័ន្ធក្នុងសំណុំរឿងវិន័យត្រូវបានជូនដំណឹងឱ្យដឹងអំពីពាក្យបណ្ដឹងដែលចោទប្រកាន់លើខ្លួន និងមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬដោយមានជំនួយពីមេធាវី នៅចំពោះមុខអង្គប្រជុំក្រុមប្រឹក្សាវិន័យ។

ការប្រជុំរបស់ក្រុមប្រឹក្សាវិន័យ ត្រូវធ្វើជាអសាធារណៈ ហើយសមាជិកនៃអង្គប្រជុំទាំងអស់ត្រូវរក្សាការសម្ងាត់នៃអង្គប្រជុំ។ ក្នុងនីតិវិធីដំបូងនៃកិច្ចប្រជុំក្រុមប្រឹក្សាវិន័យ ប្រធានក្រុមប្រឹក្សាវិន័យចាត់ឱ្យចៅក្រមរបាយការណ៍ ឬព្រះរាជអាជ្ញារបាយការណ៍ អានរបាយការណ៍នៃសំណុំរឿងវិន័យដែលខ្លួនបានស៊ើបអង្កេត និងស្រាវជ្រាវ ជូនអង្គប្រជុំ។ បន្ទាប់ពីបញ្ចប់កិច្ចសួរដេញដោល ក្រុមប្រឹក្សាវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ដំណើរការពិភាក្សាដើម្បីសម្រេច។ ចំពោះនីតិវិធីនៃការសម្រេច គឺមានបែងចែកជាពីរដំណាក់កាល ដែលដំណាក់កាលទី១ គឺត្រូវពិនិត្យសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃកំហុស និងបើសិនជាសម្រេចថាមានកំហុសហើយ ទើបឈានចូលដំណាក់កាលទី២ ដែលត្រូវសម្រេចអំពីទណ្ឌកម្ម។

- **ដំណាក់កាលទី១៖** ប្រធាន និងសមាជិកក្រុមប្រឹក្សាវិន័យទាំងអស់បោះឆ្នោតសម្រេចថាចៅក្រម ឬព្រះរាជអាជ្ញា ដែលពាក់ព័ន្ធសំណុំរឿងវិន័យ មានកំហុស ឬគ្មានកំហុស។ ក្នុងករណីការបោះឆ្នោតទទួលបានការសម្រេចថាគ្មានកំហុសនោះ សំណុំរឿងវិន័យនេះត្រូវបានបិទបញ្ចប់។
- **ដំណាក់កាលទី២៖** ក្នុងករណីការបោះឆ្នោតក្នុងដំណាក់កាលទី១ ទទួលបានការសម្រេចថាមានកំហុសនោះ ត្រូវធ្វើការបោះឆ្នោតសម្រេចអំពីកម្រិត និងប្រភេទនៃទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា ៥៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

កូរ៉ុមប្រជុំ និងការសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវអនុវត្តដូចគ្នានឹងកូរ៉ុមប្រជុំ និងការសម្រេចរបស់ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមដែរ។

កំហុសវិន័យដែលត្រូវដាក់លើចៅក្រម ឬព្រះរាជអាជ្ញា មានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា[21]។ សេចក្តីសម្រេចដាក់វិន័យ ត្រូវមានសំអាងហេតុ និងសំអាងច្បាប់។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យនេះ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យ និង សម្រេច ហើយសេចក្តីសម្រេចចុងក្រោយនេះជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

ក្នុងករណីដែលទណ្ឌកម្មវិន័យថ្នាក់ទី២ ត្រូវបានប្រកាស ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីកិច្ចការនេះដើម្បីចេញព្រះរាជក្រឹត្យដាក់វិន័យ។ ចំពោះទណ្ឌកម្មថ្នាក់ទី២ នេះរួមមាន *ការផ្លាស់ដោយបង្ខំ អាចតម្រូវឱ្យទទួលការបណ្តុះបណ្តាលបន្ថែម, ការព្យួរពីការងារមិនឱ្យមានបៀវត្ស ក្នុងរយៈពេលមិនឱ្យលើសពី១ឆ្នាំ, ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ, ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ, ការបញ្ឈប់ពីមុខងារដោយបង្ខំ និងការបណ្តេញចេញពីក្របខ័ណ្ឌ*។ទណ្ឌកម្មថ្នាក់ទី២ នេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ក្នុងករណីពិសេស ប្រសិនបើបណ្តឹងពាក់ព័ន្ធនឹងប្រធានតុលាការកំពូល គឺអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលជាអ្នកចាត់ឱ្យស្រាវជ្រាវ និងស៊ើបអង្កេតដោយប្រើយន្តការក្រុមអធិការកិច្ច ដើម្បីធ្វើរបាយការណ៍លើពាក្យបណ្តឹងនេះ។ ដូចគ្នាផងដែរ ប្រសិនបើបណ្តឹងពាក់ព័ន្ធនឹងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលនោះ គឺប្រធានតុលាការកំពូលជាអ្នកចាត់ឱ្យស្រាវជ្រាវ និងស៊ើបអង្កេតដោយប្រើយន្តការក្រុមអធិការកិច្ច ដើម្បីធ្វើរបាយការណ៍លើពាក្យបណ្តឹងនេះ។ ក្នុងករណីនេះក្រុមប្រឹក្សាវិន័យត្រូវប្រជុំក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ឬព្រះរាជតំណាង។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចូលរួមក្នុងអង្គប្រជុំនេះ ហើយកូរ៉ុមប្រជុំត្រូវមាន ៨រូប យ៉ាងតិច។ ចំពោះការសម្រេចត្រូវយកតាមមតិភាគច្រើន។

ចំពោះចៅក្រម ឬព្រះរាជអាជ្ញា ដែលបច្ចុប្បន្នជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយមានបណ្តឹងទាក់ទងនឹងខ្លួន មានសិទ្ធិចូលការពារខ្លួន ប៉ុន្តែ ត្រូវដកខ្លួនចេញនៅពេលពិភាក្សា

21. ទណ្ឌកម្មវិន័យមាន ២ថ្នាក់គឺ ទណ្ឌកម្មថ្នាក់ទី១ និងទណ្ឌកម្មថ្នាក់ទី២ ដូចមានចែងក្នុងមាត្រា ៥៥ និងមាត្រា ៩៩ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។



និងសម្រេច មានន័យថា មិនអាចចូលរួមប្រជុំក្នុងឋានៈជាសមាជិកក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ។

ជាទូទៅពាក្យបណ្តឹងតែងតែប្តឹងចំឈ្មោះទៅអ្នកចាត់ការលើសំណុំរឿងដោយផ្ទាល់ ជាពិសេសក្នុងករណីព្រះរាជអាជ្ញារងណាម្នាក់ចាត់ការសំណុំរឿងហើយត្រូវគេប្តឹងអំពីវិន័យ តើក្រុមប្រឹក្សាវិន័យពិនិត្យ និងសម្រេចលើព្រះរាជអាជ្ញារងនោះតែម្នាក់ឬយ៉ាងណា? បើពិនិត្យទៅលើច្បាប់ ព្រះរាជអាជ្ញាមានអំណាចទៅលើព្រះរាជអាជ្ញារងដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូង ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន[22]។ ដូច្នេះ ក្នុងករណីមានបណ្តឹងលើព្រះរាជអាជ្ញារងណាម្នាក់ តើគួរអញ្ជើញព្រះរាជអាជ្ញាដែលជាថ្នាក់លើរបស់ព្រះរាជអាជ្ញារងនោះមកបំភ្លឺចំពោះមុខក្រុមប្រឹក្សាវិន័យដែរឬទេ? បើរកឃើញថាព្រះរាជអាជ្ញាមានកំហុសដូចព្រះរាជអាជ្ញារងដែរ តើព្រះរាជអាជ្ញាត្រូវទទួលទណ្ឌកម្មវិន័យដែរឬទេ? ជាមួយគ្នានេះដែរ ក្នុងករណីសេចក្តីសម្រេចចេញដោយក្រុមប្រឹក្សាជំនុំជម្រះដែលជាទូទៅក្រុមប្រឹក្សាជំនុំជម្រះអាចមានចៅក្រមចំនួន ៣រូប, ៥រូប ឬ ៩រូប តាមករណីជាក់ស្តែងនីមួយៗ។ បើក្នុងករណីក្នុងសេចក្តីសម្រេចនោះត្រូវបានគេប្តឹងអំពីកំហុសវិន័យ ហើយក្រុមប្រឹក្សាវិន័យបានរកឃើញថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនោះបានប្រព្រឹត្តកំហុសវិន័យមែន។ ប៉ុន្តែ នៅក្នុងការសម្រេចសេចក្តីនោះ មានចៅក្រមប្រឹក្សាម្នាក់បានអះអាងថាខ្លួនមិនបានចូលរួមប្រព្រឹត្តកំហុសនោះទេ និងបានបង្ហាញភស្តុតាងច្បាស់លាស់ដែលអាចជឿជាក់បាន។ តើចៅក្រមប្រឹក្សាម្នាក់នោះ គួរត្រូវទទួលទណ្ឌកម្មវិន័យដូចគ្នាដែរឬទេ?

ជាគោលការណ៍ សេចក្តីសម្រេចអំពីវិន័យរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំពោះចៅក្រម ឬព្រះរាជអាជ្ញាណាម្នាក់ មិនអាចត្រូវបានប្រកាសផ្សព្វផ្សាយជាសាធារណៈ ដោយមានបញ្ជាក់ឈ្មោះចៅក្រម ឬព្រះរាជអាជ្ញាទេ។ ប៉ុន្តែ ដើម្បីផលប្រយោជន៍នៃការទទួលព័ត៌មានសម្រាប់សាធារណជន ការផ្សព្វផ្សាយនេះគួរតែផ្សព្វផ្សាយត្រឹមអង្គហេតុនៃបណ្តឹង សំអាងហេតុ និងការសម្រេចតែប៉ុណ្ណោះ ដោយមិនគួរបង្ហាញអត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធទាំងអស់នោះទេ។

22. មាត្រា ៧៥ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

# បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងព្រហ្មទណ្ឌ

ដោយៈ

-ឯកឧត្តម **ម៉ុង មុនីចរិយា** ប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ

-លោក **ឆុន ករុណា** សមាជិកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

នៅក្នុងរឿងក្តីព្រហ្មទណ្ឌ បណ្តឹងត្រូវបានបែងចែកជា ២ ប្រភេទ គឺបណ្តឹងអាជ្ញា (ឬបណ្តឹងព្រហ្មទណ្ឌ) និងបណ្តឹងរដ្ឋប្បវេណី។ យោងតាមមាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់និយមន័យបណ្តឹងអាជ្ញាថា ជាបណ្តឹងដែល "មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់"។ ផ្អែកតាមមាត្រា១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញ "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា"។ យោងតាមមាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ "បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ"។ ក្នុងន័យនេះ បណ្តឹងអាជ្ញាអាចដាក់ឱ្យដំណើរការទៅបាន លុះត្រាតែមានបណ្តឹងពីស្ថាប័នអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ច។ រីឯបណ្តឹងរដ្ឋប្បវេណី មានគោលបំណងទាមទារឱ្យមានការជួសជុលព្យសនកម្ម (ការខូចខាត) ខាងសម្ភារៈ រូបកាយ ឬផ្លូវចិត្ត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ដែលជាយុត្តិសាស្ត្រភាគីរងគ្រោះអាចទទួលបានសំណងជំងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួលរង។ បណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងដោយជនរងគ្រោះ ឬដោយអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ឬសិទ្ធិវន្តរបស់ជនរងគ្រោះ។ ក្នុងន័យនេះ ថាតើបណ្តឹងរបស់ភាគីរងគ្រោះ ឬតំណាងឱ្យជនរងគ្រោះដែលសិទ្ធិមូលដ្ឋានរបស់ខ្លួន អាចទាមទារត្រឹមតែសំណងខូចខាត ឬសំណងព្យសនកម្មនោះ មានភាពជាប់ពាក់ព័ន្ធយ៉ាងណាជាមួយបណ្តឹងអាជ្ញាដែលត្រូវអនុវត្តដោយអង្គការអយ្យការ? ថ្វីត្បិតតែបណ្តឹងអាជ្ញាត្រូវអនុវត្តដោយព្រះរាជអាជ្ញាពិតមែន ក៏ភាគីជនរងគ្រោះមានកាតព្វកិច្ចគាំទ្រការអនុវត្តបណ្តឹងអាជ្ញាដែរ ដែលក្នុងនោះមានដូចជា ការស្នើសុំឱ្យមានការចោទប្រកាន់ ការចូលរួមស្រាវជ្រាវ និងស្វែងរកភស្តុតាងដាក់បន្ទុក រួមទាំងសំណូមពរឱ្យតុលាការសម្រេចផ្តន្ទាទោសជនល្មើសចំពោះអំពើល្មើសណាមួយដែលជននោះបានប្រព្រឹត្ត និងទាមទារសំណងព្យសនកម្មដែលខ្លួនបានទទួលរងដោយសារអំពើល្មើសនោះ ជាអាទិ៍។ ម្យ៉ាងទៀត បណ្តឹងរដ្ឋប្បវេណីក៏មានតម្លៃជាពាក្យប្តឹងបរិហារពីអំពើល្មើសដែលច្បាប់ព្រហ្មទណ្ឌបានកំណត់ ប៉ុន្តែ ទោះជាយ៉ាងណាបណ្តឹងនេះមិនមានអានុភាពនាំឱ្យបណ្តឹងអាជ្ញាចាប់ផ្តើមដំណើរការដោយស្វ័យប្រវត្តិនោះទេ។ ពាក្យប្តឹងបរិហារពីអំពើល្មើសនេះ អាចធ្វើទៅមន្ត្រីនគរបាលយុត្តិធម៌ ឬទៅព្រះរាជអាជ្ញាអមសាលាដំបូងដែលមានសមត្ថកិច្ច។ ជាទូទៅ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានធ្វើឡើងក្នុងពេលជាមួយគ្នានឹងបណ្តឹងអាជ្ញា នៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌ។ បណ្តឹងរដ្ឋប្បវេណីនេះ ក៏អាចធ្វើឡើងនៅចំពោះមុខយុត្តាធិការរដ្ឋប្បវេណីបានផងដែរ ប៉ុន្តែក្នុងករណីនេះ ដូចមានបញ្ញត្តក្នុងមាត្រា ២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងរដ្ឋប្បវេណីត្រូវព្យួរសិន ដរាបណាមិនទាន់មានសេចក្តីសម្រេចស្ថាពរណាមួយត្រូវបានប្រកាសចំពោះបណ្តឹងអាជ្ញា[1]។ ទាក់ទងនឹងការព្យួរការដោះស្រាយលើបណ្តឹងរដ្ឋប្បវេណីដូចខាងដើមនេះ មិនមានចែងច្បាស់លាស់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនោះឡើយ។

នៅពេលទទួលបានពាក្យប្តឹង ឬពាក្យបរិហារអំពីបទល្មើសណាមួយ, តំណាងអយ្យការអមសាលាដំបូង អាចអនុវត្តនូវជម្រើសចំនួន ២ គឺ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ តំណាងអយ្យការត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការតាមរយៈការចេញនូវដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ដោយត្រូវមានសំអាងហេតុ និងសំអាងច្បាប់ច្បាស់លាស់ ប្រសិនបើតំណាងអយ្យការយល់ឃើញថាអំពើដែលត្រូវបានប្តឹងមិនមែនជាបទល្មើសព្រហ្មទណ្ឌ ដោយសារមិនមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ឬនៅពេលដែលអំពើល្មើសនោះបានផុតអាជ្ញាយុកាលនៃបទល្មើសតាមកំណត់ច្បាប់។ ដោយឡែក ក្នុងករណីដែលតំណាងអយ្យការពិនិត្យឃើញថា មានតម្រុយនៃបទល្មើស ឬមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់ពីអត្ថិភាពនៃបទល្មើស តំណាងអយ្យការអាចសម្រេចធ្វើបណ្តឹងអាជ្ញា ដោយធ្វើការចោទប្រកាន់ជនសង្ស័យពីបទព្រហ្មទណ្ឌណាមួយ។ ផ្អែកតាមមាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ អាចធ្វើទៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬទៅចំពោះមុខយុត្តាធិការជំនុំជម្រះ[2] តាមវិធី ៣ យ៉ាងរួមមាន៖ ការបើកធ្វើការស៊ើបសួរ, ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬតាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ ចំពោះបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ[3]។

ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន, ចំពោះករណីដែលព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមិនសុខចិត្តនឹងការសម្រេច

1. មាត្រា ២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

2. គោលការណ៍នេះ ក៏ត្រូវបានកំណត់ផងដែរនៅក្នុងមាត្រា ៧៤ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

3. មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបនេះទេ នោះដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិធ្វើបណ្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីស្នើសុំឱ្យមានការពិនិត្យឡើងវិញអំពីការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ឬស្នើសុំឱ្យធ្វើអធិបញ្ញាទៅព្រះរាជអាជ្ញាឱ្យធ្វើការចោទប្រកាន់ឡើងវិញ ឬ ប្ដឹងសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ *(១)* ដើម្បីស្នើសុំឱ្យធ្វើអធិបញ្ញាចោទប្រកាន់[4]។ លើសពីនេះ ច្បាប់ក៏បានកំណត់ច្បាស់លាស់ផងដែរថា ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការធ្វើប្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ *(២)* តាមមាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដោយឡែក សិទ្ធិក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសាលក្រមព្រហ្មទណ្ឌដែលសម្រេចផ្ដន្ទាទោសជនជាប់ចោទ ឬក៏សម្រេចឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ ដោយមិនមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញា ឬពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ច គឺជាបញ្ហាដ៏ចម្រូងចម្រាសផ្នែកច្បាប់មួយ ដែលការអនុវត្តនៅមិនទាន់មានសង្គតិភាពរវាងសាលាជម្រះក្ដីនានា *(៣)* ទាំងនៅសាលាជម្រះក្ដីជាន់ខ្ពស់ និងសាលាជម្រះក្ដីជាន់ទាប។

## ១-បណ្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចរបស់តំណាងអយ្យការ

ដូចបានគូសបញ្ជាក់ពីខាងដើម បន្ទាប់ពីទទួលបានពាក្យប្ដឹង ឬពាក្យបរិហារដែលខ្លួនទទួលបានដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក, ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្ដឹង ឬពាក្យបរិហារនោះ។ ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម។ ក្នុងករណីដែលតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្ដឹង។ ក្នុងករណីមិនសុខចិត្តជាមួយនឹងការសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា, ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិប្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីស្នើសុំឱ្យមានការពិនិត្យឡើងវិញលើការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ឬស្នើសុំឱ្យអគ្គព្រះរាជអាជ្ញាធ្វើអធិបញ្ញាទៅព្រះរាជអាជ្ញាឱ្យធ្វើការចោទប្រកាន់។ ការប្ដឹងតវ៉ានេះ ត្រូវធ្វើក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ការតវ៉ានេះត្រូវធ្វើតាមបណ្ដឹងសាមញ្ញនៅអង្គការអយ្យការពាក់ព័ន្ធ។ ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ពិនិត្យឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ, អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់។ ផ្ទុយទៅវិញ បើយល់ឃើញថា ការប្ដឹងតវ៉ានេះគ្មានមូលហេតុត្រឹមត្រូវទេ នោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចសម្រេចតម្កល់សេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការដដែល។ សេចក្ដីសម្រេចរបស់អគ្គព្រះរាជអាជ្ញាចំពោះករណីក្រោយនេះ ត្រូវតែជូនដំណឹងដល់អ្នកប្ដឹងតវ៉ា។ អ្នកប្ដឹងតវ៉ាមិនមានសិទ្ធិប្ដឹងតវ៉ាបន្តទៀតទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលទៀតនោះទេ។ ប៉ុន្តែ ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីអាចដាក់ពាក្យបណ្ដឹងសាជាថ្មីបាន ប្រសិនបើមានភស្តុតាងថ្មី ដោយហេតុថា ការសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការគ្មានអាជ្ញាអស់ជំនុំនោះទេ[5]។ ព្រះរាជអាជ្ញាក៏អាចសើរើកែប្រែសេចក្ដីសម្រេចរបស់ខ្លួនឡើងវិញបានផងដែរ ក្នុងករណីដែលបណ្ដឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ[6]។

ម្យ៉ាងទៀត ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី ក៏អាចធ្វើបណ្ដឹងសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឱ្យធ្វើអធិបញ្ញាទៅព្រះរាជអាជ្ញា ឬទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឱ្យធ្វើការចោទប្រកាន់ជនល្មើសបានផងដែរ[7]។ លើសពីនេះ យោងតាមមាត្រា ៧៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា បានបញ្ញត្តថា អង្គការអយ្យការជាអង្គឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ដែលអាចចេញអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ សិទ្ធិអំណាចក្នុងការធ្វើអធិបញ្ញារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នេះ ត្រូវបានកំណត់ផងដែរនៅក្នុងមាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងថា “រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ញា តាមការណែនាំជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់បញ្ចូលក្នុងសំណុំរឿងឱ្យទៅអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ ប៉ុន្តែ រដ្ឋមន្ត្រី

---

4. មាត្រា ២៩ និងមាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

5. មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

6. មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

7. មាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាឱ្យតម្កល់ទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ"។

## ២-បណ្តឹងឧទ្ធរណ៍ចំពោះការសម្រេចរបស់ចៅក្រមស៊ើបសួរ

ការស៊ើបសួរ ត្រូវបានបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។ ប៉ុន្តែ ចំពោះករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាចធ្វើក៏បាន ឬមិនធ្វើក៏បាន ក្នុងន័យថា អាចអនុវត្តតាមមធ្យោបាយ ៣ យ៉ាងគឺៈ (១)-បើកការស៊ើបសួរ, (២)-បញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ ឬ (៣)-បង្គាប់ឱ្យជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម។ រីឯចំពោះបទលហុ ព្រះរាជអាជ្ញាត្រូវអនុវត្តនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់[8]។ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះបានឡើយ។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ។ ក្នុងករណីដែលមានលេចចេញនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ នោះចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនេះទៅព្រះរាជអាជ្ញា។ ចំពោះករណីនេះ ព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យធ្វើការស៊ើបសួរលើអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញាទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ លើកលែងតែអង្គហេតុថ្មីនោះគ្រាន់តែជាស្ថានទម្ងន់ទៅលើអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូងតែប៉ុណ្ណោះ[9]។

ក្នុងការបំពេញកិច្ចស៊ើបសួរនេះ ចៅក្រមស៊ើបសួរត្រូវស្វែងរកទាំងភស្តុតាងដាក់បន្ទុក ទាំងភស្តុតាងដោះបន្ទុក សំដៅបង្ហាញឱ្យឃើញការពិតចំពោះអង្គហេតុដែលបានកើតឡើង។ នៅពេលបញ្ចប់ការស៊ើបសួរ ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ ដែលអាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬជាដីកាលើកលែងចោទប្រកាន់[10]។

8. មាត្រា ៤៤, មាត្រា ៤៥, មាត្រា ៤៩ និងមាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

9. មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

10. មាត្រា ២៤៧ ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



- **ករណីបញ្ជូនរឿងទៅជំនុំជម្រះៈ** ចៅក្រមស៊ើបសួរអាចសម្រេចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងករណីដែលខ្លួនយល់ថា អំពើនោះជាបទឧក្រិដ្ឋ, បទមជ្ឈិម ឬជាបទលហុ។ ការបញ្ជូនរឿងទៅជំនុំជម្រះ ក៏អាចធ្វើឡើងបានចំពោះអំពើមួយចំនួន និងអាចលើកលែងចោទប្រកាន់ចំពោះអំពើមួយចំនួនដទៃទៀតបានផងដែរ។

- **ករណីលើកលែងការចោទប្រកាន់ៈ** ប្រសិនបើចៅក្រមស៊ើបសួរ យល់ឃើញថាអង្គហេតុដែលត្រូវបានចោទប្រកាន់ មិនមានមូលដ្ឋានគ្រប់គ្រាន់នោះទេ ចៅក្រមស៊ើបសួរអាចសម្រេចចេញដីកាលើកលែងចោទប្រកាន់។ យោងតាមកថាខណ្ឌទី៣ នៃមាត្រា ២៤៧ ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដីកាលើកលែងចោទប្រកាន់នេះអាចធ្វើបានក្នុងករណីចំនួន ៤ គឺៈ (១)-កាលបើអំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ, (២)-ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់, (៣)-គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ និង (៤)-ការសម្រេចលើកលែងការចោទប្រកាន់ក៏អាចធ្វើទៅបានក្នុងករណីដែលបណ្តឹងអាជ្ញារលត់ ដូចដែលមានកំណត់នៅក្នុងមាត្រា ៧ និងមាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[11]។ ដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរដែលចូលជាស្ថាពរមិនមានអានុភាពរំលត់បណ្តឹងអាជ្ញានោះទេ។ ផ្អែកតាមមាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ក្រោយពេលដែលដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរបានចូលជាស្ថាពរ, ប្រសិនបើមានលេចឡើងបន្ទុកថ្មី ការស៊ើបសួរអាចបើកឡើងវិញបាន តាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា។

ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរចំពោះករណីទាំងពីរខាងលើនេះ ត្រូវតែមានសំអាងហេតុ។ ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ផ្អែកតាមមាត្រា ២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះ

11. ហេតុដែលមានចែងក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ រួមមានៈ (១)-មរណភាពនៃជនល្មើស, (២)-ការផុតអាជ្ញាយុកាល, (៣)-ការលើកលែងទោសជាទូទៅ, (៤)-និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ, (៥)-អាជ្ញាអស់ជំនុំ និងហេតុដែលមានចែងក្នុងមាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ រួមមានៈ (១)-ដោយការសម្របសម្រួលជាមួយរដ្ឋ, (២)-ដោយដោយការដកពាក្យបណ្តឹង ក្នុងករណីពាក្យបណ្តឹងជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ និង (៣)-ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។

គ្រប់ដីកាសម្រេចទាំងអស់របស់ចៅក្រមស៊ើបសួរ។ បណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយត្រូវធ្វើឡើងក្នុងរយៈពេលកំណត់ ដូចខាងក្រោម៖

- រយៈពេល ១ ខែយ៉ាងយូរ គិតពីពេលប្រកាសដីកា សម្រាប់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

- រយៈពេល ៥ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងពីដីកានេះ សម្រាប់ព្រះរាជអាជ្ញា និងរយៈពេល ៥ ថ្ងៃ ដូចគ្នា គិតចាប់ពីថ្ងៃជូនដំណឹងពីដីកានេះ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ ករណីការប្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ មានកំណត់ក្នុងមាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងនោះក៏រួមមានដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរផងដែរ។

ប្រសិនបើការជូនដំណឹងនេះធ្វើឡើងដោយការប្រគល់សេចក្តីចម្លងនៃដីកាដោយមានចំណារទទួល នោះរយៈពេលបណ្តឹងឧទ្ធរណ៍ផ្តើមគិតចាប់ពីកាលបរិច្ឆេទនៃចំណារទទួលនោះ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វេសប្រហែសបានឡើយ ប្រសិនបើមានបំណងប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ពីព្រោះ រយៈពេលធ្វើបណ្តឹងឧទ្ធរណ៍នេះត្រូវបានកំណត់ត្រឹមតែ ៥ ថ្ងៃប៉ុណ្ណោះ គិតពីការជូនដំណឹងពីដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ។ បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងក្រៅកាលកំណត់នេះ នឹងត្រូវបានប្រកាសថាមិនអាចទទួលយកបានដោយសភាស៊ើបសួរ ស្របតាមបញ្ញត្តិនៃមាត្រា ២៧០ និងមាត្រា ៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ៣-បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសាលក្រមព្រហ្មទណ្ឌ

ជាគោលការណ៍ច្បាប់, តុលាការអាចសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណាដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម ហើយតុលាការអាចជំនុំជម្រះតែលើបុគ្គលដែលត្រូវបានបញ្ជូនទៅចំពោះមុខខ្លួនក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ។ ប្រសិនបើពិនិត្យឃើញថាមានពិរុទ្ធភាពលើជនជាប់ចោទ ក្នុងអំពើដែលត្រូវបានចោទប្រកាន់ នោះតុលាការសម្រេចប្រកាស



ផ្តន្ទាទោសលើជនចាប់ចោទតាមបញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាធរមាន។ ដោយឡែក ប្រសិនបើតុលាការយល់ឃើញថា អំពើដែលត្រូវបានចោទប្រកាន់មិនមែនជាបទល្មើស ឬក៏ជនជាប់ចោទគ្មានកំហុសទេ នោះតុលាការត្រូវសម្រេចឱ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់។ ផ្អែកតាមមាត្រា ២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, តុលាការព្រហ្មទណ្ឌអាចសម្រេចឱ្យមានការជួសជុលព្យសនកម្ម (ការខូចខាត) បាន លុះត្រាតែបានពិនិត្យជាមុនអំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ហើយបានប្រកាសថាជនជាប់ចោទត្រូវមានពិរុទ្ធជាមុនសិន។ ប៉ុន្តែ តុលាការព្រហ្មទណ្ឌតែងតែមិនសម្រេចអំពីសំណងរដ្ឋប្បវេណីទេ នៅពេលដែលតុលាការសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់។

ផ្អែកតាមមាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលក្រមព្រហ្មទណ្ឌអាចត្រូវបានប្តឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញាអមសាលាដំបូង, អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍, ពិរុទ្ធជន, ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ចំពោះរយៈពេលនៃបណ្តឹងឧទ្ធរណ៍នេះត្រូវបានកំណត់ដូចខាងក្រោម៖

- រយៈពេល ១ ខែសម្រាប់ព្រះរាជអាជ្ញាអមសាលាដំបូង និង

- រយៈពេល ៣ ខែសម្រាប់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយគិតរាប់ពីថ្ងៃប្រកាសសាលក្រម និង

- រយៈពេល ១ ខែសម្រាប់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី ដោយគិតចាប់ពីថ្ងៃប្រកាសសាលក្រម ចំពោះសាលក្រមចំពោះមុខ ឬគិតចាប់ពីថ្ងៃទទួលដំណឹងពីសាលក្រម ចំពោះសាលក្រមចាត់ទុកថាចំពោះមុខ ឬគិតរាប់ពីថ្ងៃផុតរយៈពេលនៃបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។

ដោយហេតុថា អង្គការអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា ដូច្នេះការសម្រេចប្តឹងឧទ្ធរណ៍ចំពោះសាលក្រមត្រង់ចំណុចនៃសេចក្តីសម្រេចដែលពាក់ព័ន្ធនឹងការប្រកាសផ្តន្ទាទោស ឬការប្រកាសឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ គឺជាសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា ឬរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬអង្គការអយ្យការអនុវត្តសិទ្ធិប្តឹងឧទ្ធរណ៍តាមអធិបញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ដោយឡែក បណ្តឹង

ឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើទៅបានតែចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណីតែប៉ុណ្ណោះ នេះបើយោងតាមមាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ប៉ុន្តែ យោងតាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនសុខចិត្តនឹងទោសដែលប្រកាសដោយតុលាការព្រហ្មទណ្ឌ ឬមិនសុខចិត្តនឹងសាលក្រមដែលសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ តែងធ្វើការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌទាំងមូលតែម្តង ដោយមិនផ្តោតតែចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណីតែប៉ុណ្ណោះនោះទេ។ តើតាមច្បាប់ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ចំពោះចំណុចទាំងមូលនៃសាលក្រមព្រហ្មទណ្ឌបានដែរឬទេ *(ក)?* តើសាលាឧទ្ធរណ៍ត្រូវចាត់ការបែបណាចំពោះបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងករណីដែលគ្មានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ *(ខ)?* ទាំងនេះជាបញ្ហាផ្លូវច្បាប់ដែលមានការខ្វែងគំនិតគ្នាក្នុងការអនុវត្តនាពេលកន្លងមក។

### ក-មូលដ្ឋានគតិយុត្តនៃសិទ្ធិប្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសាលក្រមព្រហ្មទណ្ឌ

ផ្អែកតាមមាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ជនរងគ្រោះ។ អំពើល្មើសដែលត្រូវបានប្រព្រឹត្ត គឺជាអំពើអនីត្យានុកូលដែលអាចបង្កជាព្យសនកម្មដល់ជនរងគ្រោះ។ យោងតាមមាត្រា ២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ជនរងគ្រោះអាចធ្វើបណ្តឹងរដ្ឋប្បវេណីក្នុងពេលជាមួយគ្នានឹងបណ្តឹងអាជ្ញានៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌ ឬអាចធ្វើជាបណ្តឹងដោយឡែកចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណីក៏បានដែរ។ ហេតុដូចនេះ ប្រសិនបើបណ្តឹងរដ្ឋប្បវេណីត្រូវបានសាលាដំបូងសម្រេចបដិសេធចោល ឬបានសម្រេចមិនត្រូវតាមការប្តឹងសុំរបស់ខ្លួនទេ នោះដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។ សិទ្ធិប្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ត្រូវបានកំណត់ក្នុងមាត្រា ៣៧៥ និងមាត្រា ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលផ្អែកតាមបទបញ្ញត្តិទាំងនេះ បានកំណត់ថា "បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើទៅបានតែលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណី" តែប៉ុណ្ណោះ[12]។ ក្នុងន័យនេះ តាមការអនុវត្ត មានសេចក្តីវិនិច្ឆ័យមួយចំនួនបានចាត់ទុកថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចផ្នែកព្រហ្មទណ្ឌបាននោះទេ។ ប៉ុន្តែ ក៏មានសេចក្តីវិនិច្ឆ័យមួយចំនួនបានសម្រេចទទួលយកបណ្តឹងឧទ្ធរណ៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ចំពោះករណីសាលក្រមរបស់សាលាដំបូងដែលសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ដែរ ដោយផ្អែកលើហេតុផលថាការឱ្យរួចផុតពីបទចោទប្រកាន់ គឺបានប៉ះពាល់ដល់ប្រយោជន៍ផ្នែករដ្ឋប្បវេណី។ នៅក្នុងសាលដីកាព្រហ្មទណ្ឌលេខ ២៨៣ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ តុលាការកំពូល យល់ឃើញថា "*ទោះបីជាមិនមានបណ្តឹងសាទុក្ខរបស់អង្គការអយ្យការដែលជាម្ចាស់បណ្តឹងអាជ្ញាចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទក៏ដោយ ក៏ភាពជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទជាមូលដ្ឋានសម្រាប់ធ្វើការវិនិច្ឆ័យអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី គប្បីទទួលយកបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីមកធ្វើជាមូលដ្ឋានក្នុងការពិនិត្យលើពិរុទ្ធភាពរបស់ជនជាប់ចោទ*"[13]។ ដូចគ្នាផងដែរ នៅក្នុងសាលាដីកាលេខ ២៧២ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥, តុលាការកំពូលយល់ឃើញថា "តាមមាត្រា ២, មាត្រា ១៣, មាត្រា ១៤, មាត្រា ២៣ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថាបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងអាជ្ញាជាបណ្តឹងពីរផ្សេងគ្នាដែលបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធតែផលប្រយោជន៍រដ្ឋប្បវេណី ហើយតុលាការអាចប្រកាសអំពីសំណងរដ្ឋប្បវេណីបានលុះត្រាតែប្រកាសជាមុនអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ "*ដូច្នេះ បណ្តឹងសាទុក្ខរបស់ឈ្មោះ X ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនាពេលនេះ គឺមានអានុភាពឱ្យតុលាការកំពូលពិចារណាតែលើផលប្រយោជន៍រដ្ឋប្បវេណីប៉ុណ្ណោះ ក្រោយពិនិត្យជាមុនអំពីពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ Y*"[14]។ មួយវិញទៀត ក៏មានការយល់ឃើញផងដែរថា ការសម្រេចបដិសេធមិនចាត់ការលើបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសារមិនមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ឬរបស់អគ្គព្រះរាជអាជ្ញានោះ គឺជាការធ្វើឱ្យប៉ះពាល់ទៅដល់សិទ្ធិរបស់ជនរងគ្រោះ និងមិនស្របតាមគោលការណ៍នៃការរៀបចំរចនាសម្ព័ន្ធតុលាការនៅកម្ពុជា

12. មាត្រា ៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ក៏បានបញ្ញត្តដូចគ្នានេះផងដែរថា "ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ចំពោះផ្នែករដ្ឋប្បវេណី"។
13. សាលដីកាព្រហ្មទណ្ឌលេខ ២៨៣ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ របស់តុលាការកំពូល។
14. សាលដីកាលេខ ២៧២ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ របស់តុលាការកំពូល។

ដែលកំណត់ឱ្យមានសាលាជម្រះក្ដីជាន់ទាប និងសាលាជម្រះក្ដីជាន់ខ្ពស់ និងដែលអនុញ្ញាតឱ្យជនរងគ្រោះ ឬដើមបណ្ដឹង រដ្ឋប្បវេណី អាចប្ដឹងឧបាស្រ័យទៅសាលាជម្រះក្ដីជាន់ខ្ពស់បាននោះឡើយ។

## ខ-ចំណាត់ការរបស់តុលាការដែលទទួលបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី

ក្នុងការអនុវត្តជាក់ស្ដែងកន្លងមក នៅពេលដែលគ្មានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ឬរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍, សាលាឧទ្ធរណ៍ភាគច្រើនតែងតែសម្រេចមិនទទួលយកបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយចាត់ទុកថាបណ្ដឹងនេះជាបណ្ដឹងដែលធ្វើឡើងក្នុងលក្ខខណ្ឌមិនត្រឹមត្រូវ ដូចបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ៤០៤ (បណ្ដឹងឧទ្ធរណ៍ដែលមិនអាចទទួលយកបាន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយហេតុថា៖ (១)-ជាទូទៅ ដើមបណ្ដឹងរដ្ឋប្បវេណីតែងតែប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌទាំងមូលតែម្ដងដោយមិនប្ដឹងឧទ្ធរណ៍ដោយផ្ដោតតែលើផ្នែករដ្ឋប្បវេណីនោះទេ, (២)-មានតែព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទេដែលមានសិទ្ធិប្ដឹងលើផ្នែកនៃសាលក្រមដែលពាក់ព័ន្ធនឹងការផ្ដន្ទាទោស ឬការសម្រេចឱ្យរួចផុតពីបទចោទប្រកាន់នេះ និង (៣)-ផ្អែកតាមមាត្រា ២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, តុលាការព្រហ្មទណ្ឌនឹងអាចសម្រេចការជួសជុលព្យសនកម្មបាន លុះត្រាតែបានពិនិត្យជាមុនអំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ហើយបានប្រកាសថា ជនត្រូវចោទត្រូវមានពិរុទ្ធជាមុនសិន។ ប៉ុន្តែ ក៏មានទស្សនៈផ្សេងយល់ថា ការសម្រេចបែបនេះគឺមិនទាន់ត្រឹមត្រូវទាំងស្រុងនោះទេ ដោយហេតុថា ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានកំណត់ឱ្យមានករណីដែលតុលាការព្រហ្មទណ្ឌអាចសម្រេចអំពីសំណងរដ្ឋប្បវេណី ដោយមិនសម្រេចអំពីការផ្ដន្ទាទោសនោះទេ នៅពេលដែលតុលាការពិនិត្យឃើញមានអំពើល្មើស[15]។ ជាក់ស្ដែង មាត្រា ២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

15. ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ត្រង់មាត្រា៤៧០-១ កថាខណ្ឌទី១ ក៏បានកំណត់ឱ្យមានករណីដែលតុលាការអាចសម្រេចលើសំណងរដ្ឋប្បវេណីដោយផ្អែកលើវិធាននៃច្បាប់រដ្ឋប្បវេណីផងដែរ បើទោះបីជាតុលាការបានប្រកាសឱ្យជនជាប់ចោទរួចខ្លួនពីបទល្មើសអចេតនាក៏ដោយ។ មាត្រា៤៧០-១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង“Le tribunal saisi, à l'initiative du ministère public ou sur renvoi d'une juridiction d'instruction, de poursuites exercées pour une infraction non intentionnelle au sens des deuxième, troisième et quatrième alinéas de l'article 121-3 du code pénal, et qui prononce une relaxe demeure compétent, sur la demande de la partie civile ou de son assureur formulée avant la clôture des débats, pour accorder, en application des règles du droit civil, réparation de tous les dommages résultant des faits qui ont fondé la poursuite.”។



កំណត់ថា *“ដើមបណ្ដឹងរដ្ឋប្បវេណី អាចសុំឱ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនេះទទួលមរណភាពនៅក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌ។ ថ្វីត្បិតតែបណ្ដឹងអាជ្ញាត្រូវរលត់ តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ច ដើម្បីសម្រេចលើបណ្ដឹងរដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តទាំងនោះ”*។ ទន្ទឹមនេះ ការសម្រេចបែបនេះក៏មិនស្របនឹងយុត្តិសាស្ត្ររបស់តុលាការកំពូល នៅក្នុងសាលដីកាព្រហ្មទណ្ឌលេខ ២៨៣ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ របស់តុលាការកំពូល និងសាលាដីកាព្រហ្មទណ្ឌលេខ ២៧២ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ របស់តុលាការកំពូល ដូចបានបញ្ជាក់ក្នុងចំណុចខាងលើនោះដែរ។

ដោយពិនិត្យឃើញពីភាពមិនចុះសម្រុងគ្នាក្នុងការអនុវត្តចំពោះករណីនេះ មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត ដែលត្រូវបានរៀបចំឡើងកាលពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ និងមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ ថ្នាក់ដឹកនាំសាលាជម្រះក្ដី និងអយ្យការអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ ព្រមទាំងចៅក្រម និងព្រះរាជអាជ្ញានៅទូទាំងប្រទេស បានលើកចំណុចពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសាលក្រម ឬសាលដីកាក្នុងរឿងព្រហ្មទណ្ឌ មកធ្វើជាប្រធានបទមួយនៃកិច្ចពិភាក្សា។ ឆ្លងកាត់ការពិភាក្សាយ៉ាងផុសផុល អង្គមហាសន្និបាត បានសម្រេចថា *“ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការធ្វើបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសាទុក្ខបានស្របតាមមាត្រា ២, មាត្រា ២២, មាត្រា ២៣, មាត្រា ២៤, មាត្រា ៣៥០, មាត្រា ៣៧៥, មាត្រា ៤០២ និង មាត្រា ៤១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានានូវសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ក្នុងការទាមទារសំណងជំងឺចិត្តចំពោះព្យសនកម្មដែលខ្លួនបានទទួលរង ប៉ុន្តែបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខនេះមានអានុភាពតែទៅលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីប៉ុណ្ណោះ។ ក្នុងករណីដែលពុំមានបណ្ដឹងឧទ្ធរណ៍របស់អយ្យការអមសាលាដំបូង ឬមហាអយ្យការអមសាលាឧទ្ធរណ៍, តុលាការដែលទទួលបណ្ដឹងឧទ្ធរណ៍តែពីដើមបណ្ដឹងរដ្ឋប្បវេណី អាចសម្រេចបានតែអំពីសំណងរដ្ឋប្បវេណីប៉ុណ្ណោះ ក្នុងករណីពិនិត្យឃើញមានកំហុសរបស់ជនជាប់ចោទ ប៉ុន្តែ តុលាការមិនអាចសម្រេចអំពីការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌបានឡើយ។ ករណីនេះត្រូវអនុវត្តដូចគ្នាផងដែរចំពោះបណ្ដឹង*

*សាទុក្ខ*[16]”។ ផ្អែកលើការសម្រេចនេះ ក្នុងការចាត់ការលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី, សាលាឧទ្ធរណ៍អាចកត់សម្គាល់ពីអត្ថិភាពនៃបទល្មើសនៅក្នុងសំអាងហេតុ ហើយសម្រេចអំពីសំណងរដ្ឋប្បវេណីដើម្បីជួសជុលព្យសនកម្មដែលបង្កឡើងដោយអំពីល្មើសនេះ ប៉ុន្តែ សាលាឧទ្ធរណ៍មិនអាចសម្រេចផ្តន្ទាទោសជនជាប់ចោទបាននោះទេនៅពេលដែលមិនមានបណ្តឹងឧទ្ធរណ៍របស់អយ្យការ ឬរបស់មហាអយ្យការអមសាលាឧទ្ធរណ៍។ ឈរលើមូលដ្ឋាននៃសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតវិស័យយុត្តិធម៌នេះ សាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចទទួលបណ្តឹងទាស់របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងសភាព្រហ្មទណ្ឌលេខ ១១២១/១៣-០៩-២០២៣ និងបានចេញសាលាដីកាលេខ ៥៩ ក្រ IV “យ” ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០២៤ ដោយបានសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៦ ក្រ VI “យ” ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០២៣ ដែលសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២០៧២ “ទ” ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ ដោយសំអាងថាពុំមានធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែ សាលាឧទ្ធរណ៍បានសម្រេចឱ្យជនជាប់ចោទសងសំណងជំងឺចិត្តទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី[17]។

16. សេចក្តីសម្រេចចិត្តមហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ ដែលត្រូវបានចុះហត្ថលេខារួមគ្នាដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឯកឧត្តមប្រធានតុលាការកំពូល និងលោកជំទាវអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល។

17. សភាព្រហ្មទណ្ឌនៃតុលាការកំពូលបារាំងបានសម្រេចតម្កល់សាលដីកាចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ Saint-Denis de la Réunion បានសម្រេចឱ្យជនជាប់ចោទរួចខ្លួនពីបទចោទ (បទរំលោភលើទំនុកចិត្ត) ដោយសំអាងថាគ្មានធាតុផ្សំអត្តនោម័ត ប៉ុន្តែតុលាការបានសម្រេចឱ្យជនជាប់ចោទសងសំណងរដ្ឋប្បវេណីទៅដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើអង្គហេតុនៃការចោទប្រកាន់។ (សាលដីកាសភាព្រហ្មទណ្ឌនៃតុលាការកំពូលបារាំង ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ លើបណ្តឹងសាទុក្ខលេខ ១២-៨០.១៥៤ “Qu'en effet, le dommage dont la partie civile, seule appelante d'un jugement de relaxe, peut obtenir réparation de la part de la personne relaxée résulte de la faute civile démontrée à partir et dans la limite des faits objet de la poursuit ;”)។



# ការឱ្យដំណឹងអំពីសេចក្តីសម្រេចតុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ

ដោយ៖
--ឯកឧត្តម **គង់ តារាឆាត** ចៅក្រមតុលាការកំពូល
-ឯកឧត្តម **ហេង សុខណា** នាយកសាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា

“កិច្ចដំណើរការល្អនៃយុត្តិធម៌ព្រហ្មទណ្ឌ” គឺជាគោលបំណងដ៏សំខាន់មួយរបស់វិធាននៃនីតិវិធីព្រហ្មទណ្ឌដើម្បីធានានូវ “សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយសមធម៌” ដែលត្រូវបានទទួលស្គាល់ និងការពារសម្រាប់ពលរដ្ឋគ្រប់រូប ដោយសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ផ្អែកតាមមាត្រា ១០ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស, សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយសមធម៌ សំដៅដល់សិទ្ធិស្នើសុំឱ្យតុលាកាដែលរងករាជ្យ និងមិនលម្អៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ។ សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយសមធម៌នេះនៅក្នុងរឿងព្រហ្មទណ្ឌ គ្របដណ្តប់ទាំងលើ “សិទ្ធិ និងកាតព្វកិច្ច” នៅក្នុងរឿងរដ្ឋប្បវេណី និងលើ “ការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ”។ មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានបញ្ជាក់បន្ថែមពីវិសាលភាពនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកប ដោយសមធម៌នេះ ដោយផ្តោតទាំងចំពោះការសម្រេចលើការចោទប្រកាន់ក្នុងសំណុំរឿងព្រហ្មទណ្ឌ ទាំងចំពោះការសម្រេចលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី។

ការធានាការពារនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយសមធម៌នេះ ទាមទារឱ្យមានការគោរពនូវសិទ្ធិ ឬគោលការណ៍ជាមូលដ្ឋានសំខាន់មួយចំនួន ជាពិសេស សិទ្ធិពឹងពាក់តុលាការ[1], គោលការណ៍ឯករាជ្យភាព និងអព្យាក្រឹត្យភាពរបស់តុលាការ, គោលការណ៍នៃការជម្រះក្តីតាមច្បាប់[2], គោលការណ៍នៃការសន្មតជាមុនថាគ្មានទោស, សិទ្ធិការពារខ្លួនតាមផ្លូវតុលាការ[3], គោលការណ៍ចំពោះមុខ[4] និងសវនាការជាសាធារណៈ។ ចំពោះសិទ្ធិជាមូលដ្ឋានទាំងនេះ ត្រូវបានទទួលស្គាល់ និងការពារដោយរដ្ឋធម្មនុញ្ញ, ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ដោយឡែកផ្សេងទៀត។ ការធានាការគោរពសិទ្ធិជាមូលដ្ឋានទាំងនេះ ត្រូវធ្វើឡើងនៅគ្រប់ដំណាក់កាលនៃ

1. មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញ ចែងថា “ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ”។
2. កថាខណ្ឌទី១ នៃមាត្រា ១២៩ ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា “ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន”។
3. កថាខណ្ឌទី៨ នៃមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ចែងថា “ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ”។
4. វាក្យខណ្ឌទី១ នៃមាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា “ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់”។



នីតិវិធីតុលាការ តាមរយៈកិច្ចនីតិវិធីសំខាន់ៗមួយចំនួន ជាពិសេស ការកោះហៅ និងការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ។

ការកោះហៅ ជាកិច្ចនីតិវិធីតុលាការដែលត្រូវធ្វើឡើងនៅគ្រប់ដំណាក់កាលនីតិវិធីក្នុងសំណុំរឿងព្រហ្មទណ្ឌ ដើម្បីឱ្យបុគ្គលពាក់ព័ន្ធបានដឹងពីការចោទប្រកាន់ ឬការទាមទារនានាមកលើខ្លួន និងអាចប្រើប្រាស់នូវសិទ្ធិការពារខ្លួនតាមផ្លូវតុលាការដោយខ្លួនឯង និង/ឬដោយមានជំនួយពីមេធាវី។ បុគ្គលគ្រប់រូប ទាំងជនត្រូវចោទ ជនជាប់ចោទ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែទទួលបាននូវការកោះហៅឱ្យចូលរួមក្នុងកិច្ចនីតិវិធីតុលាការ ដើម្បីអាចចូលផ្តល់ចម្លើយ ធ្វើការបំភ្លឺ និងធ្វើការពិភាក្សាដេញដោលចំពោះការចោទប្រកាន់មកលើខ្លួន ឬចំពោះការទាមទាររបស់ខ្លួន និងចូលរួមក្នុងសវនាការជំនុំជម្រះក្តីស្របតាមគោលការណ៍ចំពោះមុខ។ គោលការណ៍ចំពោះមុខនេះ ធានានូវសិទ្ធិរបស់ភាគីទាំងសងខាងក្នុងការបានដឹងពីអំណះអំណាងទាំងអង្គហេតុ អង្គច្បាប់ និងភស្តុតាងដែលជាមូលដ្ឋាននៃការចោទប្រកាន់មកលើខ្លួន និងជាមូលដ្ឋាននៃការសម្រេចសេចក្តីរបស់តុលាការ។ គោលការណ៍ចំពោះមុខនេះ ធានាថាគ្មានបុគ្គលណាម្នាក់នឹងត្រូវសម្រេចសេចក្តីដោយមិនត្រូវបានស្តាប់ចម្លើយ ឬមិនត្រូវបានកោះហៅនោះទេ។ ផ្អែកលើគោលការណ៍នេះ សេចក្តីសម្រេចរបស់តុលាការដែលធ្វើឡើងដោយមានវត្តមានរបស់ភាគីពាក់ព័ន្ធ នាពេលសវនាការ ត្រូវបានកំណត់ថាជាសាលក្រម ឬសាលដីកាចំពោះមុខ។ ប៉ុន្តែ លើការជាក់ស្តែង ទោះបីជាការកោះហៅត្រូវបានធ្វើឡើងត្រឹមត្រូវក៏ដោយ ប៉ុន្តែជារឿយៗមានករណីដែលជនជាប់ចោទ ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅពេលសវនាការតាមការកោះហៅនោះទេ ហើយករណីខ្លះទៀត ការកោះហៅមិនបានទៅដល់ភាគីម្ខាងដោយសារតែមូលហេតុផ្សេងៗ។ ទោះបីជា តាមគោលការណ៍ច្បាប់ការជំនុំជម្រះក្តីរបស់តុលាការត្រូវគោរពគោលការណ៍ចំពោះមុខក៏ដោយ តុលាការនៅតែអាចបន្តកិច្ចដំណើរការជំនុំជម្រះក្តីដល់អង្គសេចក្តីបានដដែល ក្នុងករណីដែលជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី បានដឹងអំពីការកោះហៅ ប៉ុន្តែ មិនបានចូលមកបង្ហាញខ្លួននៅពេលសវនាការទៅតាមកាលបរិច្ឆេទកំណត់។ ក្នុងករណីនេះ សាលក្រម ឬសាលដីការបស់តុលាការ ត្រូវបានកំណត់ថាជា

សាលក្រម ឬសាលដីកាដែលត្រូវចាត់ទុកថាចំពោះមុខ[5]។ សាលក្រមដែលចាត់ទុកថាចំពោះមុខ បើកសិទ្ធិឱ្យមានការប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ដូចគ្នានឹងករណីសាលក្រមកំបាំងមុខដែរ។ ទន្ទឹមនេះ តុលាការក៏នៅតែអាចបន្តនីតិវិធីជំនុំជម្រះក្តីបានដដែល ទោះបីជាជនជាប់ចោទ ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅពេលសវនាការ ដោយគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនដឹងពីការកោះហៅនោះទេ។ ក្នុងករណីនេះ សាលក្រម ឬសាលដីការបស់តុលាការត្រូវបានកំណត់ថាជាសាលក្រម ឬសាលដីកាកំបាំងមុខ[6]។ សាលក្រមកំបាំងមុខ បើកសិទ្ធិឱ្យមានការប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ចំពោះសាលក្រមកំបាំងមុខ និងសាលក្រមដែលចាត់ទុកថាចំពោះមុខ ច្បាប់តម្រូវឱ្យធ្វើការជូនដំណឹងដល់ភាគីពាក់ព័ន្ធ។ ហេតុដូចនេះ ជនជាប់ចោទ ឬអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានចូលបង្ហាញខ្លួននៅពេលសវនាការ ត្រូវតែទទួលបានការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌ។ ផ្អែកតាមកថាខណ្ឌទី១ នៃមាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដីកាឱ្យដំណឹងគឺជាលិខិតដែលឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ដែលបញ្ញត្តិច្បាប់ត្រូវឱ្យជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដើម្បីឱ្យភាគីពាក់ព័ន្ធទទួលបានដំណឹងអំពីសេចក្តីសម្រេចនោះ។ ដើម្បីធានាថាការឱ្យដំណឹងពីសាលក្រមកំបាំងមុខ និងសាលក្រមដែលចាត់ទុកថាចំពោះមុខនេះ ធ្វើឡើងបានត្រឹមត្រូវ, ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីក្របខ័ណ្ឌគតិយុត្តនៃការឱ្យដំណឹងនេះ ដោយបញ្ជាក់ពីអ្នកដែលមានសមត្ថកិច្ចក្នុងការឱ្យដំណឹង *(១)* និងពីរបៀបនៃការឱ្យដំណឹងដែលត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ *(២)*។ ប៉ុន្តែ ផ្អែកលើការអនុវត្តជាក់ស្តែង មានសេចក្តីសម្រេចកំបាំងមុខ និងសេចក្តីសម្រេចដែលចាត់ទុកថាចំពោះមុខរបស់តុលាការជាច្រើន មិនអាចចូលជាស្ថាពរបាន ដោយសារតែភាគីដែលត្រូវទទួលដីកាឱ្យដំណឹងមិនមានលំនៅឋានច្បាស់លាស់នៅកម្ពុជា ឬនៅក្រៅប្រទេស ដែលការណ៍នេះទាមទារនូវដំណោះស្រាយមានលក្ខណៈច្បាស់លាស់ ដើម្បីអាចរាប់ពីថិរវេលានៃសិទ្ធិប្តឹងឧបាស្រ័យរបស់ភាគីពាក់ព័ន្ធ បាននិង

5. មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

6. មាត្រា ៣៦២ នៃក្រមនីវិធីព្រហ្មទណ្ឌ។



ទាមទារឱ្យមានការធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌសម្រាប់រយៈពេលវែង សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តស្របតាមការវិវត្តដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល *(៣)*។

## ១- សមត្ថកិច្ចក្នុងការឱ្យដំណឹងអំពីសេចក្តីសម្រេចតុលាការ

ការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ គឺជានីតិវិធីមួយដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចាប់ពីមាត្រា ៤៨២ ដល់មាត្រា ៤៩០។ ផ្អែកតាមកថាខណ្ឌទី២ នៃមាត្រា ៤៨២, ដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ត្រូវធ្វើតាមគំនិតផ្តើមរបស់ព្រះរាជអាជ្ញា របស់អគ្គព្រះរាជអាជ្ញា ឬរបស់ភាគី។ ដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការនេះ ត្រូវមានចុះនិទ្ទេស ដូចជា៖ ប្រភេទ និងការយោងនៃសេចក្តីសម្រេចដែលត្រូវជូនដំណឹង, អត្តសញ្ញាណ និងលំនៅឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្តីសម្រេច និងកាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកដែលធ្វើការជូនដំណឹង។ ទន្ទឹមនេះ ដីកានេះត្រូវបញ្ជាក់ប្រាប់អំពីផ្លូវតវ៉ាដែលអាចធ្វើបានប្រឆាំងនឹងសេចក្តីសម្រេចដែលត្រូវបានជូនដំណឹង ដោយត្រូវភ្ជាប់ទៅជាមួយនឹងលិខិតចម្លងនៃសេចក្តីសម្រេចដែលត្រូវជូនដំណឹង[7]។ ផ្អែកតាមច្បាប់ ផ្លូវតវ៉ាចំពោះសាលក្រមកំបាំងមុខ រួមមាន បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍។ បណ្តឹងទាស់ ត្រូវធ្វើឡើងក្នុងរយៈពេល ១៥ថ្ងៃ ដោយផ្តើមគិតចាប់ពី៖ (១)-ថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមនេះត្រូវបានប្រគល់ឱ្យពិរុទ្ធជន ឬដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ (២)-ថ្ងៃដែលពិរុទ្ធជន ឬដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីនេះ បានដឹងយ៉ាងពិតប្រាកដពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឱ្យដល់ពិរុទ្ធជន ឬដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។ បណ្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន របស់ដើមបណ្តឹងរដ្ឋប្បវេណី និងរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើក្នុងរយៈពេល ១ ខែ ដែលត្រូវផ្តើមគិតចាប់ពី៖ (១)-ពេលប្រកាសសាលក្រម កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ និង (២)-ពេលទទួលបានដំណឹងពីសាលក្រម កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ ទោះបីជាការឱ្យដំណឹងនេះធ្វើឡើងតាមវិធីណាក៏ដោយ។ ក្រៅពីនេះ បណ្តឹងឧទ្ធរណ៍ក៏អាច

7. មាត្រា ៤៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ធ្វើបានផងដែរចំពោះសាលក្រមកំបាំងមុខ ប៉ុន្តែរយៈពេលប្ដឹងឧទ្ធរណ៍នេះត្រូវផ្ដើមគិតពីពេលផុតកំណត់ប្ដឹងទាស់[8]។

ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថា ការជូនដំណឹងពីដីកាឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា[9] និង អាជ្ញាសាលា[10] ឬដោយបុគ្គលផ្សេងទៀតតាមការស្នើសុំរបស់ព្រះរាជអាជ្ញា[11] ដែលរួមមាន ក្រឡាបញ្ជី, អាជ្ញាធររដ្ឋបាល, ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន, អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ចំពោះក្រឡាបញ្ជី, អាជ្ញាធររដ្ឋបាល, អាជ្ញាធរពន្ធនាគារ, មន្ត្រីនគរបាលជាតិ ឬអាវុធហត្ថ ដែលព្រះរាជអាជ្ញាសុំឱ្យជូនដំណឹងនេះ ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា[12]។

## ២- របៀបនៃការឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ

ផ្អែកតាមមាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ ត្រូវធ្វើយ៉ាងណាឱ្យភាគីពាក់ព័ន្ធដែលត្រូវទទួលការឱ្យដំណឹងនេះ **"បានដំណឹងអំពីសេចក្ដីសម្រេចនោះ"**។ ទន្ទឹមនេះ, រយៈពេលបណ្ដឹងទាស់របស់ពិរុទ្ធជន និងដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវគិតចាប់ពីថ្ងៃដែលពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី "បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម" (មាត្រា ៣៦៨ និងមាត្រា ៣៧២) និង **"បានដឹងយ៉ាងពិតប្រាកដអំពីសាលដីកា"** (មាត្រា ៤១២ និងមាត្រា ៤១៦)។ ក្នុងស្មារតីនេះ នៅក្នុងសាលដីកាលេខ ១៨០ ចុះថ្ងៃទី ០៣-០៧-២០១៧, តុលាការកំពូល បានសម្រេចថាសាលដីកាកំបាំងមុខលេខ ២៤ ក្រ.II.ស ចុះថ្ងៃទី ១៩-១១-២០១៤ របស់សាលាឧទ្ធរណ៍ មិនទាន់ចូលជាស្ថាពរនោះទេ ដោយតុលាការកំពូល សំអាងថា *"ផ្អែកតាមមាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ការជូនដំណឹងមិនមែនធ្វើឡើងគ្រាន់តែបង្គ្រប់កិច្ចនោះទេ"*។ តើការឱ្យដំណឹងពីសេចក្ដីសម្រេចតុលាការត្រូវធ្វើឡើងតាមរបៀបណាខ្លះ ដើម្បីធានាថាភាគីពាក់ព័ន្ធបានដំណឹងយ៉ាងពិតប្រាកដអំពីសេចក្ដីសម្រេចនេះ? ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថា ការជូនដំណឹងអំពីដីកាឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ ត្រូវធ្វើឡើងតាមរយៈការប្រគល់ *(ក)* ឬតាមគ្រប់មធ្យោបាយជាពិសេសក្នុងករណីដែលភាគីពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់ *(ខ)* សំខាន់ឱ្យតែភាគីពាក់ព័ន្ធបានទទួលដំណឹងពីសាលក្រម ឬសាលដីកា ទោះបីជាការឱ្យដំណឹងនេះធ្វើឡើងតាមវិធីណាក៏ដោយ។

8. កថាខណ្ឌទី៤ នៃមាត្រា ៤៨២ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

9 . កថាខណ្ឌទី១ នៃមាត្រា ៤៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា "ការជូនដំណឹងដល់ភាគីពាក់ព័ន្ធអាចត្រូវធ្វើដោយព្រះរាជអាជ្ញា"។

10 . កថាខណ្ឌទី១ នៃមាត្រា ៤៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា "ការជូនដំណឹងក៏អាចត្រូវធ្វើដោយអាជ្ញាសាលាផងដែរ"។

11 . កថាខណ្ឌទី១ នៃមាត្រា ៤៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌ។

12 . កថាខណ្ឌទី២ នៃមាត្រា ៤៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌ។



### ក-ការឱ្យដំណឹងតាមវិធីប្រគល់

វិធីឱ្យដំណឹងដែលងាយស្រួលបំផុត និងដែលមិនមានវិវាទកម្ម គឺការឱ្យដំណឹងតាមវិធីប្រគល់។ ព្រះរាជអាជ្ញា ត្រូវប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចរបស់តុលាការឱ្យដល់ភាគីពាក់ព័ន្ធ។ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសលើសេចក្ដីសម្រេចដើមពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់លិខិតចម្លង ហើយភាគីពាក់ព័ន្ធចុះហត្ថលេខានៅលើសេចក្ដីសម្រេចដើមនេះ។ ចំពោះការប្រគល់ដែលធ្វើឡើងដោយអាជ្ញាសាលា ឬដោយក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរ ពន្ធនាគារ មន្ត្រីនគរបាល ឬអាវុធហត្ថ ត្រូវធ្វើឡើងតាមរបៀបដូចខាងក្រោម៖

- **ករណីជួបប្រទះភាគីពាក់ព័ន្ធនៅលំនៅឋាន ឬទីកន្លែងដទៃទៀត៖** ក្នុងករណីជួបប្រទះភាគីពាក់ព័ន្ធនៅក្នុងលំនៅឋាន ឬទីកន្លែងដទៃទៀត អ្នកប្រគល់ត្រូវប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចឱ្យដល់ភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ ហើយអ្នកប្រគល់ត្រូវចារលើសេចក្ដីសម្រេចដើមថា លិខិតចម្លងត្រូវបានប្រគល់ឱ្យភាគីដោយផ្ទាល់ដៃ និងត្រូវចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង ដោយឱ្យភាគីពាក់ព័ន្ធចុះហត្ថលេខាលើសេចក្ដីសម្រេចដើម។ សេចក្ដីសម្រេចដើមនោះត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញជាបន្ទាន់[13]។

- **ករណីអវត្តមាននៃភាគីពាក់ព័ន្ធ៖** ប្រសិនបើភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចឱ្យបុគ្គលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន ហើយអាជ្ញាសាលាត្រូវចារលើសេចក្ដីសម្រេចដើមថា លិខិតចម្លងនៃសេចក្ដីសម្រេចត្រូវបានប្រគល់ឱ្យដល់ដៃបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋាន ព្រមទាំងចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ និងកាលបរិច្ឆេទនៃការប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេច។ បុគ្គលដែលទទួល

13 . មាត្រា៤៨៦ និងកថាខណ្ឌទី៣ នៃមាត្រា៤៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

លិខិត ត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើម ហើយសេចក្តីសម្រេចដើមនេះ ត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេច ត្រូវសន្យាថានឹងប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលដ៏ខ្លីបំផុត[14]។ ច្បាប់តម្រូវឱ្យអ្នកដែលទទួល ត្រូវមានកាតព្វកិច្ចក្នុងការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឱ្យដល់ភាគីពាក់ព័ន្ធ។ ប៉ុន្តែ ច្បាប់មិនបានកំណត់ឱ្យបានច្បាស់អំពីផលវិបាកដែលកើតឡើង ក្នុងករណីដែលអ្នកទទួលមិនបានប្រគល់លិខិតចម្លងនេះដោយចេតនាក្តី ឬដោយការធ្វេសប្រហែសក្តី។ ប្រសិនបើអ្នកទទួលមិនបានប្រគល់បន្តឱ្យដល់ភាគីពាក់ព័ន្ធ ដោយសារតែការធ្វេសប្រហែសក្តី ឬដោយចេតនាក្តី តើការជូនដំណឹងនេះត្រូវចាត់ទុកជាការជូនដំណឹងដែលភាគីពាក់ព័ន្ធ "បានដឹងយ៉ាងពិតប្រាកដ" ស្របតាមស្មារតីនៃច្បាប់ដែរឬទេ?

- **ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់អាជ្ញាធរមូលដ្ឋាន៖** ក្នុងការអនុវត្តជាក់ស្តែង ពេលខ្លះភាគីពាក់ព័ន្ធបានដឹងអំពីការជូនដំណឹង ប៉ុន្តែមិនព្រមទទួលយកការជូនដំណឹងពីសេចក្តីសម្រេច ហើយពេលខ្លះអ្នកដែលមានវត្តមាននៅលំនៅឋានរបស់ភាគីពាក់ព័ន្ធមិនព្រមទទួលយកការជូនដំណឹងអំពីសេចក្តីសម្រេចនេះទេ។ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តនេះ, មាត្រា ៤៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានអនុញ្ញាតឱ្យអនុវត្តការជូនដំណឹងតាមរយៈការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចទៅមេឃុំ ចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងណាម្នាក់ក្នុងករណី ៣ យ៉ាងគឺ៖ (ទី១)-ករណីភាគីពាក់ព័ន្ធមិនព្រមទទួលសេចក្តីសម្រេច, (ទី២)-ករណីគ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ និង (ទី៣)-ករណីគ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធយល់ព្រមទទួលសេចក្តីសម្រេចនោះទេ។ ចំពោះវិធីជូនដំណឹងនេះ, អ្នកប្រគល់លិខិតនៃសេចក្តីសម្រេចទៅមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងណាមួយ ត្រូវចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើមអំពីអត្តសញ្ញាណនិងឋានៈរបស់បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេច ព្រមទាំងកាលបរិច្ឆេទនៃការប្រគល់។ បន្ទាប់មក បុគ្គលដែលទទួលលិខិតចម្លងត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចដើម ហើយសេចក្តីសម្រេចដើមនេះត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថា នឹងប្រគល់ឱ្យភាគីពាក់ព័ន្ធក្នុងរយៈពេលខ្លីបំផុត។ តើមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ដែលបានទទួលលិខិតចម្លងនៃសេចក្តីសម្រេចនេះ ត្រូវធ្វើបែបណាក្នុងករណីដែលភាគីពាក់ព័ន្ធ ឬបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធនៅតែមិនព្រមទទួលការប្រគល់លិខិតនៃសេចក្តីសម្រេចពីមេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង?

14 . មាត្រា ៤៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ខ-ការឱ្យដំណឹងក្នុងករណីភាគីពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់

ផ្អែកតាមមាត្រា ៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ "ប្រសិនបើភាគីពាក់ព័ន្ធគ្មានលំនៅឋាន ឬទីសំណាក់ទេ ឬប្រសិនបើភាគីពាក់ព័ន្ធនេះរស់នៅក្រៅដែនដីជាតិ សេចក្តីសម្រេចរបស់តុលាការក៏អាចជូនដំណឹងដល់សាមីខ្លួនបានដែរ។ ក្នុងករណីនេះ កាលបរិច្ឆេទនៃសេចក្តីសម្រេចតុលាការត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការជូនដំណឹង"។ ចំពោះករណីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ពុំទាន់បានកំណត់ឱ្យបានច្បាស់ពីនីតិវិធីលម្អិតសម្រាប់អនុវត្តសម្រាប់ករណីការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌដល់ភាគីពាក់ព័ន្ធដែលពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់ ឬភាគីពាក់ព័ន្ធដែលរស់នៅក្រៅដែនដីជាតិនៅឡើយទេ។ ប៉ុន្តែ ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឱ្យការជូនដំណឹងនេះអាចធ្វើឡើងតាមគ្រប់មធ្យោបាយ ធ្វើយ៉ាងណាឱ្យតែភាគីពាក់ព័ន្ធបានដឹងពីសេចក្តីសម្រេចរបស់តុលាការ។ តើមធ្យោបាយណាខ្លះដែលមានលក្ខណៈសមស្របនិងអាចមានភស្តុតាងបញ្ជាក់ថា ភាគីពាក់ព័ន្ធអាចទទួលបានដំណឹងយ៉ាងពិតប្រាកដពីដីកាឱ្យដំណឹងអំពីសេចក្តីរបស់តុលាការព្រហ្មទណ្ឌ ដើម្បីធានាឱ្យភាគីទទួលបាននូវសិទ្ធិប្តឹងទាស់ ឬប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់តាមកំណត់ច្បាប់។ ជាក់ស្តែង គ្រប់មធ្យោបាយនេះ អាចមានដូចជា ការជូនដំណឹងតាមប្រព័ន្ធទូរស័ព្ទ ឬប្រព័ន្ធទំនាក់ទំនងផ្សេងៗ ឬតាមការផ្សាយជាសាធារណៈ ឬតាមផ្លូវទូត ឬតាមរយៈសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ជាដើម។

ក្នុងការអនុវត្តជាក់ស្តែង តើការឱ្យដំណឹងពីសេចក្តីសម្រេចរបស់តុលាការក្នុងករណីនេះត្រូវបានអនុវត្តដោយវិធីណា? កន្លងមក ចំពោះករណីដែលភាគីពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់ការជូនដំណឹងពីសេចក្តីសម្រេចតុលាការ តែងត្រូវអនុវត្តតាមលំដាប់លំដោយ ហើយធ្វើឡើងតាមវិធីដែលបានកំណត់ក្នុងមាត្រា ៤៨៨។ នៅពេលដែលមានចំណារពីមេភូមិ

បញ្ជាក់ថាភាគីពាក់ព័ន្ធបានចេញពីមូលដ្ឋានបាត់មិនដឹងទៅរស់នៅទីណា លិខិតជូនដំណឹងនេះតែងត្រូវយកទៅបិទផ្សាយនៅសាលាឃុំ ឬសាលាសង្កាត់ដើម្បីជាការជូនដំណឹង។ បន្ទាប់មកសាលាជម្រះក្តីពាក់ព័ន្ធ អាចនឹងធ្វើការផ្សព្វផ្សាយជាសាធារណៈនូវលិខិតជូនដំណឹងនេះតាមបណ្តាញសារព័ត៌មានក្នុងស្រុកតាមការស្នើសុំរបស់ភាគីពាក់ព័ន្ធ។ ផ្អែកតាមទម្លាប់នៃការអនុវត្តការជូនដំណឹងតាមវិធីនេះរួចរាល់ក្រឡាបញ្ជីនឹងចារចូលជាស្ថាពរលើសេចក្តីសម្រេចរបស់តុលាការ។ ប៉ុន្តែ នៅក្នុងសាលដីកាលេខ ១៨០ ចុះថ្ងៃទី ០៣-០៧-២០១៧, តុលាការកំពូល បានសម្រេចថា *ការជូនដំណឹងមិនមែនធ្វើឡើងគ្រាន់តែជាការបង្គ្រប់កិច្ចនោះទេ ប៉ុន្តែ ការជូនដំណឹងនេះត្រូវតែធ្វើយ៉ាងណាឱ្យភាគីពាក់ព័ន្ធបានទទួលដំណឹងពីសេចក្តីសម្រេចនេះ ដោយតុលាការកំពូលយល់ថា ការជូនដំណឹងតាមរយៈការផ្សព្វផ្សាយជាសាធារណៈតែក្នុងសារព័ត៌មានក្នុងស្រុក ជាវិធីជូនដំណឹងដែលពុំអាចឱ្យជនជាប់ចោទដែលកំពុងរស់នៅក្រៅប្រទេស អាចទទួលបានដំណឹងពីសាលដីការបស់សាលាឧទ្ធរណ៍បានទេ នៅពេលដឹងច្បាស់ថាភាគីពាក់ព័ន្ធកំពុងរស់នៅក្រៅប្រទេស។*

ច្បាប់ជាធរមាន មិនបានកំណត់អំពីការជូនដំណឹងតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គម ដែលបច្ចុប្បន្នបានក្លាយជាមធ្យោបាយទំនាក់ទំនងដ៏មានប្រសិទ្ធភាព ហើយកំពុងមានការវិវឌ្ឍយ៉ាងឿនលឿននោះទេ។ ផ្អែកតាមស្មារតីនៃមាត្រា ៤៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត បានសម្រេចគាំទ្រឱ្យការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអាចធ្វើបានតាមរយៈការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គម។ ប៉ុន្តែ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គមសម្រាប់ធ្វើការជូនដំណឹងដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការនេះ គួរត្រូវអនុវត្តឡើងដោយមានការប្រុងប្រយ័ត្នខ្ពស់ ជាពិសេសលើភាពមិនអាចកំណត់បានច្បាស់ពីអត្តសញ្ញាណភាគីតាមប្រព័ន្ធទំនាក់ទំនងសង្គម (ករណីគណនីឈប់ប្រើប្រាស់ ឬគណនីក្លែងក្លាយ) ដែលមិនអាចបញ្ជាក់ពីភស្តុតាងថា ភាគីពាក់ព័ន្ធនឹងទទួលបានការជូនដំណឹងនេះយ៉ាងពិតប្រាកដនោះទេ។

## ៣- សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតវិស័យយុត្តិធម៌លើកទី១

ដោយការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការនេះ ជាបញ្ហាប្រឈមជាក់ស្តែងក្នុងការអនុវត្តដែលធ្វើឱ្យសេចក្តីសម្រេចមួយចំនួនធំមិនអាចចូលជាស្ថាពរបាន ការឱ្យដំណឹងអំពីសេចក្តីសម្រេចតុលាការនេះ បានក្លាយជាប្រធានបទនៃកិច្ចពិភាក្សាក្នុងអង្គមហាសន្និបាតវិស័យយុត្តិធម៌លើកទី១។ តាមរយៈកិច្ចពិភាក្សានេះ អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាមួយចំនួន ដែលរួមមាន ៖ (ទី១)-បញ្ហាកង្វះមន្ត្រីប្រតិបត្តិកិច្ចការបញ្ជូន, (ទី២)-ការអនុវត្តមិនបានត្រឹមត្រូវរបស់មន្ត្រីប្រតិបត្តិកិច្ចការបញ្ជូន, (ទី៣)-វិធីបញ្ជូនដែលបានកំណត់ក្នុងច្បាប់លែងឆ្លើយតបនឹងស្ថានភាពវិវឌ្ឍរបស់សង្គម និងបច្ចេកវិទ្យាឌីជីថល, (ទី៤)-ការអនុវត្តមិនត្រឹមត្រូវនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ និង (ទី៥)-បទប្បញ្ញត្តិច្បាប់មួយចំនួនមានភាពមិនច្បាស់លាស់ដែលនាំឱ្យមានការបកស្រាយផ្សេងគ្នា និងការអនុវត្តមិនមានសង្គតិភាព។

ដើម្បីដោះស្រាយបញ្ហាចំពោះមុខ និងក្នុងអំឡុងពេលនៃការរង់ចាំការធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ, អង្គមហាសន្និបាតវិស័យយុត្តិធម៌លើកទី១ បានសម្រេចឯកភាពគ្នាលើវិធានការបំពេញបន្ថែម ដូចខាងក្រោម៖

១-ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ អាចធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ស្របតាមស្មារតីនៃមាត្រា ៤៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-បន្ថែមលើការអនុវត្តនីតិវិធីនៃការជូនដំណឹងដែលបានអនុវត្តនាពេលកន្លងមក ស្របតាមមាត្រា ៤៨៨ និងមាត្រា ៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ អាចធ្វើឡើងតាមរយៈសារព័ត៌មាន ឬតាមយន្តការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងវិស័យយុត្តិធម៌ ក្នុងករណីដែលភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន ឬពុំមានលំនៅឋានឬទីសំណាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងយុត្តិធម៌ និងតុលាការកំពូលនឹងដាក់ចេញនូវសេចក្តីណែនាំរួមអំពីការជូនដំណឹងនេះ ដើម្បីធានាបាននូវការឯកភាពក្នុងការអនុវត្ត។

៣-ក្នុងអំឡុងពេលរង់ចាំច្បាប់ស្តីពីអាជ្ញាសាលាត្រូវបានរៀបចំនិងអនុម័តឱ្យប្រើ, ក្រសួងយុត្តិធម៌ត្រូវរៀបចំឱ្យមានមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូន ដែលនឹងទទួលបានប្រតិភូកម្ម

អំណាចពីអាជ្ញាសាលា ឬក្រឡាបញ្ជី ហើយដែលស្ថិតក្រោមការទទួលខុសត្រូវរួមរបស់ប្រធានសាលាជម្រះក្តី ដើម្បីអនុវត្តកិច្ចការបញ្ជូន។

៤-ក្រសួងយុត្តិធម៌ នឹងសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីរៀបចំឱ្យមានយន្តការរួមមួយ សំដៅលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តកិច្ចការបញ្ជូនឱ្យបានឆាប់រហ័ស និងឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ជាធរមាន។



# សារការីនៅកម្ពុជា

ដោយ៖

-លោកស្រី **នៅ សុជាតា** សារការី និងជានាយករងសាលាភូមិន្ទសារការី

សញ្ញាណសារការី និង លិខិតយថាភូតដែលធ្វើឡើងដោយសារការី បានចាប់កំណើតដំបូងឡើយនៅក្នុងនីតិកម្ពុជា តាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។ ដោយសារការតាក់តែងច្បាប់រដ្ឋប្បវេណីខ្មែរនាសម័យនោះ ត្រូវបានជួយជ្រោមជ្រែងដោយអាជ្ញាធរបារាំង ទើបធ្វើឱ្យច្បាប់ខ្មែរប្រកាន់យកប្រព័ន្ធច្បាប់រ៉ូម៉ាំង[1]។ ហេតុនេះ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ទទួលឥទ្ធិពលស្ទើរទាំងស្រុងពីក្រមរដ្ឋប្បវេណីបារាំងឆ្នាំ ១៨០៤។ សញ្ញាណនៃសារការីនៅកម្ពុជានាពេលនោះក៏បានយកលំនាំតាមប្រព័ន្ធសារការីរបស់បារាំងផងដែរ។ ផ្អែកតាមក្រមរដ្ឋប្បវេណីឆ្នាំ១៩២០, សារការី គឺជាមន្ត្រីសាធារណៈដែលរាជការបារាំងបានតែងតាំងឱ្យធ្វើជាសារការីផង ឬដែលរាជការបារាំងបានអនុញ្ញាតឱ្យធ្វើជាបណ្ដោះអាសន្នផង ក្រោយពីការផ្ទេរសមត្ថកិច្ចមកជូនរដ្ឋាភិបាលខ្មែរពេញផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាទំរាំមានសេចក្ដីសម្រេចអំពីរឿងនេះជាថ្មីទៀត[2]។ សារការីមានសមត្ថកិច្ចធ្វើលិខិតបញ្ជាក់តាមរូបមន្តយថាភូត។ លិខិតតាមរូបមន្តយថាភូត គឺជាលិខិត **"មានបញ្ជាក់ ឬធ្វើនៅសារការី**[3]"។ ហេតុដូចនេះ លិខិតយថាភូត សំដៅដល់ទាំងលិខិតបញ្ជាក់ដែលធ្វើឡើងដោយមេឃុំ ឬចៅហ្វាយស្រុក និងលិខិតយថាភូតដែលធ្វើនៅសារការី។ ច្បាប់នាសម័យនោះ តម្រូវឱ្យមានការតាក់តែងជាទម្រង់លិខិតយថាភូតដែលធ្វើនៅសារការីសម្រាប់ប្រតិបត្តិការមួយចំនួន ជាអាទិ៍ កិច្ចសន្យាផលុបភោគ[4], កិច្ចសន្យាលក់[5] ឬផ្ទេរនូវកម្មសិទ្ធិលើ

[1]. BALIVET Béatrice, « Le droit Cambodgien et les grandes familles du droit », Introduction au droit cambodgien, Phnom Penh, éd. Funan, ២០០៥, ទំព័រ ២២។

[2]. កថាខណ្ឌទី២ នៃមាត្រា៩៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ចែងថា "*លិខិតទាំងពួងដែលមន្ត្រីសាធារណៈបានធ្វើតាមរូបមន្តយថាភូត។ មន្ត្រីសាធារណៈនោះគឺ សារការី ក្រឡាបញ្ជី ដែលរាជការបារាំងបានតែងតាំងឲ្យធ្វើជាសារការីផង ឬដែលរាជការបារាំងបានអនុញ្ញាតឱ្យធ្វើជាបណ្ដោះអាសន្នក្រោយពីការផ្ទេរសមត្ថកិច្ចមកជូនរដ្ឋាភិបាលខ្មែរពេញផ្ទៃនៃព្រះរាជាណាចក្រ ទំរាំមានសេចក្ដីសម្រេចអំពីរឿងនេះជាថ្មីម្ដងទៀត*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

[3]. ជាអាទិ៍ មាត្រា៧២៨, មាត្រា៨៣៧, មាត្រា១០២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

[4]. កថាខណ្ឌទី២ នៃមាត្រា ៧២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "*កិច្ចសន្យាអំពីផលុបភោគ នឹងយកជាទីអាងបាន, សូម្បីតែរវាងភាគីផងគ្នាក៏ដោយ, ក៏ត្រូវធ្វើជាលិខិតតាមរូបមន្តយថាភូតដែរ (គឺមានបញ្ជាក់ ឬធ្វើនៅសារការី) លិខិតនេះនឹងយកជាទីអាងចំពោះតតីយជនបានតែនៅពេលដែលិខិតនេះចុះក្នុងបញ្ជីការអ៊ីម្មាទ្រីគុឡាស្យុងរួចហើយ។ នេះចំពោះតែកិច្ចសន្យាដែលទាក់ទងនឹងអចលនវត្ថុជាកម្មសិទ្ធិ*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

[5]. កថាខណ្ឌទី២ នៃមាត្រា ១០២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "*ក៏ប៉ុន្តែការលក់នូវសិទ្ធិប្រត្យ័ក្ស អចលនវត្ថុនឹងត្រូវចាត់ទុកថាជាមានបន្ទាល់ រវាងភាគីផងគ្នា ឬរវាងតតិយជនបាន ក៏លុះណាតែការលក់នោះបានធ្វើជាលាយល័ក្សអក្សរតាមរូបមន្តយថាភូត គឺមានបញ្ជាក់



អចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុ[6], កិច្ចសន្យាហ៊ីប៉ូតែក[7]។ សារការីមានសមត្ថកិច្ចធ្វើលិខិតបញ្ជាក់ចំពោះលិខិតទាំងឡាយណាដែលមានដាក់តម្លៃត្រឹម ឬលើសពី ២០០ ០០០ រៀលឡើងទៅ[8] ព្រោះជាប្រភេទប្រតិបត្តិការដែលមានតម្លៃខ្ពស់ដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់ខ្លាំងក្នុងការទាមទារឱ្យមានការបញ្ជាក់ផ្ទៀងផ្ទាត់ដោយល្អិតល្អន់ពីអ្នកជំនាញច្បាប់ក្នុងគោលបំណងការពារផលប្រយោជន៍ដល់គូភាគី។ លិខិតដែលមានតម្លៃចន្លោះពី ៥០ ០០០រៀលដល់ ២០០ ០០០រៀល គឺចៅហ្វាយស្រុកជាអ្នកបញ្ជាក់។ លិខិតដែលមានតម្លៃក្រោមពី ៥០ ០០០រៀលចុះមក ភាគីចង់យកទៅឱ្យមេឃុំ ឬចៅហ្វាយស្រុកបញ្ជាក់ក៏បាន ឬឱ្យសារការីបញ្ជាក់ក៏បាន[9]។

ទោះបីសារការីត្រូវបានកំណត់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ក៏ដោយ ប៉ុន្តែ យើងត្រូវរង់ចាំរហូតដល់ឆ្នាំ ១៩៥៤ ទើបច្បាប់ស្ដីពីវិជ្ជាជីវៈសារការីនៅកម្ពុជា ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ ៩១០ នស. ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤។ ផ្អែកតាមមាត្រា៦ នៃព្រះរាជក្រមនេះ, មន្ទីរសារការីមួយត្រូវបង្កើតឡើងនៅរាជធានីភ្នំពេញ ហើយមានសមត្ថកិច្ចធ្វើលិខិតតុបករណ៍នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ប៉ុន្តែ ផ្អែកតាមតម្រូវការចាំបាច់, គណៈរដ្ឋមន្ត្រីអាចបង្កើនចំនួនមន្ទីរសារការីរហូតដល់ ៥ កន្លែងនៅទូទាំងប្រទេស ដោយព្រះរាជក្រឹត្យ តាមសំណើរបស់

*ឬធ្វើនៅសារការី*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

[6]. មាត្រា៨៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "*ការដែលផ្ទេរនូវកម្មសិទ្ធិអចលនវត្ថុ និងសិទ្ធិប្រត្យ័ក្សអចលនវត្ថុនោះ នឹងទុកជាភ័ស្តុតាងរវាងភាគីបានលុះត្រាតែការនោះបានធ្វើជាសំបុត្រយថាភូតគឺចុះសេចក្ដីបញ្ជាក់ ឬធ្វើនៅសារការី។ បើផ្ទេរអចលនវត្ថុអ៊ីម៉ាទ្រីគុឡាស្យុងផង សំបុត្រយថាភូតនេះត្រូវចុះក្នុងបញ្ជីការអ៊ីម៉ាទ្រីគុឡាស្យុងទៀត ទើបតតិយជនមិនអាចតវ៉ាបាន*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

[7]. មាត្រា ១៣៦៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "*ហ៊ីប៉ូតែកជាកិច្ចសន្យាដែលត្រូវប្រតិបត្តិតាមល័ក្ខខណ្ឌនៃច្បាប់បារាំង ដែលស្ដីពីធ្វើបែបណាដែលទុកថាត្រឹមត្រូវគឺថាត្រូវធ្វើនៅសារការីបើមិនដូច្នោះទេត្រូវទុកជាមោឃៈជាដាច់ខាត*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

[8]. កថាខណ្ឌ៣ នៃមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "*ក៏ប៉ុន្តែលិខិតទាំងឡាយគ្រប់ប្រភេទ ដែលមានដាក់តម្លៃត្រឹម ឬលើសពី ២០០ ០០០ រៀល ឡើងទៅត្រូវតែឲ្យសារការីបញ្ជាក់តាមទម្រង់នៃអាជីវកម្មរបស់គេ*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

[9]. កថាខណ្ឌ៥ នៃមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ "*ក្រោមពី ៥០ ០០០រៀលចុះមក ភាគីចង់យកទៅឲ្យមេឃុំ ឬ ចៅហ្វាយស្រុកបញ្ជាក់ក៏បាន ឬ ឲ្យសារការីបញ្ជាក់ក៏បានតាមចិត្ត*"។ សូមមើលក្នុងសៀវភៅះ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។ និង មាត្រា ៣ នៃព្រះរាជក្រមលេខ ៩១០ នស. ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ លើមូលដ្ឋាននេះ, ព្រះរាជក្រឹត្យលេខ ១២៩ ប.រ. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៨ បានកំណត់ឱ្យមានមន្ទីរសារការីសរុបចំនួន ៥ ដោយក្នុងនោះមន្ទីរសារការីចំនួន ២ ត្រូវមានទីស្នាក់ការនៅក្រុងភ្នំពេញ និងមន្ទីរសារការី ៣ ទៀត បង្កើតនៅខេត្តបាត់ដំបង, ខេត្តកំពត និងខេត្តកំពង់ចាម។ ព្រះរាជក្រមឆ្នាំ១៩៥៤ បានអនុម័តយកប្រព័ន្ធសារការីតាមប្រព័ន្ធរ៉ូម៉ាំង[10] ឬប្រព័ន្ធច្បាប់ Civil Law ដោយបានបញ្ញត្តិក្នុងមាត្រា១ ថា សារការី គឺជា "មន្ត្រីសាធារណៈដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យរបស់រាជរដ្ឋាភិបាល និងបង្កើតឡើងក្នុងគោលបំណងចំនួន ២ គឺ (១)-ដើម្បីទទួល និងក្នុងករណីចាំបាច់ តាក់តែងលិខិត ឬកិច្ចសន្យានានាដែលគូភាគីត្រូវតែ ឬចង់ឱ្យមានការផ្តល់ចរិតយថាភាពដែលនៅជាប់ជាមួយនឹងលិខិតរបស់អាជ្ញាធរសាធារណៈ និង (២)-ដើម្បីបញ្ជាក់នូវកាលបរិច្ឆេទនៃលិខិត, រក្សាទុកលិខិតជាបញ្ញើ, ប្រគល់ឱ្យនូវសេចក្តីចម្លង និងការចម្លងបញ្ជាក់នៃលិខិតទាំងនោះ។ សារការីត្រូវបំភ្លឺ, ជូនដំណឹង និងផ្តល់ប្រឹក្សាយោបល់ដល់គូភាគីទាក់ទងនឹងលិខិតដែលពួកគាត់បានធ្វើ ឬដែលពួកគាត់មានបំណងធ្វើ ហើយក្នុងនាមជាមន្ត្រីសាធារណៈ សារការីត្រូវធានាអះអាងថា និទ្ទេសនៃលិខិតទាំងនោះស្របគ្នាយ៉ាងពិតប្រាកដទៅនឹងតថភាព"។ មាត្រា៣ នៃព្រះរាជក្រមនេះ បានបញ្ជាក់ឡើងវិញអំពីសមត្ថកិច្ចផ្តាច់មុខរបស់សារការីដែលអាចធ្វើការបញ្ជាក់តាមទម្រង់នៃវិជ្ជាជីវៈរបស់ខ្លួនចំពោះលិខិតទាំងឡាយណាដែលមានតម្លៃស្មើ ឬចាប់ពី ២០០ ០០០ រៀល[11]។

[10]. នៅសតវត្សទី ៣ នៅក្នុងចក្រភពរ៉ូម៉ាំង មានមុខងារមន្ត្រីរាជការបំពេញការងារទទួលបញ្ជាក់លើកិច្ចសន្យាក្នុងនាមរដ្ឋ និងមានប្រព័ន្ធរក្សាទុកលិខិតដែលខ្លួនធ្វើនោះ ស្រដៀងមុខងារសារការីបច្ចុប្បន្ន។ ការដាក់អាណានិគមនិយមរបស់រ៉ូម៉ាំង ផ្តល់នាទីសំខាន់ដល់ "មន្ត្រីរាជការបែបសារការី" នេះ ក្នុងការចុះបញ្ជីដីធ្លី និងកំណត់មូលដ្ឋានទារពន្ធ។ នៅស្រុកបារាំង សារការីដើរតួនាទីសំខាន់ខ្លាំងដែលរដ្ឋផ្តល់ឱ្យតាំងពីឆ្នាំ១២៧០ (Saint Louis) និង ១៣០២ (Philippe le Bel)៖ តែងតាំង និងពង្រាយទូទាំងប្រទេស។ ក្រោយបដិវត្តន៍បារាំង សារការីកាន់តែមានសារៈសំខាន់និងទទួលបានជំនឿទុកចិត្តកាន់តែច្រើនពីសង្គមបារាំងដែលគ្មានស្តេច។ ស្តេចណាប៉ូឡេអុងផ្តល់ដល់សារការីបារាំងនូវលក្ខន្តិកៈដែលប្រើរហូតមកដល់បច្ចុប្បន្ន (loi du 25 ventôse an XI)។ អាណានិគមបារាំង និងនៃប្រទេសអឺរ៉ុបផ្សេងទៀតបាននាំប្រព័ន្ធសារការីដល់អាមេរិក, អាហ្វ្រិច និងអាស៊ី។

[11]. កថាខណ្ឌទី៣ នៃមាត្រា ៩៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ចែងថា "*ក៏ប៉ុន្តែលិខិតទាំងឡាយគ្រប់ប្រភេទ ដែលមានដាក់តម្លៃត្រឹម ឬលើសពី ២០០ ០០០រៀលឡើងទៅត្រូវតែឲ្យសារការីបញ្ជាក់តាមទម្រង់នៃអាជីវកម្មរបស់គេ*"។ សូមមើលក្នុងសៀវភៅ៖ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។ មាត្រា ៣ នៃព្រះរាជក្រមលេខ ៩១០ នស. ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥៤។



វិជ្ជាជីវៈសារការីនៅកម្ពុជា ត្រូវបានលុបបំបាត់ចោលទាំងស្រុងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ វិជ្ជាជីវៈសារការីនេះ ទើបត្រូវបានបង្កើតឱ្យមានឡើងវិញតាមរយៈអនុក្រឹត្យលេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា២ នៃអនុក្រឹត្យនេះ បានកំណត់ថា "*មេធាវីសារការី ជាមន្ត្រីសាធារណៈទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងដោយអនុក្រឹត្យនេះ*"។ ការតែងតាំងឱ្យមានជាមេធាវីសារការីនេះ មានលក្ខណៈប្រហាក់ប្រហែលនឹងមុខងាររបស់ "Solicitor" នៅក្នុងប្រព័ន្ធច្បាប់ Common Law ដែលស្នាក្តី "Solicitor" គឺជាអ្នកផ្តល់យោបល់ផ្នែកច្បាប់ ទោះជាមាន ឬគ្មានវិវាទ ទាំងច្បាប់សាធារណៈ និងច្បាប់ឯកជន[12]។ ផ្អែកតាមមាត្រា ៣ នៃអនុក្រឹត្យនេះ មេធាវីសារការីមានសមត្ថកិច្ចទូទៅក្នុងវិស័យផ្នែកគ្រួសារ ចលនវត្ថុ និងអចលនវត្ថុ ហើយធ្វើនូវកិច្ចការជាអាទិ៍៖ (ក)-ទទួល និងធ្វើ ឬចារិកបញ្ជាក់ និងប្រថាប់ត្រានូវលិខិតស្នាមគតិយុត្ត ឬកិច្ចសន្យាទាំងឡាយ ដើម្បីជាបន្ទាល់ពេញលក្ខណៈតាមផ្លូវច្បាប់ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ និង (ខ)-ធ្វើការបញ្ជាក់លើកាលបរិច្ឆេទ, ទទួលតម្កល់ឯកសារ និងចេញឱ្យនូវសេចក្តីដើម ឬសេចក្តីចម្លងនៃលិខិត ឬកិច្ចសន្យាទាំងឡាយនោះតាមមុខការ។

ក្រោយពេលដែលក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រូវបានអនុម័ត និងចូលជាធរមាន, សារការីកាន់តែមានតួនាទីសំខាន់ៗឡើងនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដោយច្បាប់បានកំណត់ឱ្យប្រតិបត្តិការគតិយុត្តមួយចំនួនត្រូវតែធ្វើឡើងតាមទម្រង់លិខិតយថាភូតដែលធ្វើឡើងដោយសារការី។ ទន្ទឹមនឹងនេះ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៦ និងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏បានផ្តល់តម្លៃគតិយុត្តជាបន្ទាល់ និងផ្តល់នូវអានុភាពជាលិខិតអនុវត្តចំពោះលិខិតគតិយុត្តមួយចំនួនដែលតាក់តែងឡើងដោយសារការី ហើយដែលមានតម្លៃដូចជាសាលក្រមស្ថាពររបស់តុលាការផងដែរ។ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ បានកំណត់អំពីអត្ថន័យនៃលិខិតយថាភូត[13] និងភារកិច្ចបណ្តោះអាសន្នតាមតម្រូវការចាំបាច់ ព្រមទាំង

[12]. BALIVET Béatrice, *« Le droit Cambodgien et les grandes familles du droit »*, *Introduction au droit cambodgien*, Phnom Penh, éd. Funan, ២០០៥, ទំព័រ ២២។

[13]. មាត្រា ៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានកំណត់អំពីអត្ថន័យនៃលិខិតយថាភូត។

សិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការសារការី[14]។ បន្ទាប់ពីមានក្រមទាំង ២ នេះ, មន្ទីរសារការីមួយចំនួនធំទៀត[15] ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ដោយអនុក្រឹត្យ ដើម្បីបំពេញសេចក្តីត្រូវការចាំបាច់ក្នុងការអនុវត្តក្រមទាំង២ នេះ និងច្បាប់ជាធរមានផ្សេងទៀត។ បច្ចុប្បន្ន វិជ្ជាជីវៈសារការីបានក្លាយជាវិជ្ជាជីវៈច្បាប់មួយដែលត្រូវបានទទួលស្គាល់ និងបានចាប់ផ្តើមចាក់ឬសជាថ្មីឡើងវិញជាបណ្តើរៗនៅក្នុងសង្គមកម្ពុជា។ ផ្អែកតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន តើសារការីមានមុខងារ និងសមត្ថកិច្ចអ្វីខ្លះ **(១)**? និង តើប្រតិបត្តិការគតិយុត្តក្នុងវិស័យណាខ្លះដែលច្បាប់តម្រូវឱ្យធ្វើឡើងដោយសារការី **(២)**?

## ១- អំពីមុខងាររបស់សារការី

ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ច្បាប់ក្នុងវិស័យយុត្តិធម៌, ក្រសួងយុត្តិធម៌បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ដែលនឹងកំណត់ឱ្យបានច្បាស់លាស់អំពីលក្ខន្តិកៈសារការី និងវិជ្ជាជីវៈសារការី។ ដោយសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការីមិនទាន់ត្រូវបានរៀបចំរួចរាល់នៅឡើយ, សារការីនៅមិនទាន់មានក្របខ័ណ្ឌគតិយុត្តរួមមួយជាក់លាក់នៅឡើយទេ។ បច្ចុប្បន្ន សារការីស្ថិតក្រោមវិធានដែលត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការបង្កើតមន្ទីរសារការីផ្សេងៗទៀត។ ផ្អែកតាមលិខិតបទដ្ឋានទាំងនេះ សារការីគឺជាមន្ត្រីសាធារណៈផង **(ក)** និងជាអ្នកប្រកបវិជ្ជាជីវៈសេរីផង **(ខ)** ។

### ក- សារការីគឺជាមន្ត្រីសាធារណៈ

មាត្រា២ នៃអនុក្រឹត្យលេខ ៥០៥ អនក្រ.តត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០១ បានកំណត់ថា “**មេធាវីសារការី ជាមន្ត្រីសាធារណៈទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងដោយអនុក្រឹត្យនេះ**”។ មេធាវីសារការី គឺជាមន្ត្រីសាធារណៈដែលទទួលបាននូវប្រតិភូកម្ម

[14]. មាត្រា ១០ និងមាត្រា ១១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ បច្ចុប្បន្ន មន្ត្រីទទួលបន្ទុកកិច្ចការសារការី មានចំនួន ៤១ រូប (ប្រកាសលេខ៧២.កយ.ប្រក/១២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ ស្តីពីការកំណត់មន្ត្រីទទួលបន្ទុកកិច្ចការសារការី)។

[15]. បច្ចុប្បន្ន មានមន្ទីរសារការីសរុបចំនួន ២ និងមានសារការីចំនួន ៦៩ រូប ដែលក្នុងនោះមាន ៦៨ រូប កំពុងប្រកបវិជ្ជាជីវៈសារការីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។



អំណាចពីរដ្ឋ ដើម្បីធ្វើ ឬបញ្ជាក់នូវលិខិតគតិយុត្ត ឬកិច្ចសន្យាទាំងឡាយដែលមានតម្លៃជាបន្ទាល់ពេញលក្ខណៈតាមច្បាប់ដូចលិខិតរបស់រាជការសាធារណៈផងដែរ[16]។ ដោយឡែក អនុក្រឹត្យដែលបង្កើតមន្ទីរសារការីផ្សេងៗទៀត មិនបានកំណត់អំពីមុខងាររបស់សារការីនោះទេ ដោយគ្រាន់តែកំណត់អំពីតួនាទី និងភារកិច្ចរបស់មន្ទីរសារការីតែប៉ុណ្ណោះ។ តើសារការីដែលមិនមែនជាមេធាវី នៅតែត្រូវបានចាត់ទុកថាជាមន្ត្រីសាធារណៈតាមស្មារតីនៃអនុក្រឹត្យលេខ ៥០៥ ទៀតដែរឬទេ?

យោងតាមសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ “**សារការី គឺជាមន្ត្រីសាធារណៈដែលមានមុខងារធ្វើលិខិតយថាភូត បញ្ជាក់អំពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទតម្កល់ រក្សាទុក និងចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងឡាយដែលត្រូវតែឱ្យមានការបញ្ជាក់**”។ ផ្អែកតាមនិយមន័យនេះ សារការី គឺជាមន្ត្រីសាធារណៈ ត្រូវបានតែងតាំងដោយរដ្ឋ និងទទួលនូវប្រតិភូកម្មអំណាចពីរដ្ឋ ក្នុងការបំពេញមុខងារសំខាន់ៗចំនួន ៤ រួមមាន៖ (ទី១)-ធ្វើលិខិតយថាភូត, (ទី២)-ធ្វើលិខិតបញ្ជាក់ពីលក្ខណៈពិតប្រាកដត្រឹមត្រូវ និងធានារ៉ាប់រងអំពីកាលបរិច្ឆេទ, (ទី៣)-តម្កល់ និងរក្សាទុកនូវលិខិតទាំងឡាយដែលបានធ្វើ ឬបានបញ្ជាក់ និង (ទី៤)-ចេញសេចក្តីចម្លងយថាភូតនៃលិខិតទាំងនោះ។ ក្រមរដ្ឋប្បវេណីនេះ បានបន្តកំណត់យកប្រព័ន្ធសារការីកម្ពុជា តាមប្រព័ន្ធសារការីនៃប្រព័ន្ធ Civil Law។ នៅក្នុងប្រព័ន្ធ Civil Law, សារការីគឺជាអ្នកជំនាញផ្នែកច្បាប់ និងជាមន្ត្រីសាធារណៈ ដែលទទួលបានការតែងតែងពីរដ្ឋដើម្បីផ្តល់យថាភូតភាពដល់កិច្ចសន្យារបស់គូភាគី និងផ្តល់នូវការប្រឹក្សាយោបល់ដោយមិនលម្អៀងដល់គូភាគីទាំងសងខាង។ សារការីតាក់តែងកិច្ចសន្យាដោយយោងទៅលើបទដ្ឋានគតិយុត្តជាធរមាន។ រដ្ឋបានធ្វើប្រតិភូកម្មដល់សារការីដែលត្រូវជាបុគ្គលមានគុណវុឌ្ឍិ គ្រប់គ្រាន់ដើម្បីអនុវត្តនូវបេសកម្មក្នុងការធានានូវសុវត្ថិភាពនៅក្នុងកិច្ចសន្យាតាមរយៈការផ្តល់នូវយថាភូតភាពដល់រាល់

[16]. ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ បានរៀបរាប់លម្អិតអំពីមន្ត្រីរាជការសាធារណៈ អំពីតួនាទីនៃមន្ត្រីរាជការសាធារណៈ គឺបុគ្គលដែលទទួលបាននូវប្រតិភូកម្មអំណាចសាធារណៈពីរដ្ឋ ក្នុងការបញ្ជាក់នូវលិខិតទាំងឡាយដែលមានកំណត់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ (មាត្រា ៩៤៤ ដល់មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០)។ មន្ត្រីរាជការសារធារណៈ គឺជាបុគ្គលដែលមានសមត្ថភាពដើម្បីបញ្ជាក់នូវលិខិតទាំងឡាយក្នុងឃុំនីមួយៗនោះ គឺមេឃុំ បើមេឃុំមិននៅ ឬមានធុរៈ ត្រូវជំទប់ណាមួយក្នុងឃុំជំនួស កុំឱ្យតែការនេះប៉ះពាល់សិទ្ធិ និងដល់សិទ្ធិផ្តាច់មុខដែលបានសំដែងហើយក្នុងមាត្រានេះដើម្បីជាផលប្រយោជន៍ដល់មន្ត្រីរាជការសាធារណៈដទៃទៀត។ សូមមើលក្នុងសៀវភៅ៖ អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី១, ព.ស.២៥១០, គ.ស.១៩៦៧។

លិខិតដែលខ្លួនបានតាក់តែង។ ទម្រង់យថាភូត គឺជាយន្តការសម្រាប់ការពារនូវឆន្ទះរបស់បុគ្គលម្នាក់ៗដើម្បីធានាថាឆន្ទះរបស់គូភាគីត្រូវបានបង្ហាញឡើងដោយសេរី មិនស្ថិតក្រោមការបង្ខិតបង្ខំ និងមិនមានការភ័ន្តច្រលំ។ លិខិតធ្វើដោយសារការី ត្រូវបានកំណត់ថាជាលិខិតសារការី ដែលរួមមាន *"លិខិតយថាភូត"* និង *"លិខិតបញ្ជាក់"*។

- **លិខិតបញ្ជាក់៖** យោងមាត្រា ៩៤៤ នៃក្រមរដ្ឋប្បវេណី ដែលហៅថា លិខិតបញ្ជាក់នោះ គឺសំបុត្រដែលគូភាគីបានចុះហត្ថលេខាក្រោយដែលគេបានអានសេចក្តីសំបុត្រទាំងអស់យ៉ាងខ្លាំងៗដោយក្បោះក្បាយឱ្យគូភាគីស្តាប់ចំពោះមុខមន្ត្រីរាជការសាធារណៈនេះ ក្រោយដែលបានពិនិត្យអំពីអត្តសញ្ញាណនៃគូភាគី អំពីការចូលខ្លួននៃគូភាគី អំពីការអានលិខិតឲ្យគូភាគីស្តាប់ អំពីហត្ថលេខា ដែលភាគីបានចុះនោះឃើញថាត្រឹមត្រូវហើយ ទើបចុះហត្ថលេខាខ្លួនឯងក្បែរហត្ថលេខានៃគូភាគីព្រមទាំងបោះត្រាផង។

- **លិខិតយថាភូត៖** សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានឱ្យនិយមន័យនៃ *"លិខិតយថាភូត គឺជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀត គឺជាលិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី"* ផ្ទុយពីលិខិតឯកជនដែលជាលិខិតទាំងឡាយណាដែលបង្កើតឡើងដោយបុគ្គលឯកជនដោយមានចុះហត្ថលេខា ឬស្នាមមេដៃ។ យោងតាមមាត្រា ៩ ចំណុច ក វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ បានចែងថា " *លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦, មាត្រា ៥១៦, មាត្រា ១១៧៣ និងមាត្រា ៨៦២ នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬ លិខិតឯកជនដែលសារការីចុះនិទ្ទេសថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់*"។ លិខិតយថាភូត គឺសំដៅដល់លិខិតទាំងឡាយណាដែលធ្វើឡើងដោយសារការី ឬលិខិតឯកជនដែលសារការីចុះនិទ្ទេសថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខា ក្រោយពេលខ្លួនបញ្ជាក់ថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់, លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី, មតកសាសន៍ដោយលិខិតយថាភូតធ្វើឡើងដោយកុងស៊ុលករណីជនជាតិខ្មែរនៅឯបរទេស ឬលិខិតដែលធ្វើឡើងដោយមន្ត្រីទទួលបន្ទុកកិច្ចការសារការី។



លិខិតយថាភូតដែលធ្វើឡើងដោយសារការី ដែលត្រូវបានទទួលស្គាល់ដោយក្រមនីតិវិធីរដ្ឋប្បវេណី ថាមានតម្លៃជាលិខិតអនុវត្ត មាន ២ ប្រភេទ គឺលិខិតយថាភូតដែលធ្វើឡើងសម្រាប់ករណីសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ដែលមានចែងនៅក្នុងមាត្រា ៣៥០ និងករណីលិខិតយថាភូតដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគដែលមានចែងនៅក្នុងមាត្រា ៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ លិខិតសារការីដែលបានកំណត់ក្នុងមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ច នៃក្រមនីតិវិធីរដ្ឋប្បវេណី អាចក្លាយជាលិខិតអនុវត្តបាន ត្រូវបានកម្រិតចំពោះតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថា **"កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ"** ប៉ុណ្ណោះ។ ដោយលិខិតសារការីទាំង ២ ប្រភេទនេះ ជាលិខិតអនុវត្ត, ច្បាប់កំណត់ឱ្យមន្ទីរសារការីដែលបានរក្សាទុកច្បាប់ដើមនៃលិខិតយថាភូត គឺជាអ្នកមានសមត្ថកិច្ចក្នុងការផ្តល់រូបមន្តអនុវត្តដើម្បីអនុវត្តដោយបង្ខំផ្អែកលើលិខិតយថាភូតនោះ[17]។ សារការីអាចផ្តល់រូបមន្តអនុវត្តពីរប្រភេទគឺ *រូបមន្តអនុវត្តធម្មតា* និង*រូបមន្តអនុវត្តពិសេស*។ សារការីប្រើប្រាស់រូបមន្តអនុវត្តពិសេសក្នុងករណីដែលសិទ្ធិលើបំណុលដែលមានកំណត់ក្នុងលិខិតអនុវត្តគឺជាសិទ្ធិលើបំណុលដែលភ្ជាប់លក្ខខណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ ឬក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវមានកូនបំណុល ឬម្ចាស់បំណុលនៃការអនុវត្តគឺជាភាគីផ្សេងក្រៅពីភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្ត។ សារការីអាចប្រើប្រាស់រូបមន្តអនុវត្តធម្មតានៅក្នុងករណីដែលលក្ខខណ្ឌណាមួយនៃរូបមន្តអនុវត្តពិសេសដូចដែលបានរៀបរាប់ខាងលើមិនត្រូវបានបំពេញទេ មានន័យថាបើសិនជាភាគីនៃការអនុវត្តដោយបង្ខំ (ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត) ដូចគ្នានឹងភាគីដែលបានកំណត់នៅក្នុងលិខិតអនុវត្ត ឬសិទ្ធិលើបំណុលដែលអាចអនុវត្តដោយបង្ខំបានពុំមានភ្ជាប់លក្ខខណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ។ ដោយផ្អែក ទៅលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំ នៅគ្រប់ទីកន្លែង និងមានអានុភាពដោយមិនមានរយៈពេលកំណត់។ បុគ្គលដែលមាន

17. មាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ផលប្រយោជន៍មានសិទ្ធិធ្វើឧបាស្រ័យដូចជា ការតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ឬ បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តទៅតុលាការដែលមានសមត្ថកិច្ច[18]។

ហេតុដូចនេះ មិនមែនគ្រប់លិខិតសារការីសុទ្ធតែជាលិខិតអនុវត្តនោះទេ។ ប៉ុន្តែទោះបីជាលិខិតសារការីដែលមិនមានអានុភាពជាលិខិតអនុវត្តក៏ដោយ ការធ្វើលិខិតដោយសារការីអាចធានាបាននូវគោលដៅ ៣ យ៉ាងធំៗ។ ទីមួយ ការធានាបាននូវតុល្យភាព ប្រសិទ្ធភាព និងសុវត្ថិភាពគតិយុត្តដល់គូភាគីនៃលិខិត តាមរយៈកាតព្វកិច្ចរបស់សារការីក្នុងការផ្ទៀងផ្ទាត់ឯកសារ, ការផ្តល់ប្រឹក្សាមិនលម្អៀង និងតម្កល់ថែរក្សាច្បាប់ដើមនៃលិខិតទុក ជាដើម។ ទីពីរ ដោយសារតែជាលិខិតសារការីជាលិខិតដែលធ្វើឡើងដោយមន្ត្រីសាធារណៈដែលទទួលប្រតិភូកម្មអំណាចពីរដ្ឋ ហេតុនេះខ្លឹមសារនៃលិខិតសារការី គឺត្រូវតែមានភាពត្រឹមត្រូវតាមការពិត និងជឿជាក់បានពោលគឺមានអំណាចជាបន្ទាល់ទាក់ទងនឹងតម្លៃនៃភស្តុតាង និងមានកាលបរិច្ឆេទស្ថាពរ។ ទីបីអាចជួយបង្កើត និងបង្កើនជំនឿទុកចិត្តលើប្រព័ន្ធច្បាប់ និងកាត់បន្ថយជម្លោះក្នុងសង្គម។ ក្នុងន័យនេះហើយ ទើបច្បាប់តម្រូវឱ្យលិខិតមួយចំនួនត្រូវធ្វើឡើងតាមទម្រង់យថាភូត ដើម្បីអាចមានអានុភាព[19] និងអាចតតាំងជាមួយនឹងតតិយជនបាន។

### ១- សារការីជាអ្នកប្រកបវិជ្ជាជីវៈសេរី

ផ្អែកតាមនិយមន័យនៃសារការីដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី សារការីគឺជាមន្ត្រីសាធារណៈ។ មិនទាន់មានច្បាប់ណាមួយបញ្ជាក់ថា សារការីគឺជាអ្នកប្រកបវិជ្ជាជីវៈសេរីនោះទេ។ ទោះបីជាសារការីជាមន្ត្រីសាធារណៈដែលទទួលប្រតិភូកម្មអំណាចសាធារណៈពីរដ្ឋ តែការប្រកបវិជ្ជាជីៈរបស់សារការី គឺជាវិជ្ជាជីវៈសេរីផងដែរ ដោយក្នុងការផ្តល់នូវសេវាសាធារណៈក្នុងវិស័យច្បាប់ជូនដល់ប្រជាពលរដ្ឋដោយមិនក្លាយទៅជាបន្ទុកផ្នែកហិរញ្ញវត្ថុដល់រដ្ឋ សារការីមិនទទួលបានបៀវត្ស ឬប្រាក់ឧបត្ថម្ភណាមួយពីរដ្ឋនោះទេ។ សារការីទទួលបានចំណូលពីសកម្មភាព

18. កថាខណ្ឌទី៣ នៃមាត្រា ៣៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

19. កថាខណ្ឌទី២ នៃមាត្រា៣៣៦ នៃក្រមរដ្ឋប្បវេណី ចែងថា "ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិអចលនវត្ថុ នឹងមានអានុភាពលុះត្រាតែបានធ្វើលិខិតយថាភូត"។



ប្រកបវិជ្ជាជីវៈរបស់ខ្លួន និងទទួលខុសត្រូវលើការខាត ឬចំណេញចំពោះដំណើរការនៃមន្ទីរដោយខ្លួនឯងផ្ទាល់។

ផ្អែកតាមអនុក្រឹត្យដែលបង្កើតមន្ទីរសារការីនីមួយៗ បានអនុញ្ញាតឱ្យមន្ទីរសារការីអាចអនុវត្តតួនាទី និងភារកិច្ចផ្សេងទៀតក្រៅតែពីការធ្វើលិខិតយថាភូត និងលិខិតបញ្ជាក់។ សារការីប្រកបវិជ្ជាជីវៈរបស់ខ្លួន និងទទួលខុសត្រូវដោយឯករាជ្យគឺមិនស្ថិតនៅក្រោមការជ្រៀតជ្រែក ឬក្រោមឋានានុក្រមណាមួយឡើយ។ ទោះបីជាសារការីប្រកបវិជ្ជាជីវៈរបស់ខ្លួនដោយសេរីក៏ដោយ ក្នុងនាមជាមន្ត្រីសាធារណៈដែលទទួលប្រតិភូកម្មអំណាចសាធារណៈពីរដ្ឋ សារការីត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋដើម្បីធានាថា សារការីអនុវត្តវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយភាពថ្លៃថ្នូរ សុចរិតទៀងត្រង់ និងផ្តល់អាទិភាពក្នុងការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ និងការពារផលប្រយោជន៍ស្របច្បាប់របស់រដ្ឋ។ ការណ៍នេះបានធ្វើឱ្យសារការីប្រកបវិជ្ជាជីវៈសេរីក៏ពិតមែន ប៉ុន្តែមានលក្ខណៈខុសគ្នាពីការអនុវត្តវិជ្ជាជីវៈសេរីរបស់មេធាវី។ នៅក្នុងច្បាប់ជាធរមាន កម្រៃរបស់សារការីត្រូវបានកំណត់ដោយសេរីតាមការព្រមព្រៀងរវាងសារការី និងអតិថិជនរបស់ខ្លួន ព្រោះមិនទាន់មានបញ្ញត្តិណាមួយកំណត់អោយបានច្បាស់លាស់ឡើយ។ ការកំណត់លើអត្រាកម្រៃរបស់សារការីគឺកំពុងតែត្រូវបានរៀបចំនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី។ គោលបំណងនៃការកំណត់អំពីអត្រាកម្រៃរបស់សារការី គឺដើម្បីធានាថាប្រជាពលរដ្ឋគ្រប់រូបអាចប្រើប្រាស់បាននូវសេវាសាធារណៈដែលជាសមត្ថកិច្ចផ្តាច់មុខរបស់សារការីតាមការតម្រូវច្បាប់ ឬតាមឆន្ទៈរបស់ខ្លួនចំពោះកិច្ចដែលមិនមែនជាសមត្ថកិច្ច ផ្តាច់មុខរបស់សារការី។

## ២- អំពីភាតព្វកិច្ចរបស់សារការី

លោក Pierre-François REAL[20] បានហៅសារការី ថាជា *"អ្នកផ្តល់ការប្រឹក្សាមិនលម្អៀង និងតាក់តែងដោយអនាគតិ"* របស់គូភាគី ដែលធ្វើអោយពួកគេបានយល់នូវទំហំនៃ

20. Pierre-François REAL (១៧៥៧-១៨៣៤) គឺជាអ្នកតាក់តែងច្បាប់សារការីនៅប្រទេសបារាំង Loi 25 ventôse an XI (ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៨០៤)។ ច្បាប់នេះបានបង្កើតសារការីនៅក្នុងប្រទេសផ្សេងៗជាច្រើនក្រៅពីប្រទេសបារាំង ដូចជា បេលហ្សិក អាល្លឺម៉ង់

កាតព្វកិច្ចដែលពួកគេបានចុះកិច្ចសន្យា តាក់តែងនូវចំណងកិច្ចសន្យាដោយមានភាពច្បាស់លាស់ ផ្តល់ចរិតលក្ខណៈដល់លិខិតយថាភូត និងផ្តល់អានុភាពដូចសាលក្រមស្ថាពរដែលបិទសិទ្ធិមិនអោយមានបណ្តឹងឧបាស្រ័យ រក្សាអោយបានស្ថិតស្ថេរនូវការចងចាំ និងថែរក្សាតម្កល់ទុកលិខិតដែលតាក់តែងដោយសារការីប្រកបដោយភក្តីភាព បង្ការកុំអោយមានវិវាទកើតឡើងរវាងបុគ្គលស្លូតត្រង់។ ក្នុងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន, សារការីមានកាតព្វកិច្ចសំខាន់ៗ ដូចខាងក្រោម៖

### ក-កាតព្វកិច្ចផ្ទៀងផ្ទាត់ ធានាភាពត្រឹមត្រូវ និងអនុលោមភាពនៃច្បាប់

ក្នុងការតាក់តែងលិខិតយថាភូត, សារការីត្រូវផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់នូវឆន្ទៈពិតប្រាកដដោយមិនមានវិការៈរបស់ភាគី, អត្តសញ្ញាណភាគី និងសាក្សី, អត្តសញ្ញាណទ្រព្យ, ភាពត្រឹមត្រូវតាមច្បាប់នៃខ្លឹមសារ និងនិទ្ទេសដែលបានចុះក្នុងលិខិត, ភាពត្រឹមត្រូវនៃកាលបរិច្ឆេទនៃលិខិត និងភាពត្រឹមត្រូវនៃហត្ថលេខា ឬស្នាមមេដៃរបស់គូភាគី។ សេចក្តីអះអាងរបស់មន្ត្រីនេះ ក្នុងលិខិតនោះមានតំលៃខ្ពស់បំផុតដែលគេត្រូវជឿទុកចិត្តថាត្រឹមត្រូវ លើកលែងតែមានការប្តឹងចោទប្រកាន់ជាមុនថាជាលិខិតក្លែង។ បន្ថែមពីនេះ សារការីមានកាតព្វកិច្ចរៀបចំតាក់តែងខ្លឹមសារនៃលិខិត ឬកិច្ចព្រមព្រៀងអនុលោមទៅតាមលក្ខខណ្ឌខ្លឹមសារ និងលក្ខខណ្ឌទម្រង់ដែលច្បាប់តម្រូវ ដើម្បីធានាប្រសិទ្ធភាពនៃប្រតិបត្តិការ ព្រមទាំងផ្តល់ព័ត៌មានអំពីការគណនាពន្ធអាករលើប្រតិបត្តិការគតិយុត្ត ផ្ទៀងផ្ទាត់នូវការបង់អាករដើម្បីធានានូវការប្រមូលពន្ធអាករជូនរដ្ឋ។

ការធានាភាពត្រឹមត្រូវ ការបង្ការនូវការក្លែងបន្លំឯកសារ ការធានាភាពស្របច្បាប់នៃលិខិតដែលបានធ្វើនេះ ការផ្ទៀងផ្ទាត់នូវរាល់ឯកសារ និងព័ត៌មានសម្រាប់ការតាក់តែងលិខិតនោះ គឺជាគ្រឹះសម្រាប់បាននូវធានាសុវត្ថិភាពគតិយុត្តសម្រាប់គូភាគី និងបង្ការកុំឱ្យមានវិវាទនៅតុលាការដែលការណ៍នេះបានចូលរួមកាត់បន្ថយសោហ៊ុយ និងចំណេញពេលវេលាដល់គូភាគី

---

អាហ្សង់ទីន អូទ្រីស បៀគីណាហ្វាសូ ឈីលី ខូឡុំប៊ី កូតឌីវ័រ អេស្ប៉ាញ ក្រិក អ៊ីតាលី លុចហ្សំបួ ម៉ារ៉ុក មិកស៊ិក ហូឡង់ សាធារណរដ្ឋដូមីនិកែន រ៉ូម៉ានី សេនេហ្គាល់ និង ស្វីស។



និងចូលរួមកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ ព្រមទាំងធានានូវស្ថេរភាព និងភាពសុខដុមរមនានៅក្នុងសង្គម។

### ខ-កាតព្វកិច្ចបំភ្លឺ ផ្តល់ព័ត៌មាន និងផ្តល់ប្រឹក្សាដល់គូភាគីដោយសុចរិត ទៀងត្រង់ និងមិនលម្អៀង

សារការីមានកាតព្វកិច្ចត្រូវបំភ្លឺ ផ្តល់ព័ត៌មាន ផ្តល់ប្រឹក្សាយោបល់ច្បាប់ដោយមិនលម្អៀងដល់ភាគីទាំងអស់នៃលិខិតគតិយុត្ត អំពីខ្លឹមសារ និងលក្ខខណ្ឌ អំពីសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងផលវិបាក ឬអានុភាពគតិយុត្តនៃលិខិត ឬកិច្ចព្រមព្រៀងមុននឹងពួកគេចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ។ សារការីត្រូវពន្យល់អំពីទម្រង់ និងនីតិវិធីដែលតម្រូវដោយច្បាប់ដើម្បីធានាសុពលភាពស្របច្បាប់ និងអានុភាពអនុលោមទៅតាមគោលបំណងរបស់គូភាគី។

នៅក្នុងប្រព័ន្ធច្បាប់រ៉ូម៉ាំង ក្នុងនាមជាមន្ត្រីសាធារណៈ សារការីត្រូវបានគេហៅថាជា **“ចៅក្រមសម្រុះសម្រួល”**[21] ដែលមានតួនាទីការពារផលប្រយោជន៍គូភាគីទាំងសងខាងស្មើគ្នា ដែលផ្ទុយពីវិជ្ជាជីវៈមេធាវីដែលមានកាតព្វកិច្ចក្នុងការការពារផលប្រយោជន៍របស់អតិថិជនរបស់ខ្លួន[22]។ លោកស្រី Christiane Taubira អតីតរដ្ឋមន្ត្រីយុត្តិធម៌បារាំង (២០១២-២០១៦) បានថ្លែងនៅក្នុងសមាជលើកទី ១០៩ របស់សារការីនៃប្រទេសបារាំង ដោយបានលើកឡើងអំពីតួនាទីដ៏សំខាន់នៃវិជ្ជាជីវៈសារការីក្នុងការចូលរួមនូវសេវាផ្តល់ “សន្តិភាពស៊ីវិល (Paix Civile)”[23] តាមរយៈការលើកឡើងថា៖ «វិវាទទៅតុលាការសម្រាប់ប្រទេសប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ក្នុងចំណោម ៣ កិច្ចសន្យា មាន ១ ប្តឹងគ្នាទៅតុលាការ ខណៈដែលនៅបារាំង ក្នុងចំណោមលិខិតសារការី ១០៧០ លិខិត ទើបមាន ១ ប្តឹងគ្នាទៅតុលាការ»។ ក្នុងវិស័យអចលនវត្ថុ វិវាទទៅតុលាការមាន ០,១% នៅស្រុកបារាំង ខណៈដែលនៅសហរដ្ឋអាមេរិកមានដល់ ៣០%។ ទិន្នន័យនេះ បានឆ្លុះបញ្ចាំងឱ្យឃើញអំពីតួនាទីដែលមិនអាចខ្វះបានរបស់សារការីនៃប្រព័ន្ធ Civil Law

---

21. សូមមើលគេហទំព័ររបស់ក្រុមប្រឹក្សាជាន់ខ្ពស់សារការី http://www.notaires.Fr

22. មាត្រា២ និងមាត្រា៣ នៃក្រមចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥។

23. គេហទំព័រ https://mesinfos.fr/ile-de-france/109e-congres-des-notaires-de-france-c-taubira-reaffirme-le-role-de-la-profession-20976.html

នៅក្នុងសង្គមកម្ពុជាដែលជាតួអង្គសម្របសម្រួលដោះស្រាយវិវាទ កាត់បន្ថយជម្លោះ និងការបែកបាក់នៅក្នុងសង្គមគ្រួសារ និងសង្គមទាំងមូលតាមរយៈការផ្តល់ប្រឹក្សាយោបល់មិនលម្អៀងរបស់ខ្លួន ដើម្បីធានាផលប្រយោជន៍និងសមភាពដល់គូភាគីទាំងសងខាង ដែលផ្ទុយពីតួនាទីរបស់ស្នាក្តីនៅក្នុងប្រព័ន្ធ Common Law ដែលមានកាតព្វកិច្ចការពារតែផលប្រយោជន៍របស់អតិថិជនរបស់ខ្លួនដោយប្រកាន់ខ្ជាប់លើគោលការណ៍អ្នកណាខ្លាំងជាង អ្នកនោះនឹងឈ្នះ។

### គ- កាតព្វកិច្ចជៀសវាងនូវទំនាស់ផលប្រយោជន៍

សារការីត្រូវជៀសវាងរាល់ស្ថានភាពទាំងឡាយណាដែលអាចបង្កើតឱ្យមានជាទំនាស់ផលប្រយោជន៍។ ជាឧទាហរណ៍ នៅក្នុងមាត្រា ១១៧២ ចំណុច គ នៃក្រមរដ្ឋប្បវេណីដែលបានកំណត់ថា បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលិខិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិតរបស់សារការីនោះ មិនអាចធ្វើជាសាក្សី ឬជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍ឡើយ។ បើមិនដូច្នេះ បណ្តាំមតកសាសន៍ដែលមិនបានគោរពទៅតាមវិធានទម្រង់ដូចរៀបរាប់ខាងលើនេះ នឹងមិនមានសុពលភាពតាមផ្លូវច្បាប់ ត្រូវចាត់ទុកជាមោឃៈដែលមិនមានអានុភាពដើម្បីយកទៅអនុវត្តតាមគោលបំណងរបស់អតិថិជនឡើយ[24]។

### ឃ-កាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ

សារការី មានកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ។ ប៉ុន្តែ យោងតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងប្រឆាំងហិរញ្ញប្បទានភេរវកម្ម[25] ការសម្ងាត់វិជ្ជាជីវៈ មិនត្រូវរារាំងការអនុត្តច្បាប់ និងមិនអាចយកមកប្រើជាសំអាង ដើម្បីបដិសេធការផ្តល់ព័ត៌មាន ដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ និងស្ថាប័នត្រួតពិនិត្យ ទោះបីសម្រាប់គោលបំណងសហប្រតិបត្តិការក្នុងប្រទេស អន្តរជាតិ ឬក៏ដូចដែលបានតម្រូវក្នុងការស៊ើបអង្កេតពាក់ព័ន្ធដល់ការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្មដែលត្រូវបានបញ្ជាដោយ ឬអនុវត្តក្រោមការត្រួតពិនិត្យរបស់តុលាការ។

24. មាត្រា១១៧០ និង១១៧១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

25. មាត្រា ៦ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧។



ផ្អែកតាមច្បាប់នេះ សារការីក៏បានដើរតួជាបុគ្គលរាយការណ៍ដែលត្រូវប្រកាន់យកវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់ខ្លួនឱ្យបានច្បាស់លាស់ នៅពេលដែលខ្លួនរៀបចំតាក់តែងប្រតិបត្តិការទាក់ទងនឹងសកម្មភាពបម្រើឱ្យអតិថិជនរបស់ខ្លួន ដូចជា កិច្ចសន្យាទិញលក់អចលនទ្រព្យ ឬបរធនបាលកិច្ច ជាដើម[26]។ ក្នុងករណីដែលសារការីមានមន្ទិលសង្ស័យធ្ងន់ធ្ងរ លើប្រភពស្របច្បាប់នៃមូលនិធិសម្រាប់ធ្វើប្រតិបត្តិការ សារការីអាចបដិសេធទទួលរៀបចំតាក់តែង ឬបញ្ជាក់លិខិតសារការីបាន ហើយសារការីមានកាតព្វកិច្ចត្រូវរាយការណ៍នូវប្រតិបត្តិការសង្ស័យ ឬប្រតិបត្តិការសាច់ប្រាក់ដែលលើសពីចំនួនកំណត់ដោយស្ថាប័នត្រួតពិនិត្យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។ ទោះបីជាមិនទាន់មានបទប្បញ្ញត្តិណាមួយបញ្ជាក់អំពីកាតព្វកិច្ចរក្សាការសម្ងាត់របស់សារការីក៏ដោយ ដោយសារសារការីជាបុគ្គលរាយការណ៍[27] ដូចដែលមានចែងនៅក្នុងច្បាប់នេះ ដែលជាករណីលើកលែងមួយ។ យើងអាចបកស្រាយផ្ទុយមកវិញបានថា ក្រៅពីករណីដែលច្បាប់បានកំណត់នេះ សារការីមានកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈដោយមិនមានសិទ្ធិបញ្ចេញរាល់គ្រប់មធ្យោបាយនូវព័ត៌មានទាក់ទងនឹងអតិថិជនរបស់ខ្លួនឡើយ។

### ង-កាតព្វកិច្ចក្នុងការរក្សាទុកឯកសារ និងតម្កល់ច្បាប់ដើមនៃលិខិត ព្រមទាំងឯកសារពាក់ព័ន្ធទុកក្នុងមន្ទីរសម្រាប់រយៈពេលតម្រូវដោយច្បាប់

សារការីមានទំនួលខុសត្រូវក្នុងការរក្សាទុកឯកសារដែលពួកគេផ្ទៀងផ្ទាត់ ដោយត្រូវធានាថាឯកសារទាំងនេះអាចត្រូវបានរកឃើញ និងប្រើប្រាស់ជាភស្តុតាងប្រសិនបើចាំបាច់។ មាត្រា ១៤ នៃច្បាប់ស្តីពីបណ្ណសា បានចែងអំពីការថែរក្សាទុកលិខិតសារការីមានរយៈពេល ៤០ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃឯកសារ។ មុខងារនេះមានសារៈសំខាន់ណាស់ ដើម្បីជៀសវាងជម្លោះ ការផ្លាស់ប្តូរឆន្ទៈរបស់គូភាគី និងការក្លែងបន្លំឯកសារ។ ឯកសារច្បាប់ដើមមានភាពច្បាស់លាស់ ពេញលេញ និងអនុលោមតាមច្បាប់ សារការីដែលជួយការពារជម្លោះដែលអាចកើតមានរវាងភាគីនេះ មានសារៈសំខាន់ណាស់ ជាពិសេសនៅក្នុងបរិបទដែលវិវាទអាចមានរយៈពេលវែង និងចំណាយច្រើនក្នុងការដោះស្រាយ។ ប្រសិនបើមានការបាត់បង់ ការខូចខាត

26. មាត្រា ៤, ៥, ៨ និងមាត្រា១០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០០៧។

27. មាត្រា ៤, ៥, ៨ និងមាត្រា១០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០០៧។

ឬបំផ្លាញលិខិតសារការី សារការីមានកាតព្វកិច្ចធ្វើឱ្យឡើងវិញនូវលិខិតសារការីដោយអនុលោមតាមលិខិតសារការីដែលបានទទួលរងការបាត់បង់ ខូចខាត ឬត្រូវបានបំផ្លាញនោះ។

## ៣-អំពីប្រតិបត្តិការដែលត្រូវធ្វើឡើងដោយសារការី

ផ្អែកលើតួនាទីដ៏សំខាន់របស់សារការីដូចបានគូសបញ្ជាក់ខាងលើ, ក្រមរដ្ឋប្បវេណី និងច្បាប់ជាធរមានផ្សេងទៀតនៅកម្ពុជា បានតម្រូវឱ្យលិខិតគតិយុត្ត ឬកិច្ចព្រមព្រៀងក្នុងវិស័យមួយចំនួន ជាពិសេស ក្នុងវិស័យអចលនវត្ថុ និងបេតិកភ័ណ្ឌគ្រួសារ ត្រូវតែធ្វើឡើងក្នុងទម្រង់ជាលិខិតយថាភូតរបស់សារការី ដើម្បីអាចមានសុពលភាព និង/ឬអាចមានអានុភាពតតាំងចំពោះតតិយជន។

### ក-នៅក្នុងវិស័យនីតិអចលនវត្ថុ

រាល់កិច្ចសន្យាអនុប្បទានកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិកាន់កាប់អចលនវត្ថុ[28] ជាអាទិ៍ កិច្ចសន្យាលក់ទិញអចលនវត្ថុ[29] ការដូរ[30] ហ៊ីប៉ូតែក[31] ការបញ្ចាំអចលនវត្ថុ[32] និងប្រទានកម្ម[33] សន្តតិកម្ម និងបណ្តាំមតកសាសន៍ដោយលិខិតយថាភូត[34] តម្រូវឱ្យធ្វើឡើងក្នុងទម្រង់ជាលិខិតយថាភូត។ នៅក្នុងប្រទេសកម្ពុជា ដែលទីផ្សារអចលនទ្រព្យកំពុងមានសន្ទុះខ្លាំង សារការីដើរតួនាទីយ៉ាងសំខាន់ក្នុងការតាក់តែងកិច្ចសន្យាទិញលក់ ហើយសារការីត្រូវផ្ទៀងផ្ទាត់ដូចជាៈ

- មានការព្រមព្រៀងពិតប្រាកដរបស់គូភាគី ដោយមិនមានវិការៈ។

- អត្តសញ្ញាណរបស់គូភាគីដើម្បីបញ្ជាក់អំពីសមត្ថភាពរបស់ភាគីក្នុងការចាត់ចែងផ្ទេរសិទ្ធិកាន់កាប់ ឬសិទ្ធិកម្មសិទ្ធិបានដោយអនុលោមតាមច្បាប់។

28. កថាខណ្ឌទី២ នៃមាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
29. មាត្រា៥១៦ និងមាត្រា៥២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
30. មាត្រា៥៦៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
31. មាត្រា៨៤៥ និងមាត្រា៨៦២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
32. មាត្រា៨៣៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
33. មាត្រា៥៦៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
34. មាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។



- ផ្ទៀងផ្ទាត់អំពីឥណទានដែលយកមកប្រើប្រាស់នៅក្នុងប្រតិបត្តិការនៃការផ្ទេរប្រតិបត្តិការអចលនវត្ថុ និងថែរក្សានូវទ្រព្យមូលនិធិរបស់អតិថិជនដើម្បីធានាថានៅពេលដែលមានការផ្ទេរសិទ្ធិកាន់កាប់/សិទ្ធិកម្មសិទ្ធិរួចរាល់ហើយ ភាគីម្ខាងទៀតទទួលបានប្រាក់គ្រប់ចំនួន។

- ផ្ទៀងផ្ទាត់នូវរាល់ព័ត៌មានដើម្បីជៀសវាងប្រតិបត្តិការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដូចដែលច្បាប់បានហាមឃាត់។

- ផ្ទៀងផ្ទាត់តម្លៃទិញលក់ និងកំណត់យន្តការនៃការបង់ប្រាក់។

- កំណត់អត្តសញ្ញាណកម្មវត្ថុនៃកិច្ចសន្យា រួមមានឯកសារបញ្ជាក់ការកាន់កាប់ ឬបញ្ជាក់សិទ្ធិកម្មសិទ្ធិ ទីតាំង ទំហំ អត្ថិភាពនៃសេវភាព ផលុបភោគ ការបញ្ចាំ ហ៊ីប៉ូតែក ឬ សិទ្ធិប្រត្យក្សផ្សេងទៀតដែលដាក់បន្ទុកទៅលើអចលនវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ។

- រៀបរាប់និងពន្យល់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់គូភាគីទាំងសងខាងដោយអព្យាក្រឹត្យមិនលម្អៀង ធានានូវតុល្យភាពនៃផលប្រយោជន៍របស់គូភាគីទាំងសងខាង។

- ផ្ទៀងផ្ទាត់ខ្លឹមសារនូវរាល់លក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា និងធ្វើការចុះបញ្ជីអនុលោមទៅតាមលក្ខខណ្ឌទម្រង់ដែលតម្រូវដោយច្បាប់ដើម្បីធានានូវសុពលភាព និងអានុភាពនៃកិច្ចសន្យា។

តួនាទី និងកាតព្វកិច្ចរបស់សារការីក្នុងការផ្ទៀងផ្ទាត់ដូចរៀបរាប់ខាងលើនេះគឺដើម្បីធានានូវសុវត្ថិភាពគតិយុត្ត ធានានូវប្រសិទ្ធិភាពនៃប្រតិបត្តិការផ្ទេរសិទ្ធិកម្មសិទ្ធិដីធ្លី កាត់បន្ថយហានិភ័យនៃវិវាទដីធ្លី និងការក្លែងបន្លំឯកសារ ព្រមទាំងធានានូវការប្រមូលពន្ធរបស់រដ្ឋ។

### ខ- នៅក្នុងវិស័យនៃនីតិគ្រួសារ

ក្នុងនាមជាអ្នកជំនាញច្បាប់នៅក្នុងវិស័យនៃនីតិគ្រួសារ និងបេតិកភណ្ឌគ្រួសារ សារការីមិនត្រឹមតែផ្តល់ប្រឹក្សាយោបល់លើការរៀបចំតាក់តែងកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធមុនពេលរៀបអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ ប៉ុន្តែ សារការីក៏មានតួនាទីសំខាន់នៅអំឡុងពេលអាពាហ៍ពិពាហ៍ និងនៅពេលបញ្ចប់ចំណងអាពាហ៍ពិពាហ៍ដែលនាំឱ្យមានការជម្រះបញ្ជីទ្រព្យសម្បត្តិ ព្រមទាំងការផ្ទេរនូវទ្រព្យសម្បត្តិទាំងចលនទ្រព្យ និងអចលនទ្រព្យទៅឱ្យសន្តតិជនឬអច្ច័យលាភីរបស់ខ្លួន។ ក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ សារការីអាចផ្តល់ប្រឹក្សា

យោបល់ពីជម្រើសនៃការតាក់តែងប្រទានកម្ម ឬអច្ច័យទាន ការគ្រប់គ្រងបេតិកភណ្ឌ ជាអ្នកសម្រុះសម្រួលនៅក្នុងវិវាទគ្រួសារ ជាអ្នកតាក់តែងមតកសាសន៍ដោយលិខិតយថាភូត[35] ឬលិខិតសម្ងាត់[36] ឬមតកសាសន៍របស់បុគ្គលដែលមិនអាចនិយាយបានជាអាទិ៍[37] និងជាអ្នកជម្រះបញ្ជីនៅក្នុងពេលលែងលះ និងនៅក្នុងសន្តតិកម្ម។

ក្រមរដ្ឋប្បវេណី បានផ្ដល់នូវស្វ័យភាពដល់គូស្វាមីភរិយាក្នុងការជ្រើសរើសនូវប្រព័ន្ធទ្រព្យសម្បត្តិរបស់ខ្លួន[38]។ បើសិនជាសហព័ទ្ធមិនមានកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនោះទេ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់នឹងត្រូវយកមកអនុវត្ត[39]។ ការផ្ដល់ប្រឹក្សាច្បាប់ទាក់ទងនឹងការតាក់តែងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺមានសារៈសំខាន់ណាស់ចំពោះសហព័ទ្ធដែលជាពាណិជ្ជករ ម្ចាស់ក្រុមហ៊ុន អាជីវករ បុគ្គលដែលអនុវត្តវិជ្ជាជីវៈសេរី (ដូចជាការិយាល័យមេធាវី ឬមន្ទីរសារការី ឬគ្លីនីកឯកជន ។ល។) ឬ សហព័ទ្ធដែលមានកូនច្រើនដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍ផ្សេងៗគ្នា ព្រោះកិច្ចសន្យាប្រភេទនេះនឹងកំណត់ទុកជាមុនអំពីប្រភេទនៃទ្រព្យរបស់សហព័ទ្ធទាំងសងខាង អំពីសិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធទាំងពីរដើម្បីធានានូវសុវត្ថិភាពគតិយុត្តដល់កូនដូចដែលបានរៀបរាប់ខាងលើ និងការពារសហព័ទ្ធម្ខាងពីហានិភ័យនៃការរឹបអូសទ្រព្យដើម្បីទូទាត់បំណុលដែលកើតចេញពីការក្ស័យធនណាមួយរបស់សហព័ទ្ធម្ខាងទៀតដែលជាកូនបំណុល។

នៅពេលដែលចំណងអាពាហ៍ពិពាហ៍ត្រូវបានរលត់ សារការីក៏មានតួនាទីសំខាន់ដើម្បីធានាថាការផ្ទេរទ្រព្យសម្បត្តិពីមតកជនទៅសន្តតិជន ឬអច្ច័យលាភី ត្រូវបានប្រព្រឹត្តទៅដោយរលូន ទោះបីជាទៅតាមឆន្ទៈរបស់មតកជន ឬទៅតាមច្បាប់។ តាមរយៈគោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិដែលប្រកាន់យកដោយក្រមរដ្ឋប្បវេណីរបស់កម្ពុជា សន្តតិជនត្រូវទទួលបន្តនូវសិទ្ធិនិងករណីយកិច្ចទាំងអស់នៅពេលដែលមតកជនទទួលមរណភាព[40]។ ការផ្ទេរទ្រព្យសម្បត្តិពីមតកជនទៅកាន់បុគ្គលផ្សេងទៀតដែលអាចជាសន្តតិជន ឬអច្ច័យលាភីដោយសន្តតិកម្ម អាចត្រូវបានធ្វើឡើងទៅតាមឆន្ទៈរបស់មតកជនតាមរយៈបណ្ដាំមតកសាសន៍ ឬតាមច្បាប់បើសិនជាមតកជនមិនបានធ្វើបណ្ដាំ[41]។ ការជដែកបែងចែកមតក៏មិនតម្រូវឱ្យមានទម្រង់ជាក់លាក់ណាមួយឡើយ។ សន្តតិជនអាចធ្វើការជដែកពិភាក្សាបែងចែកមតក៏ដោយផ្ទាល់មាត់ក៏បាន។ ប៉ុន្តែទាក់ទងនឹងការផ្ទេរសិទ្ធិចំពោះវត្ថុ ច្បាប់តម្រូវឱ្យមានការធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗដែលចាំបាច់ក្នុងការផ្ទេរសិទ្ធិចំពោះវត្ថុនោះ[42]។ បើសិនជាការពិភាក្សាបែងចែកមតក៏រវាងសន្តតិជនពុំបានសម្រេច សន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមតក៏នោះបាន[43]។ សារការីដើរតួនាទីយ៉ាងសំខាន់ក្នុងសម្របសម្រួលរវាងសន្តតិជនដើម្បីឈានទៅដល់ការបែងចែកទ្រព្យសម្បត្តិប្រកបដោយសុខដុមរមនានៅក្នុងក្រុមគ្រួសារដែលជាកោសិកាដែលមិនអាចខ្វះបាននៅក្នុងសង្គម។ សារការីគឺជាអ្នកជំនាញច្បាប់ដែលទទួលបានការបណ្ដុះបណ្ដាលពិសេសទាក់ទងនឹងនីតិគ្រួសារ នីតិបេតិកភ័ណ្ឌគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិដែលទទួលបានប្រតិភូកម្មអំណាចពីរដ្ឋក្នុងតាក់តែងលិខិតយថាភូត និងលិខិតគតិយុត្តផ្សេងៗតាមការតម្រូវរបស់ច្បាប់ ឬ តាមការស្នើសុំរបស់បុគ្គល[44]។ ហេតុនេះ តាមការស្នើសុំរបស់សន្តតិជន ឬ អច្ច័យលាភី សារការីអាចដើរតួជាអ្នកជម្រះបញ្ជីតាមរយៈការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យរបស់មតកជន[45] ដើម្បីធ្វើការបែងចែកដល់សន្តតិជន ឬអច្ច័យលាភី តាមការព្រមព្រៀង ឬតាមច្បាប់ ឬតាមមតកសាសន៍។ បើសិនជាមានការព្រមព្រៀង និងស្នើសុំពីសន្តតិជនទាំងអស់ សារការីអាចចេញសេចក្ដីចម្លងលិខិតបញ្ជាក់លក្ខណៈសម្បត្តិជាសន្តតិជន[46] ឬលិខិតបញ្ជាក់អំពីអចលនវត្ថុក្រោមទម្រង់យថាភូត ឬកិច្ចព្រមព្រៀងបែងចែកមត៌ក ឬលិខិតប្រគល់សិទ្ធិពីសន្តតិជន

35. មាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
36. មាត្រា១១៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
37. មាត្រា១១៧៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
38. មាត្រា៩៦៩ និងមាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
39. មាត្រា ៩៧១ ដល់មាត្រា៩៧៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

40. មាត្រា១១៤៥ ដល់មាត្រា ១១៤៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
41. មាត្រា១១៥៧ ដល់មាត្រា ១១៦៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
42. មាត្រា ១២៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
43. មាត្រា ១២៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
44. មាត្រា ៣ នៃអនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៤ ស្ដីពីការបង្កើតមន្ទីរសារការី វាណិជ្ជនិងសហភាតានៃព្រះរាជាណាចក្រកម្ពុជា។
45. មាត្រា១២១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។
46. មាត្រា ៧៣០ កថាខណ្ឌ១ ដល់កថាខណ្ឌ៥ នៃក្រមរដ្ឋប្បវេណីបារាំង។

ម្នាក់ ឬច្រើនទៅសន្តតិជនណាម្នាក់ ឬបុគ្គលណាមួយទទួលចំណែកមត៌កជំនួស។ សេចក្ដីចម្លងលិខិតបញ្ជាក់លក្ខណៈសម្បត្តិជាសន្តតិជន គឺជាលិខិតដែលសារការីបញ្ជាក់អំពីសមាសភាពនៃសន្តតិជន និងចំណែកដែលសន្តតិជនត្រូវទទួលបាននូវចំណែកសន្តតិកម្មរបស់ខ្លួន។ រីឯលិខិតបញ្ជាក់អំពីអចលនវត្ថុក្រោមទម្រង់យថាភូត គឺជាលិខិតដែលសារការីបញ្ជាក់អំពីការផ្ទេរនូវសិទ្ធិកម្មសិទ្ធិលើអចលនទ្រព្យពីមតកជនទៅកាន់សន្តតិជនតាមច្បាប់ ឬអច្ច័យលាភីតាមបណ្ដាំមតកសាសន៍។ សារការីជាអ្នកទទួលបន្ទុកផ្ទៀងផ្ទាត់នូវវត្តមានមតកសាសន៍ ប្រទានកម្មដោយមូលហេតុមរណភាព ឬ អច្ច័យទាន ផ្ទៀងផ្ទាត់នូវលក្ខណៈសម្បត្តិរបស់សន្តតិជនតាមរយៈឯកសារអត្រានុកូលដ្ឋាន អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសាររបស់មតកជន សំបុត្រកំណើតលិខិតតំណវង្សត្រកូលមតកជន កិច្ចព្រមព្រៀងរបស់សហសន្តតិជន កិច្ចព្រមព្រៀងក្រុមប្រឹក្សាញាតិ ដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ព្រមទាំងសេចក្ដីថ្លែងអះអាងរបស់សន្តតិជន ឬបុគ្គលដែលពាក់ព័ន្ធ។ នៅក្នុងការអនុវត្តជាក់ស្ដែង លិខិតបញ្ជាក់លក្ខណៈសម្បត្តិជាសន្តតិជន ឬកិច្ចសន្យាស្ដីពីការបែងចែកមត៌កត្រូវបានសន្តតិជន ឬសហសន្តតិជនយកទៅប្រើប្រាស់ជាមួយនឹងក្រសួង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនធានារ៉ាប់រង ទាំងនៅក្នុង និងនៅក្រៅប្រទេស ដើម្បីទទួលបាននូវការផ្ទេរសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុ ឬការបង្វិលជាសាច់ប្រាក់សមតុល្យបន្ទាប់ពីការបំពេញទម្រង់ឯកសារដែលតម្រូវដោយគ្រឹះស្ថានទាំងនោះ។

បន្ថែមពីលើនេះទៀត វត្តមានរបស់សារការីគឺកាន់តែមិនអាចខ្វះបាននៅក្នុងការផ្ដល់ប្រឹក្សាយោបល់ និងតាក់តែងនូវបណ្ដាំមតកសាសន៍ដែលតាក់តែងឡើងដោយទម្រង់យថាភូត[47] និងមតកសាស៍ដោយលិខិតសម្ងាត់[48] ឬមតកសាសន៍របស់បុគ្គលដែលមិនអាចនិយាយបានជាអាទិ៍[49]។ សារការីអាចដើរតួជាអ្នកប្រតិបត្តិមតកសាសន៍ដែលអាចត្រូវបានកំណត់ដោយមតកសាសន៍[50] ឬដោយការជ្រើសតាំងដោយតុលាការ[51]។ ម្ចាស់បណ្ដាំទទួលបាននូវ

47. មាត្រា១១៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

48. មាត្រា១១៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

49. មាត្រា១១៧៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

50. មាត្រា១២១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

51. មាត្រា១២១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។



ការធានាថាឆន្ទៈពិតប្រាកដរបស់ខ្លួនត្រូវបានគោរពអនុវត្តតាមប្រកបដោយប្រសិទ្ធិភាព និងដោយរលូននៅពេលដែលខ្លួនទទួលមរណភាព តាមរយៈការទទួលបាននូវការប្រឹក្សាយោបល់ដោយល្អិតល្អន់ច្បាស់លាស់អំពីការលុបចោលឬការផ្ដាច់មត៌ក[52] ការកំណត់ចំណែកមត៌ក[53] ការកំណត់នូវវិធីបែងចែកមត៌ក[54] ការហាមឃាត់នូវការបែងចែកមត៌ក[55] ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ ការចាត់ចែងភាគបម្រុង និងភាគទំនេរនៃបេតិកភ័ណ្ឌរបស់ខ្លួនតាមរយៈអច្ច័យទានសកល ឬអច្ច័យទានពិសេស[56] ការបង្កើតវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ[57] ការកាត់កាល់ឬទទួលស្គាល់កូន[58] ការកំណត់អ្នកមានអាណាព្យាបាល[59] នៅក្នុងករណីការការពារអសមត្ថជន ដូចជាកូនអនីតិជន ឬមានពិការភាព ឬមិនមាននីតិសម្បទាគ្រប់គ្រាន់ក្នុងការប្រកបអាជីវកម្មដែលតម្រូវឲ្យមានជំនាញជាក់លាក់ណាមួយ។ ឯកសារច្បាប់ដើមនៃបណ្ដាំមតកសាសន៍ទាំងនោះ នឹងត្រូវតម្កល់នៅមន្ទីរសារការីប្រកបដោយសុវត្ថិភាពខ្ពស់។ ការបើកបណ្ដាំមតកសាសន៍ដោយលិខិតយថាភូតរបស់សារការី អាចត្រូវបានធ្វើឡើងនៅក្រៅតុលាការ។ ក្រៅពីនេះ អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ត្រូវដាក់ពាក្យសុំការបញ្ជាក់នៃលិខិត និងបើកលិខិតនៅតុលាការ។ បើមិនដូច្នេះទេ បុគ្គលនោះនឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១.០០០.០០០ (មួយលាន)រៀល[60]។ ការណ៍នេះសបញ្ជាក់ឲ្យឃើញអំពីតម្លៃនៃភាពជឿជាក់នូវលិខិតយថាភូតដែលតាក់តែងឡើងដោយសារការីដែលមានលក្ខណៈច្បាស់លាស់ និងជាក់លាក់។ ដើម្បីបើកបណ្ដាំមតកសាសន៍ដោយលិខិតយថាភូត ឬដោយលិខិតសម្ងាត់ អ្នកស្នើសុំដែលអាចជាសន្តតិជន ឬអច្ច័យលាភី ត្រូវស្នើទៅសារការីដោយភ្ជាប់នូវសេចក្ដីចម្លងសំបុត្រមរណភាពរបស់មតកជន ដើម្បីឱ្យសារការីធ្វើការកំណត់កាលបរិច្ឆេទបើក ជូនដំណឹង និងអញ្ជើញសន្តតិជន

52. មាត្រា១១៥១ ដល់មាត្រា១១៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

53. មាត្រា១១៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

54. មាត្រា១១៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

55. មាត្រា១១៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

56. មាត្រា១១៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

57. មាត្រា១១៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

58. មាត្រា៩៩៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

59. កថាខណ្ឌ១ នៃមាត្រា១០៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

60. មាត្រា១២១៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ឬអច្ច័យលាភី ព្រមទាំងសាក្សីដើម្បីចូលរួមបើកមតកសាសន៍នៅមន្ទីរសារការី។ នៅពេលបើកបណ្តាំមតកសាសន៍ សារការីនឹងធ្វើនូវឯកសារដូចជា៖ (១)- កំណត់ហេតុបើកមតកសាសន៍ និងសេចក្តីចម្លងកំណត់ហេតុជូនដល់សន្តតិជន អច្ច័យលាភី និងអ្នកប្រតិបត្តិមតកសាសន៍, (២)-សេចក្តីចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃមតកសាសន៍ជូនអ្នកប្រតិបត្តិមតកសាសន៍ ដើម្បីប្រើប្រាស់នៅតាមក្រសួង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនធានារ៉ាប់រង, (៣)-បញ្ជាក់លើពាក្យសុំផ្ទេរកម្មសិទ្ធិអចលនវត្ថុដោយមតកសាសន៍សម្រាប់សន្តតិជន ជូនអ្នកប្រតិបត្តិមតកសាសន៍ ដើម្បីដាក់ជូនមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី, (៤)-លិខិតបញ្ជាក់ការចាត់ចែងទ្រព្យផ្សេងទៀត ដូចជារថយន្ត គណនីធនាគារ ជាអាទិ៍ ជូនអ្នកប្រតិបត្តិមតកសាសន៍ ដើម្បីដាក់ជូនក្រសួងដែលមានសមត្ថកិច្ចពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង ជាដើម និង (៥)-លិខិតអមដែលភ្ជាប់ឯកសារពាក់ព័ន្ធនឹងសន្តតិកម្មទាំងមូលជូនអ្នកប្រតិបត្តិមតកសាសន៍។

### គ- នៅក្នុងនីតិក្រុមហ៊ុន

ការបង្កើត និងការផ្លាស់ប្តូរលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវធ្វើឡើងតាមទម្រង់លិខិតសារការី[61]ដែលអាចបង្កើតសុវត្ថិភាពផ្លូវច្បាប់ខ្ពស់ដល់ពាណិជ្ជករបាន។ អ្នកវិនិយោគមិនថាក្នុងស្រុក ឬបរទេស ត្រូវការការធានាសុវត្ថិភាពផ្នែកច្បាប់រឹងមាំ។ សារការីធានានូវអនុលោមភាពនៃឯកសាររបស់ក្រុមហ៊ុន សេចក្តីព្រាងលក្ខន្តិកៈ និងវិញ្ញាបនប័ត្រនៃកិច្ចសន្យាពាណិជ្ជកម្ម ដើម្បីលើកកម្ពស់បរិយាកាសនៃការជឿទុកចិត្តគ្នាលើប្រតិបត្តិការអាជីវកម្មនៃដៃគូវិនិយោគតាមរយៈការបញ្ជាក់ពីភាពស្របច្បាប់ និងសុពលភាពរបស់ឯកសារពាក់ព័ន្ធ។ សុវត្ថិភាពគតិយុត្ត និងទំនុកចិត្តគឺជាចលករមួយយ៉ាងសំខាន់ក្នុងការទាក់ទាញការវិនិយោគពីបរទេស និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា។

បន្ថែមពីនេះទៀត ដើម្បីធានានូវសុវត្ថិភាពក្នុងការថែរក្សា កាន់កាប់ គ្រប់គ្រង ចាត់ចែង និងផ្ទេរនូវទ្រព្យសម្បត្តិ ឬមូលនិធិនៅក្នុងគម្រោងវិនិយោគណាមួយ គម្រោងអភិវឌ្ឍន៍ណាមួយ

61. មាត្រា ៨២, ៩៧, ១០១ និងមាត្រា ១១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។



ដើម្បីជាផលប្រយោជន៍សាធារណៈ អង្គការ-សមាគម មនុស្សជាតិ ឬផលប្រយោជន៍របស់បុគ្គលជាក់លាក់ណាមួយដូចជាអនីតិជន ឬអសមត្ថជនផ្សេងទៀត ច្បាប់ស្តីពីបរធនបាលកិច្ចត្រូវបានបង្កើតឡើង[62]។ លិខិតបរធនបាលកិច្ច[63] មាន ២ ប្រភេទ គឺ លិខិតគតិយុត្តដែលកំណត់ជាអាទិ៍អំពីការបង្កើត ការគ្រប់គ្រង ការចាត់ចែង និងការបញ្ចប់បរធនបាលកិច្ច ដែលត្រូវបានធ្វើឡើងរវាងបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងបរធនបាល ដោយមានការបញ្ជាក់ពីសារការី ឬមេធាវី ឬមេឃុំ ចៅសង្កាត់ ឬដោយបុគ្គលផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន និងលិខិតមតកសាសន៍ដែលធ្វើឡើងស្របតាមបទប្បញ្ញត្តិស្តីពីសន្តតិកម្មនៃក្រមរដ្ឋប្បវេណី។ ដោយសារយន្តការនេះត្រូវបានបង្កើតឡើងដើម្បីបម្រើដល់ផលប្រយោជន៍ផ្សេងៗពីគ្នា បរធនបាលកិច្ចត្រូវបានបែងចែកជា ៤ ប្រភេទ[64] រួមមាន៖ ១-បរធនបាលកិច្ចពាណិជ្ជកម្ម, ២-បរធនបាលកិច្ចសាធារណៈ ៣-បរធនបាលកិច្ចសង្គម និង ៤-បរធនបាលកិច្ចបុគ្គល។ សេវារក្សាទុកទ្រព្យសម្បត្តិ ឬមូលនិធិដោយមន្ទីរសារការីដើម្បីផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិដោយបុគ្គលណាមួយឱ្យទៅបរធនបាល ហើយបរធនបាលត្រូវផ្ទេរត្រឡប់ឱ្យទៅបុគ្គលនោះវិញ ឬឱ្យទៅបុគ្គលណាមួយផ្សេងទៀត ត្រូវបានចាត់ទុកនៅក្នុងប្រភេទនៃបរធនបាលកិច្ចពាណិជ្ជកម្ម[65]។ ម្យ៉ាងទៀត អ្នកវិនិយោគិនបរទេសដែលមានបំណងធ្វើការវិនិយោគផ្នែកអចលនវត្ថុនៅក្នុងប្រទេសកម្ពុជា ក៏អាចជ្រើសរើសយកនូវយន្តការនៃបរធនបាលកិច្ចពាណិជ្ជកម្មនេះ ដើម្បីឱ្យបរធនបាលធ្វើការកាន់កាប់ទ្រព្យសម្បត្តិ ឬមូលនិធិតម្កល់ដើម្បីជាប្រយោជន៍របស់វិនិយោគិនអ្នកទិញអចលនវត្ថុ និងដើម្បីប្រតិបត្តិការពាណិជ្ជកម្មផ្សេងៗទៀត[66]។ ក្នុងករណីការពារកូនជាអនីតិជន ឬអសមត្ថជនផ្សេងទៀត ឬសន្តតិជនឬអច្ច័យលាភីដែលមិនមានជំនាញច្បាស់លាស់នៅក្នុងការទទួលនូវសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិដែលតម្រូវឱ្យមានជំនាញ និងបច្ចេកទេសជាក់លាក់ ឪពុកម្តាយ ឬអាណាព្យាបាល អាចជ្រើសរើសយកនូវយន្តការបរធនបាលនេះដើម្បីធ្វើ

62. ច្បាប់ស្តីពីបរធនបាលកិច្ច ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩។

63. មាត្រា១៣ នៃច្បាប់ស្តីបរធនបាលកិច្ច។

64. មាត្រា៩ នៃច្បាប់ស្តីបរធនបាលកិច្ច។

65. មាត្រា១០ កថាខណ្ឌ២ ចំណុច ក នៃច្បាប់ស្តីបរធនបាលកិច្ច។

66. មាត្រា១០ កថាខណ្ឌ២ ចំណុច ខ នៃច្បាប់ស្តីបរធនបាលកិច្ច។

ការគ្រប់គ្រងនូវទ្រព្យសម្បត្តិ ឬមូលនិធិរបស់ខ្លួន ហើយធ្វើការផ្ទេរនូវផល ឬទ្រព្យសម្បត្តិ ឬមូលនិធិទាំងនោះ ដើម្បីជាប្រយោជន៍ដល់បុគ្គលដូចដែលបានរៀបរាប់ខាងលើតាមរយៈការបង្កើតជាបរធនបាលកិច្ចសាធារណៈ[67]។ លិខិតបរធនបាលកិច្ចត្រូវធ្វើឡើងក្នុងទម្រង់លាយលក្ខណ៍អក្សរដែលត្រូវមានការបញ្ជាក់ពីសារការីដែលជាតួអង្គមួយក្នុងចំណោមតួអង្គផ្សេងទៀតដែលច្បាប់បានកំណត់[68]។

ក្រៅពីករណីខាងលើ សារការីក៏មានតួនាទីសំខាន់ផងដែរក្នុងការតាក់តែងកិច្ចសន្យាជាពិសេសកិច្ចសន្យាខ្ចីប្រាក់ ដែលលិខិតយថាភូតចំពោះករណីនេះ មានអានុភាពជាលិខិតអនុវត្តក្នុងករណីដែលបានបំពេញតាមលក្ខខណ្ឌដែលច្បាប់បានកំណត់។

ជារួម សារការីនៅកម្ពុជា បានចាប់ផ្ដើមចាក់ឫសឡើងវិញជាបណ្ដើរៗនៅក្នុងសង្គមកម្ពុជា ទោះបីជាវិជ្ជាជីវៈមួយនេះមិនទាន់ត្រូវទទួលស្គាល់យ៉ាងទូលំទូលាយក៏ដោយ។ ដោយបច្ចុប្បន្ន ចំនួនមន្ទីរសារការី, ចំនួនសារការី និងចំនួនមន្ត្រីទទួលបន្ទុកកិច្ចការសារការី នៅមានកំណត់ដែលមិនទាន់អាចឆ្លើយតបបានទាំងស្រុងទៅតម្រូវការរបស់ប្រជាពលរដ្ឋ, មេឃុំ ចៅសង្កាត់ និងអភិបាលក្រុង-ស្រុក-ខណ្ឌ បានបន្តដើរតួនាទីសំខាន់ ស្របតាមទំនៀមទម្លាប់របស់ច្បាប់កម្ពុជាតាំងពីបុរាណមក ក្នុងការបញ្ជាក់លើលិខិតផ្សេងៗ ជាអាទិ៍ លិខិតលក់ផ្ដាច់ អំណោយផ្ដាច់ កិច្ចសន្យាបញ្ចាំ ដាក់ធានា ហ៊ីប៉ូតែក កិច្ចសន្យាបង្កើតសេវភាព និងផលុបភោគ។ ដើម្បីលើកកម្ពស់វិជ្ជាជីវៈនេះ ច្បាប់ស្ដីពីលក្ខន្តិកៈសារការី នឹងត្រូវបង្កើតឡើងនាពេលខាងមុខ សម្រាប់ជាមូលដ្ឋានគតិយុត្តដ៏រឹងមាំក្នុងការគ្រប់គ្រងវិជ្ជាជីវៈនេះ ជាពិសេស ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនេះឱ្យបានល្អ ដើម្បីធានាថាសារការីនៅកម្ពុជាអនុវត្តមុខងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់ សំដៅធានាសុវត្ថិភាពគតិយុត្ត បង្ការ និងទប់ស្កាត់វិវាទ និងបង្កើនជំនឿទុកចិត្តលើប្រតិបត្តិការគតិយុត្ត ធានានូវតុល្យភាព តម្លាភាព ស្ថិរភាព និងសុខដុមរមនាភាពក្នុងសង្គម ព្រមទាំងការពារផលប្រយោជន៍របស់រដ្ឋ និងអ្នកប្រើប្រាស់សេវាសាធារណៈនៅក្នុងសង្គមនីតិរដ្ឋ។

---

67. មាត្រា១១ នៃច្បាប់ស្ដីបរធនបាលកិច្ច។
68. មាត្រា១៣ នៃច្បាប់ស្ដីបរធនបាលកិច្ច។



# ការបកស្រាយច្បាប់

ដោយ៖
-ឯកឧត្តម **ញាន វណ្ណៈ** រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យក្រសួងយុត្តិធម៌
-ឯកឧត្តម **សេង នាង** អនុប្រធានតុលាការកំពូល

ច្បាប់ គឺជាវិធានសម្រាប់គ្រប់គ្រងទំនាក់ទំនងក្នុងសង្គម សំដៅធានានូវសណ្តាប់ធ្នាប់សាធារណៈ និងស្វែងរកនូវឧត្តមគតិនៃយុត្តិធម៌។ ជាទូទៅ ច្បាប់មានលក្ខណៈទូទៅ អរូបីយ និងចាប់បង្ខំឱ្យបុគ្គលគ្រប់រូបនៅក្នុងសង្គមត្រូវតែប្រតិបត្តិតាម។ វិធានច្បាប់ត្រូវវិវត្តទៅតាមការវិវត្តរបស់សង្គម ដើម្បីអាចបន្តគ្រប់គ្រងទំនាក់ទំនងនៅក្នុងសង្គមបានល្អ។ ជាគោលការណ៍ ច្បាប់មានអានុភាពអនុវត្តតែចំពោះស្ថានភាពដែលនឹងកើតមាននាពេលអនាគតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន (អានុភាពមិនប្រតិសកម្មនៃច្បាប់)។ ភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយនៃវិធានច្បាប់ អាស្រ័យទៅលើកម្រិតនៃការសិក្សាអង្កេត និងការវិភាគនៅក្នុងដំណើរការនៃការបង្កើតវិធានច្បាប់ និងអាស្រ័យទៅលើការវិវត្តរបស់សង្គមផងដែរ ដែលមិនអាចត្រូវបានកំណត់ទុកមុនបានយ៉ាងច្បាស់លាស់ទាំងស្រុងនោះទេ។ ក្នុងបច្ចេកទេសនីតិកម្ម អ្នកតាក់តែងច្បាប់អាចរៀបចំនូវបទប្បញ្ញត្តិច្បាប់ដែលមានអត្ថន័យទូលាយអាចបកស្រាយបានច្រើនបែបទៅតាមស្ថានភាពសេដ្ឋកិច្ច-សង្គមដែលមានការវិវត្តជាប្រចាំ ដើម្បីចៀសវាងភាពមិនគ្រប់ជ្រុងជ្រោយរបស់ច្បាប់។ ប៉ុន្តែ ជាក់ស្តែង ដោយសារការវិវត្តយ៉ាងលឿនរបស់សង្គម និងបច្ចេកវិទ្យា វិធានច្បាប់មួយដែលសមស្របនៅក្នុងដំណាក់កាល ឬសម័យកាលមួយ អាចប្រែទៅជាមានភាពមិនសមស្របទៅវិញនាពេលអនាគត។ ទន្ទឹមនេះ វិធានច្បាប់ផ្សេងៗក៏អាចមិនមានសង្គតិភាពនឹងគ្នាទាំងស្រុងនោះដែរ។ ក្នុងន័យនេះ មិនមានច្បាប់ណាដែលមានភាពល្អឥតខ្ចោះ និងច្បាស់លាស់គ្រប់ជ្រុងជ្រោយទាំងស្រុងនោះទេ។ ភាពមិនច្បាស់លាស់ ឬភាពខ្វះចន្លោះ ឬភាពមិនគ្រប់ជ្រុងជ្រោយនៃវិធានច្បាប់ គឺជាសារជាតិផ្ទាល់របស់ច្បាប់ ហើយតែងត្រូវបានទទួលស្គាល់ដោយនីតិករផងដែរ។ ជាក់ស្តែង កថាខណ្ឌទី ២ នៃមាត្រា ៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាឆ្នាំ ១៩៩៣ ចែងថា "ក្នុងរឿងរដ្ឋប្បវេណី ***បើច្បាប់ចែងមិនច្បាស់ ឬច្បាប់មិនបានចែង*** ត្រូវជំនុំជម្រះដោយផ្អែកទៅតាមទំនៀមទម្លាប់ ប្រពៃណី វិចារណញ្ញាណ ឬសមធម៌"។ ការណ៍នេះទាមទារឱ្យមានការបកស្រាយច្បាប់ និងការទាញហេតុផលគតិយុត្តដ៏សមស្រប និងសមហេតុផលមួយនៅក្នុងការអនុវត្តជាក់ស្តែង។

ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ការបកស្រាយច្បាប់បានក្លាយជាប្រធានបទពិភាក្សាដ៏ផុសផុលមួយនៅក្នុងទ្រឹស្តីនៃនីតិ ហើយកិច្ចពិភាក្សានេះធ្វើឡើងក្នុងគោលបំណងកំណត់ឱ្យបាននូវវិធីសាស្ត្រ បច្ចេកទេស ក៏ដូចជាវិធាននៃការបកស្រាយច្បាប់។ តើអ្វីទៅជាការបកស្រាយច្បាប់? តើនរណាខ្លះជាអ្នកមានសិទ្ធិក្នុងការបកស្រាយច្បាប់ ហើយតើការបកស្រាយនេះមានអានុភាពចាប់បង្ខំសម្រាប់ការអនុវត្តដែរឬទេ? តើវិធីសាស្ត្របកស្រាយច្បាប់មានអ្វីខ្លះ? និង តើការបកស្រាយច្បាប់ត្រូវគោរពតាមវិធាន ឬគោលការណ៍អ្វីខ្លះ?

## ១. សញ្ញាណនៃការបកស្រាយច្បាប់

ការបកស្រាយច្បាប់ គឺជាប្រតិបត្តិការខាងប្រាជ្ញាដែលត្រូវបានធ្វើឡើងដើម្បីកំណត់ ឬបញ្ជាក់ពីអត្ថន័យនៃវិធានគតិយុត្តមួយ។ តាមលោក Hans Kelsen ការបកស្រាយច្បាប់មាន ២ ប្រភេទ គឺ**ការបកស្រាយដែលមានយថាភូតភាព** (Interprétation authentique) និង**ការបកស្រាយដែលមិនមានយថាភូតភាព** (Interprétation non-authentique)។ ការបកស្រាយដែលមានយថាភូតភាព សំដៅដល់ការបកស្រាយច្បាប់ដោយស្ថាប័នមានសមត្ថកិច្ចក្នុងការបកស្រាយច្បាប់។ ដោយឡែក ការបកស្រាយដែលមិនមានយថាភូតភាព ជាការបកស្រាយដោយបុគ្គលផ្សេងដែលមិនមានតួនាទីក្នុងការបកស្រាយច្បាប់។ អានុភាពនៃការបកស្រាយច្បាប់ គឺអាស្រ័យទៅលើសមត្ថកិច្ចរបស់អ្នកបកស្រាយច្បាប់។ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការបកស្រាយច្បាប់ រួមមាន ក្រុមប្រឹក្សាធម្មនុញ្ញ និងថៅក្រម។ មាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ដែលកំណត់អំពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា *"ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ"*។ លើសពីនេះ កថាខណ្ឌទី២ នៃមាត្រា១៤២ ថ្មី ចែងថា "សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចបិទផ្លូវតវ៉ា"។ ផ្អែកតាមមាត្រាទាំង ២ នេះ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នតែមួយគត់ដែលមានសិទ្ធិបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗដែលរដ្ឋសភាអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ក្នុងគោលបំណងធានាធម្មនុញ្ញភាពនៃច្បាប់ទាំងនោះ។ នៅពេលដែលច្បាប់ចូលជាធរមាន ថៅក្រម គឺជាតួអង្គដ៏សំខាន់បំផុតនៅក្នុងប្រតិបត្តិការបកស្រាយច្បាប់។ ការបកស្រាយច្បាប់ជាផ្នែកមួយដ៏សំខាន់នៃដំណើរការធ្វើវិចារណកិច្ចគតិយុត្តរបស់ថៅក្រម។ ក្រៅពីថៅក្រម តួអង្គផ្សេងទៀត ដូចជា នីតិករខ្លួនឯងផ្ទាល់ អាជ្ញាធររដ្ឋបាល និងអ្នកច្បាប់ទូទៅ

ក៏អាចធ្វើការបកស្រាយច្បាប់បានដែរ។ នៅក្នុងបណ្តាប្រទេសធំៗដូចជា អង់គ្លេស អូស្ត្រាលី កាណាដា ឬសហរដ្ឋអាម៉េរិក ជាដើម គេអាចអនុម័តច្បាប់មួយដើម្បីមកបកស្រាយភាពមិនច្បាស់លាស់របស់ច្បាប់ជាធរមាន។ ច្បាប់បកស្រាយនេះ មានអានុភាពគិតចាប់តាំងពីថ្ងៃដែលច្បាប់ដែលត្រូវបកស្រាយចូលជាធរមាន។

ការបកស្រាយច្បាប់ ខុសគ្នាពីការប្រើឆន្ទានុសិទ្ធិរបស់ចៅក្រម និងការបំពេញភាពខ្វះចន្លោះ ឬអវត្តមានរបស់ច្បាប់។ ឆន្ទានុសិទ្ធិ គឺជាអំណាចដែលប្រគល់ឱ្យចៅក្រមជ្រើសយកមធ្យោបាយណាមួយតាមការវាយតម្លៃរបស់ខ្លួនមកដោះស្រាយបញ្ហាណាមួយ[1]។ ជារឿយៗ ច្បាប់តែងផ្តល់សិទ្ធិក្នុងការវាយតម្លៃនេះទៅឱ្យចៅក្រម ដើម្បីផ្តល់នូវដំណោះស្រាយទៅតាមករណីជាក់ស្តែងនីមួយៗ។ នៅក្នុងមាត្រាច្បាប់ គេតែងឃើញនីតិករប្រើឃ្លា *“តុលាការអាច, ឬតុលាការមិនអាច ឬតុលាការត្រូវ...”* ជាដើម ដើម្បីផ្តល់សិទ្ធិក្នុងការវាយតម្លៃដោយឆន្ទានុសិទ្ធិនេះឱ្យទៅចៅក្រម។ ការវាយតម្លៃដោយឆន្ទានុសិទ្ធិនេះ មិនមែនជាការបកស្រាយច្បាប់នោះទេ។ ជាឧទាហរណ៍ កថាខណ្ឌទី៣ នៃមាត្រា ៤០៣ នៃក្រមរដ្ឋប្បវេណី ចែងថា *“ក្នុងករណីដែលភាគីទាំងសងខាងបានធ្វើការសន្យាពិសេសអំពីចំនួននៃសំណងការខូចខាត តុលាការមិនអាចបន្ថែម ឬបន្ថយចំនួននោះបានទេ។ ប៉ុន្តែ ក្នុងករណីដែលចំនួនទឹកប្រាក់ដែលភាគីទាំងសងខាងបានកំណត់ជាមុននោះច្រើនហួសហេតុពេក ឬតិចហួសហេតុពេក បើប្រៀបធៀបទៅនឹងការខូចខាតដែលត្រូវបានកំណត់តាមបញ្ញត្តិនៃមាត្រា ៤០១ (ទំហំនៃសំណងការខូចខាត) ខាងលើនេះ ទើបតុលាការអាចបន្ថែម ឬបន្ថយនូវប្រាក់សំណងដែលបានកំណត់ជាមុនបាន”*។ ផ្អែកតាមច្បាប់ គូភាគីអាចកំណត់ជាមុននូវចំនួនទឹកប្រាក់នៃសំណងដោយមិនគិតអំពីទំហំនៃការខូចខាត ហើយជាគោលការណ៍ ចំនួនទឹកប្រាក់នេះមិនអាចត្រូវបានកែប្រែបានឡើយ លើកលែងតែចៅក្រមយល់ថា ចំនួនទឹកប្រាក់នេះ ច្រើនហួសហេតុពេក ឬតិចហួសហេតុពេក បើធៀបនឹងការខូចខាតជាក់ស្តែង។ ច្បាប់មិនបានកំណត់អំពីចំនួនទឹកប្រាក់ដែលអាចជាចំនួន “ច្រើនហួសហេតុពេក ឬតិចហួសហេតុពេក” នោះទេ ប៉ុន្តែ ច្បាប់បានបញ្ជាក់យ៉ាងច្បាស់ថា ចំនួនច្រើនហួសហេតុពេក ឬតិចហួសហេតុពេក

[1]. សទ្ទានុក្រមពាក្យច្បាប់រៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧ ទំព័រទី១០។



នេះ ត្រូវវាយតម្លៃដោយប្រៀបធៀបទៅនឹងការខូចខាតទាំងឡាយដែលច្បាប់ទទួលស្គាល់។ ភាពច្បាស់លាស់នៃមាត្រានេះ មិនអនុញ្ញាតឱ្យតុលាការធ្វើការបកស្រាយនោះទេ តែផ្តល់សិទ្ធិឱ្យតុលាការធ្វើការវាយតម្លៃដោយឆន្ទានុសិទ្ធិទៅតាមករណីជាក់ស្តែងនីមួយៗ។

ការបកស្រាយច្បាប់ ក៏ខុសពីការបំពេញភាពខ្វះចន្លោះរបស់ច្បាប់ផងដែរ។ ជាទ្រឹស្តីច្បាប់ ខុសពីប្រព័ន្ធ Common Law ចៅក្រមនៅក្នុងបណ្តាប្រទេសនៃប្រព័ន្ធច្បាប់ Civil Law មានតួនាទីត្រឹមតែជាអ្នកអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ និងការបកស្រាយច្បាប់ប៉ុណ្ណោះ[2]។ ការអនុវត្តច្បាប់ និងការបកស្រាយច្បាប់ កើតមានក្នុងករណីដែលមានច្បាប់ចែង ឬច្បាប់ចែងមិនច្បាស់។ ក្នុងករណីដែលមិនមានច្បាប់ចែង គេមិនអាចនិយាយបានថាជាការបកស្រាយច្បាប់នោះទេ។ កថាខណ្ឌទី ២ នៃមាត្រា ៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាឆ្នាំ ១៩៩៣ ចែងថា *“ក្នុងរឿងរដ្ឋប្បវេណី បើច្បាប់ចែងមិនច្បាស់ ឬច្បាប់មិនបានចែង ត្រូវជំនុំជម្រះដោយផ្អែកទៅតាមទំនៀមទម្លាប់ ប្រពៃណី វិចារណញ្ញាណ ឬសមធម៌”*។ ចៅក្រមមិនអាចបដិសេធមិនជំនុំជម្រះ ដោយសារច្បាប់មិនចែងនោះទេ។ ក្នុងករណីនេះ ចៅក្រមត្រូវតែជំនុំជម្រះដោយត្រូវបំពេញបន្ថែមភាពចន្លោះប្រហោង ឬអវត្តមានរបស់ច្បាប់ ដោយផ្អែកតាមទំនៀមទម្លាប់[3] ប្រពៃណី ឬសមធម៌។ ចៅក្រមអាចទាញចេញពីគោលការណ៍សមធម៌នេះ នូវវិធានមួយដើម្បីដោះស្រាយវិវាទ ហើយវិធាននោះអាចក្លាយជាយុត្តិសាស្ត្រដែលជាប្រភពដ៏សំខាន់មួយនៃនីតិផងដែរ។ ជារួម ការបំពេញបន្ថែមភាពចន្លោះប្រហោង ឬអវត្តមានរបស់ច្បាប់នេះ មិនមែនជាប្រតិបត្តិការបកស្រាយច្បាប់ទេ ប៉ុន្តែ ជាប្រតិបត្តិការបង្កើតវិធានគតិយុត្ត។ បើទោះបីជាអ្នកច្បាប់ក្នុងប្រព័ន្ធ Civil Law បានអះអាងថា ចៅក្រមមិនមែនជាអ្នកបង្កើតច្បាប់[4]

[2]. មាត្រា ១២៩ ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចែងថា “...ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពតាមច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន”។

[3]. Béatrice BALIVET “សេចក្តីផ្តើមនៃនីតិកម្ពុជា”, PUC, រោងពុម្ព Funan, ២០០៥, ទំព័រ.២៥។

[4]. នៅក្នុងសៀវភៅស្តីពី “De l'esprit des lois” អ្នកនិពន្ធលោក Charlet-Louis de Secondat, Baron de la Brede et de Montesquieu បានសរសេរនៅក្នុងឆ្នាំ១៧៤៨ ថា ចៅក្រមគ្រាន់ជាមាត់សម្រាប់និយាយពីពាក្យពេចន៍របស់ច្បាប់តែប៉ុណ្ណោះ។ សូមអានលម្អិតនៅក្នុង Charlet DE SECONDAT, Baron de Montesquieu, De l'esprit des lois: les grands thémes, édité par J.P MAYER et A.P KAN, Paris, Gallimard, 1970, p.178.

ពោលគឺយុត្តិសាស្ត្រ[5] មិនមែនជាប្រភពនៃនីតិក៏ដោយ[6] យើងត្រូវទទួលស្គាល់ផងដែរថា ចៅក្រមក៏បាន និងកំពុងដើរតួនាទីជាអ្នកបង្កើតវិធានគតិយុត្តផងដែរ ពិសេសក្នុងករណីដែលច្បាប់មិនបានចែង។

## ២. វិធីសាស្ត្រក្នុងការបកស្រាយច្បាប់

កន្លងមក អ្នកច្បាប់មិនទាន់មានការឯកភាពគ្នាទាំងស្រុងលើវិធីសាស្ត្រក្នុងការបកស្រាយច្បាប់នោះទេ។ ប៉ុន្តែ ទោះជាយ៉ាងណាមានវិធីសាស្ត្រមួយចំនួនត្រូវបានប្រើប្រាស់ជាទូទៅក្នុងការបកស្រាយច្បាប់នៅក្នុងគ្រប់បណ្តាប្រព័ន្ធនៃនីតិទាំងអស់ ដែលវិធីសាស្ត្រទាំងនោះរួមមាន៖ *(ក)*-វិធីសាស្ត្របកស្រាយច្បាប់ទៅតាមវិធានអក្សរសាស្ត្រ, *(ខ)* -វិធីសាស្ត្របកស្រាយរួមគ្នាជាប្រព័ន្ធ និង *(គ)* -វិធីសាស្ត្របកស្រាយទៅតាមស្មារតីនៃច្បាប់។

### ក. ការបកស្រាយទៅតាមវិធានអក្សរសាស្ត្រ

នៅក្នុងការតាក់តែងច្បាប់ ពាក្យពេចន៍នីមួយៗត្រូវបានជ្រើសរើសដោយផ្ចិតផ្ចង់។ ពាក្យពេចន៍ទាំងនេះ គឺជាឧបករណ៍ដែលនីតិករប្រើដើម្បីបង្ហាញពីវិធានច្បាប់ដែលនឹងត្រូវកំណត់។ ការប្រើប្រាស់ពាក្យនីមួយៗ មិនមែនជារឿងចៃដន្យនោះទេ។ ហេតុនេះ ការបកស្រាយច្បាប់ត្រូវផ្តើមចេញពីការពិនិត្យទៅលើពាក្យពេចន៍ និងឃ្លាប្រយោគនៃអត្ថបទច្បាប់ផ្ទាល់តែម្តង។ ពាក្យពេចន៍នៅក្នុងច្បាប់ អាចជា ពាក្យធម្មតា ពាក្យច្បាប់ និងជាពាក្យបច្ចេកទេស។ ជាគោលការណ៍ច្បាប់បង្កើតឡើងសម្រាប់មនុស្សទូទៅ។ ក្នុងន័យនេះ ក្រៅពីសញ្ញាណគតិយុត្ត និងវាក្យសព្ទគតិយុត្ត អ្នកបកស្រាយច្បាប់ ត្រូវបកស្រាយពាក្យ *(អាច/ត្រូវតែ...)* អាយតនិបាត *(នឹង/និង/ឬ)* គុណនាម ឬគុណកិរិយានីមួយៗ *(ដោយច្បាស់, តាមទម្លាប់)* ដែលមានក្នុងអត្ថបទច្បាប់ ទៅតាម

[5]. ក្នុងន័យដើម យុត្តិសាស្ត្រគឺជាវិទ្យាសាស្ត្រនៃនីតិ។ យុត្តិសាស្ត្រ សំដៅទៅលើដំណោះស្រាយទាំងឡាយដែលអ្នកច្បាប់សម័យបុរាណបង្កើតឡើងនៅក្នុងការអនុវត្តការងាររបស់ខ្លួន។ បច្ចុប្បន្ន ពាក្យយុត្តិសាស្ត្រមានអត្ថន័យច្រើនបែបយ៉ាង។ ក្នុងន័យទូលាយ យុត្តិសាស្ត្រ គឺជាបណ្តាសេចក្តីសម្រេចទាំងឡាយរបស់តុលាការ។ ក្នុងន័យចង្អៀត យុត្តិសាស្ត្រសំដៅលើសេចក្តីសម្រេចផ្សេងៗជាច្រើនរបស់តុលាការដែលបានសម្រេច ដោយមានលក្ខណៈស៊ីសង្វាក់គ្នាគ្រប់គ្រាន់លើបញ្ហាច្បាប់ណាមួយដូចគ្នា”។ សូមអានលម្អិតអំពីយុត្តិសាស្ត្រនៅក្នុងសៀវភៅ “សេចក្តីផ្តើមនៃនីតិកម្ពុជា”, PUC, រោងពុម្ព Funan, ២០០៥, ទំព័រ ៨៩-៩៣។

[6]. “សេចក្តីផ្តើមនៃនីតិកម្ពុជា”, PUC, រោងពុម្ព Funan, ២០០៥, ទំព័រ.២៦, ទំព័រ ៨៩-៩៣។



ន័យនៃភាសាអក្សរសាស្ត្រដែលប្រើប្រាស់ជាទូទៅ។ អ្នកបកស្រាយច្បាប់សន្មតថានីតិករប្រើប្រាស់ពាក្យនីមួយៗក្នុងន័យអក្សរសាស្ត្រទូទៅ។ ប៉ុន្តែ ដើម្បីចៀសវាងនូវការបកស្រាយជាបច្ចេកទេសនីតិកម្ម នីតិករតែងកំណត់និយមន័យនៃវាក្យសព្ទគតិយុត្តសំខាន់ៗនៅក្នុងច្បាប់។ បច្ចេកទេសនីតិកម្មនេះ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងច្បាប់ខ្មែរ។ ហេតុដូចនេះ ចំពោះវាក្យសព្ទគតិយុត្ត ការបកស្រាយត្រូវយកតាមខ្លឹមសារដែលច្បាប់បានកំណត់ទុកជាមុន។ ដូចគ្នាផងដែរចំពោះពាក្យបច្ចេកទេសក្នុងវិស័យឯកទេសណាមួយ ត្រូវបកស្រាយក្នុងន័យបច្ចេកទេសនោះផងដែរ។ មានន័យថា ប្រសិនបើអត្ថន័យនៃពាក្យមួយមិនត្រូវបានកំណត់ដោយច្បាប់ ឬមិនមានអត្ថន័យបច្ចេកទេសជាក់លាក់នោះទេ យើងត្រូវប្រើប្រាស់វចនានុក្រមអក្សរសាស្ត្រខ្មែរ ដើម្បីកំណត់អត្ថន័យនៃពាក្យនោះ។ វិធីសាស្ត្រនេះត្រូវបានទទួលស្គាល់ និងប្រើជាសាកល[7] ដោយចៅក្រមទាំងនៅក្នុងប្រព័ន្ធច្បាប់ Civil Law ទាំងនៅក្នុងប្រព័ន្ធច្បាប់ Common Law។ នៅក្នុងប្រព័ន្ធ Common Law វិធីសាស្ត្របកស្រាយនេះ ហៅថា “Plain Meaning Rule”។ វិធីសាស្ត្រនេះ ត្រូវបានប្រើប្រាស់នៅសហរដ្ឋអាមេរិក តាំងពីឆ្នាំ ១៩១៧ ក្នុងសំណុំរឿង Caminetti v. United State[8]។

ជាឧទាហរណ៍ កថាខណ្ឌទី ១ នៃមាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណី ចែងថា *“ប្តីប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម”*។ ក្នុងការបកស្រាយតាមវិធានអក្សរសាស្ត្រ ពាក្យ **“ក្នុងការ”** នៃមាត្រា ៩៧៤ នេះ ជាអាយតនិបាត និងធ្វើឱ្យមាត្រានេះមានន័យថា ប្តីប្រពន្ធមានសិទ្ធិស្មើគ្នា “ក្នុងការប្រើប្រាស់”, សិទ្ធិស្មើគ្នា “ក្នុងការទទួលផលប្រយោជន៍” និងសិទ្ធិស្មើគ្នា “ក្នុងការគ្រប់គ្រង” ទ្រព្យសម្បត្តិរួម។ ក្នុងន័យនេះ តាមលក្ខណៈអក្សរសាស្ត្រ “សិទ្ធិស្មើគ្នា” នេះ ត្រូវតែបកស្រាយក្នុងន័យតែមួយចំពោះសកម្មភាព ឬកិច្ចទាំងបី

[7]. Lucie Lauzire, L'interprétation des lois, Aout 2012, p.17។

[8]. នៅក្នុងសំណុំរឿង Caminetti v. United State, ចៅក្រមបានសម្រេចថា "it is elementary that the meaning of a statute must, in the first instance, be sought in the language in which the act is framed, and if that is plain... the sole function of the courts is to enforce it according to its terms." And if a statute's language is plain and clear, the Court further warned that "the duty of interpretation does not arise, and the rules which are to aid doubtful meanings need no discussion"។

ខាងលើ។ ដោយឡែក ពាក្យ "ទ្រព្យសម្បត្តិរួម" គឺជាពាក្យច្បាប់ដែលត្រូវបានកំណត់នៅក្នុងមាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណី ដែលបានបញ្ញត្តិនូវទ្រព្យសម្បត្តិណាខ្លះជាទ្រព្យសម្បត្តិរួម។

វិធីសាស្ត្របកស្រាយច្បាប់តាមវិធានអក្សរសាស្ត្រនេះ ពឹងផ្អែកទាំងស្រុងលើសម្មតិកម្មដែលថា នីតិករបានប្រើប្រាស់ពាក្យ គុណនាម គុណកិរិយា ឬសញ្ញាវណ្ណយុត្ត ជាដើម បានយ៉ាងច្បាស់លាស់ និងត្រឹមត្រូវតាមក្បួនវេយ្យាករណ៍អក្សរសាស្ត្រ។ លើសពីនេះ ក្នុងការអនុវត្តវិធីសាស្ត្រនេះ យើងអាចសន្មតបានថា អត្ថបទច្បាប់អាចបង្ហាញយ៉ាងច្បាស់នូវផ្នត់គំនិតរបស់នីតិករ។ នៅក្នុងប្រព័ន្ធ Civil Law ប្រសិនបើនីតិករបានប្រើប្រាស់ពាក្យច្បាស់ និងមានន័យច្បាស់លាស់ហើយនោះថៅក្រមត្រូវអនុវត្តតាមខ្លឹមសារនោះ។ ដោយឡែក នៅក្នុងបណ្តាប្រទេសមួយចំនួននៃប្រព័ន្ធច្បាប់ Common Law ថៅក្រមអាចធ្វើការកែប្រែអត្ថន័យធម្មតានៃពាក្យ ដើម្បីចៀសវាងភាពមិនច្បាស់លាស់ ឬភាពមិនសមហេតុផលដែលអាចសំដែងចេញមកយ៉ាងច្បាស់នៅក្នុងការអនុវត្ត។ វិធាននៃការបកស្រាយនេះ ត្រូវបានគេឱ្យឈ្មោះថាជាវិធាន "Golden Rule"[៩]។ កម្រិតនៃភាពមិនច្បាស់លាស់ ឬភាពមិនសមហេតុផល ដែលចាំបាច់សម្រាប់ការអនុវត្តវិធាន Golden Rule នេះ ត្រូវកំណត់ដោយថៅក្រមទៅតាមករណីនីមួយៗ។

### ខ-ការបកស្រាយរួមបញ្ចូលគ្នាជាប្រព័ន្ធ

ច្បាប់ គឺជាសំណុំនៃបទប្បញ្ញត្តិ ឬវិធានគតិយុត្តជាច្រើន។ តាមតក្កវិជ្ជា បទប្បញ្ញត្តិទាំងនោះត្រូវមានភាពស៊ីចង្វាក់គ្នា និងបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ អត្ថន័យរបស់បទប្បញ្ញត្តិមួយនៃច្បាប់ អាចត្រូវបានយល់ច្បាស់ដោយផ្អែកលើបទប្បញ្ញត្តិផ្សេងទៀតនៃច្បាប់ដដែលនោះ។ ក្នុងន័យនេះ ការបកស្រាយច្បាប់មួយក៏ត្រូវធ្វើយ៉ាងណាធានាឱ្យបាននូវសង្គតិភាព ឬភាពស៊ីចង្វាក់ផ្ទៃក្នុងរបស់ច្បាប់នោះផងដែរ។ ជាឧទាហរណ៍ពាក់ព័ន្ធនឹងសិទ្ធិរបស់ប្តីប្រពន្ធលើទ្រព្យសម្បត្តិរួមដដែល បើយើងពិនិត្យត្រឹមកថាខណ្ឌទី១ នៃមាត្រា៩៧៤ នៃក្រមរដ្ឋប្បវេណី ដែលចែងថា *"ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និងគ្រប់គ្រងទ្រព្យសម្បត្តិរួម"*, ធ្វើឱ្យយើងចោទសួរបានថា ប្រសិនបើប្តីប្រពន្ធមានសិទ្ធិស្មើគ្នា ក្នុងការប្រើប្រាស់ ក្នុងការទទួលផលប្រយោជន៍ និងក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរួម តើមានន័យថា ប្តី ឬប្រពន្ធអាចប្រើប្រាស់ ឬគ្រប់គ្រង ឬ ចាត់ចែងទ្រព្យរួមតែឯកឯងដោយសេរី និងដោយមិនចាំបាច់មានការចូលរួម ឬការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬចាំបាច់ត្រូវតែមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតជាដាច់ខាតចំពោះគ្រប់ករណីទាំងអស់? តើសិទ្ធិស្មើគ្នានេះ សំដៅសិទ្ធិក្នុងចំណែក ៥០% ឬសិទ្ធិក្នុងចំណែក ១០០% ដូចៗគ្នា។ បើសិទ្ធិស្មើគ្នាក្នុងន័យ ៥០% ម្នាក់ គឺចាំបាច់ត្រូវតែមានការព្រមព្រៀងគ្នាក្នុងគ្រប់ករណី។ តែបើសិទ្ធិស្មើគ្នានេះក្នុងន័យ ១០០% វិញ នោះមិនចាំបាច់មានការព្រមព្រៀងគ្នាជាមុននោះទេក្នុងគ្រប់ករណី។ ការបកស្រាយលើអត្ថន័យនៃកថាខណ្ឌទី១ នៃមាត្រា៩៧៤ នេះត្រូវផ្អែកបន្ថែមលើកថាខណ្ឌបន្តបន្ទាប់នៃមាត្រា៩៧៤ ដដែលនេះ ដែលក្នុងនោះកថាខណ្ឌទី២ កំណត់ថា *"សហព័ទ្ធមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួមនៅក្នុងទំហំដែលចាំបាច់ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព"* ដែលនេះមានន័យសិទ្ធិស្មើគ្នាសម្រាប់សិទ្ធិប្រើប្រាស់ គឺមានន័យថា ១០០% ដូចគ្នា និង កថាខណ្ឌទី៣ ដែលកំណត់ថា *"សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា"* ដែលនេះមានន័យថា សិទ្ធិស្មើគ្នាក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរួម គឺ ៥០% ម្នាក់ ហើយទាមទារឱ្យមានការព្រមព្រៀងគ្នាជាមុនរវាងប្តីប្រពន្ធ។

### គ- ការបកស្រាយទៅតាមឆន្ទៈរបស់នីតិករ ឬស្មារតីរបស់ច្បាប់

ស្មារតីរបស់ច្បាប់ គឺជាហេតុផល (ratio legis) នៃការបង្កើតច្បាប់។ រាល់ច្បាប់ទាំងអស់សុទ្ធតែមានគោលដៅ និងគោលបំណង។ បទប្បញ្ញត្តិច្បាប់ គ្រាន់តែជាមធ្យោបាយមួយដែលនីតិករប្រើដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃគោលនយោបាយគតិយុត្តរបស់ខ្លួនតែប៉ុណ្ណោះ។ ការអនុវត្តច្បាប់ត្រូវតែធ្វើឡើងឱ្យស្របទៅតាមស្មារតីរបស់ច្បាប់ ឬឆន្ទៈរបស់នីតិករ។ ហេតុដូចនេះ ការបកស្រាយច្បាប់ ក៏ត្រូវតែធ្វើឡើងឱ្យស្របទៅតាមស្មារតីរបស់ច្បាប់ ឬឆន្ទៈរបស់នីតិករផងដែរ។ ឧទាហរណ៍ថា ប្រសិនបើវិធានច្បាប់មួយត្រូវបានបង្កើតឡើងដើម្បីការពារកុមារ ឬអ្នកប្រើប្រាស់ ការបកស្រាយច្បាប់នោះត្រូវធ្វើឡើងដើម្បីជាប្រយោជន៍ដល់ជនទាំងនេះ។ យោងតាមស្មារតីរបស់ច្បាប់ អ្នកបកស្រាយច្បាប់អាចធ្វើការបត់បែនបានទៅតាមការវិវត្តរបស់

[៩]. វិធីសាស្ត្រ Golden Rule នេះត្រូវបានបង្កើតនៅឆ្នាំ ១៨៥៧ ក្នុងរឿងក្តី Grey v Pearson។ ថៅក្រមបានលើកឡើងថា "In construing… statutes… the grammatical and ordinary sense of the words is to be adhered to, unless that would lead to some absurdity, or some repugnance or inconsistency with the rest of the instrument, in which case the grammatical and ordinary sense of the words may be modified, so as to avoid the absurdity and inconsistency, but no farther" ។

សង្គម។ ភាពបត់បែននេះ គឺធ្វើយ៉ាងណាឱ្យវិធានច្បាប់មួយអាចអនុវត្តបានស្របតាមស្មារតីរបស់ច្បាប់។ ការបកស្រាយច្បាប់មួយ ត្រូវផ្តោតជាសំខាន់ទៅលើគោលបំណង ឬស្មារតីរបស់ច្បាប់ មិនមែនត្រឹមតែទៅលើពាក្យពេចន៍នៃច្បាប់តែប៉ុណ្ណោះទេ។ ដោយសារសង្គម និងបច្ចេកវិទ្យាមានការវិវត្តឆាប់រហ័ស ពាក្យដែលបានប្រើអាចមានលក្ខណៈមិនគ្រប់ជ្រុងជ្រោយ និងមិនគ្របដណ្តប់លើរាល់ធាតុផ្សំថ្មី។ វិធីសាស្ត្របកស្រាយច្បាប់នេះ ជាវិធីសាស្ត្រទំនើបដែលអនុញ្ញាតឱ្យអ្នកបកស្រាយច្បាប់អាចបត់បែនទៅតាមកាលៈទេសៈ និងការវិវត្តរបស់សង្គម ដើម្បីធានាថាច្បាប់អាចអនុវត្តបានស្របតាមគោលបំណងរបស់ច្បាប់នោះ។

សម្រាប់វិធីសាស្ត្រនេះ អ្នកបកស្រាយច្បាប់ត្រូវរកឱ្យឃើញនូវឆន្ទៈរបស់នីតិករ ឬស្មារតីច្បាប់នៅពេលអនុម័តច្បាប់ ហើយដែលឆន្ទៈនេះអាចស្តែងឡើងដោយមានលក្ខណៈច្បាស់លាស់ងាយយល់ ឬជួនកាល គេត្រូវប្រើវិធីវិចារណវិទ្យាដើម្បីយល់វាបាន[10]។ ជាក់ស្តែងការស្វែងរកឆន្ទៈពិតប្រាកដរបស់នីតិករនេះ មិនមែនជារឿងងាយស្រួលពេកនោះទេ។ គេអាចធ្វើឡើងតាមរយៈការសិក្សាទៅលើសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់/សេចក្តីស្នើច្បាប់, កំណត់ហេតុនៃកិច្ចពិភាក្សាសេចក្តីព្រាងច្បាប់/សេចក្តីស្នើច្បាប់ ឬប្រវត្តិនៃច្បាប់។ អ្នកបកស្រាយច្បាប់ក៏អាចពិនិត្យលើរចនាសម្ព័ន្ធនៃច្បាប់ ថាតើមាត្រាច្បាប់ដែលត្រូវយកមកធ្វើការបកស្រាយស្ថិតនៅក្នុងផ្នែកណា ជំពូកណា និងគន្លឹណានៃច្បាប់។ វិធីសាស្ត្រនេះ ត្រូវបានប្រើប្រាស់ជាចម្បងនៅក្នុងប្រវត្តិច្បាប់នៃប្រទេសអង់គ្លេស[11]។

ជាឧទាហរណ៍ កថាខណ្ឌទី១ នៃមាត្រា ៩ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ចែងថា *"ក្រុមហ៊ុនដែលបានចុះបញ្ជីនៅកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី ៥១% ឡើងទៅកាន់កាប់ដោយរូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជា អាចជាកម្មសិទ្ធិករនៃទ្រព្យជាដីបាន។ មានតែចំនួនភាគរយនៃប្រាក់ហ៊ុនដែលមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុនតែប៉ុណ្ណោះទេដែលទទួល*

10. "សេចក្តីផ្តើមនៃនីតិកម្ពុជា", PUC, រោងពុម្ព Funan, ២០០៥, ទំព័រ.២៥។

11. ចៅក្រមអង់គ្លេសបានសម្រេចក្នុងសំណុំរឿង *Sussex Peerage Case* ក្នុងឆ្នាំ ១៨៤៤ ថា "The only rule for construction of Acts of Parliament is that they should be construed according to the intent of the Parliament which passed the Act. If the words of the Statute are in themselves precise and unambiguous, then no more can be necessary than to expound those words in that natural and ordinary sense. The words themselves alone do, in such a case, best declare the intention of the lawgiver"។



*យកជាការបាន។ រាល់ការព្រមព្រៀងដែលចុះហត្ថលេខាជាលក្ខណៈឯកជនរវាងអ្នកចូលហ៊ុនទាំងឡាយដែលមានន័យផ្ទុយពីនេះ ត្រូវទុកជាមោឃៈ និងគ្មានអានុភាព"*។ តើអ្វីទៅជានីតិបុគ្គលនៃច្បាប់កម្ពុជា? តើនីតិបុគ្គលនៃច្បាប់កម្ពុជាសុទ្ធតែជានីតិបុគ្គលដែលមានសញ្ជាតិខ្មែរ? តើនីតិបុគ្គលនៃច្បាប់កម្ពុជាអាចជានីតិបុគ្គលបរទេសដែរឬទេ? ការបកស្រាយទៅតាមពាក្យពេចន៍នៃមាត្រា ៩ នេះ បានបើកចំហចំពោះរាល់នីតិបុគ្គលទាំងអស់ មិនថាជានីតិបុគ្គលដែលមានគោលដៅស្វែងរកប្រាក់ចំណេញ ឬនីតិបុគ្គលដែលមិនស្វែងរកប្រាក់ចំណេញនោះទេ។ ប៉ុន្តែក្រុមហ៊ុនជានីតិបុគ្គលដែលមានគោលដៅស្វែងរកប្រាក់ចំណេញ។ ហេតុដូចនេះ ជាស្មារតីរបស់ច្បាប់ នីតិបុគ្គលនៃច្បាប់កម្ពុជានេះចង់សំដៅដល់តែនីតិបុគ្គលដែលស្វែងរកប្រាក់ចំណេញប៉ុណ្ណោះ។ ម្យ៉ាងទៀត យោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនបរទេស ជានីតិបុគ្គលដែលបង្កើតឡើងតាមច្បាប់នៃកម្ពុជា ប៉ុន្តែ ជានីតិបុគ្គលបរទេស។ ហេតុដូចនេះ យោងតាមស្មារតីរបស់ច្បាប់នៃមាត្រា ៩ នេះ *"...កាន់កាប់ដោយរូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជា..."* ជាស្មារតីរបស់នីតិករ គឺចង់សំដៅដល់តែនីតិបុគ្គលនៃច្បាប់កម្ពុជាដែលមានសញ្ជាតិខ្មែរ ដូចជារូបវន្តបុគ្គលតែប៉ុណ្ណោះ។

វិធីសាស្ត្របកស្រាយទៅតាមឆន្ទៈរបស់នីតិករ ត្រូវបានអ្នកច្បាប់មួយចំនួនរិះគន់ ដោយបានលើកឡើងថា ភាពខ្វះចន្លោះជាសារជាតិផ្ទាល់របស់ច្បាប់។ មានន័យថា នីតិករមិនអាចចែងបានគ្រប់ជ្រុងទាំងអស់បាននោះទេ។ ហេតុដូចនេះ ការព្យាយាមស្វែងរកឆន្ទៈរបស់នីតិករនៅក្នុងវិស័យដែលគាត់មិនបានប្រមើលទុក ជារឿងដែលមិនសមហេតុផល។ លើសពីនេះ វាជារឿងដ៏លំបាកក្នុងការស្វែងរកនូវឆន្ទៈពិតប្រាកដ ដែលជាឆន្ទៈរួមរបស់នីតិករណាស់ ដោយសារសមាជិកទាំងអស់នៃអង្គនីតិប្បញ្ញត្តិដែលចូលរួមធ្វើការអនុម័តច្បាប់មានច្រើននាក់។ វាក៏ជារឿងដែលមិនអាចជឿជាក់បានដែរថា សមាជិកទាំងអស់នៃអង្គនីតិបញ្ញត្តិមានឆន្ទៈ និងគំនិតដូចគ្នានៅពេលអនុម័តច្បាប់[12]។ អ្នកនិពន្ធទាំងនេះយល់ថា អ្នកបកស្រាយច្បាប់គួរតែអាចធ្វើការបកស្រាយច្បាប់ប្រកបដោយវិចារណញ្ញាណដោយសេរី និងមានលក្ខណៈវិទ្យាសាស្ត្រ។

12. Mélanie Samon, La théorie structurante du droit: plaidoyer pour une redéfinition de l'agir juridique, Lex Electronica, Vol.14, nº1, Printemps 2009, p. 4។

ជារួម ក្នុងចំណោមវិធីសាស្ត្របកស្រាយច្បាប់ដែលបានរៀបរាប់ទាំងអស់ខាងលើ តើអ្នកបកស្រាយច្បាប់គួរផ្តល់អាទិភាពឱ្យវិធីសាស្ត្រមួយណា? ការកំណត់ពីលំដាប់អាទិភាពនេះ ជារឿងដ៏ចម្រូងចម្រាសមួយ។ នៅប្រទេសអាល្លឺម៉ង់ គេផ្តល់ជម្រើសទី ១ ដល់វិធីសាស្ត្របកស្រាយតាមក្បួនវេយ្យាករណ៍ (Grammatical Interpretation)។ នៅប្រទេសកាណាដា តុលាការកំពូលបានសម្រេចប្រើប្រាស់វិធីសាស្ត្រចម្រុះរួមគ្នាក្នុងការបកស្រាយដែលស្នើដោយលោកសាស្ត្រាចារ្យ Driedger[13] ក្នុងសាលដីកាឆ្នាំ ១៩៨៤ លើសំណុំរឿង Stubart Investments Ldt.។ ការបកស្រាយត្រូវផ្អែកទាំងទៅលើលក្ខណៈអក្សរសាស្ត្រ និងទៅតាមឆន្ទៈរបស់នីតិករ ឬស្មារតីរបស់ច្បាប់ ដោយមិនអាចកាត់ផ្តាច់ចេញពីវិធីសាស្ត្រណាមួយបាននោះទេ។

## ៣- វិធាននៃការបកស្រាយច្បាប់

ខុសពីវិធីសាស្ត្របកស្រាយច្បាប់ វិធាននៃការបកស្រាយច្បាប់គឺជាគោលការណ៍មូលដ្ឋានដែលអាចផ្តល់ជាអំណះអំណាង ឬហេតុផលចំពោះជម្រើសនៃការបកស្រាយណាមួយ។ ក្នុងច្បាប់កម្ពុជា ក្រៅពីក្រមព្រហ្មទណ្ឌ ច្បាប់ផ្សេងៗទៀតមិនបានកំណត់ពីវិធាននៃការបកស្រាយច្បាប់នោះទេ។ ដើម្បីឱ្យការបកស្រាយច្បាប់មានភាពរឹងមាំ ការបកស្រាយច្បាប់គួរត្រូវគោរពនូវគោលការណ៍មួយចំនួន ដែលរួមមាន៖ *(ក)*-ការបកស្រាយវិធានច្បាប់មិនត្រូវឱ្យផ្ទុយនឹងចរិកលក្ខណៈនៃវិធានគតិយុត្ត, *(ខ)*-ការបកស្រាយច្បាប់អាចជាការបកស្រាយក្នុងន័យទូលាយ ឬន័យចង្អៀត, *(គ)*-ការបកស្រាយក្នុងន័យផ្ទុយ ឬន័យស្រប និងការបកស្រាយតាមបែបសទិសភាព, ***(ឃ)***-ការបកស្រាយច្បាប់មិនត្រូវធ្វើឱ្យប៉ះពាល់ដល់គោលការណ៍គ្រឹះនៃនីតិ, *(ង)*-ការបកស្រាយ ច្បាប់ត្រូវធានាឱ្យបាននូវសុខដុមនីយកម្មនៃវិធានច្បាប់ និង *(ច)*-ការបកស្រាយច្បាប់ត្រូវគោរពគោលការណ៍សមធម៌។

[13]. Elmer A. DRIEDGER, *Construction of Statutes,* 2nd edition, Toronto, Butterworths, 1983, p.87. "Today there is only one principle or approach, namely, the words of an Act are to be read in their entire context in their grammatical and ordinary sense harmoniously with the scheme of the Act, the object of the Act, and the intention of Parliament. This principle is expressed repeatedly by modern judges"។



### ក-ការបកស្រាយច្បាប់មិនត្រូវឱ្យផ្ទុយនឹងចរិកលក្ខណៈនៃវិធានគតិយុត្ត

វិធានច្បាប់ អាចត្រូវបែងចែកជា ២ ប្រភេទគឺ វិធានច្បាប់ដែលមានលក្ខណៈជាសេចក្តីបង្គាប់ជាសាធារណៈ និងវិធានច្បាប់ដែលបំពេញបន្ថែមឱ្យឆន្ទៈរបស់គូភាគី។ វិធានដែលមានលក្ខណៈជាសេចក្តីបង្គាប់ជាសាធារណៈ ច្រើនមានគោលដៅការពារភាគីទន់ខ្សោយនៃទំនាក់ទំនងកិច្ចសន្យាដូចជា កម្មករនិយោជិត អ្នកប្រើប្រាស់ ឬកូនបំណុលជាដើម ដែលមិនមានអំណាចសេដ្ឋកិច្ចគ្រប់គ្រាន់ក្នុងការចរចាលក្ខខណ្ឌនៃកិច្ចសន្យាជាមួយភាគីម្ខាងទៀត។ ជាគោលការណ៍ វិធានគតិយុត្តដែលមានលក្ខណៈជាសេចក្តីបង្គាប់ជាសាធារណៈ មិនអាចត្រូវបានធ្វើបដិប្បញ្ញត្តិដោយអានុភាពនៃគោលការណ៍ស្វ័យភាពនៃឆន្ទៈបាននោះទេ។ រាល់កិច្ចព្រមព្រៀងទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃវិធានគតិយុត្តនេះ ត្រូវទុកជាមោឃៈ។ ការធ្វើបដិប្បញ្ញត្តិទៅនឹងវិធាននេះ អាចធ្វើទោះបានតែក្នុងករណីដែលច្បាប់បានកំណត់ប៉ុណ្ណោះ ហើយតែងត្រូវបានធ្វើឡើងក្នុងគោលដៅផ្តល់ផលប្រយោជន៍ ឬសិទ្ធិទាំងឡាយដែលប្រសើរជាងផលប្រយោជន៍ និងសិទ្ធិដែលកំណត់ក្នុងច្បាប់។ រាល់បដិប្បញ្ញត្តិដែលធ្វើឡើងក្នុងគោលបំណងលុបបំបាត់ ឬកាត់បន្ថយផលប្រយោជន៍ដែលច្បាប់បានកំណត់ ត្រូវទុកជាមោឃៈដោយពេញច្បាប់។ *ជាឧទាហរណ៍ មាត្រា ១៣ នៃច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ចែងថា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ការងារនេះ មានលក្ខណៈជាសេចក្តីបង្គាប់ជាសាធារណៈ វៀរលែងតែមានបដិប្បញ្ញត្តិបញ្ជាក់ច្បាស់។ រាល់វិធានដែលកើតឡើងដោយការសម្រេចចិត្តជាឯកតោភាគីក្តី ដោយកិច្ចសន្យា ឬអនុសញ្ញាណាមួយក្តី ដែលមិនគោរពបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬដែលមិនគោរពអត្ថបទទាំងឡាយដែលណែនាំអនុវត្តច្បាប់នេះ ត្រូវទុកជាមោឃៈដោយពេញច្បាប់។* តើយើងអាចសម្គាល់ថាវិធានមួយជាវិធានដែលមានលក្ខណៈជាសេចក្តីបង្គាប់បានយ៉ាងដូចម្តេច? ជាទូទៅ គេឃើញមានការប្រើប្រាស់ឃ្លាថា *"រាល់កិច្ចព្រមព្រៀងទាំងឡាយដែលផ្ទុយ... ឬ ខទាំងឡាយ នៃកិច្ចសន្យាដែលផ្ទុយ...ត្រូវទុកជាមោឃៈ ឬត្រូវចាត់ទុកថាគ្មានប្រសិទ្ធភាព ឬ ភាគីពុំអាចកំណត់ផ្សេងពីបញ្ញត្តិនៃមាត្រា...នៅក្នុងកិច្ចសន្យាបានឡើយ[14]"* នៅក្នុងវិធានច្បាប់ ដើម្បីបញ្ជាក់ថាវិធានដែលបានកំណត់ជាវិធានដែលមានលក្ខណៈជាសេចក្តីបង្គាប់ជាសាធារណៈ។

[14]. មាត្រា ៨៤៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី។

ដោយឡែក វិធានដែលមានលក្ខណៈបំពេញបន្ថែមឱ្យឆន្ទៈរបស់គូភាគី គឺជាវិធានដែលអាចត្រូវបានកំណត់ផ្សេងដោយគូភាគី។ គូភាគីអាចចែងនូវប្រការនៃកិច្ចសន្យាដែលមានខ្លឹមសារខុសពីវិធានដែលច្បាប់បានកំណត់។ វិធានដែលច្បាប់បានកំណត់ ត្រូវយកមកអនុវត្តតែក្នុងករណីដែលគូភាគីមិនបានកំណត់តែប៉ុណ្ណោះ។ ប៉ុន្តែ បើគូភាគីបានកំណត់ផ្សេងនៅក្នុងកិច្ចសន្យា គឺត្រូវអនុវត្តទៅតាមការកំណត់ក្នុងកិច្ចសន្យា។ ជាឧទាហរណ៍ មាត្រា ៦១៥ នៃក្រមរដ្ឋប្បវេណី កំណត់ថា "ក្នុងករណីដែលការស្នើសុំឱ្យរំលាយ (ភតិសន្យា) មិនបានបញ្ជាក់អំពីពេលរលាយ...ភតិសន្យាត្រូវរំលាយនៅពេលដែលអំឡុងពេលដូចបានកំណត់ខាងក្រោមនេះបានកន្លងហួស គិតចាប់ពីពេលស្នើសុំឱ្យរំលាយ (១ ថ្ងៃចំពោះចលនវត្ថុ, ៣ ខែចំពោះអគារ និង ១ ឆ្នាំចំពោះដី)។ ជាទូទៅ គេតែងប្រើឃ្លាថា *"នៅក្នុងករណីដែលមិនបានកំណត់... នៅក្នុងកិច្ចសន្យា"* ឬ *"បើពុំបានកំណត់... នៅក្នុងកិច្ចសន្យាទេ[15]"* ឬ *"លើកលែងតែកិច្ចសន្យាចែងផ្សេងៗ ឬចែងផ្ទុយពីនេះ[16]"* ឬ *"លើកលែងតែមានការព្រមព្រៀងគ្នាផ្សេង"* ឬ *"ប្រសិនបើគ្មានការព្រមព្រៀង គ្នាផ្សេងអំពី...ទេ[17]"* ដើម្បីកំណត់ថាវិធានច្បាប់មួយជាវិធានដែលបំពេញបន្ថែមឱ្យឆន្ទៈរបស់ភាគី។

អ្វីដែលទាមទារឱ្យមានការបកស្រាយ គឺនៅពេលដែលច្បាប់មិនបានបញ្ជាក់ឱ្យបានច្បាស់ថាវិធានមួយជាវិធានដែលជាសេចក្ដីបង្គាប់ជាសាធារណៈ ឬជាវិធានដែលបំពេញបន្ថែមឱ្យឆន្ទៈរបស់ភាគី។ នៅក្នុងរឿងរដ្ឋប្បវេណីដែលផ្ដល់តម្លៃឱ្យគោលការណ៍ស្វ័យភាពនៃឆន្ទៈ វិធានច្បាប់ភាគច្រើន ជាវិធានដែលបំពេញបន្ថែមឱ្យឆន្ទៈរបស់ភាគី។ ប៉ុន្តែ យើងមិនអាចយកគោលការណ៍ស្វ័យភាពនៃឆន្ទៈនេះ មកសំអាងដោយគ្មានព្រំដែននោះទេ។ វិធានមួយចំនួន មិនអាចត្រូវបានកំណត់ផ្ទុយដោយកិច្ចសន្យានោះទេ ពីព្រោះការកំណត់ផ្ទុយនេះ អាចនឹងខុសពីស្មារតីរបស់ច្បាប់ ឬធ្វើឱ្យកិច្ចសន្យាពិសេសណាមួយបាត់បង់នូវចរិកលក្ខណៈគតិយុត្តរបស់ខ្លួន។ ជាឧទាហរណ៍ មាត្រា ៥៥ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលកំណត់ថា ការដាក់ធានាដែលបង្កើតដោយច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបានលុបចោលដោយក្រមរដ្ឋប្បវេណី ហើយជំនួសដោយហ៊ីប៉ូតែកវិញ។ ការដាក់ធានា ជាកិច្ចសន្យាដែលធ្វើឡើងដើម្បីធានាការសងបំណុល

15. មាត្រា ៦១០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី។

16. មាត្រា ១០៤, មាត្រា១០៥ និងមាត្រា១០៨ នៃក្រឹត្យច្បាប់លេខ ៣៨។

17. មាត្រា ៤៤៥ និងមាត្រា ៤៤៦ នៃក្រមរដ្ឋប្បវេណី។



ដែលក្នុងនោះកូនបំណុល ឬអ្នកធានា ត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិនៃទ្រព្យទៅឱ្យម្ចាស់បំណុលរបស់ខ្លួន។ ដោយឡែក ហ៊ីប៉ូតែក មិនមានការប្រគល់ប័ណ្ណកម្មសិទ្ធិ ឬទ្រព្យនោះទេ ពោលគឺមានតែការចុះលេខាចារិកក្នុងបញ្ជីសុរិយោដីតែប៉ុណ្ណោះ។ ហេតុដូចនេះ ទើបកថាខណ្ឌទី ៣ នៃមាត្រា ៥៥ តម្រូវឱ្យម្ចាស់បំណុលត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិទៅឱ្យកូនបំណុលវិញ។ បញ្ហានៅត្រង់ថា តើគូភាគីអាចកំណត់ក្នុងកិច្ចសន្យាថាកូនបំណុល ឬអ្នកធានាលះបង់សិទ្ធិដែលផ្ដល់ឱ្យ ដោយកថាខណ្ឌទី ៣ នៃមាត្រា ៥៥ នេះចោល ហើយយល់ព្រមប្រគល់ប័ណ្ណកម្មសិទ្ធិឱ្យទៅម្ចាស់បំណុលកាន់កាប់បានដែរឬទេ? តើវិធាននៃកថាខណ្ឌទី ៣ នៃមាត្រា ៥៥ នេះជាវិធានដែលមានលក្ខណៈជាសេចក្ដីបង្គាប់ជាសាធារណៈ ឬជាវិធានដែលបំពេញបន្ថែមឱ្យឆន្ទៈរបស់ភាគី? តាំងពីដើមរៀងមក ជាចរិកលក្ខណៈគតិយុត្តរបស់ហ៊ីប៉ូតែក គឺមិនមានការប្រគល់ប័ណ្ណកម្មសិទ្ធិ ឬប្រគល់អចលនវត្ថុទៅឱ្យម្ចាស់បំណុលកាន់កាប់នោះទេ។ ក្នុងន័យនេះ បើអនុញ្ញាតឱ្យភាគីនៃកិច្ចសន្យាអាចកំណត់ដូចបានលើកឡើងខាងលើ នោះគោលបំណង ឬស្មារតីរបស់ក្រមដែលលុបចោលការដាក់ធានានឹងមិនអាចសម្រេចបាននោះទេ ហើយយើងលែងអាចធ្វើការបែងចែករវាងការដាក់ធានា និងហ៊ីប៉ូតែកបានទៀតហើយ។ និយាយម្យ៉ាងទៀត ចរិកលក្ខណៈគតិយុត្តរបស់ហ៊ីប៉ូតែកត្រូវបានកែប្រែ។ ហេតុដូចនេះ ប្រសិនបើយោងតាមចរិកលក្ខណៈគតិយុត្តរបស់ហ៊ីប៉ូតែក ខនៃកិច្ចសន្យាដែលតម្រូវឱ្យកូនបំណុលត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិឱ្យម្ចាស់បំណុលហ៊ីប៉ូតែកកាន់កាប់ ត្រូវចាត់ទុកជាមោឃៈ។

### ខ-ការបកស្រាយច្បាប់ក្នុងន័យចង្អៀត ឬន័យទូលាយ

វិធានច្បាប់ អាចត្រូវបានបកស្រាយក្នុងន័យចង្អៀត ឬក្នុងន័យទូលាយ។ ជាគោលការណ៍ វិធានច្បាប់ត្រូវបានបង្ហាញជាលក្ខណៈទូទៅ និងមិនចំពោះ ហើយគ្រប់គ្រងលើគ្រប់ប្រធាននៃនីតិទាំងអស់ដែលស្ថិតក្នុងស្ថានភាពដូចគ្នា។ ក្នុងន័យនេះ វិធានច្បាប់ដែលមានលក្ខណៈជាគោលការណ៍ គួរត្រូវបានបកស្រាយក្នុងន័យទូលាយ។ ដូចគ្នាផងដែរចំពោះច្បាប់ដែលបង្កើត ឬផ្ដល់ជាសិទ្ធិសេរីភាពដល់ប្រជាពលរដ្ឋ។ ផ្ទុយទៅវិញ បដិប្បញ្ញត្តិ ឬអញ្ញត្រកម្មដែលច្បាប់បានកំណត់ ត្រូវបកស្រាយក្នុងន័យចង្អៀត ដើម្បីចៀសវាងការពង្រីកវិសាលភាពអនុវត្តខុសពីឆន្ទៈរបស់នីតិករ។ ជាឧទាហរណ៍ មាត្រា ២៦ នៃក្រមរដ្ឋប្បវេណី ចែងថា "សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាល

ទូទៅអាចលុបចោលបាន។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ”។ យោងតាមមាត្រានេះ ជាគោលការណ៍ រាល់សកម្មភាពគតិយុត្ត ទាំងអស់របស់ជននៅក្រោមអាណាព្យាបាលទូទៅអាចលុបចោលបាន លើកលែងតែចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ តើអ្វីទៅជាសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ? ដោយសញ្ញាណនេះ ជាអញ្ញត្រកម្មទៅនឹងគោលការណ៍ និងដើម្បីការពារផលប្រយោជន៍របស់ជនស្ថិតក្រោមអាណាព្យាបាលទូទៅ សញ្ញាណ “សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ” នេះ គួរត្រូវបានបកស្រាយក្នុងន័យចង្អៀត។ ការបកស្រាយក្នុងន័យចង្អៀតនេះ ក៏ត្រូវធ្វើផងដែរចំពោះច្បាប់ធ្វើការដកហូត ឬរិតត្បិតសិទ្ធិសេរីភាពរបស់ពលរដ្ឋ ឬដាក់ជាបន្ទុកកាតព្វកិច្ចមកលើពលរដ្ឋ។

### គ-ការបកស្រាយក្នុងន័យផ្ទុយ និងការបកស្រាយតាមបែបសទិសភាព

វិធានច្បាប់ អាចត្រូវបានបកស្រាយក្នុងន័យផ្ទុយ *(a contrario)* និងការបកស្រាយតាមបែបសទិសភាព *(par analogie)*។ ការបកស្រាយក្នុងន័យផ្ទុយ ត្រូវបានប្រើដើម្បីកំណត់នូវដំណោះស្រាយផ្សេងពីអ្វីដែលច្បាប់បានកំណត់ចំពោះស្ថានភាព ឬករណីជាក់លាក់ណាមួយ។ ជាឧទាហរណ៍ ប្រសិនបើច្បាប់ហាមឃាត់ចំពោះករណីជាក់លាក់ណាមួយ នោះករណីផ្សេងៗទៀតដែលច្បាប់មិនបានកំណត់គឺមិនត្រូវបានហាមឃាត់នោះទេ។ ជាគោលការណ៍ បុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពពេញលេញ លើកលែងតែសិទ្ធិនេះត្រូវបានកម្រិតដោយច្បាប់។

ដោយឡែក សម្រាប់ការបកស្រាយតាមបែបសទិសភាព, ជាវិធីសាស្ត្របកស្រាយដើម្បីពង្រីកវិសាលភាពនៃវិធានច្បាប់។ សទិសភាព មានន័យថាភាពត្រូវគ្នា ឬភាពស្រដៀងគ្នា។ ក្នុងវិធីសាស្ត្រនេះ ការបកស្រាយច្បាប់ធ្វើឡើងដើម្បីយកវិធានគតិយុត្តដែលច្បាប់បានកំណត់ចំពោះករណីជាក់លាក់មួយ ទៅអនុវត្តដូចគ្នាចំពោះករណីមួយផ្សេងទៀតដែលច្បាប់មិនបានចែងឱ្យបានច្បាស់ ប៉ុន្តែ មានលក្ខណៈស្រដៀងគ្នា ឬត្រូវគ្នានឹងករណីដែលច្បាប់បានកំណត់។ ការបកស្រាយច្បាប់តាមបែបសទិសភាពនេះ អនុញ្ញាតឱ្យចៅក្រមអាចបំពេញបន្ថែមនូវភាពខ្វះចន្លោះរបស់ច្បាប់ ដើម្បីទទួលបាននូវដំណោះស្រាយមួយប្រកបដោយសមធម៌។ សមធម៌នេះគឺជាមូលដ្ឋានដ៏រឹងមាំសម្រាប់ការបកស្រាយច្បាប់តាមបែបសទិសភាព។ ការបកស្រាយតាមបែបសទិសភាពនេះ ត្រូវបានប្រើជាញឹកញាប់ ប៉ុន្តែក្នុងករណីខ្លះ ច្បាប់ហាមមិនឱ្យមានការបកស្រាយតាមបែបសទិសភាពនេះទេ។ ជាក់ស្តែង ក្រមព្រហ្មទណ្ឌ បានកំណត់យ៉ាងច្បាស់នៅក្នុងមាត្រា ៥ ថា *“ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។...ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ”*។ គោលការណ៍នៃការបកស្រាយយ៉ាងតឹងរ៉ឹងនូវបទប្បញ្ញត្តិព្រហ្មទណ្ឌ គឺជាលទ្ធផលនៃគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោស ដែលមានចែងក្នុងមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ដែលចែងថា *“មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន”*។

### ឃ-ការបកស្រាយដោយគោរពតាមឋានានុក្រម និងគោលការណ៍គ្រឹះនៃនីតិ

តាមទ្រឹស្តីរបស់លោក Hans Kelsen ក្នុងការបកស្រាយច្បាប់ អ្នកបកស្រាយច្បាប់ត្រូវធានាថា បទប្បញ្ញត្តិច្បាប់មានសង្គតិភាពជាមួយនឹងច្បាប់កំពូល, គោលការណ៍គ្រឹះនៃនីតិរួម និងត្រូវគោរពតាមឋានានុក្រមនៃច្បាប់ផ្សេងៗនៅក្នុងវិស័យឯកទេសតែមួយ ដើម្បីចៀសវាងវិវាទក្នុងការបកស្រាយច្បាប់។

- **ការបកស្រាយត្រូវគោរពតាមគោលការណ៍នៃរដ្ឋធម្មនុញ្ញ៖** ជាគោលការណ៍ ច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើ ត្រូវបានចាត់ទុកថាស្របតាមគោលការណ៍គ្រឹះទាំងឡាយនៃរដ្ឋធម្មនុញ្ញ។ ហេតុដូចនេះ ចៅក្រមត្រូវធ្វើការបកស្រាយច្បាប់ដែលមានភាពមិនច្បាស់លាស់ឱ្យស្របតាមគោលការណ៍គ្រឹះនានានៃរដ្ឋធម្មនុញ្ញ ដែលរួមមានជាអាទិ៍ ការគោរពសិទ្ធិសេរីរបស់ពលរដ្ឋ, ការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល, សមភាពរវាងបុរសនារី, គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទជាដើម។

- **ការបកស្រាយច្បាប់ត្រូវធានាបាននូវសុខដុមនីយកម្មជាមួយច្បាប់ផ្សេង៖** ច្បាប់មួយអាចមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងច្បាប់មួយផ្សេងទៀត។ ក្នុងករណីនេះ អ្នកបកស្រាយច្បាប់ត្រូវធ្វើការបកស្រាយច្បាប់ ដោយធានានូវសុខដុមនីយកម្មរវាងច្បាប់ទាំងនេះ។ ដើម្បីចៀសវាងវិវាទនៃការបកស្រាយច្បាប់ ក្នុងការបកស្រាយច្បាប់ត្រូវគោរពតាមគោលការណ៍

សំខាន់ ២ គឺ៖ គោលការណ៍ឧត្តមានុភាពនៃវិធានពិសេស និង គោលការណ៍ឧត្តមានុភាពនៃវិធានថ្មី។ ចំពោះឧត្តមានុភាពនៃវិធានពិសេស, ក្នុងករណីដែលច្បាប់ពិសេសចែងនូវបទប្បញ្ញត្តិផ្ទុយ ឬខុសពីវិធានទូទៅ យើងត្រូវអនុវត្តនូវវិធានពិសេស។ វិធានទូទៅត្រូវអនុវត្តក្នុងករណីដែលវិធានពិសេសមិនត្រូវបានកំណត់។ ដោយឡែក ចំពោះឧត្តមានុភាពនៃវិធានថ្មី, វិធានថ្មីមានអានុភាពទៅនិរាករណ៍វិធានចាស់។ ច្បាប់ថ្មីមួយអាចធ្វើនិរាករណ៍ច្បាប់ចាស់ទាំងស្រុង ឬនិរាករណ៍តែមាត្រាណាមួយនៃច្បាប់ប៉ុណ្ណោះ។ ដើម្បីធានានូវសុវត្ថិភាពគតិយុត្ត ច្បាប់ថ្មីមិនមានអានុភាពប្រតិសកម្មទេ លើកលែងតែច្បាប់បានកំណត់ច្បាស់ផ្សេងពីនេះ។

- **ការបកស្រាយច្បាប់ត្រូវគោរពតាមគោលការណ៍គ្រឹះនៃនីតិ៖** ជាទូទៅ គេសន្មតថា នីតិករគោរពតាមគោលការណ៍គ្រឹះ ឬគោលការណ៍ជាមូលដ្ឋាននៃនីតិរួម លើកលែងតែនីតិករបានបង្ហាញយ៉ាងច្បាស់ផ្សេងពីនេះ។ ការបកស្រាយច្បាប់ មិនត្រូវធ្វើឡើងដោយមិនគោរពតាមគោលការណ៍គ្រឹះនៃនីតិរួមដែលមានចែងក្នុងនីតិរដ្ឋប្បវេណី, នីតិព្រហ្មទណ្ឌ ឬនីតិរដ្ឋបាល ជាដើមនោះទេ។ ក្នុងនីតិរដ្ឋប្បវេណី គោលការណ៍គ្រឹះនៃនីតិ រួមមានជាអាទិ៍ គោលការណ៍សមភាពរវាងបុរសនារី, គោលការណ៍នៃសិទ្ធិលើទ្រព្យសម្បត្តិ, គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន, គោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ ឬគោលការណ៍នៃការហាមឃាត់មិនឱ្យមានការបំពានសិទ្ធិជាដើម។ ក្នុងនីតិព្រហ្មទណ្ឌ គោលការណ៍គ្រឹះនៃច្បាប់ព្រហ្មទណ្ឌ រួមមានជាអាទិ៍ គោលការណ៍នីត្យានុកូលភាព, គោលការណ៍នៃការបកស្រាយច្បាប់ព្រហ្មទណ្ឌ, គោលការណ៍នៃការប្រកាសទោស, គោលការណ៍នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា និងក្នុងលំហ និងគោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ជាដើម។

### ង- ការបកស្រាយច្បាប់ត្រូវធានាបាននូវសមធម៌

នៅក្នុងច្បាប់ចាស់ កថាខណ្ឌទី ២ នៃមាត្រា៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាឆ្នាំ ១៩៩៣ ចែងថា *“ក្នុងរឿងរដ្ឋប្បវេណី បើច្បាប់ចែងមិនច្បាស់ ឬច្បាប់មិនបានចែង ត្រូវជំនុំជម្រះដោយផ្អែកទៅតាមទំនៀមទម្លាប់ប្រពៃណី វិចារណញ្ញាណ ឬសមធម៌”*។ យោងតាមមាត្រានេះ ចៅក្រមត្រូវបានសន្មតថាជាបុគ្គលប្រកបដោយវិចារណញ្ញាណ។ ចៅក្រមត្រូវជំនុំជម្រះប្រកបដោយវិចារណញ្ញាណ ដោយផ្អែកតាមទំនៀមទម្លាប់ ប្រពៃណី ឬ



សមធម៌ ក្នុងករណីដែលច្បាប់ចែងមិនច្បាស់ ឬច្បាប់មិនបានចែង។ សមធម៌ មានតួនាទីសំខាន់ ២ គឺ សមធម៌ជាវិធាននៃនីតិដែលបំពេញបន្ថែមភាពខ្វះចន្លោះរបស់ច្បាប់ និង សមធម៌ជាវិធានក្នុងការបកស្រាយច្បាប់។ ជាទូទៅ គេសន្មតថា វិធានច្បាប់គឺមានលក្ខណៈសមធម៌។ ដូច្នេះ ការបកស្រាយច្បាប់ក៏ត្រូវធ្វើឡើងដោយធានាឱ្យបាននូវដំណោះស្រាយមួយប្រកបដោយសមធម៌ផងដែរ។ នេះមានន័យថា ក្នុងករណីដែលមានការបកស្រាយច្រើនយ៉ាង ចៅក្រមត្រូវជ្រើសយកការបកស្រាយណាមួយដែលនឹងផ្តល់នូវដំណោះស្រាយដែលសមស្រប និងសមហេតុផលជាងគេ។ កថាខណ្ឌទី៣នៃមាត្រា៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ បានបញ្ជាក់យ៉ាងច្បាស់ពីគោលការណ៍សមធម៌នេះ ដោយចែងថា *“បញ្ញត្តិនៃកថាខណ្ឌទី១ និងកថាខណ្ឌទី២ ខាងលើនេះ មិនត្រូវរារាំងការយកក្រមរដ្ឋប្បវេណីមកអនុវត្តជាគោលការណ៍សមធម៌ ចំពោះបញ្ហាដែលកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ក្នុងករណីពុំមានបទដ្ឋានគតិយុត្ត ឬបញ្ញត្តិទំនៀមទម្លាប់ដែលកំណត់អំពីបញ្ហានេះ ឬក្នុងករណីមិនដឹងច្បាស់ថាមានបញ្ញត្តិទំនៀមទម្លាប់”*។ ផ្អែកតាមមាត្រា៥ នេះ បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវបានចាត់ទុកថាជាវិធានច្បាប់ដែលប្រកបដោយសមធម៌។

តើអ្វីទៅជាសមធម៌? លោក Aristote បានបង្កើតនូវទំនាក់ទំនងរវាងវិធាននៃនីតិ និងសមធម៌ ដោយបានផ្តល់និយមន័យឱ្យសមធម៌ ថាជាឧបករណ៍សម្រាប់ធ្វើការកែតម្រូវនូវភាពអយុត្តិធម៌ដែលបណ្តាលមកពីភាពតឹងរ៉ឹងដាច់ខាតនៃវិធាននៃនីតិ[18]។ លោក Aristote បានកំណត់និយមន័យបែបនេះនៅក្នុងសម័យកាលដែលវិធាននៃនីតិត្រូវបានបង្ហាញឡើងដោយមានលក្ខណៈតឹងរ៉ឹងខ្លាំង ដោយមិនទុកឱកាសឱ្យការអនុវត្តអាចមានភាពបត់បែនខ្លះទៅតាមកាលៈទេសៈជាក់ស្តែងនោះទេ។ តួនាទីរបស់សមធម៌ គឺការស្វែងរកនូវការសម្របសម្រួលមួយដែលសមស្រប និងសមហេតុសមផលរវាងផលប្រយោជន៍ផ្សេងៗគ្នា ដើម្បីធានាឱ្យបាននូវសេចក្តីសម្រេចមួយប្រកបដោយយុត្តិធម៌។ គឺនៅក្នុងទស្សនទាននេះហើយដែល Equity ត្រូវបានបង្កើតឡើងនៅក្នុងប្រព័ន្ធច្បាប់ Common Law ។ នៅក្នុងប្រព័ន្ធច្បាប់ Common Law របស់ចក្រភពអង់គ្លេស Equity មិនចូលរួមអន្តរាគមន៍ដោះស្រាយបញ្ហាក្នុងគោលដៅបង្កើតឱ្យមានជា

[18]. M. Ralph A. Newman, La nature de l'équité en « droit civil », In Revue internationale de droit comparé. Vol. 16 N°2, Avril-juin 1964. pp. 290។

វិធាននៃនីតិថ្មីនោះទេ ពោលគឺ Common Law នៅតែជាមូលដ្ឋានចម្បងនៃការផ្តល់យុត្តិធម៌ ដដែល ប៉ុន្តែ Equity ចូលរួមដោះស្រាយបញ្ហាក្នុងនាមសីលធម៌សង្គមដើម្បីចៀសវាងនូវភាពអយុត្តិធម៌ផ្សេងៗ[19]។ Equity មិនមានគោលដៅកែប្រែច្បាប់ Common Law ទេ ប៉ុន្តែវាបំពេញបន្ថែម ឬកែតម្រូវ Common Law ឱ្យរឹតតែល្អ ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យសេចក្តីសម្រេចមួយប្រកបដោយសមភាព និងយុត្តិធម៌។ នៅក្នុងបណ្តាប្រទេសមួយចំនួនដូចជា ប្រទេសកាណាដា និងប្រទេសអង់គ្លេសជាដើម ចៅក្រមអាចបកស្រាយវិធានច្បាប់ឃ្លាតចេញពីឃ្លាប្រយោគរបស់ច្បាប់បាន នៅពេលមានភាពមិនសមហេតុផល ឬមិនមានដំណោះស្រាយប្រកបដោយសមធម៌។ នៅក្នុងប្រព័ន្ធច្បាប់ Common Law វិធីសាស្ត្របកស្រាយច្បាប់មួយនេះហៅថា Golden Rule។

19. “សេចក្តីផ្តើមនៃនីតិកម្ពុជា”, PUC, រោងពុម្ព Funan, ២០០៥, ទំព័រ៣៥។



# ការចេញដីកាសម្រេចរក្សាការពារ

ដោយ៖
-លោក **ឈឿន គុយអេង** សមាជិកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
-កញ្ញា **គន្ធា ស្រីសុជាតា** សមាជិកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី ក្នុងគោលបំណងទទួលបានការដោះស្រាយដោយផ្អែកតាមច្បាប់ និងការការពារសិទ្ធិបុគ្គលឯកជន[1]។ ប៉ុន្តែ បើត្រូវរង់ចាំរហូតដល់តុលាការចេញសេចក្តីសម្រេចដែលកំណត់ជាស្ថាពរអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនៅក្នុងបណ្តឹងអង្គសេចក្តីនៃរឿងក្តីរដ្ឋប្បវេណី ប្រសិនបើមានការប្រែប្រួលចំពោះស្ថានភាពនៃទ្រព្យសម្បត្តិរបស់ភាគី ឬស្ថានភាពផ្សេងៗទៀត នោះនឹងអាចជាហេតុនាំឱ្យកើតមានឧបសគ្គក្នុងការអនុវត្តសេចក្តីសម្រេចតុលាការនាពេលអនាគតផងដែរ។ ដើម្បីបង្ការស្ថានភាពនេះ, ក្រមនីតិវិធីរដ្ឋប្បវេណី បានបង្កើតឱ្យមាននូវយន្តការស្តីពីការចាត់ចែងរក្សាការពារ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុល ក្នុងគោលគំនិតថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំង ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ[2]។ ការចាត់ចែងរក្សាការពារ គឺជាការធានាជាបណ្តោះអាសន្ន ដែលពុំជះឥទ្ធិពលដល់ការសម្រេចលើបណ្តឹងអង្គសេចក្តីឡើយ។ នៅមុនពេលមានក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ យន្តការនេះត្រូវបានប្រើប្រាស់ក្រោមទម្រង់ជា “ការសម្រេចជាវិធានការណ៍ប្រញាប់ និងបណ្តោះអាសន្ន”[3]។ ក្រមនីតិវិធីរដ្ឋប្បវេណី បានបង្កើតឱ្យមាននូវយន្តការចាត់ចែងរក្សាការពារនេះ ដែលមានចរិតលក្ខណៈបន្ទាប់បន្សំពីបណ្តឹងអង្គសេចក្តី, មានលក្ខណៈបណ្តោះអាសន្ន និងមានលក្ខណៈបន្ទាន់បង្ខំ និងលក្ខណៈសម្ងាត់ ហើយការសម្រេចរបស់តុលាការត្រូវធ្វើឡើងដោយ ឆាប់រហ័សជាងបណ្តឹងអង្គសេចក្តី និងមិនឆ្លងកាត់នីតិវិធីស្មុគស្មាញឡើយ។

ផ្អែកតាមមាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ការចាត់ចែងរក្សាការពារ មាន ២ ប្រភេទ រួមមានៈ (១)-ការរឹបអូសជាបណ្តោះអាសន្ន និង (២)-ការចាត់ចែងជាបណ្តោះអាសន្ន ដែលមានការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន។ ***ការរឹបអូសជាបណ្តោះអាសន្ន*** សំដៅដល់ការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ

---

[1]. មាត្រា ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[2]. មាត្រា ៥៣០ នៃក្រមនីវិតិធីរដ្ឋប្បវេណី

[3]. សេចក្តីណែនាំលេខ ០៩/០៤ តកនសត ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៤ របស់តុលាការកំពូល ស្តីពីការសំរេចជាវិធានការណ៍ប្រញាប់ និងបណ្តោះអាសន្ន។



ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។ ការរឹបអូសជាបណ្តោះអាសន្នមានគោលបំណងថែរក្សាតម្លៃនៃទ្រព្យសម្បត្តិរបស់កូនបំណុល ឬរបស់បុគ្គលពាក់ព័ន្ធ ដែលអាចជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំសម្រាប់ទូទាត់សងនូវសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុល តាមរយៈការចាត់ចែងប្តូរទ្រព្យសម្បត្តិនេះជាប្រាក់សម្រាប់សងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៅពេលម្ចាស់បំណុលទទួលបានសាលក្រម ឬសាលដីកាស្ថាពរនាពេលអនាគត។ ការរឹបអូសជាបណ្តោះអាសន្ននេះ ត្រូវធ្វើឡើងតាមរយៈការចេញជា **“ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន”**។ ដោយឡែក, ***ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ*** សំដៅដល់ការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទនេះ ជាការចាត់ចែងដើម្បីរក្សាឱ្យបាននូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ កុំឱ្យមានការប្រែប្រួល (ជាអាទិ៍ មិនឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធិករ ឬមានការចុះបន្ទុកលើវត្ថុដែលជាកម្មវត្ថុនៃវិវាទ) ដោយមិនកម្រិតត្រឹមតែការថែរក្សាតម្លៃនៃវត្ថុដូចករណីនៃការរឹបអូសជាបណ្តោះអាសន្នឡើយ។ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ អាចមាន ២ ប្រភេទ គឺ ***ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់*** ដូចមានចែងក្នុងមាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង ***ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង***។ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាប់ គឺជាការសម្រេចដែលបង្គាប់ឱ្យដកហូតការកាន់កាប់ពីកូនបំណុល ហើយបង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះជំនួសវិញ។ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺជាការសម្រេចហាមឃាត់មិនឱ្យចាត់ចែងវត្ថុ ដែលអាចជាការហាមឃាត់ការលក់ ដូរ ជួល ឬដាក់ប្រាតិភោគជាដើម។ រីឯ ***ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន*** សំដៅដល់ការចាត់ចែងដែលកំណត់ស្ថានភាពជាបណ្តោះអាសន្នរហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។ ខុសពីការរឹបអូសជាបណ្តោះអាសន្នដែលមានគោលបំណងថែរក្សាតម្លៃនៃទ្រព្យសម្បត្តិ និងខុសពីការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទដែលមានគោលបំណងរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុ, ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ននេះ មាន

គោលបំណងកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ដែលស្ថានភាពជាបណ្ដោះអាសន្ននេះ អាចមានជាអាទិ៍ សិទ្ធិទាក់ទងនឹងឋានៈបុគ្គល ឬសិទ្ធិក្នុងទំនាក់ទំនងញាតិ។ ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ត្រូវធ្វើឡើងក្រោមទម្រង់ជា **"ដីកាសម្រេចចាត់ចែងបណ្ដោះអាសន្ន"**។

ក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់អំពីក្របខ័ណ្ឌគតិយុត្តនៃការចេញដីកាសម្រេចរក្សាការពារទាំង ២ ប្រភេទខាងលើ *(១)* គឺ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន។ ច្បាប់បានកំណត់អំពីគោលគំនិតច្បាស់លាស់នៃការចេញដីកាទាំង ២ ប្រភេទនេះ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្ដែង ដោយបទប្បញ្ញត្តិពាក់ព័ន្ធមួយចំនួនមិនមានភាពច្បាស់លាស់ ធ្វើឱ្យការចេញដីកាសម្រេចរក្សាការពារ នៅមិនទាន់មានសង្គតិភាពគ្នាទាំងស្រុងនៅឡើយទេ ហើយការអនុវត្តខ្លះក៏អាចប្រាសចាកពីស្មារតីដើមនៃក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ *(២)*។ តើការចេញដីកាសម្រេចរក្សាការពារទៅតាមប្រភេទនីមួយៗខាងលើ ត្រូវបំពេញលក្ខខណ្ឌ និងនីតិវិធីអ្វីខ្លះ? តើអ្វីខ្លះជាបញ្ហាប្រឈមក្នុងការអនុវត្តជាក់ស្ដែងពាក់ព័ន្ធនឹងការចេញដីកាសម្រេចរក្សាការពារនេះ?

## ១- ក្របខ័ណ្ឌគតិយុត្តនៃការចេញដីកាសម្រេចរក្សាការពារ

ក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់អំពីលក្ខខណ្ឌដែលត្រូវបំពេញ *(ក)* និងនីតិវិធីដែលត្រូវអនុវត្ត *(ខ)* សម្រាប់ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និង ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន។

### ក-លក្ខខណ្ឌសម្រាប់ការចេញដីកាសម្រេចរក្សាការពារ

ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន និងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន អាចធ្វើទៅបាន លុះត្រាតែបានកំណត់ជាមុនអំពីៈ អត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ **(ក-១)**, ភាពចាំបាច់នៃការចេញដីកាសម្រេចរក្សាការពារ **(ក-២)** និង កម្មវត្ថុនៃដីកាសម្រេចរក្សាការពារ **(ក-៣)**។

#### ក-១.ការកំណត់អំពីអត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ

- **ចំពោះការរឹបអូសជាបណ្ដោះអាសន្នៈ** ម្ចាស់បំណុលត្រូវបញ្ជាក់ជាមុនអំពីអត្ថិភាពនៃសិទ្ធិលើបំណុលរបស់ខ្លួនចំពោះកូនបំណុល។ សិទ្ធិលើបំណុលដែលជាមូលដ្ឋានសម្រាប់ការស្នើសុំចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននេះ ត្រូវតែជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ដែលរួមមានជាអាទិ៍ សិទ្ធិទាមទារឱ្យសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ, សិទ្ធិទាមទារឱ្យបង់ថ្លៃលក់ទិញដោយផ្អែកលើកិច្ចសន្យាលក់ទិញ ឬ សិទ្ធិទាមទារឱ្យបង់ថ្លៃឈ្នួលដោយផ្អែកលើភតិសន្យា ជាដើម។ សិទ្ធិលើបំណុលផ្សេងទៀតដែលមិនមានគោលបំណងឱ្យសងជាប្រាក់ ជាអាទិ៍ សិទ្ធិកម្មសិទ្ធិលើអចលនវត្ថុ មិនអាចជាមូលដ្ឋានសម្រាប់ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ននេះបានទេ។ ការបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុលនេះ ត្រូវធ្វើឡើងតាមវិធីបញ្ជាក់ដំបូង ដែលជាការដាក់នូវភស្តុតាងជាឯកសារដែលតុលាការអាចធ្វើការត្រួតពិនិត្យបានភ្លាមៗ ដូចជា កិច្ចសន្យាខ្ចីបរិភោគជាលាយលក្ខអក្សរណ៍, លិខិតប្រគល់ទទួលប្រាក់ ឬតារាងប្រតិបត្តិការទូទាត់ប្រាក់ ជាដើម។ ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចចេញបានទោះបីជាសិទ្ធិលើបំណុលនោះមានភ្ជាប់នឹងលក្ខខណ្ឌ ឬមានពេលកំណត់ក៏ដោយ។

- **ចំពោះការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទៈ** សិទ្ធិលើបំណុលដែលអាចជាមូលដ្ឋាននៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ គឺជាសិទ្ធិលើបំណុលដែលមានការពាក់ព័ន្ធដោយផ្ទាល់លើវត្ថុជាក់លាក់ ក្រៅពីសិទ្ធិដែលមានគោលបំណងឱ្យសងជាប្រាក់។ កថាខណ្ឌទី១ នៃមាត្រា ៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។ សិទ្ធិដែលត្រូវបានរក្សាការពារនេះ រួមមានជាអាទិ៍ សិទ្ធិទាមទារឱ្យប្រគល់វត្ថុ, សិទ្ធិទាមទារឱ្យបណ្ដេញចេញពីដី, សិទ្ធិទាមទារឱ្យរុះរើការរៀផ្សេងៗ ឬសិទ្ធិទាមទារឱ្យធ្វើនីតិវិធីចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ។

- **ចំពោះការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្នៈ** សិទ្ធិដែលអាចត្រូវបានរក្សាការពារ ដោយការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ននេះ អាចជាសិទ្ធិលើទ្រព្យសម្បត្តិ រួមទាំងសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ សិទ្ធិលើបំណុលដែលគ្មានគោលបំណងឱ្យសងជាប្រាក់ ឬសិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល ដូចជាទំនាក់ទំនងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងឪពុកម្ដាយ និងកូន ជាដើម។

### ក-២. ការកំណត់អំពីភាពចាំបាច់នៃការចេញដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរក្សាការពារនេះ អាចចេញបានតែក្នុងករណីដែលមានភាពចាំបាច់ប៉ុណ្ណោះ។ តើភាពចាំបាច់នេះត្រូវកំណត់យ៉ាងដូចម្ដេច?

- **ចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន៖** ផ្អែកតាមមាត្រា ៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ភាពចាំបាច់នៃដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន កើតមានឡើង *"ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ"*។ តើមានករណីណាខ្លះដែលធ្វើឱ្យការអនុវត្តដោយបង្ខំនឹងមិនអាចអនុវត្តបាន ឬនឹងមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំ? ការវាយតម្លៃនេះគឺជាឆន្ទានុសិទ្ធរបស់តុលាការ។ ជាក់ស្ដែង ភាពចាំបាច់នេះ អាចកើតមានឡើងក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុល ទំនងជាអាចធ្លាក់តម្លៃយ៉ាងខ្លាំង ឬធ្លាក់បរិមាណ ឬគុណភាព ដោយសារការចាយវាយខ្ជះខ្ជាយ ការដាក់លក់ក្នុងតម្លៃថោក និងការបង្វែរទ្រព្យដើម្បីគេចវេសពីការរឹបអូស ឬការគេចខ្លួន និងការប្ដូរលំនៅឋានជាញឹកញាប់របស់កូនបំណុលដែលអាចជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំជាដើម។

- **ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ៖** មាត្រា ៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ថា ភាពចាំបាច់នេះ គឺសំដៅដល់ *"ករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុ"*។ ភាពចាំបាច់នៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ កើតឡើងនៅពេលមានហានិភ័យនៃការខូចខាត ឬហានិភ័យនៃការបង្វែរ ការផ្ទេរ ឬការរារាំងសិទ្ធិលើវត្ថុដែលជាកម្មវត្ថុវិវាទដោយកូនបំណុល ឬតតិយជន ដូចជាករណីកូនបំណុលដែលជាអ្នកលក់បានព្យាយាមលក់ដីបន្តទៅឱ្យអ្នកផ្សេង ខណៈពេលដែលម្ចាស់បំណុលដែលជាអ្នកទិញកំពុងទាមទារឱ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យាលក់ទិញ ឬ ករណីដែលកូនបំណុលកំពុងបន្តការសាងសង់ ខណៈពេលដែលម្ចាស់បំណុលកំពុងទាមទារឱ្យរុះរើសំណង់ទាំងឡាយនៅលើដីវិវាទដោយផ្អែកលើការបំពានកម្មសិទ្ធិ ជាអាទិ៍។

- **ចំពោះដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន៖** កថាខណ្ឌទី២ នៃមាត្រា៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងដល់ម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តិដែលមានវិវាទ។ ភាពចាំបាច់នៃការរក្សាការពារប្រភេទនេះ ត្រូវបានវាយតម្លៃដោយ**ផ្អែកលើស្ថានភាពចាំបាច់របស់ម្ចាស់បំណុល មិនមែនផ្អែកលើសកម្មភាពនៃការចាត់ចែងទ្រព្យសម្បត្តិ ឬវត្ថុវិវាទ ដូចករណីការរឹបអូសជាបណ្ដោះអាសន្ន ឬការចាត់ចែងបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទឡើយ**។ ជាឧទាហរណ៍ ចំពោះករណីវិវាទពាក់ព័ន្ធនឹងភាពស្របច្បាប់នៃការបញ្ឈប់ពីការងារ ហើយកម្មករនិយោជិកនឹងជួបការលំបាកសម្រាប់ជីវភាពប្រចាំថ្ងៃ ក្នុងអំឡុងពេលដំណើរការក្ដីជាមួយភាគីនិយោជក ប្រសិនបើកម្មករនិយោជិកបាត់បង់ប្រាក់ខែក្នុងអំឡុងពេលដំណើរការក្ដី, ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន អាចសម្រេចឱ្យនិយោជកបន្តបង់ប្រាក់ខែឱ្យទៅកម្មករនិយោជិកជាបណ្ដោះអាសន្នសិន រហូតដល់មានសាលក្រម ឬសាលដីកាស្ថាពរដែលកំណត់ជាក់លាក់អំពីភាពស្របច្បាប់នៃការបញ្ឈប់ពីការងារ។ ដូចគ្នាផងដែរ ចំពោះករណីជនរងគ្រោះនៃគ្រោះថ្នាក់ចរាចរណ៍ ដែលត្រូវការថវិកាជាបន្ទាន់សម្រាប់ព្យាបាលរបួស។ ចំពោះករណីនេះ ដោយជនរងគ្រោះកំពុងស្ថិតនៅក្នុងស្ថានភាពបន្ទាន់ដែលមិនអាចរង់ចាំរហូតដល់មានសាលក្រម ឬសាលដីកាស្ថាពរ, ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន អាចសម្រេចឱ្យកូនបំណុលដែលអាចជាជនបង្ក ឬក្រុមហ៊ុនធានារ៉ាប់រង បង់ប្រាក់សំណងមួយផ្នែក ឬទាំងស្រុងឱ្យទៅម្ចាស់បំណុលជាមុនសិន រហូតដល់ពេលមានសាលក្រម ឬសាលដីកាស្ថាពរដែលកំណត់អំពីចំនួនទឹកប្រាក់សំណងជាក់លាក់។

### ក-៣. ការកំណត់នូវកម្មវត្ថុនៃដីកាសម្រេចរក្សាការពារ

- **ការរឹបអូសជាបណ្ដោះអាសន្ន៖** ជាគោលការណ៍ ក្នុងការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន, តុលាការត្រូវកំណត់ឱ្យជាក់លាក់នូវកម្មវត្ថុនៃការរឹបអូស[4]។ ដោយឡែកចំពោះការរឹបអូសវត្ថុដែលជាចលនវត្ថុ តុលាការអាចចេញដីកាសម្រេចនេះបានដោយមិនចាំបាច់កំណត់កម្មវត្ថុនោះទេ។ ការរឹបអូសជាបណ្ដោះអាសន្ននេះ អាចធ្វើបានចំពោះចលនវត្ថុ[5], អចលនវត្ថុ[6], សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត[7] និងនាវា[8]។

---

4. មាត្រា ៥៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
5. មាត្រា ៥៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
6. មាត្រា ៥៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
7. មាត្រា ៥៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
8. មាត្រា ៥៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

- **ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ៖** ការចាត់ចែងនេះ ធ្វើឡើងដើម្បីរក្សាទុកឱ្យបាននូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ។ ហេតុដូចនេះ ការចាត់ចែងជាបណ្ដោះអាសន្ននេះ ត្រូវធ្វើចំពោះតែវត្ថុជាក់លាក់ដែលជាកម្មវត្ថុនៃវិវាទតែប៉ុណ្ណោះ។

- **ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន៖** គោលបំណងនៃការចាត់ចែងរក្សាការពារប្រភេទនេះ មិនមែនជាការថែរក្សាទ្រព្យសម្បត្តិរបស់កូនបំណុលសម្រាប់អនុវត្តដោយបង្ខំក្នុងពេលអនាគតដូចករណីការរឹបអូសជាបណ្ដោះអាសន្នឡើយ តែជាការទប់ស្កាត់ ឬការដកចេញនូវគ្រោះថ្នាក់ ឬការខូចខាតពិសេសដែលអាចកើតឡើងចំពោះម្ចាស់បំណុល ក្នុងអំឡុងពេលដែលទំនាក់ទំនងគតិយុត្តមិនទាន់អាចត្រូវបានកំណត់ជាក់លាក់ដោយសាលក្រម ឬសាលដីកាស្ថាពរ។

## ២- នីតិវិធីសម្រាប់ការចេញដីកាសម្រេចរក្សាការពារ

- **សមត្ថកិច្ចតុលាការ៖** ជាគោលការណ៍, ការរក្សាការពារអាចធ្វើឡើងនៅមុនពេលមានបណ្ដឹងអង្គសេចក្ដី ឬនៅក្នុងអំឡុងពេលបណ្ដឹងអង្គសេចក្ដីបាន។ រឿងក្ដីនៃដីកាសម្រេចរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃវត្ថុដែលនឹងត្រូវរឹបអូសជាបណ្ដោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ។ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី សំដៅទៅលើតុលាការនៃការជំនុំជម្រះលើកទី១ ក្នុងករណីដែលបណ្ដឹងអង្គសេចក្ដីកំពុងស្ថិតនៅក្នុងចំណាត់ការរបស់សាលាដំបូង ឬតុលាការកំពូល។ ប៉ុន្តែ បើសិនជាបណ្ដឹងអង្គសេចក្ដីត្រូវបានចាត់ការក្នុងនីតិវិធីបណ្ដឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី គឺតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍[9]។ ចំពោះករណីមុនពេលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី តុលាការមានសមត្ថកិច្ច គឺតុលាការដែលមានសមត្ថកិច្ចលើរឿងក្ដីនៃបណ្ដឹងអង្គសេចក្ដីដែលនឹងធ្វើនាពេលអនាគត ហើយម្ចាស់បំណុលអាចជ្រើសរើសយកតុលាការណាមួយបាន ប្រសិនបើតុលាការមានសមត្ថកិច្ចមានច្រើន។ ដោយឡែក, ចំពោះការរឹបអូសជាបណ្ដោះអាសន្នដែលមានកម្មវត្ថុជាសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត សាលាដំបូងដែលមានសមត្ថកិច្ចជម្រះក្ដីនៅលំនៅឋានរបស់កូនបំណុលទី៣ គឺជាតុលាការដែលមានសមត្ថកិច្ច។ សមត្ថកិច្ចរបស់តុលាការចំពោះសំណុំរឿងរក្សាការពារជាសមត្ថកិច្ចផ្ដាច់មុខ។

---

9. មាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។



- **ទម្រង់នៃសេចក្ដីសម្រេច៖** ការសម្រេចសេចក្ដីដែលទាក់ទងនឹងនីតិវិធីនៃដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយដីកាសម្រេច។ ហេតុដូចនេះ តុលាការអាចចេញដីកាសម្រេចនេះ ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ឬការសួរភាគីបាន[10]។ ដោយដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវធ្វើឡើងដោយលក្ខណៈសម្ងាត់ ជាទូទៅតុលាការត្រូវចេញដីកាសម្រេចនេះដោយគ្រាន់តែសួរម្ចាស់បំណុលប៉ុណ្ណោះ[11]។ តុលាការអាចពិនិត្យលើការបំពេញលក្ខខណ្ឌនៃការចេញរក្សាការពារ ដោយផ្អែកលើឯកសារដែលម្ចាស់បំណុលបានដាក់ ដោយមិនចាំបាច់ជូនដំណឹង ឬស្ដាប់ការលើកឡើងរបស់កូនបំណុលឡើយ។ ដូចគ្នាផងដែរ តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ ដោយមិនបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬការសួរភាគីនោះទេ។ ផ្ទុយទៅវិញ, ក្នុងការសម្រេចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈបណ្ដោះអាសន្ន, តុលាការត្រូវតែធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬនីតិវិធីសាកសួរដែលកូនបំណុលអាចចូលរួមបានជាដាច់ខាត[12] ដោយសារការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ននេះ មានលក្ខណៈជាការសម្រេចលើខ្លឹមសារនៃសិទ្ធិទាមទារលើអង្គសេចក្ដីតែម្ដង ដែលបង្កនូវការប៉ះពាល់ដល់សិទ្ធិរបស់កូនបំណុល លើសពីការរក្សាការពារ ២ ផ្សេងទៀត។ ប៉ុន្តែ ក្រមនីតិវិធីរដ្ឋប្បវេណីក៏អនុញ្ញាតឱ្យតុលាការអាចចេញដីកាសម្រេចនេះភ្លាមៗបានដោយពុំឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬនីតិវិធីសាកសួរបានដែរ បើសិនជាការឆ្លងកាត់នីតិវិធីនេះធ្វើឱ្យគោលបំណងនៃការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននេះ មិនបានសម្រេចទាល់តែសោះចំពោះស្ថានភាពពិសេសមួយចំនួន។ ឧទាហរណ៍ ការរង់ចាំនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ធ្វើឱ្យហួសពេលសម្រាប់ព្យាបាលដល់ម្ចាស់បំណុលដែលរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ជាដើម។

- **ការបង្គាប់ឱ្យដាក់ប្រាតិភោគ និងប្រាក់រំដោះ៖** ការចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន អាចធ្វើឡើងដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគ តាមឆន្ទានុសិទ្ធិរបស់តុលាការ[13]។ ការបង្គាប់ឱ្យដាក់ប្រាតិភោគ គឺដើម្បីធានានូវការផ្ដល់សំណងជូនកូនបំណុលវិញ

---

10. មាត្រា ៥៣៩ និង មាត្រា ១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

11. សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគីស្ដីពីការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ ទំព័រ ១៩៨។

12. កថាខណ្ឌទី៤ នៃមាត្រា ៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

13. មាត្រា ៥៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ចំពោះការរឹបអូសជាបណ្ដោះអាសន្នដែលមានលក្ខណៈមិនត្រឹមត្រូវចំពោះកូនបំណុល[14]។ ចំនួននៃប្រាតិភោគត្រូវវាយតម្លៃដោយផ្អែកតាមតម្លៃនៃកម្មវត្ថុដែលត្រូវបានរក្សាការពារ។ លើសពីនេះ, នៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន តុលាការត្រូវកំណត់អំពីចំនួននៃប្រាក់រំដោះជាដាច់ខាត ដើម្បីកូនបំណុលអាចទទួលបានការលុបចោលការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន[15]។ ប្រាក់រំដោះ គឺជាប្រព័ន្ធដែលបង្កើតឡើងក្នុងគោលបំណងការពារកូនបំណុល ពីការរឹបអូសជាបណ្ដោះអាសន្នដែលមិនមានភាពចាំបាច់។ មានន័យថា បើកូនបំណុលមានប្រាក់គ្រប់គ្រាន់សម្រាប់ផ្ញើនៅតុលាការដើម្បីធានាការសងបំណុលរួចហើយ នោះការរឹបអូសជាបណ្ដោះអាសន្នលែងមានន័យទៀតហើយ។ ប្រាក់រំដោះត្រូវផ្ញើនៅតុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬតុលាការអនុវត្តការរក្សាការពារ[16]។ ដូចគ្នាផងដែរចំពោះការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ, តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ។ ប៉ុន្តែ តុលាការមិនត្រូវកំណត់អំពីចំនួននៃប្រាក់រំដោះដូចការរឹបអូសជាបណ្ដោះអាសន្នឡើយ ពីព្រោះការរក្សាការពារនេះធ្វើឡើងដោយពាក់ព័ន្ធនឹងវត្ថុជាក់លាក់ មិនមែនពាក់ព័ន្ធតែនឹងតម្លៃនៃវត្ថុសម្រាប់លក់ដោយបង្ខំឡើយ។

- **បណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេចចាត់ចែងរក្សាការពារ៖** ការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារមាន ៣ ប្រភេទ រួមមាន៖ ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ, ការស្នើសុំលុបចោលនូវការរក្សាការពារ និង បណ្ដឹងជំទាស់។ ការតវ៉ាចំពោះរក្សាការពារ និងការស្នើសុំលុបចោលនូវការរក្សាការពារ ត្រូវធ្វើនៅតុលាការដើមដែលចេញដីកាសម្រេចរក្សាការពារ។ រីឯបណ្ដឹងជំទាស់ត្រូវធ្វើទៅតុលាការថ្នាក់លើនៃតុលាការដើម។

**ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ** គឺជាឱកាសដែលផ្ដល់ឱ្យកូនបំណុលដែលពុំអាចចូលរួមនៅក្នុងនីតិវិធីមុន អាចដាក់នូវមធ្យោបាយតទល់ និងការពារខ្លួនបាន និងស្នើសុំឱ្យតុលាការដែលបានចេញដីកាសម្រេចរក្សាការពារធ្វើការវិនិច្ឆ័យអំពីភាពត្រឹមត្រូវនៃដីកាសម្រេចរក្សាការពារឡើងវិញ ពីព្រោះការចេញដីកាសម្រេចនេះអាចមានការពិចារណាមិនបាន

14. “នៅប្រទេសជប៉ុន ស្ទើរតែគ្មានដីកាសម្រេចរក្សាការពារណាដែលមិនបង្គាប់ឱ្យដាក់ប្រាតិភោគនោះទេ”។ សូមអានឯកសារពន្យល់ “ការរក្សាការពារក្នុងរឿងរដ្ឋប្បវេណី ផ្នែកទី២” ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ MAEDA Yuta, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨, ទំព័រទី១៨។
15. មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
16. មាត្រា ៥៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។



ពេញលេញ ដោយសារតុលាការត្រូវវិនិច្ឆ័យជាលក្ខណៈបន្ទាន់បង្ខំ និងធ្វើការពិនិត្យតែសេចក្ដីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុលប៉ុណ្ណោះ។ នៅក្នុងការវិនិច្ឆ័យអំពីការតវ៉ានេះ តុលាការត្រូវពិនិត្យមើលអំពីសិទ្ធិដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ ដោយត្រូវឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន ដើម្បីផ្ដល់ទៅឱ្យភាគី (ជាពិសេសកូនបំណុល) នូវការធានានៅក្នុងការចូលរួមនីតិវិធី[17]។ ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារនេះ មាន ៣ប្រភេទ[18] គឺ៖ (ទី១)-ការទទួលស្គាល់ (ចំពោះដីកាសម្រេចរក្សាការពារដែលមានលក្ខណៈត្រឹមត្រូវ), (ទី២)-ការផ្លាស់ប្ដូរ (ចំពោះដីកាសម្រេចរក្សាការពារដែលត្រូវកែសម្រួល) និង (ទី៣)-ការលុបចោល (ចំពោះដីកាសម្រេចរក្សាការពារដែលមានលក្ខណៈមិនត្រឹមត្រូវ)។ ចំពោះដីកាសម្រេចដែលលុបចោលដីកាសម្រេចរក្សាការពារពុំមានអានុភាពទេ បើមិនទាន់ចូលជាស្ថាពរ ប៉ុន្តែតុលាការអាចប្រកាសថាដីកាសម្រេចលុបចោលនេះមានអានុភាពភ្លាមៗ បើយល់ឃើញថាចាំបាច់ពិសេស[19]។

**បណ្ដឹងជំទាស់៖** ផ្អែកតាមមាត្រា ៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ អាចប្ដឹងជំទាស់បានក្នុងអំឡុងពេល ២ សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូន។ ជាគោលការណ៍, តុលាការនៃបណ្ដឹងជំទាស់ត្រូវអនុវត្តដូចគ្នានឹងនីតិវិធីតវ៉ាចំពោះដីការក្សាការពារ ពោលគឺការវិនិច្ឆ័យលើសិទ្ធិលើបំណុលដែលត្រូវរក្សាការពារ, ភាពចាំបាច់នៃការរក្សាការពារ និងការទាញហេតុផលដោយផ្ទាល់មាត់ ឬការសួរនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបានជាអាទិ៍។ ការសម្រេចសេចក្ដីរបស់តុលាការនៃបណ្ដឹងជំទាស់ ជាការសម្រេចសេចក្ដីដែលបិទផ្លូវតវ៉ា ដោយភាគីមិនអាចធ្វើឧបាស្រ័យទៅតុលាការថ្នាក់លើបន្ថែមទៀតឡើយ។

**ការលុបចោលនូវការរក្សាការពារ** ត្រូវធ្វើឡើងនៅតុលាការដែលចេញដីកាសម្រេចរក្សាការពារ ដូចគ្នានឹងការតវ៉ាចំពោះដីកាសម្រេចរក្សាការពារដែរ។ ការលុបចោលនៃការរក្សាការពារ រួមមានការលុបចោលការរក្សាការពារដោយសារការមិនដាក់ពាក្យបណ្ដឹង

17. មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
18. មាត្រា ៥៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។
19. មាត្រា ៥៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

អង្គសេចក្តី[20], ការលុបចោលការរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព[21] និងការលុបចោលការរក្សាការពារដោយសារស្ថានភាពពិសេស[22]។ តុលាការដែលទទួលបានពាក្យសុំលុបចោល ត្រូវវិនិច្ឆ័យអំពីការស្នើសុំលុបចោលដោយផ្អែកលើមូលហេតុនៃការលុបចោលនីមួយៗខាងលើ។ ឧទាហរណ៍ ចំពោះករណីស្នើសុំឱ្យលុបចោលនូវការរក្សាការពារដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តីជាអាទិ៍, នៅពេលទទួលបានពាក្យសុំនេះពីកូនបំណុល, តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយបង្គាប់ឱ្យដាក់ឯកសារបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងអង្គសេចក្តីនោះ ដោយកំណត់អំឡុងពេលមិនតិចជាង ២ សប្តាហ៍។ បើម្ចាស់បំណុលមិនបានដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងអង្គសេចក្តីតាមពេលកំណត់ទេ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់កូនបំណុល។

## ២-ការអនុវត្តជាក់ស្តែងក្នុងការចេញដីកាសម្រេចរក្សាការពារ

នៅក្នុងការអនុវត្តជាក់ស្តែង, ការចេញដីកាសម្រេចរក្សាការពារ ជួបនូវបញ្ហាប្រឈមមួយចំនួន *(ក)* ដែលទាមទារឱ្យមាននូវដំណោះស្រាយទាំងសម្រាប់រយៈពេលចំពោះមុខ ទាំងសម្រាប់រយៈពេលវែង *(ខ)*។

### ក-បញ្ហាប្រឈមក្នុងការអនុវត្តការចេញដីកាសម្រេចរក្សាការពារ

- **ការបែងចែកមិនដាច់រវាងភាពចាំបាច់នៃការចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង ភាពចាំបាច់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ៖** មាត្រា ៥៤៥ កំណត់ថា ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ *"ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ"* ហើយមាត្រា ៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ថា តុលាការអាចចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន *"ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ"*។ តើ *"ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ"* និង *"ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ"* មានភាពខុសគ្នាយ៉ាងដូចម្តេច? លើការជាក់ស្តែង យើងមិនអាចធ្វើការបែងចែកឱ្យដាច់ពីគ្នារវាងភាពចាំបាច់ទាំង ២ នេះនោះទេ។ បើផ្អែកតាមមាត្រា ៥៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលចែងពីគោលគំនិតនៃការចាត់ចែងរក្សាការពារ, ភាពចាំបាច់នៃដីកាសម្រេចទាំង ២ ខាងលើនេះ គួរតែមានភាពដូចគ្នា គឺ *"ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យរបស់កូនបំណុលនៃការអនុវត្ត"*។ ធាតុពិតមូលដ្ឋានតែមួយគត់ដែលអាចឱ្យយើងអាចបែងចែកដាច់ពីគ្នារវាង ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺ សិទ្ធិដែលជាកម្មវត្ថុនៃវិវាទ ដោយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវប្រើនៅពេលដែលសិទ្ធិដែលជាកម្មវត្ថុនៃវិវាទ គឺ *"សិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់"* ហើយដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ត្រូវប្រើនៅពេលដែលសិទ្ធិដែលជាកម្មវត្ថុនៃវិវាទ គឺ *"សិទ្ធិលើវត្ថុ"*។

- **ការកំណត់ខ្លឹមសារនៃដីកាសម្រេចចាត់ចែងរក្សាការពារ៖** មាត្រា ៥៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានបញ្ញត្តថា "តុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬមិនធ្វើអំពើណាមួយជាកំណត់ ឬឱ្យកូនបំណុលផ្តល់តាវកាលិក ឬឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន ឬធ្វើការចាត់ចែងផ្សេងទៀតបាន **តាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណង**នៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន"។ ខ្លឹមសារនៃការចាត់ចែងជាបណ្តោះអាសន្ន ត្រូវតែកំណត់ "**ត្រឹមកម្រិតនៃភាពចាំបាច់**" និង "**ដើម្បីសម្រេចគោលបំណង**" នៃពាក្យសុំចេញដីកាសម្រេចនេះ ដែលគោលបំណងនេះ គឺ **"ការរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ[23]"**។ ប៉ុន្តែ លើការជាក់ស្តែង ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នមួយចំនួន បានចេញលើសពីកម្រិតនៃភាពចាំបាច់នេះ និងលើសពីគោលបំណងនៃ **"ការរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ"** ជាអាទិ៍ ការហាមឃាត់មិនឱ្យកូនបំណុលបន្តស្នាក់នៅលើផ្ទះដែលបាននិងកំពុងស្នាក់នៅ

[20]. មាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[21]. មាត្រា ៥៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[22]. មាត្រា ៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[23]. មាត្រា ៥៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

តាំងពីមុនពេលមានវិវាទមក ឬហាមមិនឱ្យជួលនូវអចលនវត្ថុដែលកំពុងជួលស្រាប់ ឬការបង្គាប់ឱ្យវាយកម្ទេចចោលនូវរបង ឬការរៀផ្សេងៗដែលមានស្រាប់នៅលើទីតាំងដីវិវាទជាដើម។ ការចេញដីកាសម្រេចបែបនេះ អាចហួសពីភាពចាំបាច់នៃការរក្សាការពារ និងផ្ទុយពីលក្ខណៈនៃការរក្សាការពារ។ ចំពោះវិវាទបែបនេះ ការចេញដីកាសម្រេចរក្សាការពារត្រឹមកម្រិតហាមឃាត់មិនឱ្យកូនបំណុលបន្តសាងសង់របង ឬការរៀផ្សេងៗលើដីវិវាទ ឬមិនឱ្យចាត់ចែងដីវិវាទ គឺធ្លុនល្មមសម្រាប់រក្សាការពារសិទ្ធិរបស់ម្ចាស់បំណុល ដើម្បីរង់ចាំការសម្រេចឱ្យបានជាក់លាក់ក្នុងបណ្ដឹងអង្គសេចក្ដី ហើយការសម្រេចត្រឹមកម្រិតនេះ គឺស្របនឹងចរិតនៃការរក្សាការពារត្រង់លក្ខណៈបន្ទាប់បន្សំពីបណ្ដឹងអង្គសេចក្ដី និងលក្ខណៈបណ្ដោះអាសន្ន។ លើសពីនេះ ការចេញដីកាសម្រេចរក្សាការពារត្រូវតែពិចារណាឱ្យបានល្អិតល្អន់អំពីលទ្ធភាពនៃការធ្វើបដិទាន ជាពិសេសការធ្វើបដិទាននូវការខូចខាតដែលអាចកើតមានឡើងចំពោះកូនបំណុល ពីព្រោះការរក្សាការពារមិនមែនជាការកំណត់ស្ថាពរនៃសិទ្ធិនោះទេ ហើយការសម្រេចនៅក្នុងការរក្សាការពារអាចត្រូវបានផ្លាស់ប្ដូរដោយការសម្រេចនៅក្នុងអង្គសេចក្ដី។

- **ការមិនកំណត់ច្បាស់លាស់ពីប្រភេទដីកាសម្រេចរក្សាការពារ៖** ខ្លឹមសារនៃដីកាសម្រេចរក្សាការពារ ត្រូវបានសរសេរឡើងទៅតាមទម្រង់ជាច្រើន ហើយក្នុងនោះយើងអាចកត់សម្គាល់ឃើញនូវការសរសេរដែលមានខ្លឹមសារថា ហាមឃាត់មិនឱ្យកូនបំណុលធ្វើការលក់ដូរ ជួល បញ្ចាំ ធ្វើប្រទានកម្ម ដាក់ហ៊ីប៉ូតែក ឬធ្វើការចាត់ចែងនានាលើវត្ថុណាមួយ ជាអាទិ៍។ តើការសរសេរនូវខ្លឹមសារដីកាសម្រេចរក្សាការពារបែបនេះត្រឹមត្រូវដែរឬទេ? តើការចេញដីកាសម្រេចបែបនេះមានអានុភាពដូចម្ដេច? មានទស្សនៈមួយចំនួនបកស្រាយថា ដីកាសម្រេចនេះអាចជាការរឹបអូសជាបណ្ដោះអាសន្ន ឬជាការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយសារតែការសរសេរបែបនេះគ្រាន់តែជាការរៀបរាប់លម្អិតអំពីសិទ្ធិដែលត្រូវបានហាមឃាត់ដោយសារការរក្សាការពារប៉ុណ្ណោះ។ ប៉ុន្តែ, ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នមានគោលបំណងថែរក្សាទ្រព្យសម្បត្តិរបស់កូនបំណុល សម្រាប់ការអនុវត្តដោយបង្ខំដោយប្ដូរជាប្រាក់ ដើម្បីយកទៅសងម្ចាស់បំណុលនាពេលអនាគត។ យើងអាចបកស្រាយថា ការរឹបអូសជាបណ្ដោះអាសន្នមានអានុភាពថែរក្សាតម្លៃសេដ្ឋកិច្ចនៃវត្ថុ ដោយហាមឃាត់មិនឱ្យកូនបំណុលអាចចាត់ចែងបាន ឬមិនអាចចាត់ចែងជាស្ថាពរ។ មានន័យថា នៅពេលមានការរឹបអូសជាបណ្ដោះអាសន្នលើទ្រព្យសម្បត្តិណាមួយរបស់កូនបំណុល នោះកូនបំណុលក្នុងនាមជាកម្មសិទ្ធិករត្រូវបានដកហូតនូវសិទ្ធិចាត់ចែង ប៉ុន្តែ ការរឹបអូសនេះមិនមានអានុភាពហាមឃាត់មិនឱ្យកូនបំណុលប្រើប្រាស់ និងអាស្រ័យផលឡើយ។ ហេតុនេះ ការបកស្រាយថា ជាការរឹបអូសជាបណ្ដោះអាសន្នចំពោះដីកាសម្រេចរក្សាការពារដែលមានខ្លឹមសារហាមឃាត់មិនឱ្យជួលជាអាទិ៍ ពុំទាន់ត្រឹមត្រូវទាំងស្រុងនោះទេ។ ទន្ទឹមនេះ, ការបកស្រាយថាជាការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ ក៏មិនទាន់គ្រប់ជ្រុងជ្រោយដែរ ពីព្រោះថា ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ ត្រូវមានខ្លឹមសារជាក់លាក់ថាជាការហាមឃាត់ការផ្ទេរការកាន់កាប់ ឬការហាមឃាត់ការចាត់ចែងលើវត្ថុវិវាទ។ ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ពុំមានអានុភាពហាមឃាត់មិនឱ្យកូនបំណុលប្រើប្រាស់ និងអាស្រ័យផលលើវត្ថុវិវាទឡើយ លើកលែងតែនៅក្នុងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នបានកំណត់យ៉ាងច្បាស់ថា ដកហូតវត្ថុដែលជាកម្មវត្ថុវិវាទពីកូនបំណុល ហើយប្រគល់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រង ឬអនុញ្ញាតឱ្យម្ចាស់បំណុលប្រើប្រាស់បន្ត[24]។

- **ការលុបចោលដីកាសម្រេចរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី៖** ផ្អែកតាមមាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី, តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងនោះក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល។ អំឡុងពេលនេះមានរយៈពេលមិនតិចជា ២ សប្ដាហ៍នោះទេ។ ប្រសិនម្ចាស់បំណុលមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី និងឯកសារដែលបញ្ជាក់ពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីនេះទេ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល។ ក្នុងការអនុវត្ត, មានម្ចាស់បំណុលបានដាក់ពាក្យសុំដីកាសម្រេចរក្សាការពារ ដោយមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដីនោះទេ។ ម្ចាស់បំណុលមានកាតព្វកិច្ចដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ទាល់តែមានការបង្គាប់ពីតុលាការ តាមពាក្យសុំរបស់កូនបំណុល ដែលនេះជាបន្ទុកសម្រាប់កូនបំណុល ទាំងលើប្រាក់ប្រដាប់ក្ដី ទាំងលើភស្ដុតាង។ ប៉ុន្តែ ជាសមធម៌ ម្ចាស់បំណុលដែលស្នើសុំដាក់រក្សាការពារគួរតែមានកាតព្វកិច្ចដាក់ពាក្យបណ្ដឹងអង្គសេចក្ដីក្នុងរយៈពេលមួយកំណត់ ដោយមិនចាំបាច់ទាល់តែមានពាក្យសុំរបស់កូនបំណុលនោះទេ។

- **ការប្រើប្រាស់នូវដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ក្នុងគោលបំណងសម្រេចនូវការអនុវត្តដោយបង្ខំ ដើម្បីជាមធ្យោបាយឆាប់រហ័សជំនួសឱ្យការធ្វើបណ្ដឹងអង្គសេចក្ដី** (ផ្លូវកាត់) ក៏ជាបញ្ហាប្រឈមដែលត្រូវបានសង្កេត

---

24. "ជាគោលការណ៍អនុវត្តនៅប្រទេសជប៉ុន គឺអនុញ្ញាតឱ្យកូនបំណុលបន្តប្រើប្រាស់វត្ថុដែលជាកម្មវត្ថុវិវាទ"។ សូមអានឯកសារពន្យល់ "ការរក្សាការពារក្នុងរឿងរដ្ឋប្បវេណី ផ្នែកទី២" ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ MAEDA Yuta, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨, ទំព័រទី២៨។

ឃើញជាញឹកញាប់ផងដែរ។ ដូចបានគូសបញ្ជាក់ពីខាងលើ ដីកាសម្រេចប្រភេទនេះធ្វើឡើងក្នុងគោលបំណងជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដែលនឹងកើតឡើងលើម្ចាស់បំណុលចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។

-**ការប្តឹងសុំរក្សាការពារដដែលៗ៖** ក្រៅបញ្ហាខាងលើ ក៏នៅមានបញ្ហាផ្សេងទៀតផងដែរ ដូចជា បញ្ហានៃការចេញដីកាសម្រេចរក្សាការពារដដែលៗ ដោយមិនមានមូលហេតុថ្មី ឬដោយមិនមានការប្រែប្រួលស្ថានភាពអ្វី ក្រោយពេលដែលដីកាសម្រេចនេះត្រូវបានសម្រេចលុបចោល។ ច្បាប់មិនបានហាមមិនឱ្យមានការប្តឹងសុំដីកាសម្រេចរក្សាការពារម្តងហើយម្តងទៀត ទោះបីជាគ្មានមូលហេតុនៃភាពចាំបាច់ថ្មីក៏ដោយនោះទេ។ បញ្ហាកើតឡើងជាញឹកញាប់ដោយសារតែក្នុងការអនុវត្តជាក់ស្តែង ភាគច្រើននៃដីកាសម្រេចរក្សាការពារពុំមានបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគនោះទេ។ ករណីនេះជាការរំខានដល់តុលាការផង និងដល់កូនបំណុលផងក្នុងករណីដែលតុលាការថ្មីបានចេញដីកាសម្រេចរក្សាការពារដោយផ្អែកលើមូលហេតុដដែល ប៉ុន្តែដីកាសម្រេចរក្សាការពារនេះត្រូវបានសម្រេចលុបចោលច្រើនដងរួចហើយដោយតុលាការជាន់ខ្ពស់។

## ២-សេចក្តីសម្រេចចិត្តរបស់អង្គមហាសន្និបាតវិស័យយុត្តិធម៌ឆ្នាំ ២០២៤

ដោយពិនិត្យឃើញពីបញ្ហាប្រឈមក្នុងការអនុវត្តពាក់ព័ន្ធនឹងការចេញដីកាសម្រេចរក្សាការពារនេះ មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត ដែលត្រូវបានរៀបចំឡើងកាលពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ និងមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ ថ្នាក់ដឹកនាំសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ព្រមទាំងចៅក្រម និងព្រះរាជអាជ្ញានៅទូទាំងប្រទេស បានលើកចំណុចពាក់ព័ន្ធនឹងការចេញដីកាសម្រេចរក្សាការពារមិនត្រឹមត្រូវតាមប្រភេទនៃការចាត់ចែងរក្សាការពារ និងមិនទាន់មានសង្គតិភាពលើទម្រង់នៃដីកាសម្រេចរក្សាការពារ ព្រមទាំងពុំមានលក្ខខណ្ឌតាមច្បាប់គ្រប់គ្រាន់ក្នុងការចេញដីកាសម្រេចរក្សាការពារមកធ្វើជាប្រធានបទមួយនៃកិច្ចពិភាក្សា។ ឆ្លងកាត់ការពិភាក្សាយ៉ាងផុសផុល អង្គមហាសន្និបាតបានសម្រេចថា *“រៀបចំ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវទម្រង់រួមនៃដីកាសម្រេចរក្សាការពារ នៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីធានាសង្គតិភាព ទាំងលើទម្រង់នៃដីកាទាំងលើខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ តាមប្រភេទនៃការចាត់ចែងរក្សាការពារ និងអាចយកទៅអនុវត្តបានប្រកបដោយប្រសិទ្ធភាព។ ក្នុងការអនុវត្តការងារនេះ, អង្គមហាសន្និបាត បានសម្រេចប្រគល់ភារកិច្ចជូន ក្រសួងយុត្តិធម៌ ដើម្បីរៀបចំឱ្យមានទម្រង់រួមនៃដីកាសម្រេចរក្សាការពារ ដោយមានការពិគ្រោះយោបល់ជាមួយសាលាជម្រះក្តីទាំងអស់មុននឹងដាក់ឱ្យអនុវត្តនៅទូទាំងប្រទេស”*។ ជាលទ្ធផល, ក្រុមការងារក្រសួងយុត្តិធម៌កំពុងពិនិត្យមើលទម្រង់ និងខ្លឹមសារនៃដីការក្សាការពារដែលរៀបចំឡើងដោយគម្រោងអភិវឌ្ឍន៏វិស័យច្បាប់ និងយុត្តិធម៌ ក្រោមកិច្ចសហការរបស់អង្គការ JICA និងក្រសួងយុត្តិធម៌ ដើម្បីដាក់ជូនតុលាការទូទាំងប្រទេសប្រើប្រាស់។ ទន្ទឹមនេះ, បញ្ហាប្រឈមខាងលើ និងបញ្ហាប្រឈមផ្សេងទៀត ក៏នឹងក្លាយជាកម្មវត្ថុនៃការធ្វើវិសោធនកម្មនាពេលខាងមុខ ក្នុងក្របខ័ណ្ឌនៃការធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណីផងដែរ។

# ជីវប្រវត្តិសង្ខេបអ្នកនិពន្ធ
# អត្ថបទស្រាវជ្រាវ និងវិភាគផ្នែកច្បាប់



ឯកឧត្តម **សេខ ប៊ុនឃាខ** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ឯកឧត្តមបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅឆ្នាំ១៩៩៨, បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ ឆ្នាំ២០០៥ និងថ្នាក់បណ្ឌិតច្បាប់ នៅឆ្នាំ២០២២។ ឯកឧត្តមបានចូលបម្រើការងារតាំងពីឆ្នាំ ១៩៩៨។ ឯកឧត្តមក៏ជាគ្រូបង្រៀនច្បាប់នៅបណ្ឌិត្យសភាភូមិន្ទ យុត្តិធម៌កម្ពុជា និងនៅសាកលវិទ្យាល័យនានផងដែរ។



ឯកឧត្តម **ញាន វណ្ណា:** ជារដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យក្រសួងយុត្តិធម៌។ ឯកឧត្តមបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅឆ្នាំ ២០០៥ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ពីសាកលវិទ្យាល័យ Jean Moulin Lyon 3 នៃប្រទេសបារាំងនៅឆ្នាំ២០០៧។ ឯកឧត្តមក៏ជាគ្រូបង្រៀនផ្នែកច្បាប់ នៅតាមសាកលវិទ្យាល័យនានាតាំងពីឆ្នាំ២០០៨មកផងដែរ។



ឯកឧត្តម **សេខ នាខ** ជាអនុប្រធានតុលាការកំពូល។ ឯកឧត្តមទទួលបានបរិញ្ញាបត្រនីតិសាស្ត្រនៅឆ្នាំ១៩៩៨, វិញ្ញាបនបត្រមេធាវីនៅឆ្នាំ១៩៩៩, បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រនៅឆ្នាំ២០០៥, សញ្ញាបត្រចៅក្រមនៅឆ្នាំ២០០៦, និងសញ្ញាបត្របណ្ឌិតច្បាប់ពីសាកលវិទ្យាល័យ St Clements University ប្រទេសស្វីសក្នុងឆ្នាំ ២០២៣។ ឯកឧត្តម ក៏ជាគ្រូបណ្តុះបណ្តាលនៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជានិងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។



ឯកឧត្តម **គង់ តារាឆាត** ជាចៅក្រមតុលាការកំពូល។ ឯកឧត្តមបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅឆ្នាំ១៩៩៩, សញ្ញាបត្រចៅក្រមនៅឆ្នាំ២០០៨, បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់នៅឆ្នាំ២០១៦ និងថ្នាក់បណ្ឌិតច្បាប់នៅឆ្នាំ២០២០។ ឯកឧត្តមក៏ជាគ្រូបណ្តុះបណ្តាលនៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងនៅតាមសាកលវិទ្យាល័យនានាផងដែរ។



ឯកឧត្តម **ម៉ុខ មុនីចរិយា** ជាប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ ឯកឧត្តមទទួលបានអនុបណ្ឌិតផ្នែកនីតិសាស្ត្រពីសាកលវិទ្យាល័យជាតិ ALfarabi, Republic of Kazakhstan នៅឆ្នាំ ១៩៩៣ និងបានបញ្ចប់ការសិក្សាវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រមនៅឆ្នាំ ១៩៩៥។ ឯកឧត្តមជាចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពីឆ្នាំ ២០០៦ រហូតដល់បច្ចុប្បន្ន។ ឯកឧត្តមក៏ជាគ្រូបង្រៀនផ្នែកច្បាប់នៅបណ្ឌិត្យសភាភូមិន្ទយុត្តិកម្ពុជាផងដែរ។



ឯកឧត្តម **ហេខ សុខណា** ជានាយកសាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។ ឯកឧត្តមបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រនីតិសាស្ត្រ នៅឆ្នាំ២០០៥ និងបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រនៅឆ្នាំ២០០៨។ ឯកឧត្តមធ្លាប់ជាចៅក្រមនៃសាលាដំបូង និងសាលាឧទ្ធរណ៍ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០២៣។ ឯកឧត្តមក៏ជាគ្រូបង្រៀនប្រចាំបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជាផងដែរ។



កញ្ញា **គន្ធា ស្រីសុជាតា** ជាសមាជិកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ កញ្ញាបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅឆ្នាំ២០១៤ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រពីសាកលវិទ្យាល័យ Tokyo នៃប្រទេសជប៉ុននៅឆ្នាំ២០២០។ កញ្ញាធ្លាប់បំពេញការងារនៅគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌ចាប់ពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៦ និងចាប់ពីឆ្នាំ២០២០ដល់ឆ្នាំ២០២២។ កញ្ញាក៏ជាគ្រូបង្រៀនផ្នែកច្បាប់នៅសាកលវិទ្យាល័យផងដែរ។



លោក **ឈឿន គុយអេខ** ជាសមាជិកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅឆ្នាំ២០១៣ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ពីសកលវិទ្យាល័យ Nagoya នៃប្រទេសជប៉ុននៅឆ្នាំ២០១៦។ លោកធ្លាប់បំពេញការងារជាមន្ត្រីច្បាប់ជាន់ខ្ពស់ និងជាទីប្រឹក្សាច្បាប់ សម្រាប់គម្រោងអភិវឌ្ឍន៍វិស័យច្បាប់និងយុត្តិធម៌ពីឆ្នាំ២០១៦ដល់ឆ្នាំ២០២២។



លោក **ឆុន ករុណា** ជាសមាជិកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅឆ្នាំ២០២១ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ពីសាកលវិទ្យាល័យលុយមីញ៉េរលីយ៉ុង២ ប្រទេសបារាំង នៅឆ្នាំ២០២៣។ លោកក៏ជាគ្រូបង្រៀនច្បាប់នៅសាកលវិទ្យាល័យផងដែរ។